ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

លេខ ១

កុង្សីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨២
គ. ស. ១៩៤០

...IOTHÈQUE
...TIONALE
...AMBODGE

# អារម្ភកថា

# នៃទស្សនាវដ្ដីកម្ពុជសុរិយា

## ឆ្នាំទី១២ គ្រិស្ដសករាជ ១៩៤០

ទស្សនាវដ្ដីកម្ពុជសុរិយា ដែលលោក អ្នកកំពុងតែចាប់មើលសេចក្ដីតទៅខាងមុខនេះ យើងសូមជំរាបទុកជាមុនថា រឿងការផ្សេងៗ ដែលយើងបានរៀបចំផ្សំឡើងជាថ្មីនេះ គង់ធ្វើឲ្យលោក-អ្នកដែលធ្លាប់មើលទស្សនាវដ្ដីរបស់យើងពីដើមនឹកចំឡែកក្នុងចិត្តខ្លះមិនខានថា យីអើ! ទស្ស-នាវដ្ដីឆ្នាំថ្មីនេះ ថ្មីទាំងរូបរាង ថ្មីទាំងសេចក្ដីដែលចុះផ្សាយ គឺពីដើមមកកំ-ណត់ចេញផ្សាយ ៣ ខែម្ដង មួយឆ្នាំមានត្រឹម ៤ ក្បាលប៉ុណ្ណោះ ដល់មកឆ្នាំ ១៩៤០ នេះជាដើមទៅ បែរជាកែប្រែកំណត់នេះជាថ្មី គឺចេញផ្សាយរាល់ខែវិញ ដើម្បីឲ្យបានទាន់ចិត្តអ្នកមើលទស្សនាវដ្ដីនេះរាល់គ្នាៗ មួយវិញទៀត ពីដើមមកទស្សនាវដ្ដីនេះច្រើនតែចុះផ្សាយគតិធម៌ មានគតិ-លោកបន្តិចបន្តួច តាំងអំពីឆ្នាំនេះជាដើមទៅ យើងនឹងចុះផ្សាយគតិលោកឲ្យបានច្រើនបំផុតដោយយើងយល់ថា កម្ពុជរដ្ឋរបស់យើងវេលានេះ ពុទ្ធ-សាសនិកជនទូទៅមានចំណេះចេះដឹងគតិធម៌ល្មមសមគួរហើយដែរ ទាំងសៀវភៅផ្សេងៗ ដែលមានបោះពុម្ពទាំងអម្បាលម៉ាណក៏សុទ្ធតែរឿងគតិធម៌ស្ទើរតែទាំងអស់ ចំណែកឯក្បួនច្បាប់គតិលោកមានចំនួនស្ដួចស្ដើងណាស់ ហេតុនេះទើបយើងយល់ថា សេចក្ដីកែប្រែដែលបានថ្លែងមកនេះ

គង់នឹងបានសម្រេចជាហិតានុហិតប្រយោជន៍ដល់ប្រជាជនជាតិខ្មែរខ្លះទៅ ដូចមានគោលសំខាន់ៗ ដែលយើងបានបោះពុម្ពផ្សាយក្នុងប្រូក្រាមជូនដំណើររបស់ព្រះរាជបណ្ណាល័យ កាលពីឆ្នាំ ១៩៣៩ នេះស្រាប់ ។

ឯគតិធម៌នោះ គង់តែមានចុះផ្សាយក្នុងទស្សនាវដ្ដីនេះជាលំដាប់ៗទៅដែរ តែនឹងជ្រើសរើសរកតែត្រង់ដែលមាននិយាយពីគតិធម៌ប្លែកៗ ដែលពុទ្ធសាសនិកជនជាតិយើងមិនសូវមានអ្នកដឹងឮដល់គ្នាប៉ុណ្ណោះ ក្រៅពីនេះ នឹងចុះផ្សាយខាងគតិលោកទាំងអស់ ទុកគតិធម៌ប្រគល់ឲ្យសាសនកិច្ចានុក្រមបោះពុម្ពផ្សាយដោយឡែក ដោយមិនបាច់ឲ្យមានរឿងគតិលោកចូលទៅច្រឡូកច្រឡំផង ។

ការរៀបចំផ្សំគ្រឿងតាមទំនងនេះ ដើម្បីដំរូវទៅតាមចំណង់របស់លោកអ្នកជាវមើលទស្សនាវដ្ដីទាំងពីរមុខ តាមសេចក្ដីស្ម័គ្រចិត្តរៀងខ្លួនៗ មុននឹងបញ្ចប់ការម្ភកថាដោយសង្ខេបនេះ សូមរំឭកអស់លោក-អ្នក ដែលបានមើលទស្សនាវដ្ដីនេះជួយផ្សាយដំណឹងនេះដល់លោក-អ្នកដទៃៗតទៅទៀត ដើម្បីជាប្រយោជន៍ដល់ប្រជាជនរួមជាតិជាមួយគ្នា ដោយការនាំគ្នាជួយទំនុកបំរុងអក្សរសាស្ត្ររបស់ជាតិខ្មែរឲ្យបានចំរើនទាន់កាលសម័យនឹងគេឡើង ក្រុមអ្នកតែងរឿងចុះផ្សាយ សូមថ្លែងសេចក្ដីអរគុណទុកជាមុន ។

ទេបរង្សី

# បញ្ជីរឿង


១ — សេចក្ដីផ្ដើមក្នុងការធ្វើសាកលប្រវត្តិសាស្ត្ររបស់អ្នកមហា ញ៉ុក-ថែម . . . . ៣

២ — សិក្ខាកាមកថា របស់ទេវរង្សី . . . . . . . . . . . . . . . . . . ១៥

៣ — ដំណើរស្មើង ៥ របស់លោកអគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យ . . . . ២១

៤ — បកិណ្ណកកថា របស់ទេវរង្សី . . . . . . . . . . . . . . . . . . ២៩

៥ — ប្រជុំពាក្យកាព្យភាគទី ៣ (តពីឆ្នាំទី ១១ និងចប់) ពាក្យកាព្យសង្វាស ជារបស់
ស្មៀងកេហារឆ្នា . . . . . . . . . . . . . . . . . . . . . ៣៩

៦ — រឿងព្រេងខ្មែរ រឿងបុរសកំសត់ចេញទៅខ្ជិល . . . . . . . . . . . . ៤៥


## រូបក្រៅរឿង


ផែនទីក្បូនភាគ របស់ចាវក្តុ ទៅហ្វាយស្រុក ស្រុកខ្លួន ផ្ញើមកជូនព្រះរាជ-
បណ្ណាល័យកម្ពុជា កាលពីខែធ្នូ ឆ្នាំ ១៩៣៩ . . . . . . . . . . . . . ៦

# TABLE DES MATIÈRES


Pages.

1° Exposé sommaire sur l'histoire universelle par Maha Nhok-Thêm ........ 3

2° Curiosité des hommes par khemararansi ........ 15

3° Informations diverses ........ 21

4° Pakinnakakatha ou faits divers par khemararansi ........ 29

5° Recueil de Poèmes cambodgiens 3e partie (suite et fin) .. 35

6° Conte et légende populaires cambodgiens inédits:

Un homme pauvre qui fait le commerce ........ 45

HORS TEXTE :

Porte-écrans en forme de Naga offerts par Thao Kou de Khong à la Bibliothèque Royale. Août 1939 ........ 1



នេះជើងម្ជិតរូបនាគ
ជាវត្ថុធ្វើអំណោយ

## សេចក្ដីផ្ដើម

## ក្នុងការធ្វើប្រវត្តិសាស្ត្រនានាជាតិ

កាលបើលោក-អ្នកពិនិត្យមើលបំណងដើមខាងលើនេះ គង់តែនឹងជ្រាបច្បាស់ថា រឿងរ៉ាវដែលនឹងបើកមើលជាលំដាប់ ៗ តទៅខាងមុខនេះ មិនមែនជាសេចក្ដីខ្លី ៗ មើលឆាប់ចប់ទេ ដ្បិតគោលពណ៌នាអំពីពង្សាវតាររបស់នានាជាតិក្នុងលោក គង់មានសេចក្ដីសារសព្វវែងឆ្ងាយទូលាយលន្ទង់លន្ទោច ហាក់ដូចជាធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាលទម្រាំតែដើរដល់ទៅចុងផ្លូវគោង ប្រើពេលវេលាជាយូរអង្វែង។ កាលបើលោក-អ្នកនឹកដូច្នេះ គង់តែនឹងមានចិត្តធុញទ្រាន់មិនចង់ចាប់រឿងរ៉ាវអស់នេះពិនិត្យមើលទៅខាងមុខទៀត មុខតែនឹងទម្លាក់ចោលត្រឹមណោះហើយ វៀរលែងតែលោកអ្នកដែលត្រូវការចង់ចេះចង់ជ្រាបរឿងរ៉ាវរបស់ប្រទេសផ្សេង ៗ ដោយស្ម័គ្រចិត្តប៉ុណ្ណោះ ទើបហ៊ានដើរផ្លូវឆ្ងាយដាច់ស្រយាលនេះរហូតដល់ចុងផ្លូវសមតាមបំណងបាន។

តែយើងសូមអង្វរលោក-អ្នកបន្តិចសិន កុំអាលទម្លាក់ចោលដោយស្រកាន់ ព្រោះការរៀបរៀងពង្សាវតារលោកឡើងនេះ យើងមានបំណងឲ្យបានប្រយោជន៍ជា ២ ផ្លូវ គឺត្រូវការឲ្យបានប្រយោជន៍ទាំងអ្នកត្រូវការមើលដោយសង្ខេបឬដោយសេចក្ដីពិស្ដារ តែនឹងបានសម្រេចជាប្រ-

យោជន៍ដល់លោក-អ្នក ត្រឹមណា យើងមិនទាន់ហ៊ានទទួលប៉ាន់ទេ គ្រាន់តែយើងសូមឲ្យលោកអ្នកជឿចុះថា យើងមានបំណងល្អបំផុតដល់ប្រជា-ជនរួមជាតិជាមួយគ្នា ដោយមានមេត្រីចិត្តចង់ចែកផ្សាយចំណេះវិជ្ជានឹងរឿងរ៉ាវនានាដល់មិត្តរួមជាតិប៉ុណ្ណោះ ដោយយល់ថា អស់លោក-អ្នកជាញាតិមិត្តរួមជាតិជាមួយគ្នាបំពួកខ្លះ ដែលមិនទាន់បានជ្រាបរឿងរ៉ាវផ្សេងៗក្នុងពង្សាវតាររបស់នានាជាតិនោះ នោះមានចំនួនច្រើនណាស់ដែរ ប្រសិនបើគំនិតនេះបែរជាខុសទៅវិញ សូមអស់លោក-អ្នកអភ័យទោសឲ្យបានផង ព្រោះមានមេត្តាចិត្តពន្យល់ទៅឲ្យយើងៗ សូមអរគុណចំពោះមេត្រីចិត្តរបស់លោក នឹងសូមប្តេជ្ញាទទួលយកសេចក្តីពន្យល់របស់លោកដោយសេចក្តីគោរព ។

ឯវិធីរៀបរៀងពង្សាវតារនេះ យើងនឹងរៀបរៀងចែកចែកតាមយុគតាមសម័យដូចមានរបៀបតទៅនេះ :

## ក — វិធីបែងកាលសម័យតាមប្រវត្តិសាស្ត្រ

វិធីនេះមាន ២ ប្រការ គឺបែងចែកជាសម័យមុនមានប្រវត្តិសាស្ត្រនឹងសម័យមានប្រវត្តិសាស្ត្រហើយ ប្រការ ១ ចែកចេញជាសម័យចាស់, សម័យកណ្តាល, សម័យថ្មី នឹងសម័យបច្ចុប្បន្នប្រការ ១ ។

ប្រការ ១ ខាងដើមនោះ គប្បីយល់ថា មនុស្សជាតិនេះបានកើត

ឡើងក្នុងលោកនេះហើយ ប្រមាណ ១ សែនឆ្នាំ តែចំណែកដែលមាន ប្រវត្តិសាស្ត្រឬពង្សាវតារល្មមយកមកភ្ជាប់គ្នាជាកងពេលល្មមប្រើការបាន នោះមិនហួសពី ៧ ពាន់ឆ្នាំដែលកន្លងមកនេះទេ តាមទំនងនេះឃើញថា យើងបានដឹងរឿងរ៉ាវរបស់មនុស្សជាតិដង់គ្នាតិចពេក មិនសមនឹងកំណើត របស់មនុស្សជាតិដែលកើតមកហើយជាអន្លើនឆ្នាំ ៗ

ហ្លួងវិចិត្រវាទការ រដ្ឋមន្ត្រី នៃប្រទេសថៃ ជាអ្នកតែងពង្សាវតារ លោកមកជាភាសាថៃ ហើយធ្វើជាគ្រូបង្រៀនពង្សាវតារនានាជាតិនៅ មហាវិទ្យាល័យ បានពោលក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោកថា អ្នកប្រាជ្ញពង្សាវតារទាំងឡាយ បានបែងចែកប្រវត្តិសាស្ត្រនេះជា ២ ចំណែក គឺចំណែកមុនមានប្រវត្តិសាស្ត្រ និងចំណែកមានប្រវត្តិសាស្ត្រហើយ ៗ ឯចំណែកមុនមានប្រវត្តិសាស្ត្រនោះ មានអ្នកប្រាជ្ញពង្សាវតារជាច្រើន នាក់បានរៀបរៀងធ្វើរឿងរ៉ាវឡើង តែក្រមានលក្ខខណ្ឌមាំមួន គោង តែមានសេចក្តីសន្និដ្ឋានជាត្រើងប្រកបសេចក្តីអធិប្បាយ កាលបើមានគំនិតគិតឃើញដោយខ្លួន សេចក្តីសន្និដ្ឋានក៏ដោយខ្លួន សេចក្តីអធិប្បាយក៏ដោយខ្លួន ទើបមានការយល់ខុសគ្នា ខ្វែងគ្នាជានិច្ច មិនអាចនឹង វិនិច្ឆ័យបានថា អ្នកណាខុសអ្នកណាត្រូវទេ ដូចជាមានប្រស្នាមួយសួរថា មនុស្សកើតមកអំពីអ្វី? ពុកជាករកេតស្តាំងមកប្រកបសេចក្តីពន្យល់

យ៉ាងណា ក៏នៅតែមានចន្លោះដែលគ្នាមិនបេះបិទមិនបេះអស់ឡើយ ។ តាំង ដោយពិត ការស្រាវជ្រាវរកឃើញរបស់មនុស្សមុនសម័យ ៧.០០០ ឆ្នាំឡើងទៅនោះ មិនមែនធ្វើបានដោយងាយទេ ទើបត្រូវតែលើកទុកដោយឡែក គ្រាន់តែនាំគ្នាមកសិក្សាក្នុងសម័យដែលមានដម្រាផាលក្ខ-ខណ្ឌប៉ុណ្ណោះ ជីវិតយើងនៅតែមិនវែងល្មមនឹងឱ្យយើងសិក្សាបានល្អិតល្អមែនៗនោះផង ។

ប្រការទី ២– និយាយតាំងពីសម័យមានប្រវត្តិសាស្ត្រ អ្នកប្រាជ្ញពង្សាវតារបានចែកចេញជា ៤ សម័យគឺ (១) សម័យបុរាណ ត្រូវនាំយកចាប់តាំងពី ៤.៥០០ ឆ្នាំ មុនពុទ្ធសករាជ (មុនគ្រិស្តសករាជ ៥០០០ ឆ្នាំ) រហូតមកដល់ពុទ្ធសករាជ ៩៣៨ ឆ្នាំ (គ្រិស្តសករាជ ៤៣៨) ជាវេលាជាង ៥០០០ ឆ្នាំ (២) សម័យកណ្ដាល តាំងអំពីពុទ្ធសករាជ ៩៣៩ ដល់ពុទ្ធ-សករាជ ២.០៤១ ជាពេលា ១.១០៣ ឆ្នាំ (៣) សម័យថ្មី ចាប់តាំងពីពុទ្ធ-សករាជ ២.០៤២ ដល់ពុទ្ធសករាជ ២.៣៣២ ជាវេលា ២៩១ ឆ្នាំ និង (៤) សម័យបច្ចុប្បន្ន តាំងអំពីពុទ្ធសករាជ ២.៣៣៣ រហូតដល់សព្វថ្ងៃនេះ ។ វិធីបែងសម័យជារយៈៗ តាមទំនងនេះមានហេតុផលដ៏សមគួរពិតៗ គឺក្នុងសម័យនីមួយៗ សេចក្ដីចំរើនគំនិតគិតគូរ និងហេតុភេទរបស់លោករមែងប្រែប្រួលជាច្រើនណាស់តាមយុគតាមសម័យនោះៗ ។

"ក្រៅនេះ", អន្យ "ដទៃ, ឯទៀត"; អន្យតរ "ណាមួយ, ម្នាក់", អន្យតម "ណាមួយ, ម្នាក់" ៗ ឯ ឥតរេតរ នឹង អន្យោន្យ "ដទៃនឹងដទៃ, ទៅវិញទៅមក, គ្នានឹងគ្នា" ទាំងពីរសព្ទនេះ ប្រើបានចំពោះតែត្រង់ឯកវចន តែម្យ៉ាង. ឧ. តេ ជនា ឥតរេតរំ ទ្វិឞ្ដ: — "ជនពីរនាក់នោះ ស្អប់គ្នា ទៅវិញទៅមក, — អន្យោន្យស្យ ឝត្រុ, "ជាសត្រូវ ដល់គ្នានឹងគ្នា ឬ ជាសត្រូវនឹងគ្នាទៅវិញទៅមក" ៗ

ខ) គុណសព្ទទាំងឡាយ ដែលមានវិធីបំបែកដូចគ្នានឹងសវ៌នាម ទាំងអស់ដែរ វៀរលែងតែ នបុំ. ត្រង់ ប. ទុ. ឯក. ជា អម្ នោះគឺ សព្ទដូចមានតទៅនេះ :

សវ៌, "ទាំងពួង" ប. ឯក. បុំ. សវ៌ស៑, នបុំ. សវ៌ម៑, ស្ត្រី. សវ៌ា ។ល។

វិឝ្វ, "ទាំងពួង" ប. ឯក. បុំ. វិឝ្វស៑, នបុំ. វិឝ្វម៑, ស្ត្រី. វិឝ្វា ។ល។

ឯក, "មួយ, ពួកមួយ" ប. ឯក. បុំ. ឯកស៑, នបុំ. ឯកម៑, ស្ត្រី. ឯកា ។ល។ ប. ពហុ. បុំ. ឯកេ (ជនទាំងឡាយ) ពួកមួយ ។

គ) គុណសព្ទទាំងឡាយ ដែលមានវិធីបំបែកតាមទំនងនៃសវ៌នាម ដែរ ប៉ុន្តែតាមដោយធម្មតា ច្រើនតែបំបែកដូចជានាមសព្ទ ឬគុណសព្ទ ជាអការន្ត សព្ទទាំងនោះ គឺ :

ឧត្តរ, "ប្រសើរ," ឧត្តម, "ឧត្តម, ខ្ពង់ខ្ពស់"; អធរ "ថោកទាបជាង" អធម, "ថោកទាបបំផុត"; បូរ្វ "ដែលមាន ឬដែលកើតក្នុងកាលមុន"; បរ, «ដទៃ»; ស្វ "របស់ខ្លួន, ជារបស់ខ្លួន" ។

៤. គុណសព្ទទាំងឡាយ ដែលកើតមកពីសវ៌នាម (ល. ៨០-៨១-៨២) ដោយអាស្រ័យនឹងប្រត្យយ វន្ត ហៅថាគុណសព្ទក្លាយ គុណសព្ទនោះ គឺ:

ក) យាវន្ត "ប៉ុនណា, (ធំ) ប៉ុនណា, (មានទំហំ) ប៉ុនណា", តាវន្ត "ប៉ុណ្ណោះ, (ធំ) ប៉ុណ្ណោះ, (មានទំហំ) ប៉ុណ្ណោះ (ម. ល. ៦៥); នបុំ. កិ. វិ: យាវត "(យូរ) ដរាបណា, ត្រឹមណា", តាវត "(យូរ) ដរាបនោះ, ត្រឹមនោះ" (បើមានតែ យាវត ប្រែថា "រីឯ, ចំណែកឯ, ចំណែកខាង...")

ខ) តទ-វន្ត = តទ្វន្ត "មានយ៉ាងនោះ, មានដូចជា...នោះ, ប្រហែលដូចជា...នោះ" (ម. ល. ៦៨); នបុំ. កិ. វិ. តទ-វត = តទ្វត "តាមបែបយ៉ាង, តាមវិធី..." ។

(ប្រត្យយ វត ដែលភ្ជាប់នឹង នបុំ. កិ. វិ. ខាងលើនេះ, កាល

ហើយកមកភ្ជាប់នឹងនាមសព្ទវិញ គេអាចប្រើដូចនិបាតសព្ទ ជាឧបមានត្ថ ប្រែថា "ដូច..." ។ ទេវ-វត៌, "ដូចជាទេវតា", មនុស្ស-វត៌ "ដូចជាមនុស្ស", អហិ-វត៌ "ដូចជាពស់"; ចំណែកគុណសព្ទខ្លះ ក៏អាចប្រកបដោយប្រត្យយ វត៌ នេះដែរ ប្រើបានដូចគ្នា: បុរិ-វត៌ "ដូចកន្លកាលមុន") ។

គ) យទិយ, "របស់អ្នកណា", តទិយ "របស់អ្នកនោះ" (ម. ល. ៧៨ ត្រង់ ល. ៤) ។

ឃ) កតិ [១], "មានប៉ុន្មាន"; យតិ, "ប៉ុនណា"; តតិ, "ប៉ុននោះ".- សព្ទទាំងនេះ ប្រើចំពោះតែពហុវចន, វេលាបំបែកដូចគ្នាទាំង ៣ លិង្គ ឥតមានប្រែប្រួលផ្លាស់ប្តូរឲ្យផ្សេងគ្នាទៅតាមលិង្គឡើយ ។ ទឹងបំបែកតែ កតិ ១ ទុកជាបែបយ៉ាង: ប្រ. កតិ, ទុ. កតិ, ត. កតិភិ, ច. កតិន្នំ, ប. កតិភិ, ឆ. កតិន្នំ, ស. កតិសុ ។

ង) យតិ, តតិ បំបែកដូចគ្នានឹង កតិ ខាងលើនេះដែរ ។

---

១ បើជា កតិបយ, ប្រែថា "មានប៉ុន្មាន" ដូចគ្នា តែប្រើបានទាំង ៣ វចន វេលាបំបែកក៏ផ្លាស់ប្តូរទៅតាមលិង្គទាំង ៣ : ប្បុ. ឯក. បុំ. កតិបយោ; — ស្ត្រី. កតិបយា; — នបុំ. កតិបយំ ។ល។

ដំណើរដេរ្យង ។

# បំរៀនក្នុងឥណ្ឌា

យើងគិតថា បណ្ដាអ្នកមើលទស្សនាវដ្ដីរបស់យើង គង់ចង់ដឹងរឿងបំរៀនរបស់ប្រជាជនពួង ដែលគេតែងនាំគ្នារៀននោះខ្លះដែរ ពួកនេះមានទៅក្នុងចំណោមខេត្តនៃប្រទេសឥណ្ឌាកណ្ដាល ឯបទបំរៀនរបស់គេនោះ ពេញដោយសេចក្ដីពីរោះរាប់ចិត្តនឹងមានគំនិតត្រឹមត្រូវផង ។

ឯបទបំរៀននេះមាន ៦ បទដែលយើងស្រង់យកតែសេចក្ដីសំខាន់ៗ មកពន្យល់ដល់អ្នកមើលទស្សនាវដ្ដីនេះ ។

— ១ —

ផ្លែស្វាយទុំសម្រាប់ប្រើជាគ្រឿងបរិភោគ ឯសេចក្ដីមេត្តា ត្រូវគេរក្សាទុកជាទីពឹង ។

— ២ —

ធ្មេញរបស់អ្នកសស្អាតដូចជាពណ៌ប្រាក់ ហើយមុខរបស់អ្នកក៏ស្រស់ប៉ប្រិម ស្អួតជាទីទស្សនា ។ អ្នកនេះហើយដែលធ្វើឲ្យចិត្តខ្ញុំគាន់គាំងកិស្វង់ ប៉ុន្តែតាមពិតនោះដួងចិត្តរបស់អ្នកមិនមានមួយសុចរិតទៀងត្រង់ទេ ។ ហើយជីវិតរបស់ខ្ញុំនៅតែរាប់រាប់នៃសេចក្ដីទុក្ខជាដរាប ។

— ៣ —

កាលណាអ្នកព្រាត់ប្រាសចាកសំឡាញ់ម្នាក់ទៅ អ្នកអាចរកមកជំនួសវិញបាន ។ ប៉ុន្តែកាលណាអ្នកព្រាត់ប្រាសចាកម្តាយរបស់អ្នកទៅ កាលណោះ អ្នកនឹងងងឹតឈឹងតែម្តង ។ កាលបើគំនិតរបស់អ្នកងងឹត (ទាល់គំនិត) មានតែសំឡាញ់ជួយបំភ្លឺ ហេតុនេះ ទើបអ្នកត្រូវតែទៅស្វែងរកទាំងយំនៅកណ្តាលពិភពនេះ ។

— ៤ —

កាលទូតរបស់មច្ចុរាជមកដល់ផ្ទះគឺរាងកាយ ដែលបានចាត់ការថែទាំយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែទូតរបស់មច្ចុរាជនៅតែមកឈរចាំនៅមាត់ទ្វារ ហើយក៏ទឹងបិទទ្វារគ្រឹបមួយរំពេច នាំឱ្យៈ

— ម្តាយទ្រហោយំ អហឹ-អហឹ-អហឹ

— ប្អូនស្រីយំសោកដល់បងប្រុស ៦ ខែ

— ប្រពន្ធយំសោកដល់ប្តីត្រឹម ៣ ថ្ងៃ

ហើយពីនោះទៅទើបប្រទះនឹងបុរសថ្មីទៀត ។

— ៥ —

យើងរាល់គ្នាតែងជាប់នៅក្នុងសំណាញ់ ពោលគឺៈ

— ៦៣ —

សេចក្ដីស្នេហាចំពោះបុគ្គលដែលត្រូវជា ម្ដាយឪពុក

— បងប្អូនប្រុស

— បងប្អូនស្រី

— ប្ដីប្រពន្ធ

— ៦ —

ស្បែកជើងគេធ្វើឡើងសម្រាប់ពាក់នៅជើង សត្វពាហនៈ មានប្រយោជន៍សម្រាប់អ្នកជិះ ប៉ុន្តែម្ដាយឪពុករើសប្ដីមកជាគូនោះ មិនមែនបានជាប់មកខ្ញុំទេ ស្រេចនៅជោគជតារបស់ខ្ញុំ តែងជាប់មកនឹងខ្លួន តាំងអំពីព្រេងនាយ ៗ ឱះឱ! ឱះឱ! បើពោលតាមពិត តើក៏មានប្រយោជន៍តិចទេឬអ្វី? ដ្បិតជីវិតទុកដូចជាដុំពពុះទឹក គ្រាន់តែត្រូវខ្យល់ផាត់មកដំបូងក៏បែកទៅហើយ ៗ

*

* *

# អំពីជាតិសម្រែ

លោកបាក៉ដាត់ជាគ្រូពេទ្យសត្វនៅខែត្របាត់ដំបង មុនលោកនឹងចេញទៅឈប់សម្រាក លោកបានបង្ហើយបែបបង្រៀនពាក្យជាតិសម្រែមួយ ដែលមានប្រយោជន៍ច្រើន ៗ នៅក្នុងសេចក្ដីអស់នោះ មាននិយាយ

ពីចម្រៀងនិងវិធីសម្រាលកូនរបស់ជាតិពារ (Pear) សឹងមានរបៀបបែបផែនល្អ ។ ការងាររបស់លោកនេះមានប្រយោជន៍យ៉ាងធំដល់មនុស្សទូទៅ ដែលការគេគោលចារិកអំពីមនុស្សជាតិផ្សេងៗ នៅស្រុកខ្មែរ ។

មេបទបង្រៀនជាភាសាបារាំង- ខ្មែរ- សៀម (ទាំង ៣ ភាសានេះ) កាលបើបានបោះពុម្ពឡើង នឹងសម្រេចជាការងារដ៏ប្រសើរមួយរបស់លោកគ្រូពេទ្យនោះ ។

* * *

## អំពីការសិក្សាភាសាបាលី

ក្នុងទស្សនាវដ្ដីមហាពោធិប្រចាំខែណូវែម្ប្រ៍ ១៩៣៩ មានសេចក្ដីផ្សាយដំណឹងថា នៅមហាវិទ្យាល័យកល់គុតានិងបមបៃ និងមហាវិទ្យាល័យឯទៀតៗ នៅប្រទេសឥណ្ឌាមានចំនួនអ្នកសិក្សាជាច្រើនពាន់ ដែលនាំគ្នាសិក្សាក្នុងថ្នាក់បង្រៀនបាលី ហើយភាសាបាលីនេះចាត់ជាវិជ្ជាមួយ ដែលកូនសិស្សត្រូវប្រឡងដែរ ។

* * *

## អំពីភាពយន្តរាមកេរ្តិ៍

កាលពីខែណូវែម្ប្រ៍ ១៩៣៩ នោះ នៅក្រុងភ្នំពេញមានលេងកុន ១ ខ្សែល្អមើលណាស់ នៅមន្ទីរលេងកុន ។ គេលេងពីរឿងរាមាយណៈ

ឬរាមកេរ្តិ៍ ។ ឯគន់ទ័ពស្វានោះគេយកមនុស្សលេងជំនួសដោយពាក់មុខស្វា ដាក់ជាគន់ទ័ព ១ លេងក្នុងចំនួននេះ ធ្វើឲ្យយើងនឹកឃើញល្ខោនខ្មែរដែលមានពាក់មុខស្វា ប៉ុន្តែរឿងរ៉ាវដែលគេលេងនោះមិនបានលេងតាមចំនួនក្នុងរឿងរាមាយណៈជាភាសាសំស្ក្រឹត ឬដែលប្រែមកជារឿងរាមកេរ្តិ៍នោះទេ ។ បណ្ដារឿងរ៉ាវដែលល្អមើលណាស់នោះគឺត្រង់ដែលហនុមានបាចទឹកសមុទ្រដោយកន្ទុយ ហើយយកកន្ទុយធ្វើជាកំពែងខ្ពស់ការពារព្រះរាមនិងព្រះលក្ស្មណ៍ ហើយហនុមានដំណែងជាក្រពើចម្លងមហាសមុទ្រ ។

ប្រសិនបើយើងមានឱកាសល្មមប្រែរឿងរាមាយណៈរបស់ឥណ្ឌាទាំងស្រុងមកជាខ្មែរបាន យើងក៏នឹងប្រែផ្សាយដល់អ្នកមើលទស្សនាវដ្ដីនេះមិនខាន ។

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ៣

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម




ក្រុមជំនុំទំនៀមទំលាប់
COMMISSION DES MŒURS & CO TUMES

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស ២៤៨២
គ.ស. ១៩៤០

# បញ្ជីរឿង


១ — អារម្ភកថារបស់ពុទ្ធប្បវត្តិ តាមគោលបារិករបស់ចិន (នៅមានត) . . . . . . . ៣

២ — និយាយពីសាលាបង្រៀនមនុស្សខ្វាក់នៅប្រទេសសៀមនឹងទ្វីបអឺរ៉ុប ខេមររង្សី ប្រែរួបរួមពីសៀវភៅផ្សេងៗ . . . . . . . . . . . . . . . . . . ៩

៣ — ហេតុដូចម្ដេចបានជាព្រះពុទ្ធសាសនាផុតរលត់បាត់ទៅពីប្រទេសឥណ្ឌៀ? ខេមរៈរង្សីស្រង់មកអំពីទស្សនាវដ្ដីធម្មចក្សុសៀម ហើយប្រែមកជាខេមរភាសា . . . . ១៩

៤ — ប្រវត្តិលោកមីលរេប៉ៈ តាមសេចក្ដីប្រែពីភាសាទីបេតាំងមកជាបារាំងសែសរបស់លោកស័កបាកូត៍ (នៅមានត) . . . . . . . . . . . . . . . . . . ៣១

៥ — ពង្សាវតារប្រទេសអេស៊ីប្ដ៍ លោកមហាថែម ប្រែចេញពីប្រវត្តិសាស្ត្រសាកល របស់ហ្លួងវិចិត្រវាទការ (ត) . . . . . . . . . . . . . . . . . . ៣៥

៦ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . ៤៥

៧ — វេយ្យាករណ៍សំស្ក្រឹត ភាគទី ៥ របស់ព្រះសាក្យវង្ស (តនឹងចប់) . . . . . . . ៥៣

៨ — ប្រជុំពាក្យកាព្យភាគទី ៤ របស់រក្សកិរម្យ អ៊ូង (មានត) . . . . . . . . ៥៧


## រូបក្រៅរឿង


១ — សុបិននិមិត្តនៃព្រះនាងមហាមាយា . . . . . . . . . . . . . . . . . . ១

២ — ព្រះពោធិសត្វទ្រង់ប្រសូតិ . . . . . . . . . . . . . . . . . . . ៧

៣ — ទ្រង់ឈាន ៧ ជំហាន . . . . . . . . . . . . . . . . . . . . ១៧

៤ — យាងទៅកាន់ក្រុងកបិលពស្តុ . . . . . . . . . . . . . . . . . . ៣៣

៥ — លោកមីលរេប៉ៈ មកចាប់កំណើត . . . . . . . . . . . . . . . . . . ២៩

# មនុស្សជាតិ

អំពីមនុស្សនានាជាតិ ដែលនៅលើផ្ទៃពិភពលោកនេះ មានអ្នកប្រាជ្ញបែងចែកជាច្រើនយ៉ាងផ្សេងៗគ្នា តែបើប្រមូលឲ្យខ្លីទៅ មាន ២ យ៉ាង គឺបែងតាមពណ៌សម្បុរម្យ៉ាង បែងតាមសំដីដែលនិយាយម្យ៉ាង ។

ការបែងតាមលក្ខណៈពណ៌សម្បុរនោះចែកចេញជា ៣ ពួក គឺជាតិលឿង ១ ពួក, ជាតិស ១ ពួក, ជាតិខ្មៅ ១ ពួក តែតមកសម័យក្រោយគេបានថែម ១ ពួកទៀត គឺពួកជាតិក្រហម ដែលធ្លាប់ជាម្ចាស់ទ្វីបអាមេរិកអំពីដើម ។ ហេតុនេះ ក្នុងសម័យនេះគេបែងមនុស្សជាតិជា ៤ ពួក គឺ:

១) ជាតិលឿង មានភូមិលំនៅដើមនៅក្នុងទ្វីបអាស៊ីខាងជើង ខាងកើតនិងត្រង់ភាគកណ្ដាល គឺចិន, ជប៉ុន, សៀម, ភូមា, មន, ខ្មែរ, យួន ។ល។

២) ជាតិស មានភូមិលំនៅដើមនៅក្នុងទ្វីបអឺរ៉ុបនិងអាស៊ីទិសខាងលិចនិងអាហ្វ្រិកទិសខាងកើតឆៀងខាងជើង ។

៣) ជាតិខ្មៅ មានភូមិលំនៅដើមនៅក្នុងទ្វីបអាហ្វ្រិកៈជាច្រើន និងទីដទៃៗក្នុងអាស៊ីក៏មានខ្លះ តែជនពួកនេះមានសេចក្ដីចំរើនតិចតួចស្ទើរស្ដើងពេក មិនមានរឿងរ៉ាវដែលគួរនាំមកសិក្សាប៉ុន្មានទេ ។

៤) ជាតិក្រហម ជាម្ចាស់ទ្វីបអាមេរិកអំពីដើម តែជាតិអឺរ៉ុបចូលទៅ

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1° Introduction à une maquette sur la Vie du BOUDDHA d'après des documents chinois | 3 |
| 2° Au sujet de l'inauguration de l'école des Aveugles en THAILAND et de celles en EUROPE par KHEMARARANSI | 9 |
| 3° Pourquoi le Bouddhisme a-t-il disparu des INDES? extrait de la Revue thailandaise DHAMMA CAKKSU et traduit en cambodgien par KHEMARARANSI | 19 |
| 4° La Vie de Milarépa d'après la traduction du tibétain en FRANÇAIS de Mr. JACQUES BACOT (suite) | 31 |
| 5° Histoire de l'ÉGYPTE, extraits de l'histoire générale thailandaise, par LUONG VICHITRA-VADAKAR et traduit en cambodgien par MAHA THÈM (suite) | 35 |
| 6° INFORMATIONS DIVERSES | 45 |
| 7° GRAMMAIRE SANSCRITE 5e partie, par le Vénérable Préas SAKYAVONG (H.-Tath suite et fin) | 53 |
| 8° RECUEIL DE POÈMES cambodgiens, 4e partie par RAK-PHROM UONG (suite) | 57 |


HORS TEXTE :


| | |
|---|---|
| 1° Le rêve de la reine MAYA | 1 |
| 2° La naissance du BOUDDHA | 7 |
| 3° Les sept premiers pas | 17 |
| 4° Vers la cité royale | 33 |
| 5° La naissance de Milarépa | 29 |



១ នេះត្រង់សុបិននិមិត្តរបស់ព្រះនាងមហាមាយាទេវី
(មើលសេចក្តីពន្យល់នៅទំព័រ ៨ ត្រង់លេខ ១)

## អារម្ភកថា

គំនូរទាំង ៤៩ រូបដែលមានបោះពុម្ពផ្សាយក្នុងសៀវភៅនេះ ជារូបដំណាងត្រង់រឿងរ៉ាវសំខាន់ៗក្នុងពុទ្ធប្បវត្តិ ជារូបគំនូរយួនដែលមាននៅក្នុងសៀវភៅយួនជាន់ចាស់ពីរក្បាល បោះពុម្ពកាលពីពុទ្ធសករាជ ២៤០០ និង ២៤១២ ។ សៀវភៅទាំងពីរក្បាលនេះ គេបានចម្លងមកត្រង់ៗឥតល្អៀងអំពីសៀវភៅចិនជាន់ចាស់ពីរក្បាលដែរ ដែលគេបានធ្វើឡើងកាលពីពុទ្ធសករាជ ១៨៨៧ ។ ព្រះរាជបណ្ណាល័យកម្ពុជា មានសៀវភៅដែលបោះពុម្ពជាភាសាយួន ១ ក្បាល កាលពីពុទ្ធសករាជ ២៤០០ ។

ការបោះពុម្ពរូបអស់នេះ យើងមានសង្ឃឹមថា នឹងមានប្រយោជន៍ដល់ពុទ្ធសាសនិកជនទូទៅ ដ្បិតក្រៅពីសេចក្ដីសារសព្វនៅមានរូបគំនូរល្អៗ សម្រាប់ឲ្យមើលថែមទៀតផង សុទ្ធតែជារូបធៀបនាំឲ្យមើលឃើញកិច្ចការនិងរឿងរ៉ាវដែលមាននៅតាមធម្មតាក្នុងប្រទេសចិន នៅក្នុងពុទ្ធសករាជ ១៨៨៧ នោះ ។ មួយវិញទៀត រូបអស់នេះបង្ហាញឲ្យយើងបានដឹងរបៀបធ្វើបុណ្យ, របៀបស្លៀកបំពាក់, ការសាងវាំង-សាងវត្តនិងគេហស្ថាន, សណ្ឋានទ្រង់ទ្រាយទីក្រុង និងស្រុកនានាក្នុងប្រទេសចិនសម័យនោះ ។

ក្រៅពីនេះ សៀវភៅនេះនឹងបង្ហាញឲ្យយើងដឹងរឿងរ៉ាវពុទ្ធប្បវត្តិ តាមបែបមហាយាន ដែលមាននៅក្នុងស្រុកយួន និងស្រុកចិនថែមទៀតផង ។

ក្រៅពីនេះ លទ្ធិមហាយានជាកំឡាំងមួយ ដែលបានជួយឲ្យកើតបែបចនាផ្សេង ៗ ក្នុងចំណោមប្រាសាទខ្មែរបុរាណ ដូចប្រាសាទអង្គរ ប្រាសាទព្រះខ័ន, តាព្រហ្ម និងបន្ទាយក្តីជាដើម ។

ឯសៀវភៅចិននោះ គេបានបោះពុម្ពច្រើនលើកច្រើនគ្រាដែរ តែមិនសូវជាថ្លៃថ្លាទេ ។ លុះមកដល់ពុទ្ធសករាជ ២៤២៤ ទើបមានលោកសង្ឃចិន ១ អង្គកាន់បែបមហាយាន បានចាត់ចែងបោះពុម្ពឲ្យត្រឹមត្រូវល្អឡើង ។ លុះតមកឆ្នាំក្រោយ ៗ នេះ មានគណៈអ្នកផ្សាយសាសនាកាតូលិក ១ រូប នៅស្រុកចិន ឈ្មោះលោកសង្ឃក្រហង់រីដូរេ (Père Henri Doré) បានចាត់បោះពុម្ពរឿងរ៉ាវពុទ្ធប្បវត្តិនេះជាភាសាបារាំងសែស មានទាំងរូបគំនូរនានាដូចគ្នាដែរ (មានពណ៌ផង) ឯសៀវភៅនេះនៅព្រះរាជបណ្ណាល័យកម្ពុជាក៏មានដែរ ។

មានរឿងរ៉ាវខ្លះ មិនត្រូវគ្នានឹងរឿងរ៉ាវដែលមានសំដែងទុកក្នុងគម្ពីរបាលី ប៉ុន្តែសេចក្តីប្លែកគ្នានេះ យើងមិនត្រូវមានសេចក្តីងឿងឆ្ងល់ទេ ព្រោះខាងគម្ពីរមហាយាន គេបានប្រែចេញពីគម្ពីរសំស្ក្រឹត មានគម្ពីរលលិតវិស្តារៈជាដើម គម្ពីរនេះនៅព្រះរាជបណ្ណាល័យកម្ពុជាក៏មានដែរ តែជា

ភាសាបាលីផងសែស ។ ឯសេចក្តីពន្យល់អំពីរូបគំនូរអស់នេះបានមកពីលលិតវិស្តារៈ និងខ្សែកុនពុទ្ធប្បវត្តិ ដែលគេបានស្រង់យកសេចក្តីពន្យល់អំពីសៀវភៅរបស់លោកសញ្ញពដពៃតរដូរ សុទ្ធតែជារបស់ដែលមាននៅក្នុងព្រះរាជបណ្ណាល័យទាំងអស់ ។

## ១) — អំពីសុបិននិមិត្តរបស់ព្រះនាងមហាមាយា

. . . ថ្ងៃពេញបូណ៌មី គឺថ្ងៃ ១៥ កើត ព្រះពោធិសត្វចុះចាកស្ថានតុសិតចូលកាន់ផ្ទៃនៃព្រះរាជមាតា ជារូបដំរីសសុទ្ធមួយ ។

## ២) — ព្រះពោធិសត្វប្រសូតិ

. . . សម្តេចព្រះនាងមហាមាយាទេវីទ្រង់ឈោងព្រះហស្តតោងចាប់មែកដើមបលសៈ ស្រាប់តែព្រះពោធិសត្វស្តេចចេញចាកឆ្អឹងជំនីរខាងស្តាំរបស់ព្រះរាជមាតា ខណៈនោះព្រះឥន្ទ្រាធិរាជជាស្តេចនៃទេវតា ស្តេចចុះមកទទួលព្រះអង្គដោយព្រះហស្តទាំងពីរ ។

## ៣) — ព្រះពោធិសត្វទ្រង់ធ្វើដំណើរ ៧ ជំហាន

. . . ខណៈនុ៎ះ មានផ្កាឈូក ១ យ៉ាងធំផុះចេញពីផែនដីទទួលទ្រព្រះបាទ ស្តេចនាគទ្រង់ផ្ងូតព្រះអង្គដោយទឹកក្តៅ-ទឹកត្រជាក់ ។ ព្រះពោធិសត្វ

ទ្រង់បែរព្រះភក្ត្រទៅទិសខាងកើត ហើយទ្រង់ឈាន ៧ ជំហាន ហើយមានព្រះបន្ទូលថា "អាត្មាអញនឹងបង្អុរភ្លៀងឲ្យធ្លាក់ចុះពីមហាមេឃពោលគឺព្រះធម៌ ស្រោចស្រង់សត្វលោកឲ្យបានសេចក្តីក្សេមក្សាន្ត" ។

## ៤)– ស្តេចយាងត្រឡប់ទៅព្រះនគរ

. . . ព្រះពោធិសត្វទ្រង់គង់លើរាជរថដែលមានស្រីទេពអប្សរចំនួន ២០.០០០ នាក់សឹងស្អិតស្អាងដោយគ្រឿងអលង្ការចាប់អូសព្រះរាជរថ ហើយស្តេចចូលទៅកាន់មហានគរកបិលពស្តុ (សេចក្តីនេះមិនមានសំដែងទុកក្នុងគម្ពីរហីនយាន ) ។

(មានត)



២ នេះត្រង់ព្រះពោធិសត្វប្រសូតិ

(មើលសេចក្ដីពន្យល់នៅទំព័រ ៨ ត្រង់លេខ ២)

អំពីសាលាបង្រៀនមនុស្សខ្វាក់

# នៅប្រទេសថៃនិងឱរុប

ខេមរវង្ស

ប្រែនិងរួបរួមពីកាសែតថៃនិងវិចនានុក្រមបារាំងសែស

# អំពីសាលាបង្រៀនមនុស្សខ្វាក់

កាសែតប្រជាមិត្រ ចុះថ្ងៃ ២០ យូកុំង ឆ្នាំ ១៩៣៩ មានថ្លែងសេចក្ដីសារសព្វថា តំបន់ខៅឌិនវណា (កុំដីវនា) ក្បែរស្ទួនគុសិត នៅក្រុងបាងកកនោះ តាំងអំពីបានរៀបចំទីនោះជាថ្មី តែងមានប្រជាជនប្រុស-ស្រី ទៅដើរកំសាន្តចិត្តពុំសូវដែលខាន ។

នៅទំព័រ ១ របស់កាសែតនេះ គេបោះពុម្ពរូបស្រីម្នាក់ជាតិអាមេរិកាំង មានភ្នែកខ្វាក់ទាំងសងខាង មានអាយុច្រើនហើយតែនៅក្រមុំ ឈ្មោះ នាងយេនេវីហ្វគលហ្វីលដ៍ នៅក្បែរខាងមានស្រីម្នាក់ទៀត គឺកូនចិញ្ចឹម របស់នាង និងអ្នកនាំផ្លូវជាតិសៀមម្នាក់ នាងគលហ្វីលដ៍នេះហើយដែល ជាអ្នកចាត់តាំងសាលាបង្រៀនមនុស្សខ្វាក់ជាដំបូងនៅក្រុងបាងកក ។

# អំពីការជួយសង្គ្រោះមនុស្សខ្វាក់

ក្នុងកាសែតដដែលនេះ ចុះថ្ងៃ ២១ តមកមានថ្លែងសេចក្ដីអំពីរបៀប ចាត់តាំងក្រុមជំនុំមួយក្រុម ដើម្បីជួយសង្គ្រោះមនុស្សខ្វាក់ក្នុងស្រុកសៀម ដូចមានសេចក្ដីសារសព្វថា:

ការជួយសង្គ្រោះមនុស្សខ្វាក់ក្នុងប្រទេសសៀម ឈ្មោះថាបានចាប់តាំងឡើងហើយ ដោយមានបុគ្គលដែលជាអ្នកយកចិត្តទុកដាក់ជួយ

សង្គ្រោះមនុស្សផងគ្នាដែលមានភ្នែកពិការ (ខ្វាក់) ទើបបានតាក់តាំងមូល-និធិឡើងដើម្បី " ជួយទីងបង្រៀនមនុស្សខ្វាក់ " ហើយក្រសួងមហាផ្ទៃបានចុះបញ្ជីឲ្យអំណាចមូលនិធិនេះធ្វើការបានតាមច្បាប់ហើយ ។

គ្រូពេទ្យហ៊ុនថង ស៊ែងសិងកែវ តាំងហ្វាំងមន្ទីរពេទ្យរក្សាពេគចិត្តតំបន់ប៉ាកខ្លងសាន ដែលជាអ្នកយកចិត្តទុកដាក់ទីងរឿងនេះ តមកបានទៅនិយាយការជាមួយទីងនាងស្រីយេនើហ្គូលហ្វីលដ៍ ជាសុភាពស្រីខ្វាក់ភ្នែកជាតិអាមេរិកាំង នាងធ្លាប់ធ្វើជាគ្រូបង្រៀនអក្សរផុសមនុស្សខ្វាក់ក្នុងប្រទេសជប៉ុន ។ ការពិគ្រោះប្រឹក្សាគ្នាអំពីការសង្គ្រោះមនុស្សខ្វាក់ក្នុងប្រទេសស្យាម ហើយបានសុំអនុញ្ញាតដល់ក្រសួងមហាផ្ទៃដោយមានបុគ្គលអស់នេះជាក្រុមជំនុំ :

ហ្វូងលេខាវិហារណ៍ជា (អធិបតី) គ្រូពេទ្យហ៊ុនថង ស៊ែងសិងកែវ ជាលេខាធិការ ហ្វូងប្រចក្ខវេជសុទ្ធិ ជាហេរញ្ញិក នាងស្រីយេនើ-ហ្គូលហ្វីលដ៍, គ្រូពេទ្យថង, ព្រះអង្គម្ចាស់ពិបិត្របិកកាទេវកុល, គ្រូពេទ្យស្រីកៀន ហ៊ុនត្រកូល, នាយស្និទ្ធប្រើនវេជ្ជ នាងនោក៉, ប្អូងព្យុងវេជ្ជសាស្ត្រ, ព្រះយ៉ាប្រីជានុសាស្ត្រ, ព្រះវិនិចវនន្ទរ, នាយហ្វូងវ៉ែន, ធនសារ, ហ្វូងវិជៀនពេទ្យាគម (ជាក្រុមជំនុំ) ។

គ្រប់គ្រងត្រួតត្រា ទើបក្លាយទៅជាទ្វីបដែលមានសេចក្ដីចំរើនស្តុកស្តម្ភបំផុតក្នុងលោកនេះ ។

ឯវិធីចែងតាមសំដីភាសារបស់នានាជាតិក្នុងលោកនេះ អ្នកប្រាជ្ញច្រើនតែចែកចេញជា ៣ ពួក ហៅថា ហេមីទិក ១ សេមីទិក ១ និងអារិយ៉ាន ១ ។ កំណើតភាសាហេមីទិកនោះ បានដល់ពួកអេស៊ីប្ដ៍បូរាណជាដើម ។ កំណើតភាសាសេមីទិក បានដល់ពួកបាបិឡូន អស្ស៊ីរី, អារ៉ាប និងស៊ីរី ។ អារិយ៉ាន បានដល់ពួកឱរុប, ឥណ្ឌូ, ប៉ែរ្ស៍ជាដើម ។ បើរាប់បញ្ចូលភាសាចិនមួយទៀត ត្រូវរាប់ថាកំណើតភាសាក្នុងលោកនេះមាន ៤ ពួក គឺថាភាសាក្នុងលោកនេះចែកចេញជា ៤ ប្រភេទ ហៅថា ហេមីទិក ១ សេមីទិក ១ អារិយ៉ាន ១ និងចិន ១ ។ បើយើងពិនិត្យមើលសំដីភាសា ទាំង ៤ ប្រភេទនេះនឹងឃើញថា ពួកភាសាអារិយ៉ានមានសេចក្ដីចំរើនរុងរឿងជាងពួកភាសាដទៃ ៗ ទាំងអស់ ស្ទើរតែភាសាអារិយ៉ានជានាយចៅហ្វាយភាសាសំដីនៅក្នុងលោកសព្វថ្ងៃនេះ ។

## វិធីរៀបរៀងប្រវត្តិសាស្ត្រ

ការរៀបរៀងប្រវត្តិសាស្ត្រលោកនេះ យើងមានបំណងនឹងធ្វើឱ្យបានសម្រេចជាប្រយោជន៍ ២ ប្រការ គឺដើម្បីញុំាងអ្នកដែលមិនធ្លាប់មើលប្រវត្តិសាស្ត្រនោះ ឱ្យមើលសេចក្ដីអស់នេះយល់បានមិនលំបាកពេក

ខណៈនេះ នាងស្រីគលហ្វិលដ៍នឹងស្ត្រីជាកូនចិញ្ចឹមជាតិជប៉ុន បានបើកសាលាបង្រៀនអក្សរដល់ក្មេងខ្វាក់ ហើយបង្រៀនវិជ្ជាការដែលធ្វើដោយដៃផ្សេង ៗ ដែលសមគួរនឹងមនុស្សខ្វាក់ល្មមធ្វើបាន នៅក្នុងរោងរៀនមនុស្សខ្វាក់ គឺនៅទីសំណាក់មូលនិធិ ថ្នល់កតឈេ សាលាដែង ។

បំណងនៃការតាំងមូលនិធិឡើងនេះ ដើម្បីជួយសង្គ្រោះមនុស្សខ្វាក់ឲ្យបានការមាំមួនឡើង ដោយមានសង្ឃឹមថានឹងបានទទួលធនធានជាដើមទុនអំពីបណ្ដាអ្នកមានចិត្តសទ្ធាជ្រះថ្លា ជាការកុសលជួយសង្គ្រោះពួកមនុស្សដែលមុខគួរអាណិតនេះ ឲ្យបានទទួលការសិក្សាល្មមឲ្យមានសភាពជាមនុស្សគ្រាន់បើឡើងខ្លះ កុំឲ្យមានសេចក្ដីវេទនាពេកប៉ុណ្ណោះ ។

មានដំណឹងថា ក្រុមជំនុំកំពុងរៀបចំចាត់របៀបវិធីផ្សេង ៗ ដើម្បីឲ្យបានជំនួយពីប្រជាជន ជាការសង្គ្រោះមនុស្សឲ្យមានសេចក្ដីចេះដឹងកិច្ចការផ្សេង ៗ សមនឹងសង្ខាររបស់ខ្លួនតរៀងទៅ ។

## ប្រ៊ៃយ៍ (Braille)

ក្នុងសព្វវចនាធិប្បាយឡារូសធំ ត្រង់ដែលនិយាយពន្យល់អំពីកំណើតប្រ៊ៃយនោះថា ប្រ៊ៃយ គឺលោកអាចារ្យបង្រៀនមនុស្សខ្វាក់នៅក្រុងប៉ារីស មានកំណើតនៅគុបរ៉េ កាលពីឆ្នាំ ១៨០៩ អនិច្ចកម្មនៅក្រុង

ប៉ារីសកាលពីឆ្នាំ ១៨៥២ ។ លោកនេះខ្វាក់តាំងពីអាយុបាន ៣ ឆ្នាំហើយ បានចូលរៀនក្នុងសាលាមនុស្សខ្វាក់កាលពីឆ្នាំ ១៨១៩ លោកល្វីប្រ៉ៃយនេះខំព្យាយាមរៀនភ្លេង ហើយបានទៅជាអ្នកភ្លេងអរកែសប្រចាំព្រះវិហារជាច្រើនក្នុងក្រុងប៉ារីស ។ តមកបានធ្វើជាអាចារ្យបង្រៀនពួកមនុស្សខ្វាក់ ហើយបានរៀបចំរបៀបបែបឲ្យងាយស្រួលក្នុងការរៀន ដោយគិតប្រឌិតបែបអក្សរធ្វើជាចុច ៗ មានពន់ទុលឡើងជាគ្រឿងចំណាំជាជំនួសព្យញ្ជនៈនិងស្រៈ សម្រាប់សិស្សសិក្សាវិជ្ជាអក្សរបានឆាប់ថេះ ៗ ដល់មកឥឡូវនេះ គេនិយមប្រើវិធីប្រ៉ៃយទូទៅក្នុងលោក ហេតុនេះពាក្យថា ប្រ៉ៃយក្លាយទៅជាឈ្មោះអក្សរ ឈ្មោះគ្រឿងសំគាល់បទភ្លេងជាដើម ក៏និយមហៅថា ប្រ៉ៃយទាំងអស់ ។

កាលពីពុទ្ធសករាជ ១.៧៦៣ មានស្តេច ១ អង្គក្នុងមហានគរបារាំងសែស បានសាងសាលាបង្រៀនមួយសម្រាប់បង្រៀនមនុស្សខ្វាក់ ។ ដល់មកក្នុង ព. ស. ២.៣២៧ ទើបលោកវ៉ាឡាំងតាំងហ៊ុយបានកសាងសាលាបង្រៀនមនុស្សខ្វាក់មួយឡើងជាដំបូងនៅក្រុងប៉ារីស ទើបគ្រប់ ៗ ប្រទេសនៅទ្វីបឥរុបនាំគ្នាធ្វើតាមឡើង គឺបង្កើតឲ្យមានសាលាមនុស្សខ្វាក់ក្នុងស្រុករបស់ខ្លួន ៗ ដល់មកក្នុងឆ្នាំ ២.៣៩៥ ទើបមានជនជាតិ

បារាំងសែសម្នាក់ទៀតឈ្មោះលោកល្វីប្រ៉ាយ បានគិតប្រឌិតព្យញ្ជនៈជាគ្រឿងសញ្ញាមានចុច ៗ ជាពន់ទុលជាគ្រឿងសំគាល់ដោយខ្សែ វិធីនេះងាយស្រួលដល់ការហាត់រៀនបែបក្មេង, ស្តេណូទីងវិជ្ជាដាក់ទីឡូក្រា-ហ្វី ។ នៅលោកតាំងមូល គេប្រើអក្សរប្រ៉ាយនេះជាគ្រឿងបង្រៀនមនុស្សខ្វាក់ ព្រោះរូបព្យញ្ជនៈបែបនេះជាគ្រឿងសញ្ញាប្រើការបានគ្រប់ៗភាសា គឺប្រើជាភាសាបារាំងសែស, ភាសាអង់គ្លេស, ភាសាអាល្លឺម៉ង់, ជប៉ុន, ស៊ុយអែតជាដើមបានទាំងអស់ ។

ដល់មកឥឡូវនេះ មានដំណឹងថា ស្រុកសៀមទើបនឹងបង្កើតព្យញ្ជនៈបែបនេះឡើង ជាបែបអក្សរសម្រាប់បង្រៀនមនុស្សខ្វាក់ក្នុងស្រុកសៀម ។ ចុះនៅស្រុកខ្មែរយើង ៗ យល់ថានៅមានចំនួនមនុស្សខ្វាក់តិចឬ? មានអ្នកប្រាជ្ញបារាំងសែសពីរនាក់ បាននាំយកគ្រឿងប្រដាប់សំរាប់បង្រៀនមនុស្សខ្វាក់ក្នុងលោកតាំងមូលមកផ្សាយហើយ តើរាជការនឹងគួរឲ្យយកមកប្រើការជាប្រយោជន៍ដល់មនុស្សខ្វាក់នៅស្រុកខ្មែរខ្លះដែរឬទេ? ព្រោះនៅប្រទេសឯទៀត ៗ ក្នុងចំណោមឥណ្ឌូស៊ីនគេបង្កើតឲ្យមានសាលាបង្រៀនមនុស្សខ្វាក់អស់ហើយ ។

ខេមររង្សី ប្រែនិងរៀបរៀង

ពីកាសែតថៃ និងវចនានុក្រមបារាំងសែស



៣ នេះត្រង់ព្រះពោធិសត្វទ្រង់ធ្វើដំណើរ ៧ ជំហាន

(មើលសេចក្ដីពន្យល់ទំព័រ ៨)

# ព្រះពុទ្ធសាសនាបាត់ទៅ
# ពីប្រទេសឥណ្ឌៀ ដោយហេតុយ៉ាងណា?

ខេមរង្សី

ប្រែនិងរៀបរៀង

( មានត )

# ពុទ្ធសាសនាបាត់ទៅ
# ពីប្រទេសឥណ្ឌា ដោយហេតុយ៉ាងណា?

បណ្ដាហេតុការណ៍ទាំងពួង ដែលមានប្រាកដក្នុងពង្សាវតាររបស់សាសនានានាក្នុងលោកនេះ ហាក់ដូចជាមិនមានហេតុការណ៍ដទៃ ដែលមុខគួរឲ្យសង្វេគស្លុតចិត្ត ប្រហែលនឹងការលេតសាបសូន្យទៅ នៃព្រះពុទ្ធ-សាសនាក្នុងប្រទេសឥណ្ឌា ដែលជាស្រុកកំណើតរបស់ខ្លួននោះឡើយៗ

ស្រុកឥណ្ឌានោះ មិនមែនត្រឹមតែជាស្រុកកំណើតរបស់ព្រះពុទ្ធប៉ុណ្ណោះទេ ឥណ្ឌាជាទីប្រជុំមនៃគណៈធម្មទូតដែលចេញទៅប្រកាសព្រះពុទ្ធសាសនាគ្រប់ទិសក្នុងទ្វីបអាស៊ី គប់តាំងពីផែនដីដែលដេរដាសដោយទឹកសន្សើម-ទឹកកកនៅប្រទេសស៊ីបេរី រហូតទៅដល់កោះជ្វា ដែលជាទីបរិបូណ៌ដោយនានារុក្ខជាតិ ក្នុងគ្រានោះផែនដីផ្សេងៗ អស់នេះរុងរឿងទៅដោយពន្លឺព្រះធម៌របស់ព្រះពុទ្ធទាំងអស់ ។

ព្រះពុទ្ធសាសនាបានផ្សាយចូលទៅក្នុងប្រទេសចិន តាំងអំពី ២០០ ឆ្នាំមុនគ្រិស្ដសករាជ ទឹងនៅក្នុងរវាងគ្រិស្ដសករាជ ៣៧២ និង ៤០០ សាសនានេះក៏ផ្សាយចូលទៅក្នុងប្រទេសកូរ៉េនិងជប៉ុនដោយលំដាប់ ៗ ប្រទេសសៀម, លាវ, ខ្មែរ, មន, ភូមា, ក៏បានទទួលយកពុទ្ធសាសនា

មកគោរពប្រតិបត្តិជាយូរអង្វែងហើយដែរ ឯលង្កាទ្វីបនោះជាបង្គោលរបស់ពុទ្ធសាសនាមុនគេ ហើយបានទំនុកបំរុងសាសនានេះទុកដោយល្អ ដរាបមកដល់ឥឡូវនេះ ។

ប្រទេសអស់នេះនឹងប្រទេសឯទៀត ៗ ដែលទទួលយកឥទ្ធិពលរបស់ពុទ្ធសាសនាមកមុនឬក្រោយ តែងមានសម្ពន្ធទាក់ទងនឹងប្រទេសឥណ្ឌា ដោយខ្ជាប់ខ្ជួនរហូតមក បណ្ដាអ្នកសិក្សាពុទ្ធសាសនាចេញពីប្រទេសអស់នេះ នាំគ្នាដើរសំដៅទៅរៀនសូត្រធម្មវិន័យតាមសំណាក់ផ្សេង ៗ ក្នុងឥណ្ឌា មានស្រុកនាឡន្ទាវិក្រមសិលា នឹងឧទន្តបុរីជានិច្ចមិនសូវដាច់ខាន ។

ក្នុងសម័យនោះ មហាជនក្នុងលោកមានសេចក្ដីគប់អានឥណ្ឌា ហាក់ដូចជាឃ្លាំងនៃបញ្ញា វប្បធម៌របស់ឥណ្ឌាក្នុងសម័យនោះខ្ពង់ខ្ពស់ ទាំងអាចដុសខាត់ចិត្តគំនិតប្រទេសឯទៀត ៗ ឲ្យបានខ្ពង់ខ្ពស់បានទៀតផង ការអប់រម្យចិត្តរបស់ឥណ្ឌា គ្រានោះមានសេចក្ដីចំរើនរុងរឿងល្អណាស់ ៗ ការរចនា, ការកសាង, ការឆ្លាក់ ការគូររសៈផ្សេង ៗ ដែលសេសសល់នៅឲ្យយើងមើលឃើញច្បាស់ហើយ ៗ វត្ថុបុរាណផ្សេង ៗ ដែលជាផលនៃសិល្បកម្មអស់នេះ ទុកជានៅក្នុងសភាពទ្រុឌទ្រោមអស់ទៅជាច្រើន ក៏នៅមានមនុស្សក្នុងសម័យនេះ សរសើរស្នាដៃជាន់នោះជាអនេក

គឺថាមនុស្សក្នុងសម័យនោះ មានសេចក្ដីចំរើនរុងរឿងជាសម័យ "សុវណ្ណ-យុគ" នៅក្រោមរស្មីនៃព្រះពុទ្ធសាសនាដោយពិត ។

ក្នុងបច្ចុប្បន្ននេះ ចិន, ជប៉ុននឹងទីបេត៍នៅខាងជើង; សៀម, ភូមា, មន, ខ្មែរនៅខាងត្បូង កាន់ការត្រួតត្រាសាសនារបស់ព្រះសម្ពុទ្ធដោយល្អ ឥណ្ឌាក៏ចាប់ភ្ញាក់ទឹកឃើញដល់មរដកដ៏មានដំលៃរបស់ខ្លួនដែលបាត់បង់ទៅពីស្រុកខ្លួន ។ ក្នុងសម័យព្រះចៅទេវានម្បិយតិស្សនោះ ព្រះម-ហាមហិន្ទត្រូវបានពណ៌នា ពីប្រទេសឥណ្ឌាថា "ប្រទេសឥណ្ឌាធ្លុះពន្លឺដោយសំពត់ព័ណ៌លឿងគ្រប់តំបន់" តែមកដល់កាលឥឡូវនេះ អាចពោលបានថា មិនមានពុទ្ធសាសនិកជនសេសសល់នៅសោះឡើយក្នុងប្រទេសឥណ្ឌា ។

ឯហេតុការណ៍ប្រែប្រួលនៃព្រះពុទ្ធសាសនានេះ កើតឡើងពីកាលណា? ហេតុប្រែប្រួលដ៏អស្ចារ្យនេះកើតឡើងក្រោយគ្រិស្តសករាជ ១២០០ តាំងអស់ តែកាលបើពិនិត្យស្រាវជ្រាវរកហេតុផលដោយសព្វគ្រប់ទៅ ការរលត់សាបសូន្យទៅនៃសាសនានេះ ដោយហេតុកើតចលាចលឡើង ព្រោះមានពួកមុស្លិមរុករានទន្ទ្រានចូលមកញាំញីបន្តិចម្ដងៗ ជាលំដាប់ៗមក ។

ព្រះពុទ្ធជាម្ចាស់រលត់ខន្ធចូលកាន់បរិនិព្វានទៅ, មុនគ្រិស្តសករាជ ៤៨៣ ឆ្នាំ ក្នុងវេលានោះ ធម្មវិន័យរបស់ព្រះអង្គមិនទាន់បានកត់ត្រាចុះ

ជាល័ក្ខហានទៅឡើយ  អាចនឹងលេចបាត់ទៅពីក្នុងលោកនេះ  ដោយឆាប់រហ័សមិនខាន  ព្រះសាវ័ករបស់ព្រះសាស្ដាបានពិចារណាឃើញហេតុការណ៍ខាងមុខបានឆ្ងាយ  ទើបមានព្រះថេរៈ ១ ក្រុមជាអ្នកទ្រទ្រង់ធម្មវិន័យជ្រៅជ្រះនាំគ្នាធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះជាប្រញាប់ ក្រោយពុទ្ធបរិនិព្វានទៅបន្តិច  ទើបលោកប្រកាសហៅប្រជុំសង្ឃទូទៅទាំងប្រទេស  ដើម្បីប្រជុំធ្វើសង្គាយនាជំនុំជម្រះធម្មវិន័យឡើងជាដំបូង ។

ព្រះមហាកស្សបត្ថេរ ត្រូវក្រុមជំនុំប្រជុំជ្រើសរើសលោកឡើងធ្វើជាអធិបតីក្រុមជំនុំសង្ឃ  ព្រះអានន្ទត្ថេរត្រូវជាព្រះញាតិនឹងជាសិស្សជំនិតរបស់ព្រះពុទ្ធជាម្ចាស់  ត្រូវទទួលនាទីជាអ្នកឆ្លើយដោះប្រស្នាធម៌ផ្សេង ៗ ព្រះឧបាលិត្ថេរជាអ្នកចេះស្ទាត់ខាងវិន័យ  ត្រូវទទួលនាទីជាអ្នកឆ្លើយដោះប្រស្នាខាងវិន័យ លុះជំនុំជម្រះរៀបចំធម្មវិន័យរួចស្រេចហើយ ទើបព្រះសង្ឃទាំងអស់ក្នុងទីប្រជុំ  ក៏នាំគ្នាសូត្រស្វាធ្យាយឡើងព្រមគ្នា  ដើម្បីសំដែងសេចក្ដីយល់ព្រមតាមសេចក្ដីជំនុំជម្រះរបស់ព្រះថេរទាំង ២ អង្គនោះ ។

តាំងអំពីគ្រានោះមក ធម្មវិន័យរបស់ព្រះពុទ្ធឈ្មោះថាបានរៀបចំឲ្យមានរបៀបបែបផែន  ភិក្ខុដែលមានចំណេះចេះស្ទាត់ឬស្ម័គ្រចិត្តសិក្សាខាងណាក៏នាំគ្នាសិក្សាទឹងកំណត់កត់ចាំទុកដោយឡែក ៗ ពីគ្នា  គឺលោកខ្លះចាំសិក្សាខាងវិន័យចេះស្ទាត់ខាងវិន័យ  ហៅថា “វិន័យធរ” ដែលចេះស្ទាត់ទឹង

ទ្រទ្រង់ខាងព្រះសូត្រ ហៅថា "សុត្តន្តិកៈ" ឯអង្គដែលចេះស្ទាត់ទីង ទ្រទ្រង់ព្រះអភិធម្ម ហៅថា "មាតិកាធរ" ។

ការប្រជុំជំនុំជម្រះធម៌វិន័យក្នុងគ្រានោះ ហៅថា "បឋមសង្គាយនា" សម្រេចជាប់ស្រេចដោយការចាត់ចែងរបៀបរៀបចំធម្មវិន័យជាពួក ៗ ជាផ្នែក ៗ គឺព្រះវិន័យ, ព្រះសូត្រ, ព្រះអភិធម្ម ។

លុះកន្លងមក ១០០ ឆ្នាំ ក្រោយពុទ្ធបរិនិព្វាន ក៏កើតមានសេចក្តីយល់បែកខ្ញែកគ្នាឡើងក្នុងពួកគណសង្ឃ អំពីធម្មវិន័យនឹងរឿងឯទៀត ៗ បណ្តាព្រះសង្ឃទាំងពួងក៏ត្រូវនិមន្តមកប្រជុំគ្នាជាគ្រាទី ២ នៅស្រុកវេសាលី តែការប្រជុំគ្នាគ្រានេះមិនអាចនឹងរួបរួមយោបល់ឲ្យបានជាទីគាប់ចិត្តដល់គណៈសង្ឃដែលចូលប្រជុំទាំងអស់បាន ហើយថែមទាំងគណៈសង្ឃមានពួកធំ ១ ពួក ដែលមានយោបល់មិនយល់ព្រមតាមទីប្រជុំក៏នាំគ្នាទៅប្រជុំរៀបចំធម្មវិន័យនៅទីឯទៀត ។ គណៈសង្ឃដែលបែកចេញទៅនេះហៅថា "មហាសង្ឃិកៈ" ឯគណៈសង្ឃដែលនៅរួបរួមជាមួយនឹងព្រះថេរៈពួកចាស់ឈ្មោះដើមហៅថា "ថេរវាទី" លុះ ១០០ ឆ្នាំតមក ទើបកើតមាននិកាយផ្សេង ៗ ឡើងទៀត តាមនិកាយធំទាំងពីរនេះរួមទាំងអស់ ១៦ និ-កាយ រួមជា ១៨ និកាយទាំងនិកាយដើមផង ។

និកាយឯទៀតៗ ដែលបែកខ្ញែកចេញទៅអំពីនិកាយថេរវាទីទៀត នោះគឺ វជ្ជីបុត្តិយ, មហិសាសក, ធម្មគុត្តិក, សៅតន្ត្រិក, សព្វត្ថិក-

ព្រោះអស់លោក-អ្នកដែលមិនធ្លាប់មើលពង្សាវតារលោកនេះ គង់មានចំនួនមិនមែនតិចទេ បើពោលឲ្យចំ គឺថាតាំងពីដើមរហូតមកដល់សព្វថ្ងៃនេះ មិនទាន់មានអ្នកប្រាជ្ញរៀបរៀងពង្សាវតារលោកជាភាសាខ្មែរនៅឡើយ ទើបយើងយល់ថា ការរៀបរៀងប្រវត្តិសាស្ត្រនេះនឹងសម្រេចប្រយោជន៍ដល់បណ្ដាអ្នកចេះមើលអក្សរខ្មែរខ្លះទៅ នេះប្រការ ១ ប្រការមួយទៀតនោះ យើងមានសង្ឃឹមទុកជាមុនថា កាលណាខេមរជាតិយើងបានមើលពង្សាវតាររបស់នានាជាតិព្រមទាំងជាតិរបស់ខ្លួន តាំងពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ នឹងនាំឲ្យកើតមេគំនិតក្នុងការដឹកនាំប្រទេសជាតិឲ្យបានសេចក្ដីចំរើនទៅថ្ងៃក្រោយ ព្រោះយើងនឹងបានដឹងហេតុដែលនាំឲ្យចំរើន និងហេតុដែលនាំឲ្យវិនាសខូចខាតអន្តរាយ ដោយមានទំនង់ផ្សេងៗ គ្នាជាអនេកប្រការ ។

ហេតុនេះយើងនឹងរៀបរៀងពង្សាវតាររបស់ប្រទេសចាស់ៗ ដែលមានសេចក្ដីចំរើនមកមុនប្រទេសឯទៀតៗ ក្នុងសម័យដែលមានប្រវត្តិ-សាស្ត្រខ្លះហើយ នៅក្នុងរវាង ៦-៧ ពាន់ឆ្នាំកន្លងមកហើយនេះ ដើម្បីសំដែងឲ្យឃើញសេចក្ដីចំរើននិងមិនចំរើន និងហេតុទាស់ដែលនាំឲ្យជោគទាបដល់ប្រទេសជាតិ ៗ ដំបូង យើងនឹងចាប់និយាយពីប្រទេសអេស៊ីព្ទ ដែលជាប្រទេសមានសេចក្ដីចំរើនមកមុនប្រទេសឯទៀតៗ តាំងពីមុនគ្រិស្តសករាជប្រមាណ ៥.០០០ ឆ្នាំ ដូចមានឧទាហរណ៍តទៅនេះ:

ទិន, កាស្សបិយៈ, សង្ក្រាន្តិក, សាម្មតិយ, សន្នាគារិក, កទ្រយានិយៈ និងធម៌មោត្តរិយៈ, ឯនិកាយមហាសង្ឃិកៈ ក៏បែកខ្ញែកចេញទៅជាច្រើននិកាយដែរ គឺឯកវ្យវហារិក, សោកុលិក, ពហុស្រុតិយ, ចៃតិកៈ និងប្រជ្ញាប្រតិវាទិន ។

ប្រមាណ ២០០ ឆ្នាំក្រោយពុទ្ធបរិនិព្វាន ទើបព្រះបាទអសោកមហារាជក្សត្រក្នុងរាជវង្ស "មោរ្យៈ" បានប្រែព្រះទ័យមកកាន់ព្រះពុទ្ធសាសនា ព្រះមោគ្គលីបុត្តតិស្សត្ថេរ លោកពិចារណាយល់ថា ត្រូវតែហៅប្រជុំគណៈសង្ឃទូទៅក្នុងអាណាចក្រ ដើម្បីសម្រេចអំពីប្រស្នាផ្សេងៗ ដែលមានការយល់មិនស្របគ្នានោះ ការនេះព្រះបាទធម្មាសោក ទ្រង់ឧបត្ថម្ភពេញកំឡាំង ។ ការរៀបចំធម្មវិន័យគ្រានេះរាប់ជាសង្គាយនាទី ៣ ធ្វើក្នុងបរិវេណវត្ត "អសោការាម" ក្នុងក្រុងបាដលីបុត្រ (ឥឡូវនេះហៅថា ប៉ាត្នា Patna) ដែលជាទីក្រុងធំក្នុងគ្រានោះ ។

ក្នុងការប្រជុំគ្រាទី៣នេះ មានភិក្ខុសង្ឃចូលប្រជុំច្រើនជាង ១.០០០ រូប មានប្រមាណ ១១ និកាយ ដែលត្រូវបដិសេធមិនឲ្យចូលប្រជុំក្នុងទីប្រជុំធំនោះ ទើបលោកអស់នោះនាំគ្នា ទៅប្រជុំធ្វើនៅទីដទៃហៅថាស្រុកនាឡន្ទា (Nalanda) លុះតមកគ្រាក្រោយកន្លែងនោះក្លាយទៅជាប្រជុំធំនៃពួកនិកាយ "សព៌ាស្តិវាទ" ឬមហាយាន ។

ព្រះមហាមោគ្គលីបុត្តតិស្សត្ថេរជាអធិបតីក្រុមជំនុំក្នុងគ្រានោះ គួរ

គាត់ជាជាអ្នកមានប្រាជ្ញាញាណជ្រៅជ្រះ ជាឯកអគ្គបុគ្គលមួយ ទោះគាត់ថែរការពារខាងពុទ្ធសាសនាឲ្យបានផលចំរើនទៀតគាត់ហ្មត់ចត់ល្អណាស់ ដោយលោកមានយោបល់យល់ការវែងឆ្ងាយទាំងសេចក្តីព្យាយាមយ៉ាងម៉ឺង-ម៉ាត់របស់លោក ទើបលោករៀបចំរើសរកព្រះថេរៈដែលមានចំណេះវិជ្ជាជ្រៅជ្រះ ចាត់ជាគណធម្មទូតចេញទៅផ្សាយពុទ្ធសាសនានៅនានាប្រទេស ធ្វើឲ្យព្រះពុទ្ធសាសនាប្រតិស្ឋាននៅទីនោះៗ យ៉ាងខ្ជាប់ខ្ជួន អាចគង់ទ្រាំទាំងសេចក្តីប្រែប្រួលរបស់លោកជាវេលា ២.២០០ ឆ្នាំ ៗ មួយវិញទៀត ដោយអំណាចសេចក្តីទូន្មានរបស់ព្រះថេរអង្គនេះហើយ ទើបធ្វើឲ្យព្រះមហាមហិន្ទត្ថេរជាព្រះរាជឱរសរបស់ព្រះបាទធម្មាសោក នាំយកព្រះពុទ្ធសាសនាទៅប្រតិស្ឋាននៅកោះលង្កា ធ្វើឲ្យជម្ពូទ្វីបនិងកោះលង្កាមានស្ពានមេត្រីជាមួយគ្នាកើតមកដោយអំណាចពុទ្ធសាសនានេះឯង, ឯធម៌វិន័យដែលគណធម្មទូតនាំទៅប្រតិស្ឋានទុកនៅកោះលង្កានោះ បានរូបរួមរក្សាទុកដោយការចាំមាត់រៀងៗតៗគ្នាមកជាយូរអង្វែងដរាបមកដល់សម័យ "ព្រះបាទវដ្តគាមិនីអភ័យ" ឬដែលហៅថា "វលគមពាហុ" ទើបប្រជុំចារិកជាអក្សរនៅក្នុង "អលុវិហារ" ខេត្ត "មាតលេ" កិច្ចការដ៏ប្រសើរនេះ នាំឲ្យព្រះធម្មវិន័យគង់ទ្រង់រហូតមកមិនសាបសូន្យទៅអស់កាលជាយូរអង្វែង ៗ

(មានត)



១ នេះត្រង់លោកមើលរបើះមកចាប់កំណើត

# ប្រវត្តិរបស់មីលរេប៉ៈ

តាមសេចក្តីប្រែ

ពីភាសាទីបេតាំង មកជាភាសាបារាំងសែស របស់

លោកហ្សាក់បាកូត៍ ( Jacque Bacot )

ប្រទេសទីបេត៍ ជាទីទួលខ្ពស់មានកំពស់ខ្ពស់ជាងទឹកសមុទ្រដល់ទៅ ៥.០០០ ម៉ែត្រ ។ នៅទីនោះមានអាកាសត្រជាក់ណាស់ហើយស្ងួតហែងផង ។ ប្រទេសនេះនៅជាខាងជើងឆៀងខាងកើតនៃប្រទេសឥណ្ឌា នឹងជាខាងត្បូងឆៀងខាងលិចនៃប្រទេសចិន ។ ប្រជាជនប្រទេសនេះកាន់ព្រះពុទ្ធសាសនាបែបមហាយាន ។

ឯរឿងរ៉ាវរបស់លោកមីលរេប៉ៈនោះ មានសេចក្តីដំណាលថា លោកមីលរេប៉ៈជាព្រះអរហន្តមួយអង្គ ក្នុងប្រទេសទីបេត៍ លោកនេះកើតឡើងក្នុងសម័យនៃពុទ្ធសករាជ ១.៥២៣ ( មើលរូបទំព័រ ២៩ ) ។ មានសិស្សម្នាក់របស់លោកបានដំណាលប្រវត្តិរបស់គ្រូខ្លួនទុកតមក ដែលជារឿងល្បីល្បាញមួយៈនៅប្រទេសទីបេត៍សព្វថ្ងៃនេះ ។ លោកបាកូត៍ជាអ្នកប្រាជ្ញជាតិបារាំងសែសម្នាក់ ដែលលោកបានទៅនៅប្រទេសទីៈបេត៍ជាយូរអង្វែង ហើយបានចាត់ចែងប្រែប្រវត្តិលោកមីលរេប៉ៈមកជាភាសា

បាក់ងសែស មានតាំងគំនូរប្រកបរឿងក៏រនេះដែលជាស្នាដៃរបស់ពួកទីបេតាំង ក្នុងសៀវភៅរបស់លោកផង ។

ការដែលយើងនាំយករូបអស់នោះមកបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីនេះរៀងៗទៅ គង់មានប្រយោជន៍ដល់អ្នកមើលទស្សនាវដ្ដីរបស់យើងខ្លះមិនខាន ឯរូបនិងប្រវត្តិរបស់លោកម៉ិលរេប៉ៈនឹងមានចុះផ្សាយក្នុងលេខជាលំដាប់តទៅ ។

(មានត)



៤ នេះកាលស្តេចយាងត្រឡប់ទៅព្រះនគរ

( មើលសេចក្តីពន្យល់ទំព័រ ៦ )

ពង្សាវតារប្រទេសអេស៊ីប្ត៍

ខេមររង្សី

ប្រែចេញពីប្រវត្តិសាស្ត្រសាកល

របស់ហ្លួងវិចិត្រវាទការ រដ្ឋមន្ត្រីនៃប្រទេសថៃ

(តមក)

រាប់តាំងអំពីបឋមក្សត្រមោណស ដរាបមកដល់សម័យជនជាតិប៉ែរ្សក៏យកស្រុកអេស៊ីប្ដ៍ទៅបាន ជាវេលាជិត ៤៥ សតវត្សរ៍ រាប់វង្សក្សត្រដែលគេរាប់ជារួម ២៦ វង្ស ១០ វង្សដំបូងតាំងទីក្រុងនៅម៉មហ្វិស ១០ វង្សតមកទៀតតាំងក្រុងនៅថែប្ស ។ បន្ទាប់ពីនោះពួកលោកសង្ឃមានអំណាចត្រួតត្រាប្រទេសអេស៊ីប្ដ៍ ទើបផ្លាស់ក្រុងទៅតាំងឯស្រុកអេត្យូ-ពីដែលឆ្ងាយសមុទ្រទៅទិសខាងត្បូង ក្នុងគ្រានោះស្រុកទេសកើតចលា-ចលបែកខ្ញែកចេញទៅជាច្រើន ទើបបណ្ដាព្រះអង្គម្ចាស់ក្នុងវង្សក្សត្រទី ២៦ រួបរួមបណ្ដាខេត្តក្រៅដែលបែកខ្ញែកគ្នាបានឡើងវិញទៀត ហើយមកតាំងក្រុងនៅស្រុកសាអ៊ិត ។ តាមធម្មតា ជនជាតិអេស៊ីប្ដ៍មិនសូវដែលចេញទៅនៅក្រៅប្រទេសរបស់ខ្លួនទេ តែមានខ្លះដែរម្ដងមួយកាលដូចក្នុងផែនដីស្ដេចសេទិទី ១ នឹងស្ដេចរ៉ាមសេសទី ២ តែច្រើនមិនបានសេចក្ដីសុខមានសត្រូវខាងក្រៅមកបៀតបៀនរឿយៗ ដំបូងមានពួកហិកសូសមកពីសមុទ្រ ដែលនៅឆ្ងាយពីព្រែកស៊ុយអេស ចូលមកបៀតបៀនក្នុងសម័យតាំងក្រុងនៅម៉មហ្វិស តមកពួកអស្ស៊ីរីចូលលុកលុយក្នុងរវាង ២៨ ឆ្នាំមុនពុទ្ធសករាជ ហើយនៅទីបំផុតពួកប៉ែរ្ស បានចូលមកបំផ្លាញវង្សក្សត្រទី ២៦ កាលពុទ្ធសករាជ ១៨ ឆ្នាំ ។

សេចក្ដីជឿប្រកាន់របស់ជាតិអេស៊ីប្ដ៍នោះ ចែកចេញជា ៣ ប្រការ គឺ ១ កាប់អានព្រះភូមិ, ២ កាប់អានព្រះអគ្គិធំ, ៣ កាប់អានអ្នកដែលចែកស្ថាន ។

១ ក្នុងស្រុកតូច ៗ នីមួយ ៗ តាមទន្លេនីលផ្ទៃផែនដី, មេឃ ទឹង ព្រះអាទិត្យ តាំងឡើងជាព្រះ ៗ នីមួយ ៗ នោះ គេទុកដូចជាមនុស្សម្នាក់ៗ មានសេចក្ដីត្រូវការដូចមនុស្សធម្មតា គឺត្រូវការផឹក បរិភោគអាហារ ស្លៀកពាក់ ខុសគ្នាត្រឹមតែថាព្រះអស់នេះមានជីវិតរស់នៅជានិច្ច ហើយមានអំណាចដ៏ធំអស្ចារ្យតែងខ្ទង់ទៅស្ថិតក្នុងកាយរបស់សត្វនានា លុះតមកពួកអេស៊ីប្ដ៍ គេធ្វើរូបព្រះរបស់គេជារូបផ្សេង ៗ គឺធ្វើកងកាយជារូបមនុស្ស តែព្រះសិរៈជារូបសត្វ ព្រោះអស់នេះមានឫក្រកិរិយាមានទំនងដូចមនុស្សសាមញ្ញធម្មតា ។

២ បណ្ដាព្រះនៅស្រុកតូច ៗ គោរពចំណុះព្រះនៅទីក្រុង ហេតុនេះទើបជាហេតុឲ្យមានការកាប់អានព្រះអគ្គិធំឡើង ព្រះអគ្គិធំអស់នេះ គេនិយមសន្មតពីដួងអាទិត្យ មានលក្ខណៈផ្សេង ៗ គ្នាតាមសភាពរបស់ដួងអាទិត្យ មានរូបទឹងគេហៅឈ្មោះផ្សេង ៗ គ្នា ដូចជា:

ព្រះហូរុស ជារូបសន្មតរបស់ដួងអាទិត្យ ចួនកាលគេធ្វើជារូបកូនក្មេង ចួនកាលជារូបមេទ័ពកំឡោះ ព្រះអគ្គិនេះមានជ័យជំនះព្រះសេតដែលជាស្ដេចនៃសេចក្ដីងងឹត ។

ព្រះអូស៊ីរីស ជារូបសន្មតរបស់ដួងអាទិត្យលិច ត្រូវព្រះសេតផ្តាច់ជីវិតបង់ទៅ តែព្រះអ៊ីស៊ីស (ដួងចន្ទ្រា) ភរិយារបស់លោកបណ្តាលឲ្យមានជីវិតរស់ឡើង ហើយបុត្ររបស់លោកគឺព្រះអូរ៉ុស បានធ្វើការសងសឹកវិញបាន តមកទើបស្លាប់ដោយអំណាចព្រះម្ឫត្យុ ។

ព្រះរ៉ា ជាបិតានៃស្តេចផែនដីទាំងឡាយជារូបសន្មតរបស់ដួងអាទិត្យទ្រង់បាំងក្លស់ ។

ព្រះអាមម៉ុង ជាព្រះនៃស្រុកថែប ជារូបដំណាងអគ្គិ ដួងអាទិត្យត្រង់ប្រទេសអេស៊ីប្ត ។

ព្រះមេហាត់ ជារូបដំណាងដួងអាទិត្យក្នុងពេលមានលំអ ជាព្រះនៃសិល្បសាស្ត្រ ។

៣ - នៅមានព្រះដែលគេនិយមរាប់អាន ១ ប្រភេទទៀត ហៅថាព្រះម្ឫត្យុ គឺអូស៊ីរីស, ជោគទឹងអានុពិស ស្រុករបស់អ្នកដែលចែកស្ថានទៅក៏មានរាជអាណាចក្រដូចជាក្នុងស្ថានសួគ៌ទីងផ្ទៃផែនដី ព្រះអូស៊ីរីសទ្រង់គ្រប់គ្រងស្រុកអស់នេះ ។

រូបសន្មតផ្សេង ៗ តាមផ្លូវសាសនារបស់អេស៊ីប្តនេះ ដំបូងយល់បានដោយកម្រ តែថាបើយើងដើរទៅតាមមាគ៌ាទ្រឹស្តីនិល យើងអាចយល់ដឹងការបានសព្វគ្រប់ សមនឹងពាក្យដែលពោលថាទន្លេនិលជាទីកើតនៃសាសនា ចរិយា ធម្មក្រិត្យា សីលធម៌ ទំនំទំនៀមរបស់ជាតិអេស៊ីប្ត ។

## សម័យបុរាណ

## ប្រទេសអេស៊ីប្ត

និយាយពីប្រទេសអេស៊ីប្តសម័យបុរាណ, ទន្លេនីលនៅប្រទេសអេស៊ីប្ត, ប្រជាជនជាតិអេស៊ីប្ត, របៀបសាសនាអេស៊ីប្ត, ប្រាសាទបុរាណ, បែបរចនា, របៀបអក្សរនិងចម្លាក់ជាដើម ។

## ប្រទេសក្រិក

វគ្គទី ១ — និយាយពីភូមិប្រទេស កំណើតជាតិក្រិក · សាសនារបស់ក្រិក - ព្រះរបស់ក្រិក ។ វគ្គទី ២ — និយាយពីស្រុកស្ប៉ាតនិងអាថែន - វិធីគ្រប់គ្រង - វិធីអប់រំ - សភាដំណាងរាស្ត្ររបស់ក្រិក ។ វគ្គទី ៣ — និយាយពីសង្គ្រាមក្រិកនិងប៉ែរ្ស - សហករណ៍របស់ក្រិក ចរិតប្រពៃណី - របៀបស្ត្រី - ពន្ធភាសី - របៀបរចនា ។ វគ្គទី ៤ — និយាយពីសង្គ្រាមអាថែននិងស្ប៉ាត - អ្នកប្រាជ្ញក្រិក - អំណាចប្រាក់របស់ប៉ែរ្ស ។ វគ្គទី ៥ — និយាយពីដែនមាសេដូនី - ព្រះបាទហ្វីលិប - ព្រះបាទអាលេក្សង់ដ្រឺមហារាជជាដើម ។

## រោម

វគ្គទី ១ — និយាយពីការសាងក្រុងរោម និងភូមិប្រទេស ។ វគ្គទី ២ — និយាយពីរបៀបសាសនាទំនៀមទម្លាប់ប្រពៃណី - របៀបត្រួតត្រា

ក៏មានរូបសន្ទតតាមផ្លូវសាសនា ដូចជាតិបុរាណឯទៀតៗដែរ ដូចជា ផ្កាឈូកជាគ្រឿងសំគាល់សេចក្តីបរិសុទ្ធ ព្រោះរុក្ខជាតិបែបនេះ ដុះនៅ ក្នុងទន្លេនីល ហើយមានទឹកហូរលាងសំអាតជានិច្ច ។

ឯរូបសន្ទតជាដំណាងជួងអាទិត្យនោះ គេធ្វើជារូបមនុស្សក្បាលគោ មានវង់មូលនៅត្រង់ចន្លោះស្នែងគោទាំងសងខាងព្រោះថាបើសំឡឹងមើល ពីទន្លេនីលនឹងឃើញព្រះអាទិត្យរះឡើងពីចន្លោះដងភ្នំអារ៉ុប មានកំពូល ខ្ពស់ត្រដែតទាំងសងខាងមានទំនងដូចស្នែងគោ ។

គេជឿប្រកាន់ថា ជនជាតិអេស៊ីប្ត៏ ពេលស្លាប់មិនមែនស្លាប់ទៅ ភ្លាមទេ មានរូបកាយផ្សេងទៀត ដែលយើងមិនអាចមើលឃើញផុន ចេញទៅពីរូបកាយដើមរបស់ខ្មោច កាយនេះគេហៅថាកាយភ្ជោះឬ វិញ្ញាណនៅមានជីវិតទៅទៀត ទម្រាំតែកាយដើមនោះរលួយរលាយ អស់ទៅ ព្រោះហេតុនេះ ទើបជនជាតិអេស៊ីប្ត៏ ចេះធ្វើវិធីអប់រក្សាសព មិនឲ្យពុកផុយស្អុយរលួយ ឯវិញ្ញាណដែលមិនមានរូបកាយក៏តោងរក្សាទុក ដែរ គេធ្វើបន្ទប់ងងឹតៗ សម្រាប់ជាលំនៅរបស់វិញ្ញាណ ទីងជាទីទុក ខ្មោចផង ក្នុងបន្ទប់នេះគេបានដាក់ដំកល់គ្រឿងប្រដាប់ផ្ទះនិងអាហារ ហើយបានសាងរូបរបស់ខ្មោចទុកនៅក្បែរខាងផង ទីដំកល់សពនេះគេ ធ្វើជាអនុស្សាវរីយ៍យ៉ាងខ្ជាប់ខ្ជួន ហើយប្រុងប្រយ័ត្នមិនឲ្យពួកចោរឬមាន ការមើលងាយដល់សពឬនិងទីកន្លែងទុកសពផង ។

ទីកន្លែងកប់ខ្មោចគេធ្វើឆ្ងាយពីទន្លេបឹង មិនឲ្យមានទឹកជោរជន់លិចទៅដល់ ជាទីហែងស្ងួតមិនសើមទើបទុកសពបានយូរអង្វែង ដោយហេតុជនជាតិអេស៊ីប្តជឿថា អ្នកដែលស្លាប់ទៅ នៅតែទៅមកកាន់គ្នានឹងបណ្តាញាតិដែលមានជីវិតរស់នៅសព្វថ្ងៃនេះ ទើបជនជាតិអេស៊ីប្តយកចិត្តទុកដាក់ទំនុកបំរុងធ្វើឲ្យបុព្វបុរសដែលចែកស្ថានទៅនោះ ឲ្យបានសុខសប្បាយដោយវិធីផ្សេង ៗ ។

នៅក្នុងស្រុកនីមួយ ៗ មានអ្នកចិញ្ចឹមជីវិតដោយវិធីអប់សពដោយគ្រឿងក្រអូប សម្រាប់ទុកឲ្យបានយូរ កាលញាតិរបស់ខ្មោចទៅនិយាយជួលឲ្យធ្វើហើយប្រគល់សពឲ្យទៅ គេក៏ចាប់យកឈើលាបថ្នាំចេញមកឲ្យមើលហើយគេសួរថា ត្រូវការបែបណា? រូបឈើនេះមាន៣យ៉ាង ដំឡៃផ្សេងៗគ្នា ដែលមានដំឡៃជាងគេនោះ គេធ្វើជារូបដំណាងព្រះអូស៊ីរិស កាលញាតិរបស់ខ្មោចនិយាយថ្លៃស្រេចហើយក៏ត្រឡប់មកផ្ទះវិញ ។ ឯពួកអ្នកអប់សពក៏ធ្វើការនៅផ្ទះរបស់ខ្លួន ៗ សម្រាប់វិធីអប់សពយ៉ាងលេខ១នោះ ដំបូងគេខ្វេះយកខួរក្បាលចេញដោយស៊កដែកទំពក់ទៅតាមរន្ធច្រមុះ ហើយលាងបាញ់ទឹកបញ្ចូលទៅក្នុងក្បាល ហើយវះពោះឆ្អឹងជំនីរទាញយកពោះវៀនចេញមកលាងដោយស្រាត្នោត ច្របល់ដោយគ្រឿងក្រអូបដែលកិនខ្ទេចជាផង់ ទើបគេញាត់បញ្ចូលទៅវិញជាមួយនឹងគ្រឿងថ្នាំដែល

ធ្វើពីជ័រឈើក្រអូបទឹកគ្រឿងក្រអូបឯទៀត ៗ ហើយដេរភ្ជិតទៅវិញ ទើបគេយកស្ពកមកដាក់សពត្រាំក្នុងថ្នាំអំបិលម្យ៉ាងចំនួន ៦០ ថ្ងៃ ។

កាលគ្រប់កំណត់ ៦០ ថ្ងៃហើយ រាងកាយនោះក៏ស្ងួតក្រៀមទៅ នៅសល់តែស្បែកដណ្ដប់ឆ្អឹង ទើបគេយកសំពត់តូច ៗ ជ្រលក់ជ័រ ហើយរុំដោយសំពត់ដទៃទៀតជា ៣ ជាន់ ទើបយកសំពត់ជាតិរុំ ១ ជាន់ទៀត កាលរៀបចំស្រេចហើយ គេយកសពនោះដាក់ក្នុងមឈូស ដែលធ្វើជាឈើពីរជាន់ ហើយមានលក្ខណៈប្រហែលនឹងរូបមនុស្ស នៅចំណែកខាងក្បាលនោះ គេឆ្លាក់ជារូបមុខរបស់ខ្មោចនោះឯង ។

ការធ្វើពិធីនេះជាហេតុរក្សាសពទុកបានយូរអង្វែងជាវេលាច្រើនពាន់ឆ្នាំ ក្នុងវេលានេះគង់មានសល់នៅជាចំនួនច្រើន ៗ ជនជាតិអេស៊ីព្ទប្រកាន់តទៅទៀតថា កាលដល់ពេលស្លាប់ទៅត្រូវទៅស្នើដល់ព្រះអូស៊ីរិស ដែលទ្រង់ជម្រះទោស ហេតុនេះបានជាគេដាក់សៀវភៅមួយក្បែរខ្លួនខ្មោចក្នុងសៀវភៅនោះមានសរសេរសេចក្ដីដែលខ្មោចត្រូវតែទន្ទេញឲ្យចាំមាត់ថា “ខ្ញុំបាទមិនមានពោលពាក្យកុហកដល់សាន ខ្ញុំបាទមិនមែនជាមនុស្សខ្ជិលច្រអូស, ខ្ញុំបាទមិនមែនមានចេតនាអាក្រក់, ខ្ញុំបាទមិនដែលមើលងាយប្រមាថទេវរូប, ខ្ញុំបាទមិនដែលឆបោកយកដីរបស់អ្នកដទៃ, ខ្ញុំបាទមិនបានធ្វើឲ្យអ្នកដទៃមានសេចក្ដីទោមនស្ស ខ្ញុំបាទមិនដែលសម្លាប់

អ្នកណា, ខ្ញុំបាទមិនដែលបំពុលផ្លូវគេនៃព្រែក-ស្ទឹង, ខ្ញុំបាទមិនដែលទាញដោះម្តាយចេញពីមាត់កូនខ្ចី; ខ្ញុំបាទបរិសុទ្ធ, ខ្ញុំបាទបរិសុទ្ធ, ខ្ញុំបាទបរិសុទ្ធ" ។ កាលបើយើងពិចារណាពាក្យអស់នេះដោយសព្វគ្រប់ទៅ នឹងឃើញថា ជនជាតិអេស៊ីបជាមនុស្សឧស្សាហ៍ខ្នះខ្នែងទាំងប្រកបដោយបរិយាមារយាទល្អផង ។

ជនជាតិនេះចូលខាងការធ្វើការកសិកម្ម, ការគ្រប់គ្រង និងការកសាង តែមិនមាននិស្ស័យជាអ្នកចម្បាំងឬរុករានទន្ទ្រានយកដែនដីជាតិដទៃ ព្រោះដីក្នុងប្រទេសខ្លួនមានជីជាតិល្អផង ទាំងមិនមានជនជាតិដទៃមករករឿងឈ្លោះផង ។ ពួកអេស៊ីប មានការប្រាស្រ័យកាន់គ្នាទៅវិញទៅមកជាកិច្ចរបររួមគ្នាជារបៀបរៀបរយល្អ ដើម្បីរួមកម្លាំងគ្នាកសាងទំនប់ ជីកព្រែកនិងជួយគ្នាធ្វើការដាំដំណាំនានា ។ ហេតុដែលជីវិតមនុស្សប្រែប្រួលនឹងសាបសូន្យទៅមិនជាការចំឡែកទេសម្រាប់ពួកអេស៊ីប ព្រោះពួកគេនៅចំពោះមុខ ទន្លេនិល និងព្រះអាទិត្យដែលមិនចេះប្រែប្រួល ហេតុនេះហើយបានជាធ្វើឲ្យកើតជំនឿថា មនុស្សយើងស្លាប់ទៅគង់តែកើតទៀតជាដរាប ។

ជនជាតិអេស៊ីបបានបែងចែកវណ្ណៈចេញជា ៦ ពួក គឺពួកអ្នកបួស ១ អ្នកចម្បាំង ១ ស្មៀន ១ អ្នកជំនួញ ១ កម្មករ ១ អ្នកស្រែ ១ ។

ពួកអ្នកបួសជាអ្នកមានអំណាចខាងសាសនា មានជួនកាលមានអំណាចត្រួតត្រាការផែនដីផងក៏សឹងមាន តែតាមធម្មតា ពួកលោកសង្ឃជាអ្នករក្សាទ្រព្យសម្បត្តិរបស់ព្រះ ជាអ្នកថែរក្សាអាថិស្ងាត់កំបាំងដែលស័ក្តិសិទ្ធិនៅខាងលើ ត្រូវប្រកាន់តាមវិន័យយ៉ាងម៉ឺងម៉ាត់ ពាក់អាវអែម្បោះ កោរសក់ ហើយមានអត់បាយ ស្រដៀងនឹងអ្នកបួសក្នុងពុទ្ធសាសនាដែរ ។

(មានតទៅទៀត)

ដំណើរផ្សេងៗ

# អំពីសត្វរុយនិងសត្វមូស

របស់លោកសេគុយ

មានសៀវភៅមួយដែលទើបបោះពុម្ពថ្មីនៅស្រុកបារាំងសែស យើងយល់ថាជាសៀវភៅមានប្រយោជន៍ដល់អ្នកមើលច្រើន ដោយសៀវភៅនោះមានសេចក្ដីពន្យល់ថា បណ្ដាសត្វតូចៗល្អិតៗ ជាសត្វមានកំឡាំងលើសមនុស្សយើងទៅទៀត តាមដោយសេចក្ដីរកឃើញប្រទះតាមវិជ្ជាវិទ្យាសាស្ត្រនៅសព្វថ្ងៃនេះ ។ សត្វតូចៗអស់នេះហើយដែលបណ្ដាលឲ្យកើតទុក្ខវេទនាដល់មនុស្សជាតិជាយ៉ាងច្រើន ។

ចំពួកសត្វរុយនិងសត្វមូស ដែលយើងប៉ះពាល់ប្រទះដោយដៃ ក៏ស្លាប់មួយរំពេច ប៉ុន្តែសត្វអស់នេះហើយជាហេតុធ្វើឲ្យមានចំនួនសត្វគង់សកលពិភពស្លាប់ទៅដល់ពាក់កណ្ដាលកល់ៗឆ្នាំ ដោយវាមកទំរុកយាំអាយ៉ៈយើងក៏មាន ដោយវាទៅទំនៅលើចំណីអាហារដែលយើងបរិភោគធ្វើឲ្យអាហាររបស់យើងមិនស្អាត ស្មោកគ្រោកកើតទោសដល់អ្នកបរិភោគក៏មាន ។ យើងដឹងច្បាស់ថា ជម្ងឺគ្រុនចាញ់ដោយមកអំពីសត្វមូសដែលមានជម្ងឺគ្រុនចាញ់ដែរ ។

អ្នកតែងសៀវភៅនេះពោលថា មានអ្នកប្រាជ្ញអាមេរិកាំងម្នាក់និយាយថា

សត្វពីរបំពួកនេះជាសត្វសាហាវបំផុតនៅលើផែនដី ។ សត្វល្អិត ៗ អស់នេះហើយដែលមានចំនួនច្រើនបំផុតលើផែនដី មានសត្វបំពួកខ្លះនៅខាងចំណែកភូមិភាគក្តៅនៃពិភពលោក ទុកដូចជានាយទៅហ្វាយនៅត្រង់ភូមិភាគនោះ ហើយជាសត្វធ្វើឲ្យមានផែនដីមានដីជាតិឡើងទៀត ។ បំពួកសត្វអស់នេះតែងតែបំផ្លាញបង្ហិនរបស់យើង ហើយកចូលចិត្តតែមកទំទឹងក្បាល ធ្វើឲ្យយើងខាតពន់ពេក ៗ នៅប្រទេសឧរុប ពួកមនុស្សគេខ្ចាយកំចាត់សត្វល្អិត ៗ អស់នេះ ដែលកំតែងប្រទូសរ៉ាយផលស្រែ-ចំការឲ្យដំណាំរបស់គេ ។

ការគេសិក្សារ៉េងពួកមនុស្សទើងពួកបាណកជាត (សត្វកំទេចកំទី) ដ៏សាហាវអស់នេះ តាំងអំពីដើមដំបូងរហូតមកនោះ មានចំនួនបាណកជាតិច្រើនជាង ១២.០០០ បំពូក ហើយមានសត្វរុយចំនួន ៤.០០០ ពួក ប៉ុន្តែមិនមែនជាសត្វបំពួកឃោរឃៅទេ ៗ អ្នកតែងសៀវភៅបាននិយាយអំពីសេចក្តីអន្តរាយដែលកើតអំពីសត្វមូស ហើយពួកអ្នកប្រាជ្ញដែលបានសិក្សាស្រាវជ្រាវរកហេតុអំពីសត្វអស់នេះ នាំឲ្យកើតអន្តរាយដែលឃើញស្តែងទីងក្លែក ៗ គេពិនិត្យឃើញសេចក្តីអន្តរាយទាំងឡាយ ដែលកើតអំពីគ្រឿងស្មោកគ្រោកដែលជាប់នឹងជើងរុយ ឬសត្វរុយទៅពងដាក់លើអាហារចំណីរបស់យើង ដែលមិនទាន់គ្របជិតជិតល្អ ៗ មួយវិញទៀត

សត្វរុយទៅទំលើខ្លួនសត្វដែលយើងបរិភោគសាច់វាក្ដី ឬទំនៅខ្លួនរបស់យើងក្ដី គេយល់ថា សេចក្ដីអន្តរាយដែលកើតអំពីបាណកជាតិអស់នេះ មានច្រើនលើសលុបវិទ្យាសាស្ត្ររបស់មនុស្សទៅទៀត ។

អ្នកតែងសៀវភៅនេះ ពន្យល់អំពីរបស់ដែលសំខាន់មួយដែលយើងមិនសូវនឹកនាសោះ គឺរបស់ដែលយើងហៅថា សេចក្ដីចំរើនជ្រោមដ្រែងឲ្យកំឡាំងដល់ពួកសត្វបាណកជាតិ ដែលវានាំគ្រឿងស្មោកគ្រោកមកដាក់លើអាហារចំណីជាយ៉ាងច្រើន នឹងបណ្ដាសត្វរុយដែលហើរតាមមនុស្សហូតទៅដល់លំនៅរបស់ខ្លួន ហើយគេមិនអាចបណ្ដេញវាបានផង ។ ពេលនោះហើយ មនុស្សយើងបានធ្វើការការពារសត្វសាហាវធំៗ នឹងពំពួកតូច ៗ ល្អិត ៗ គ្រប់ពំពួក ។

ការច្បាំងតទល់នឹងពួកសត្វបាណកជាតទុកជាចម្បាំងមួយដែលព្រះពុទ្ធសាសនាមិនអាចពោលពាក្យតិះដៀលទេ ដោយហេតុសត្វអស់នោះធ្វើឲ្យកើតទុក្ខវេទនាយ៉ាងច្រើនដល់មនុស្សជាតិលើផែនដីនេះ បើចង់ចៀសវាងអំពីជម្ងឺអស់នេះ ត្រូវតែការពារពួកសត្វដាសត្រូវនឹងមនុស្សអស់នេះកុំឲ្យវាមកយាយីបាន ។ ពួកអ្នកប្រាជ្ញបានស្រាវជ្រាវរកហេតុដែលនាំឲ្យកើតទុក្ខសោកមុខគួរស្ញប់ស្ញែង ហើយពន្យល់ប្រាប់ឲ្យប្រតិបត្តិតាមដម្បូន្មានរបស់លោក ។

## អំពីរបាក្សត្រខ្មែរបុរាណ

កាលពីរបីឆ្នាំមកនេះ គេបានបោះពុម្ពសៀវភៅមួយតូចជាភាសាបារាំងសែស និយាយពីរបាក្សត្រខ្មែរជាន់ដើមលំដាប់វង្សក្សត្ររហូតមកដល់កណ្ដាល ១៤ សតវត្សរ៍ គឺក្នុងរវាងពុទ្ធសករាជ ១.៨៩៣ ។

លោកម៉ាដ្រាល ( madralle ) លោកបានសិក្សាការកើររឿងនេះ បានប្រែចេញពីសិលាចារឹកអក្សរខ្មែរ ដែលលោកហ្វីណូត៍ និងលោកសឺ-ដេសបានរៀបរៀងបោះពុម្ពផ្សាយនោះ ហើយលោកបានអធិប្បាយរឿងរ៉ាវ តាមពង្សាវតារចិន អំពីសៀវភៅចិន ត្រង់ដែលមាននិយាយអំពីស្រុកខ្មែរ ហើយប្រែមកជាភាសាបារាំងសែស ។

មហាអាណាចក្រខ្មែរនោះមានឈ្មោះជាពីរយ៉ាងគឺ ហ្វូណន១ ចិន-ឡា១ ពង្រីកពេញទៅរហូតដល់ស្រុកកូសាំងស៊ីន និងផ្សាយចេញទៅដល់កណ្ដាលស្រុកសៀម ។ ប៉ុន្តែបើពិនិត្យតាមសិលាចារឹកខ្មែរ ឈ្មោះទីក្រុងដែលល្បីល្បាញបំផុតហៅថា វ្យាធបុរៈ ឥឡូវនេះហៅថា អង្គរបុរី ជាឈ្មោះក្រុងកាលពីសតវត្សរ៍ទី ៥ និងទី ៦ ប្រហែលក្នុង ព. ស. ៩៥៣ ដល់ ១.០៥៣ ។

## អំពីសង្គ្រាម

## ប្អូនយកសិល្បវិត្តជាដំបូងក្នុងលោក

គេទើបនឹងស្រាវជ្រាវឃើញថា ក្រិករ៉ូមមិនមែនជាដើមកំណើត

ក្នុងការបង្កើតសីលធម៌ជាន់ខ្ពស់បំផុតក្នុងសម័យបុរាណទេ ប៉ុន្តែរ៉ូមបាន ធ្វើសង្គ្រាមប្លន់ដណ្តើមសិល្បវត្ថុអំពីជនជាតិអេទ្រុស្កមានចំនួន ២.០០០ ដុំ នាំមកប្រដាប់ក្រុងរ៉ូម ហើយក្លាយជាបែបផែនតៗមក ។

នេះជាសេចក្តីដកស្រង់យកអំពីកាសែតថៃប្រមូលសារលេខ២៧ ឆ្នាំទី៤ ខែសេប្តេម្ប៊ែ ឆ្នាំ ១៩៣៨ មានសេចក្តីថា នៅពិពិធភណ្ឌសិល្បមេត្រូ-បូលីតាំងនៅក្រុងនិវយ៉ក មានរូបផ្សេងៗ សំដែងប្រវត្តិរឿងការមុខគួរ យកចិត្តទុកដាក់ គឺជាច្រើនសតវត្សរ៍មកហើយមុនគ្រិស្តសករាជ ក្រុងរ៉ូម បានបោះត្រាកងទ័ពទៅវាយយកស្រុកអេទ្រុស្កនៃប្រទេសតូស្កានី ។ ការ ដែលរ៉ូមទៅធ្វើសង្គ្រាមនេះ មិនមែនត្រូវការមាសប្រាក់ពេជ្រនិលចិន្តាអ្វី ឡើយ ឬមួយត្រូវការផ្សាយអំណាចខាងផ្លូវជំនួញក៏ទេដែរ មានសេចក្តី ត្រូវការចំពោះរូបចម្លាក់ដែលជាសិល្បកម្មប៉ុណ្ណោះ ទម្រាំតែសង្គ្រាមស្ងប់ចុះ ដើម្បីដណ្តើមរូប ២.០១០ បំណែកនេះបានមក តោងខូចសាច់ឈាមជីវិត របស់មនុស្សទៅមិនមែនតិចឡើយ ។

ជាតិអេទ្រុស្កនេះមកអំពីទីដំបន់ណា មានខ្សែស្រឡាយតគ្នាមកដូច ម្តេច មិនទាន់មានលក្ខណ្ឌប្រាកដច្បាស់ ប៉ុន្តែដោយសេចក្តីពិត ជាតិ អេទ្រុស្កនេះហើយជាអ្នកសាងសេចក្តីចំរើនដ៏ខ្ពង់ខ្ពស់ទឹងបង្ហាត់បង្រៀន សិល្បវិជ្ជាការផ្សេងៗ ដល់ក្រុងរ៉ូម ។

ស្រុក ។ វគ្គទី ៣– និយាយពីកំឡាំងទាហាននិងជ័យជំនះរបស់ក្រុងរោម ។ វគ្គទី ៤– និយាយពីការប្រែប្រួលក្នុងផែនដីរោម ។ វគ្គទី ៥– និយាយពីក្រុងរោមតាំងមហាអាណាចក្រជាដើម ។

## ឥណ្ឌា

វគ្គទី ១–និយាយពីពង្សាវតារតាំងពីបុរាណរហូតមកដល់ពុទ្ធកាល ។ វគ្គទី ២ - និយាយពីរាជវង្សក្សត្រមោរិយៈ ព្រះបាទធម្មាសោក - ភាសាបាលី ។ វគ្គទី ៣– និយាយពីព្រះបាទមិលិន្ទនិងលទ្ធិសាសនាមហាយាន - ជាតិក្រិកនៅឥណ្ឌា ។ វគ្គទី ៤– និយាយពីឥណ្ឌានៅភាគកណ្ដាល - ក្សត្ររាជវង្សគុប្តៈ - សមណៈទូតចិន - ពុទ្ធសាសនាសាបសូន្យទៅពីប្រទេសឥណ្ឌា - លទ្ធិត្រិស្ដ៍ - លទ្ធិសាសនាព្រាហ្មណ៍ ។ វគ្គទី ៥– និយាយពីប្រទេសឥណ្ឌាចំណែកខាងត្បូង - ជាតិទមិឡ - កោះលង្កា ។

## ចិន

វគ្គទី ១– និយាយពីប្រវត្តិសាស្ត្រខាងដើមរបស់ចិន - លក្ខណៈរបស់ចិន - កំណើតជាតិចិន - ខុងជឺអ្នកប្រាជ្ញចិន - ជាតិហ័ន ។ វគ្គទី ២– និយាយពីរាជវង្សហ័ន - ជាតិចិននិងជាតិហ័ន - ស្រុកចិនសម័យសាមកុក ។ វគ្គទី ៣– និយាយពីអាណាចក្រចិនខាងត្បូង - អំណាចជាតិហ័ន - ពុទ្ធសាសនានៅស្រុកចិន ។ វគ្គទី ៤– និយាយពីរាជវង្សថាំង - សម័យ

អ្នកប្រវត្តិសាស្ត្រជាតិក្រិកពោលថា ក្រុងរោមច្បាំងឈ្នះប៉ូល័មៀ រោមបានប្រមូលយកពេជ្រ ទិល មាស ប្រាក់ ភ្លុកដំរី គ្រឿងសំរិទ្ធទង់ព្រំដាចំនួនច្រើន ៗ

ការច្បាំងឈ្នះហើយប្រមូលយកទ្រព្យសម្បត្តិទៅច្រើន ៗ នោះ ជារបស់ធម្មតាមិនជាការប្លែក តែការច្បាំងដណ្ដើមយកសិល្បវត្ថុនេះបំប្លែកណាស់ សូម្បីព្រះបាទអាឡេក្សន្ទ្រមហារាជ កាលទ្រង់ច្បាំងឈ្នះប្រទេសប៉ែរស៍ (Perse) ក៏ឲ្យប្រមូលយកសម្បត្តិទ្រព្យរបស់ក្សត្រប្រទេសនេះទៅជាច្រើន ៗ

គុប៊ីឡៃខាន់ ជាមហារាជាធិរាជដ៏ល្បីល្បាញនៃប្រទេសម៉ុគ្គលមានព្រះរាជទ្រព្យលើសលន់គណនាល្បីទៅសព្វទិស ក៏ព្រោះធ្វើសង្គ្រាមឈ្នះហើយដណ្ដើមទ្រព្យសម្បត្តិរបស់សត្រូវទៅបំពេញឃ្លាំងរបស់ទ្រង់ ៗ

ជាតិអេទ្រុស្គ៍បាននាំសេចក្ដីចំរើនរុងរឿងមកកាន់ក្រុងរោមយ៉ាងច្រើន ដូចជាបង្រៀនឲ្យចេះធ្វើទឹកសម្រាប់បញ្ចេញទឹកស្មោកគ្រោកឲ្យចេះធ្វើកន្លែងផ្ទុកទឹក ឲ្យចេះធ្វើស៊ុមក្លោងទ្វារមានលក្ខណៈរាងកោង បង្រៀនឲ្យចេះលេងគុណដាវ-ដំបង ប្រដៅឲ្យចេះគោរពបក់អានព្រះនឹងប្រកាន់ជោគជតាផ្សេង ៗ តែរោមធ្វើប្លែកជាងនេះទៅទៀត ដូចជាទៅលបលួចយកព្រះស៊ុយនុទ ជាព្រះស្រីរបស់ជាតិអេទ្រុស្គ៍ទៅផ្សំផ្គុំនឹងព្រះ

ស៊ុយពីទែរ (jupiter) ដែលជាព្រះរបស់ខ្លួន ប៉ុន្តែអេទ្រុស្គ័មិនសូវពេញចិត្តឡើយ ។

ការដែលជាតិប្រទេសរបស់អេទ្រុស្គ័លេតសាបសូន្យទៅ មិនមានអ្វីសល់នៅ ដោយហេតុក្រុងរ៉ូមធ្វើការញាំញីឲ្យវិនាសសាបសូន្យទៅថែមទាំងពោលសង្កត់សង្កិនថាជាជនជាតិអាក្រក់ មិនមានចិត្តសុចរិតស្មោះត្រង់ល្មោភច្រើន ប៉ុន្តែអ្នកប្រាជ្ញខាងពង្សាវតារ បានជីកគាស់ការរកឃើញវត្ថុបុរាណអស់នេះ ទើបប្រាកដច្បាស់ថា ជាតិអេទ្រុស្គ័មិនអាក្រក់ដូរជាតិដូចក្រុងរ៉ូមពោលបង្កាច់នោះឡើយ ។

គេជឿថា ជាតិអេទ្រុស្គ័បានចំរើនដល់កំរិតខ្ពស់បំផុតជាង ៤០០ ឆ្នាំមុនរ៉ូមទៅទៀត ក្នុងសម័យនោះ ស្រុកអេទ្រុស្គ័ជាស្រុកធំ ហើយមានរោងល្ខោនកណ្ដាលវាលយ៉ាងល្អ ដែលរ៉ូមបានថតចំឡងយកបែបមកធ្វើ ទាំងកំពែងព័ទ្ធជុំវិញក្រុង ស៊ុមក្លោងទ្វារស្រុក អាងស្តុកទឹកជាសាធារណៈ ក្រៅអំពីនេះជាជាតិស្ទាត់ខាងជួរដំនួញតាមជាយសមុទ្រឥតាលីបានចេញទៅឆ្ងាយដល់ទៅប្រទេសអង់គ្លេសផង ។

បណ្ដារូបទាំងពួងដែលជាតិអេទ្រុស្គ័ធ្វើប្រឌិតជារូបផ្សេង ៗ ទាំងតូចធំមានចំនួនច្រើន គង់បានសាងរោងឡធំ ៗ សម្រាប់ដុតចំអិនរូបរស់នេះផង ។

វត្ថុបុរាណអស់នេះដែលគេជីកគាស់បានមក ធ្វើឲ្យយើងបានជ្រាប អំពីប្រវត្តិរបស់គេ ៗ អ្នកដែលគិតថាមនុស្សបុរាណមិនមានស៊ីវិឡ្យនោះ ខុសទេ ៗ ជាតិអេទ្រុស្ក៍នេះឯង ជាជាតិប្រដៅឲ្យរ៉ូមស្គាល់ស៊ីវិឡ្យ័ នឹងបែបផែនសិល្បៈផ្សេងៗ ។

តែមុខគួរឲ្យស្តាយណាស់ដែលបុរាណវត្ថុអស់នេះច្រើនបែកបាក់ប្រេះឆារខ្ទេចខ្ទីអស់ទម្រាំតែយកផ្សំផ្គុំរូបជារូបនីមួយ ៗ បានគ្រប់គ្រាន់តោងនឿយហត់ច្រើន តែលុះបានសម្រេចនីមួយ ៗ ទៅជារូបល្អឆើតមានសិល្បកម្មយ៉ាងវិចិត្រ ។

ឯប្រទេសកម្ពុជាយើងនេះជាប្រទេសបុរាណមួយ ដែលមានសេចក្តីចំរើនមកយូរហើយ ។ ជាគ្រូគេក្នុងការបង្កើតសិល្បកម្មនិងបែបចម្លាក់រចនា បែបកសាងជាដើម ក្នុងចំណោមឥណ្ឌូស៊ីននេះដែរ ។

ចេបរក្ស

# អវ្យយសព្ទ[១]

(៨៤) សព្ទដែលមិនវិនាស គឺមិនប្រែប្រួលចាកភាពដើមរបស់ខ្លួន រូបដើមយ៉ាងណា ក៏នឹងនៅយ៉ាងនោះ មិនផ្លាស់ប្តូរទៅតាមលិង្គទាំង៣, មិនប្រែប្រួលទៅតាមវចនទាំង ៣ និងវិភត្តិទាំង ៧ ឡើយ ហៅថាអវ្យយសព្ទ ។ នោះ បានដល់ឧបសគ៌, និបាត និងប្រត្យយដែលភ្ជាប់ជាមួយនឹងនាមសព្ទ មានចំនួនច្រើនពេកណាស់ កន្លែងនេះ នឹងពោលចំពោះតែអវ្យយសព្ទ ដែលត្រូវការប្រើញឹកញាប់ច្រើនជាងគេ ដូចតទៅនេះ:

១. អវ្យយសព្ទ ដែលក្លាយចេញពីបុព្វាសវ៌នាម, អនិយមសវ៌នាមនិងនិយមសវ៌នាម កើតទៅជាកិរិយាវិសេសន ប្រព្រឹត្តទៅក្នុងអត្ថនៃសប្តមីវិភត្តិខ្លះ បញ្ចមីវិភត្តិខ្លះ មិនប្រព្រឹត្តទៅក្នុងអត្ថនៃវិភត្តិទាំង ២ នោះក៏មានខ្លះ ដោយអាស្រ័យនឹងប្រត្យយ ត្រ ថ្លែងពីទីកន្លែង, ប្រត្យយ ថា ធា ថម៑ ថ្លែងពីបែប, យ៉ាង, វិធី, ប្រការ, ប្រត្យយ ទា ថ្លែងពីកាល, ប្រត្យយ តោ សិ ថ្លែងពីទីដែលកើត, ដែលចេញមក ។.

---

១ ដែលពោលក្នុងទីនេះដោយសង្ខេបពេកណាស់ ចំពោះតែអវ្យយសព្ទដែលត្រូវការប្រើញឹកញាប់ ដែលនៅសល់ក្រៅពីនេះជាអនេក, អ្នកសិក្សាបើត្រូវការចង់ដឹងដោយពិស្តារ ចូរមើលក្នុងសៀវភៅកច្ចាយនូបត្ថម្ភ ភាគទី ១ ត្រង់លេខ ១៥២ សៀវភៅនោះទោះបីជាបាឡីក៏ពិតមែន តែក៏គង់ត្រូវគ្នាដូចគ្នានឹងសំស្ក្រឹតដោយច្រើន បើប្លែកពីគ្នាខ្លះក៏មិនច្រើនឡើយ ។

កុត្រ, ក្នុង... ដូចម្ដេច, ឯណា?; យត្រ, ក្នុង...ណា, ឯណា; តត្រ, ក្នុង...នោះ; អត្រ, ក្នុង...នេះ ។ កថំ, ដូចម្ដេច?; យថា យ៉ាងណា, ដូចអ្វី; តថា, យ៉ាងនោះ, ដូចនោះ ។ កទា, កាលណា, ក្នុងកាលដូចម្ដេច?; យទា, ក្នុងកាលឯណា; តទា, ក្នុងកាលនោះ ។ កុតសិ, អំពីណា, អំពី... ដូចម្ដេច?; យតសិ, អំពីណា, អំពី....ណា; តតសិ អំពីនោះ, អំពី....នោះ; អតសិ, អំពីនេះ ។

២. បច្ច័យ ត្រ, ថា, ទា ទាំង ៣ នេះ អាចភ្ជាប់ទៅនឹងសវ៌នាមឯទៀត ៗ ក៏បាន ។ ១. សវ៌ត្រ, សព្វអន្លើ, ក្នុងទីទាំងពួង; អន្យត្រ, ក្នុងទីឯទៀត, ដទៃ; បរត្រ, ក្នុងខាងមុខ, ក្នុងទីដទៃ ។ល។ សវ៌ថា, គ្រប់បែប, គ្រប់យ៉ាង, ដោយប្រការទាំងពួង; អន្យថា, ដោយប្រការដទៃ; ឧភយថា, ដោយបែបទាំងពីរ, ដោយប្រការទាំងពីរ ។ល។ អន្យទា, ក្នុងកាលដទៃ, ឯកទា, ក្នុងកាល ១, ១ គ្រា, ១ ដង; និត្យទា, ក្នុងកាលជានិច្ច ។ល។

៣. បច្ច័យ តសិ អាចភ្ជាប់ចំពោះទៅនឹងសវ៌នាមនឹងនាមសព្ទបាន. ១. ស្វតសិ, អំពីខ្លួនឯង; មត្តសិ, អំពីខ្ញុំ; អស្មត្តសិ, អំពីយើង; ជន្មតសិ អំពីកំណើត; មុខតសិ អំពីមុខ, អំពីមាត់; អគ្រតសិ, អំពីកំពូល អំពីទីបំផុត; ជាប្រធាន ។ល។

៤. ប្រត្យយ ត្រ និង តសិ ទាំង ២ នេះ មានសេចក្ដីផ្សេងគ្នា គឺ ត្រ មានសេចក្ដីប្រើជំនួសសប្តមីវិភត្តិបាន ឯ តសិ មានសេចក្ដីប្រើជំនួសបញ្ចមីវិភត្តិបាន ហើយអាចប្រើជាវិសេសណសព្វនាម មាននាមសព្ទដែលបំបែកត្រង់សប្តមីនឹងបញ្ចមី នៅខាងមុខបាន. ឧ. កុត្រ ទេសេ (ដូចជា កស្មិំ ទេសេ), ក្នុងប្រទេសដូចម្ដេច; អត្រ ទេសេ (ដូចជា អស្មិំ ទេសេ) ក្នុងប្រទេសនេះ យត្រ ទេសេ (ដូចជា យស្មិំ ទេសេ) ក្នុងប្រទេសឯណា; តត្រ ទេសេ (ដូចជា តស្មិំ ទេសេ), ក្នុងប្រទេសនោះ ៗ សព្វតោ ភយតោ, អំពីភ័យគ្រប់យ៉ាង; កុតញ្ចិ ទេសាគតោ, មកអំពីប្រទេសណាមួយ ៗ

ម្យ៉ាងទៀត, ប្រត្យយ ត្រ និង តសិ នេះ ជួនកាលភ្ជាប់ទៅនឹងនាមសព្ទក៏មាន ទេវត្រ (ដូចជា ទេវេសុ), ក្នុងសំណាក់នៃទេវតាទាំងឡាយ; ទេវតសិ, អំពីសំណាក់នៃទេវតា ឬ នៃទេវតាទាំងឡាយ ។ល។

៥. ប្រត្យយ ធា និង ធសិ ភ្ជាប់នឹងសំខ្យាសព្ទ ធ្វើឲ្យកើតទៅជាកិរិយាវិសេសន សំដែងពី ភាគ, ចំណែក (ប្រែថា "ដោយ...") ឯកធា, ឯកធសិ, ដោយចំណែក ១; ទ្វិធា, ទ្វិធសិ ដោយចំណែក ២; ត្រិធា, ត្រិធសិ, ដោយចំណែក ៣; សតធា, សតធសិ, ដោយចំណែក ១០០ ។ល។

ប្រត្យយ ធា ថំ ធ សោ នេះ អាចភ្ជាប់នឹងនាមសព្ទ ឬ គុណសព្ទបានខ្លះទៀត ធ្វើឲ្យកើតទៅជាកិរិយាវិសេសន សំដែងពីភាគ, បំណែកដូចគ្នា ឧ. ពហុធា, ដោយច្រើន; អក្ខរសោ, ដោយចំណែកនៃព្យាង្គ; សព្វសោ, ដោយសព្វគ្រប់, ដោយប្រការទាំងពួង ។ល។

៦. សព្វនាម ឬ នាមសព្ទ ជានបុំ. ដែលបំបែកត្រង់ទុតិយា, តតិយា, បញ្ចមី និងសត្តមីឯកវចន គេអាចយកមកប្រើជាកិរិយាវិសេសន តែដែលប្រើច្រើនជាងគេ ត្រង់ទុតិយាឯកវចនៈ

តំ, តេន, តស្មា, “ព្រោះហេតុនោះ, ដោយហេតុនោះ” ឧ. អនិច្ចំ ជីវិតំ តំ (ឬ តេន, តស្មា) បុញ្ញំ ចយិតព្វំ, ជីវិត ជាធម្មជាតិមិនទៀងទេឡើយ ព្រោះហេតុនោះ គេ គប្បីសន្សំ នូវបុណ្យ;

នាម, “ដោយពិត” (ទុ. ឯក. មកពី នាមន, ឈ្មោះ); កាមំ, “ដោយពិត, ប្រសិនណាបើ, អ្វីក៏ដោយ” (ទុ. ឯក. មកពី កាម, សេចក្តីប្រាថ្នា); តង្ខណំ, តង្ខណេន, “ដោយមួយរំពេច”; សុខំ, សុខេន, “ដោយសុខ, ដោយស្រួល, ដោយសប្បាយ”; ឧច្ចំ, “ខ្ពស់”; នីចំ “ទាប”; ទូរេ “ឆ្ងាយ, ក្នុងទីឆ្ងាយ”; ឫតេ “គ្មាន” ។ល។ល។

# ប្រជុំពាក្យកាព្យ

## ភាគ ទី ៤

## របស់រក្សភិរម្យ (អ្លុង)

## ហុមព្រៃមហាតឡៀក

# ពាក្យនាំ

ខ្ញុំបានឃើញថាពាក្យកាព្យជាន់មុន ពួកដែលតែងមានវោហារយ៉ាងជានោះគួរគប្បីរក្សាចំនួនទុក ខ្ញុំមានបំណងនឹងចុះពុម្ពមកជាយូរហើយ ពុំទាន់បានចុះពុម្ព ព្រោះមានធុរៈឯទៀតជាច្រើន គ្មានពេលានឹងរើសពាក្យរៀបតាមដោយពួកៗ ការដែលនឹងចុះពុម្ពពាក្យកាព្យនោះ លំបាកជាងរឿងឯទៀត ដោយពាក្យកាព្យសំរាប់ប្រៀនក៏មាន ពាក្យកាព្យជារឿងនិពសក៏មាន ជាពាក្យកាព្យសង្វាសក៏មាន បើនឹងចុះពុម្ពមានតែចាត់រៀបឲ្យជាពួកគ្នាតាមលំដាប់ ក្នុង ព. ស. ២៤៧៤ ខ្ញុំបានចាត់រៀបរួចជាស្រេចបំរុងនឹងចុះពុម្ព ក្នុងរវាងនោះប្រជួបវេលាខ្វះខ្ញុំបានទទួលសេចក្តីទុក្ខជាទម្ងន់ ក៏បង្អង់ខានពុំបានបោះពុម្ពពាក្យកាព្យទាំងនោះរហូតមកក្នុងគ្រាឥឡូវនេះ ខ្ញុំទើបលើកពាក្យកាព្យទាំងនេះជូនដល់ចាងហ្វាងព្រះរាជ-បណ្ណាល័យ ឲ្យចាត់ការបោះពុម្ពតាមត្រូវការ ។

ព្រះអគ្គម្ចាស់ក្សត្រីមាលិកា

# ប្រវត្តិអ្នកតែងកាព្យ

ឈ្មោះ អួង ជាបុត្រចៅហ្វាយស្រុកបារាយណ៍ កាលអាយុបាន ១៦ ឆ្នាំ ចូលថ្វាយខ្លួនជាខ្ញុំព្រះរាជការ នៃព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម ជាម្ចាស់ផែនដីក្រុងកម្ពុជាធិបតី រាំងដើមរជ្ជកាល, ក្រោយនោះទ្រង់ព្រះមេត្តាប្រោសឲ្យធ្វើជាពួកហុមព្រៃមហាតឡិក ធ្វើការជារ័ក្សក្រិរម្យ ក្រោយនោះមកទៀត នាយរ័ក្សក្រិរម្យ អួង ហុមព្រៃមហាតឡិក មានសេចក្តីពាក់ព័ន្ធបដិព័ទ្ធនឹងស្តេចក្សត្រីក្នុងព្រះបរមរាជវាំង គឺព្រះអង្គម្ចាស់ ស្រ.អ. ។ ក្រោយនោះមកទៀត សេនាបតីក្រសួងព្រះបរមរាជវាំង បានដឹងហេតុការនោះ ទើបសេនាបតីក្រសួងព្រះរាជវាំងក្លែងធ្វើជាប្រើនាយរ័ក្សក្រិរម្យ អួង ឲ្យចេញទៅធ្វើជាមេកងកត់ពន្ធស្រូវ នាយរ័ក្សក្រិរម្យ អួង ដំរៀនពន្ធស្រូវរួចហើយ ត្រឡប់ចូលមកធ្វើរាជការជាហុមព្រៃមហាតឡិកដូចដើមវិញ មានយប់ ១ វេលាអធ្រាត្រនាយរ័ក្សក្រិរម្យ អួង ហុមព្រៃមហាតឡិក ដើរទៅប្របជិតជើងព្រះបរមរាជវាំង បួនចួបប្រទះនឹងក្រុមទាហានក្រុម-វាំង នោះទាហានក្រុមវាំងចាប់ខ្លួននាយរ័ក្សក្រិរម្យ អួង នាំខ្លួនទៅប្រហារជីវិតចន់ ធ្វើដោយការសម្ងាត់ មិនឲ្យខ្ចរខ្ចាយសេចក្តី មិននាំសេចក្តីក្រាបបង្គំទូលព្រះករុណាជាម្ចាស់ទ្រង់ជ្រាបឡើយ ព្រះករុណាមិនបានទ្រង់ជ្រាបរហូត ។

ក្សត្រថៃស៊ីនមហាកដ - ថៃស៊ីនច្បាំងនឹងជាតិភាគ ។ វគ្គទី ៥ - និយាយពីពង្សវង្សប្រាំងក្នុងសម័យនៅក្រោមអំណាចអគ្គមហេសី ។ វគ្គទី ៦ — និយាយពីអវសានកាលនៃពង្សប្រាំង - ក្សត្រក្រោយ ៗ ត ៗ មក - ការចលាចល ។ វគ្គទី ៧ - និយាយពីវង្សស៊ីន - ការចលាចលមុនតាំងវង្សស៊ីន - ក្រុងប៉ាំងកកចាប់ចំរើន - ស្រុកចិនថៃនិងខ្មែរគ្នាពីរចំណែក ។

ឯសម័យកណ្ដាល សម័យថ្មីនិងសម័យបច្ចុប្បន្ននោះ យើងនឹងរម្ល សេចក្ដីថ្លែងជាលំដាប់ ៗ ទៅរហូតដល់ចប់សព្វគ្រប់ ។

ហេតុនេះ សូមអស់លោក-អ្នកមើលជ្រាបថា ឧទាហរណ៍ដែលយើងនាំមកសំដែងតែគោល ៗ ខាងលើនេះ គ្រាន់តែពន្យល់ឲ្យលោក-អ្នកបានជ្រាបអំពីរបៀបរៀងប្រវត្តិសាស្ត្រនានាជាតិនេះដោយទូស ៗ ប៉ុណ្ណោះ ។ មួយវិញទៀត សូមឲ្យយល់ថា មិនមែនត្រឹមតែប៉ុន្មានជាតិដែលថ្លែងមកខាងលើនេះទេ នានាជាតិដទៃទៀតនៅមានចំនួនច្រើនជាតិណាស់ រួមទាំងខេមរជាតិរបស់យើងផង ដែលយើងនឹងព្យាយាមសំដែងដោយសេចក្ដីពិស្ដារដល់ជាតិដទៃ ៗ ទាំងអស់ តែនឹងបានសម្រេចប្រយោជន៍ត្រឹមណា យើងមិនទាន់ហ៊ានប៉ាន់ទេ ព្រោះស្រុកខ្មែរយើងមិនទាន់មានពង្សាវតាររបស់ជាតិបរិបូណ៌នៅឡើយ នឹងប្រកាន់តាមពង្សាវតារដែលសរសេរចម្លងច្បារចម្លងត ៗ គ្នាមកជាលក្ខខណ្ឌក៏ពុំបាន អាចពាស់

# ពាក្យកាព្យ

១ សន្ធិយា នាក្នុងថ្ងៃអាទិត្យ

ចួបជិតមិត្រមូលចូលដីវៃ

ឃើញភក្ត្រហាក់បានក្សាន្តចិត្តគ្រាន់

លុះចួបថ្ងៃចន្ទ្របាត់ទៅទៀត ៗ

និតនៅខ្លោចផ្សាឲពណែន

ហាក់ប្រាសមួយសែនកាល្ប៍ចង្អៀត

ថាបើមិនជឿស្បថជូនទៀត

ចូរទៀតមើលចុះធ្ងុះថ្ងើមបង ៗ

ទឹកម្ដងចិត្តបង់យាត់ឲ្យទៅ

គិតទៅក្រែងកើតសេចក្ដីហ្មង

គេដឹងនិន្ទាដល់ខ្លួនបង

នួនល្អងនឹងព្រួយតែដោយសារ ៗ

ប្អូនអើយថ្ងើមបងសៅហ្មងណាស់

ដូចដឹងដាក់ច្បាស់ក្នុងឲព

នៃបទិត្យផិតអូនពេលាណា

កក់ក្ដៅឲពថ្ងាដូចទឹក ៗ

រំពេចប្រែប្រាសពីទ្រូងទៅ
ឱកផ្សាក្តៅសែនរពុក
សន្ទួមមៃមមាញឹក
ព្រឹកទឹងស្តាយថ្នាយមេត្រី ។
សន្និយាពត្រីខាងរនោច
ព្រះចន្ទពីរពេចអន់ស្ញូ
ដូចរៀមឃ្លាតខ្ទឹមខ្លួនស្រស់ស្រី
សេចក្តីគួរគិតឲ្យអនិច្ចំ ។
តែទឹករពុកឡើងកាលណា
ចិន្តាសែនខ្វល់អំពល់ខ្ទាំង
លុះជិតព្រះចន្ទដើរបើងបាំង
បងកាំងក្បេខ្លួនចូនធ្វេសលក់ ។
លុះយូរបន្តិចបែរប្រែខ្លួន
គិតស្មានប្អូនស្ងួនខ្លួននៅមុខ
ប្រាំឱនឱបក្រសោបទុក
បើកនេត្រមើលមុខឃើញតែខ្នើយ ។
ឱយើងទាំងពីរធ្លាប់តែជិត
តែងនែបស្នាលស្និទ្ធជិតកៀកកើយ
បើបានឃើញភក្ត្រកាលណាហើយ

កែវអើយបងមហាចិន្តាព្រើស ។
នៃបងនិត្យជិតស្ងួនពេលាណា
ប្រាយប្រាប់កិច្ចការមិនឲ្យលើស
វេទនាពេហារមិនមានផ្ញើស
ឲ្យល្មើសលើសលស់ខុសចិន្តា ។
សេចក្តីនេះដល់និមិលមិត្ត
ផ្សិតរៀមព្រួយចិត្តណាស់ធីតា
ពីដួចបែកមកពេលាណា
ទុកស្ទើរប្រេះរបេះបេញ ។
រំដំរំជួលផ្ដួលសព្វសាច់
ហាក់គេប្រចាប់ឈ្លួចញាំញី
មានតែទីទុក្ខទីអំមួញ
ជ្រក់ជ្រេញស្រពន់ទន់កាយា ។
ផ្គុំក្លិនក្រអូបនៅថ្មី ៗ
ហាក់ថ្ងៃនៅនិត្យជិតទុក
ភ្នាឡើងលោលើកនៃហត្ថា
ប្រាកេបាត់ស្វាត់ពុំយល់ ។
មានតែទឹកភ្នែកស្រក់ផ្សើយ

កាលណានឹងស្បើយទុក្ខសែនសល់
ឲម្ល៉េះសមថ្លៃព្រះទ័យខ្វល់
អម្ពល់ទឹករៀមដៃដើងអើយ ។
ពីកាលដែលចេញពីកដឋាន
ទៅបានរួមកក់ស្ន័គ្រកៀកកើយ
រួមសម្ពលមិត្តស្នេហ៍ស្និទ្ធហើយ
មិនស្បើយវិយោគសោកសែនទ្វី ។
ឥឡូវរៀមកក់នឹងទៅឆ្ងាយ
ថ្លើមម៉ាយរៀមសូមផ្តាំនារី
កុំយាងចេញពោលឆ្ងាយពីទី
ក្រែងគេមើលងាយណាធីតា ។
ដ្បិតមនុស្សផ្សព្វពាក់ទុច្ចរិត
ប្រែចិត្តដូចអ្នកក្រៅសាស្នា
រង់ចាំទំពាំតែផ្កា
មកដល់ថ្ងៃណាសិមយាងទៅ ។
អាសូរចិត្តរៀមដែលក្រៀមក្រំ
ប្រឹងទៅតាំងទំតាំងផ្សព្វក្តៅ
មានតែវិយោគសោកសែនសៅ
ម្ល៉ៅមិនមានក្សាន្តសោះឡើយ ។

ល : 08

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

## កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ៤

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨២
គ. ស. ១៩៤០

AMBODGE

# បញ្ជីរឿង


១ — ប្រវត្តិសាស្ត្រនៃច្បាប់ របស់លោកលង្កាត់ទីប្រឹក្សាច្បាប់នៅក្រុងបាងកក ខេមរៈរង្សី ប្រែពីភាសាថៃមកជាខេមរភាសា . . . . . . . . . . . . . . . . . ៣

២ — ពង្សាវតារប្រទេសអេស៊ីប្ត ស្រង់យកអំពីប្រវត្តិសាស្ត្រសាកលថៃ របស់ក្លួងវិចិត្រវាទការ សេចក្តីប្រែនិងរៀបរៀងរបស់អ្នកមហា ញ៉ុក-ថែម (តនិងចប់) . ១៧

៣ — ពុទ្ធប្បវត្តិបិទ (តមក) . . . . . . . . . . . . . . . . . . . . . ៣៥

៤ — ប្រវត្តិលោកមីលរេប៉ៈ លោកស័កបាកូត់ប្រែចេញពីភាសាទីបេតាំងមកជាភាសាបារាំងសែស (តមក) . . . . . . . . . . . . . . . . . . . . . ៣៩

៥ — ព្រះពុទ្ធសាសនាបាត់ទៅពីប្រទេសឥណ្ឌៀដោយហេតុយ៉ាងណា? ខេមររង្សី ប្រែចេញពីទស្សនាវដ្តីធម្មចក្សុថៃមកជាខេមរភាសា (នៅមានត) . . . . . . . ៤៣

៦ — អំពីគំនូរថ្មីពីរបែបរបស់ព្រះរាជបណ្ណាល័យ (តនិងចប់) . . . . . . . . . ៥១

៧ — ប្រជុំពាក្យកាព្យ ភាគទី ៤ របស់ក្សេត្រិរម្យ អួន មហាគលិក ហ៊ុមព្រៃ (តមក) ៥៧

៨ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . . ៦៧


## រូបក្រៅរឿង


១ — រូបដំណាងៈ ការធ្វើកិច្ចវត្តនៅក្នុងវត្តនៃភិក្ខុសាមណេរ តាមជម្ស្នានរបស់ព្រះពុទ្ធជាម្ចាស់ . . . . . . . . . . . . . . . . . . . . . . . ១

២ — អំពីការព្យាករណ៍ . . . . . . . . . . . . . . . . . . . . . . ១៥

៣ — អំពីការសុខសម្រាន្តនៃព្រះពោធិសត្វ . . . . . . . . . . . . . . . ៣៣

៤ — ខណៈត្រង់ដែលលោកមីលរេប៉ៈ ដំណាលប្រវត្តិជីវិតខ្សែការរបស់លោកឲ្យពួកសិស្សស្តាប់ . . . . . . . . . . . . . . . . . . . . . . . . . ៣៧

៥ — អំពីការសិក្សាអក្សរសាស្ត្រ . . . . . . . . . . . . . . . . . . . ៤១

៦ — អំពីការប្រត់ព្រះខន្ទុល . . . . . . . . . . . . . . . . . . . . ៥៥

៧ — អំពីការសិក្សាក្បួនពិជ័យសង្គ្រាម . . . . . . . . . . . . . . . . ៦៥

# TABLE DES MATIÈRES


Pages.

1° Histoire du droit par R. Lingat Conseiller Juristre à Bangkok, traduit du thailandais en Cambodgien par KHEMARARANSI .................................... 3

2° Histoire de l'ÉGYPTE, extrait de l'histoire générale thailandaise, par LUONG VICHITRA-VADAKAR et traduit en cambodgien par MAHA THÈM (suite)........................ 17

3° La Vie du BOUDDHA d'après des documents Chinois (suite).................................................. 35

4° La Vie de Milarépa d'après la traduction du tibétain en français dè Mr. JACQUES BACOT (suite)................. 39

5° Pourquoi le Bouddhisme a-t-il disparu des INDES? Extrait de la Revue thailandaise DHAMMA CAKKSU et traduit en cambodgien par KHEMARARANSI (suite).................. 43

6° Commentaire sur deux dessins de l'artiste Tuk par KHEMARARANSI (suite et fin)........................... 51

7° RECUEIL DE POÈME cambodgiens, 4e partie par RAK-PHIROM UONG (suite)......................................... 57

8° INFORMATIONS DIVERSES........................................ 67


HORS TEXTES :


1° L'hygiène et la propreté dans les monastères d'après les Conseils du BOUDDHA................................ 1

2° Les prédictions........................................ 15

3° Les délassements du Bodhisattva..................... 33

4° Milarépa raconte sa vie étrange à ses disciples...... 37

5° Son enseignement littéraire........................... 41

6° Les premières semailles............................... 55

7° Enseignement dans l'art militaire.................... 65



៥ ព្រះអង្គមានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីធ្វើវត្ត
ធ្វើសំអាតឲ្យស្អាតហើយរៀបទុកដាក់, ភិក្ខុមិនត្រូវទុកចីវរឲ្យសើម ត្រូវ
ហាលចីវរឲ្យស្ងួតសិនសឹមដាក់. មនុស្សភាគច្រើនដែលត្រូវការនូវបាត្រ ចាប់រំលែក
ដាច់, មនុស្សភាគច្រើនចង់ឃើញព្រះភិក្ខុ, ភិក្ខុមិនត្រូវលាក់ចីវរ ហើយដើម
ទីកន្លែងធ្វើវត្ត. ត្រូវបោសសំអាតវិហារ, កុដិ, សាលា, កុដិ និងបរិវេណឲ្យ
ស្អាត, វិហារធ្វើត្រូវ ត្រូវមិនឲ្យមានធូលីដី, ស្មៅឬឈើកំទេចត្រូវបោសសំអាត
ចេញឲ្យស្អាត, ត្រូវរក្សាកុំឲ្យមានដំណក់ទឹកកខ្វក់សម្រាប់ផ្សារ. ( ដកស្រង់
អំពីវិនយបិដក ចុល្លវគ្គ ផ្នែកវត្តក្ខន្ធក និង ខុទ្ទកវត្ថុក្ខន្ធក ) ៖—

# ប្រវត្តិសាស្ត្រនៃច្បាប់

## របស់លោក លង្កាត់ ទីប្រឹក្សាច្បាប់ស្រុកសៀម

(តៅ៨.៩៣)

# ប្រវត្តិសាស្ត្រនៃច្បាប់

របស់លោក លង្កាត់ ទីប្រឹក្សាច្បាប់ស្រុកសៀម

## សេចក្តីផ្តើម

### និយាយពីការប្រែប្រួលនៃវិជ្ជាច្បាប់

១ — ច្បាប់ឬបែបបញ្ញត្តិទាំងឡាយសម្រាប់កិច្ចការផ្សេងៗគ្នារបស់មនុស្សដែលនៅរួបរួមគ្នាជាជំនុំជន មិនមែនបានតាំងឡើងតាមទំនើងចិត្តរបស់អ្នកដែលជាធំជាអធិបតីក្នុងជំនុំជននោះៗ ក៏ឥតអង្គឹមាន ។ កាលបើយើងពិនិត្យមើលប្រវត្តិសាស្ត្ររបស់ច្បាប់ ឬសេចក្តីប្រែប្រួលនៃច្បាប់ នឹងយល់ថា សេចក្តីបញ្ញត្តិផ្សេងៗដែលរួមហៅថា "ច្បាប់" នេះកើតឡើងដោយហេតុមនុស្សយើងនៅរួបរួមគ្នាជាជំនុំជនតាមវិស័យសត្វលោក ទើបបទបញ្ញត្តិផ្សេងៗដែលពោលមកនេះក៏សន្សំៗ កើតឡើងជាលំដាប់រៀងមក ហើយរៀបចំចាត់បៀបឲ្យកាន់តែរៀបរយច្បាស់លាស់ឡើង ។ បែបបញ្ញត្តិអស់នេះហើយជាគ្រឿងពន្យល់ឲ្យមនុស្សដឹងខ្លួនច្បាស់លាស់ថា ខ្លួនមានអំណាចធ្វើការអ្វីបានខ្លះ ដែលមិនមែននាំឲ្យខូចខាត ឬបៀតបៀនដល់អ្នកដទៃ ឬជាគ្រឿងធ្វើឲ្យមនុស្សដឹងខ្លួនថា ខ្លួនមានអំណាចលើអ្នកដទៃត្រឹមណា អ្នកដទៃមានអំណាចមកលើខ្លួនត្រឹមណា ដែលជាទំនងយុត្តិធម៌ល្អ ។ តាមដែលពោលមកនេះ យើងល្មមយល់ឃើញថា ច្បាប់

បុរុសពីសិលាចារឹកដែលមាននៅតាមបុរាណស្ថានផ្សេងៗ នឹងស្រេចយក ចំពោះសេចក្ដីក្នុងអក្សរថ្មកបរិយាយជាមួយនឹងសេចក្ដីសន្និដ្ឋាន គង់បាន សេចក្ដីខ្វះពេកទាំងមិនតគ្នាជាលំដាប់លំដោយផង ។ ហេតុនេះ ការរៀបរៀងពង្សាវតារខ្មែរជាតិយើងដោយពិស្ដារនេះមិនមែនជាការងាយធ្វើទេ តោងអាស្រ័យពង្សាវតារចាស់ៗដែលចារចំឡងតៗគ្នាមកផង តោងអាស្រ័យពង្សាវតាររបស់ប្រទេសជិតខាង ដែលមាននិយាយពីស្រុកខ្មែរយើងនេះខ្លះផង តោងអាស្រ័យចុតហ្មាយហេតុឬសេចក្ដីកត់ហេតុរបស់ប្រទេសខាងក្រៅផង រួមទាំងសិលាចារឹកនឹងសេចក្ដីសន្និដ្ឋានរបស់អ្នកប្រាជ្ញប្រកបផង ទើបមានសេចក្ដីពិស្ដារល្មមសមតាមបំណងរបស់យើងបាន ។

មុនបញ្ចប់សេចក្ដីពន្យល់អំពីវិធីរៀបរៀងប្រវត្តិសាស្ត្រនេះ យើងសូមបញ្ជាក់ទុកជាមុនថា ការធ្វើពង្សាវតារលោកទាំងមូលឲ្យបានចប់សព្វគ្រប់នោះ មិនមែនធ្វើបានដោយងាយស្រួលទេ ព្រោះតោងអាស្រ័យសេចក្ដីព្យាយាមយ៉ាងធំទើបធ្វើសម្រេច ឯពង្សាវតាររបស់នានាជាតិក្នុងលោកដែលបានរៀបរៀងឡើងនេះ យើងអាស្រ័យសៀវភៅប្រវត្តិសាស្ត្រសាកល របស់ហ្វង់វិចិត្រពាំងការ ដែលជាអ្នកប្រាជ្ញខាងពង្សាវតារមួយរបស់ប្រទេសថៃ ក្រៅពីនេះយើងអាស្រ័យពង្សាវតារលោក របស់លោក

នេះមិនគឺអ្វីដទៃទេ គឺជាទីប្រជុំរួមសេចក្ដីអនុញ្ញាតនិងបញ្ញត្តិ ដើម្បីញុំាងប្រជុំជននោះៗ ឲ្យប្រព្រឹត្តការងារផ្សេងៗ បានស្រួលនិងចំរើនឡើងៗ

២— ក្នុងកាលជាដំបូង នៅវេលាដែលមនុស្សទើបនឹងរួបរួមគ្នាជាជំនុំជននោះ ក៏នៅមិនទាន់មានច្បាប់កត់ត្រាជារូបអក្សរនៅឡើយ គ្រាន់តែប្រកាន់តាមគ្នាជាប្រវេណីតគ្នាជាលំដាប់មកប៉ុណ្ណោះ គឺគ្រាន់តែជាទំនៀមទម្លាប់ ដោយហេតុការងាររបស់មនុស្សតោងតែអាស្រ័យពួកអាស្រ័យក្រុម ទើបប្រព្រឹត្តទៅបានស្រួលៗ ទើបធ្វើឲ្យយើងយល់ដល់ហេតុដែលធ្វើច្បាប់នានាឲ្យមានលក្ខណៈផ្សេងៗគ្នាៈទៅតាមប្រទេសនិងកាលសម័យៗ ឯទំនៀមទម្លាប់ដែលប្រកាន់ជាច្បាប់នេះហើយ ដែលមានទំនងដូចជាស្រមោលឬវត្ថុដែលគេចំឡងយកពីនិស្ស័យសន្តានរបស់មនុស្សសម័យនោះៗ ក្នុងសម័យនេះ នៅមានជំនុំជនបំពួកខ្លះក្នុងតំបន់ខ្លះ ដែលមានជាប់តមកពីជំនុំជនសម័យជាន់ដើម ទើបយើងអាចសង្កេតឃើញទំនៀមទម្លាប់ច្បាប់ប្រវេណី ដែលមិនបានកត់ត្រាទុកជាតួអក្សរនៅឡើយៗ តែពួកមនុស្សដោយច្រើនដែលទៅរួបរួមគ្នាជាជំនុំជន (ធំៗ) សឹងត្រូវការប្រកាសផ្សាយសេចក្ដីបញ្ញត្តិប្រការខ្លះ ដើម្បីបញ្ជាក់ជំនុំជនឲ្យយល់ច្បាស់នឹងគោរពប្រតិបត្តិតាមដោយម៉ឺងម៉ាត់ ឬដើម្បីប្រកាសផ្សាយនូវច្បាប់ទំនៀមទម្លាប់របស់ខ្លួន ឬដើម្បីកំណត់បែបផែនទំនៀមទម្លាប់ប្រវេណីនោះឲ្យមានរបៀបទៀងទាត់ល្អឡើងៗ

ការរៀបចំធ្វើបែបនេះ ចាត់ជាថ្នាក់ដំបូងនៃច្បាប់ដែលមានការកត់ត្រាជាអក្សរឡើង ថ្នាក់នេះហើយជាមេគំនិតឬជាគំនូសនៃការរៀបចំច្បាប់តាមករហូតដល់បច្ចុប្បន្ននេះ ។ ឯអ្នកដែលមានអំណាចជាអធិបតីក្នុងជុំនុំជនសម័យនេះ គ្រាន់តែជាអ្នកត្រួតត្រាឃុំគ្រងប្រយោជន៍ឲ្យមានសេចក្ដីស្ងប់ រៀបរយភ្ជាប់ខ្ជាប់ខ្ជួនក្នុងរវាងសមាជិករបស់ជុំនុំជនប៉ុណ្ណោះ ។ ខណៈដែលពោលនេះ បទបញ្ញត្តិជាអក្សរនេះ គ្រាន់តែជាគ្រឿងឧបការៈរបស់ប្រពៃណី ហើយគោរពស្រ័យប្រកាន់យកប្រពៃណីជាគោលប្រតិបត្តិ ទើបសំរេចប្រយោជន៍តាមបំណងរបស់ច្បាប់ដែលបានត្រាទុកមកនេះ ។ តាមដែលពោលមកនេះ ចាត់ជាថ្នាក់មួយនៃការប្រែប្រួលរៀង ៗ មកក្នុងច្បាប់ហ៊ឹងមានប្រជាជននៅតំបន់ខ្លះ ក៏គង់នៅក្នុងថ្នាក់នេះឬទើបតែនឹងឡើងពីថ្នាក់នេះអស់កាលមិនយូរប៉ុន្មានទេ ។

៣ — តាមធម្មតាគំនិតរបស់មនុស្សលោកយើងចេះតែធ្វើដំណើរទៅមុខជាដរាប មិនបាននៅនឹងតែមួយកន្លែងទេ ទាំងការចងបាច់គ្នាទៅវិញទៅមកក្នុងមនុស្សក៏កាន់តែច្រើនកើតឡើងគ្រប់ស្រុក សឹងមានលក្ខណៈប្លែក ៗ នានាជានិច្ច ។ ច្បាប់ដែលជាឧបគ្គាប់សម្រាប់មនុស្សទើបត្រូវតែកែប្រែឲ្យត្រូវទំនងតាមហេតុគេដែលពោលមកនេះ តែទំនៀមប្រពៃណីដែលមនុស្សសម័យដំបូងប្រើជាឧបគ្គាប់នោះ គ្រាន់តែជាបទ

បញ្ញត្តិប្រើបានចំពោះករណីយហេតុនីមួយ ៗ ប្រសិនបើមានករណីយ-ហេតុដទៃផ្សេងទៀតកើតឡើង ក៏ត្រូវឲ្យធ្វើច្បាប់ប្រវេណីមួយផ្សេងទៀតដែរ កាលបើកិច្ចការទាក់ទងរវាងមនុស្សផងគ្នា កាន់តែកើតឡើងប្លែក ៗ ថ្មី ៗ ហើយទ្វេចំនួនច្រើនឡើង ទើបត្រូវតែគិតរិះរកវិធីត្រាខបង្គាប់ ទុកសម្រាប់បញ្ញត្តិដល់ករណីយហេតុនីមួយ ៗ ហើយរិះរកវិធីត្រាខបង្គាប់យ៉ាងធំទូលាយ អាចប្រើបង្គាប់ដល់ករណីយហេតុដែលមានលក្ខណៈនៅក្នុងប្រភេទដូចគ្នា ដែលជាវិធីដោះប្រស្នាដែលកើតឡើងថ្មីបានស្រួលល្អ ៗ ប្រវេណីដែលជាខបង្គាប់នេះសន្សំមកតែប្រយ៉ាងយឺតៗអស់កាលជាយូរអង្វែង ហើយច្រើនតែនៅនឹងដដែលមិនប្រែប្រួល អាស្រ័យហេតុនេះហើយ ទើបត្រូវតែចាត់ចែងច្បាប់ឲ្យទាន់ធុរៈរបស់មនុស្សដែលកើតថ្មីៗយ៉ាងរហ័ស មិនព្រមបង្អង់នៅតាមក្រោយប្រវេណីដែលមានដំណើរយ៉ាងយឺត ៗ នោះឡើយ ហើយមានជួនកាលគោងចាត់ចែងកែប្រែទំនៀមទម្លាប់នេះផងក៏មាន នឹងបណ្ដោយទៅតាមទំនើងមិនបាន មានជួនកាលគោងចាត់តាំងបទបញ្ញត្តិផ្សេងៗ ឡើងថ្មីតែម្ដង ដើម្បីប្រើឲ្យត្រូវនឹងធុរៈកិច្ចរបស់មនុស្សដែលកើតឡើងថ្មី ។ ការរៀបចំក្បួនច្បាប់និងការកែប្រែជាលំដាប់ៗ ដូចពោលមកនេះ ដើម្បីរៀបចំច្បាប់ឲ្យបានផលប្រយោជន៍សមរម្យតាមកាលសម័យ និងដើម្បីធ្វើច្បាប់ឲ្យមាន

លក្ខណៈបរិបូណ៌ល្អឡើង ៗ តាមដំណើរគំនិតរបស់មនុស្សតែងប្រព្រឹត្ត ទៅតាមផ្លូវគំនិតរបស់មនុស្សផងគ្នា មិនថាជនជាតិណាទេ តែងប៉ះនឹង ប្រស្នាដ៏លំបាកមានទំនងដូចគ្នា ហេតុនេះទើបឃើញថាមិនគួរយើងនឹកចំ-ឡែកឡើយអំពីរបៈនៃសេចក្តីចំរើនរបស់ច្បាប់ ទុកជាប្រជាជនមានជាតិ ទីទំនៀមប្រពៃណីខុសផ្សេងៗពីគ្នាក៏ដោយ តែត្រង់គោលច្បាប់នោះ រមែងប្រកាន់ទៅតាមទំនងដូចគ្នាទាំងអស់គ្រប់ប្រទេស ឬតាមទំនងដែល ល្មមប្រៀបធៀបគ្នាបាន ៗ ប្រទេសទាំងឡាយដែលបានបញ្ញត្តច្បាប់ ឡើងទៅតាមទំនងវិទ្យាសាស្ត្រសម្រេចហើយ ច្បាប់របស់ប្រទេសនោះៗ រមែងមានលក្ខណៈស្រដៀងៗគ្នាយ៉ាងអស្ចារ្យ ៗ

# ប្រយោជន៍នៃការបង្រៀនប្រវត្តិច្បាប់

៤ — ហេតុជាទីកើតឡើងនៃច្បាប់ គឺកើតមកពីច្បាប់ទំនៀមប្រពៃ-ណីប្រការ ១ ប្រការមួយទៀត កើតមកពីគំនិតយោបល់របស់មនុស្ស ដើម្បីផ្ទេរតាមចំណង់របស់ជំនុំជនដូចបានពោលមកខាងដើមនេះ គឺមាន លក្ខណៈ ២ ប្រការៈ

ក — សេចក្តីបញ្ញត្តិទុកជាស្រមោលរបស់ទំនៀមប្រពៃណី, ប្រវត្តិ របស់ច្បាប់គ្រប់ប្រទេសនីមួយៗទុកជាចំណេះតាមផ្លូវប្រវត្តិសាស្ត្រដែលលះ បង់ពោលមិនបានសម្រាប់ជាតិដែលមានវប្បធម៌ដ៏បរិបូណ៌ ៗ ប្រវត្តិ

សាស្ត្ររបស់ច្បាប់អាចធ្វើឲ្យយើងស្គាល់របៀបបែបផែនផ្សេងៗ របស់ជំនុំជនក្នុងអតីត រួមទាំងសេចក្ដីលូតលាស់ឡើងនៃរបៀបបែបផែនរបស់ជំនុំជន ។ អ្នកប្រាជ្ញខាងវិជ្ជាច្បាប់នេះតោងតែបង្រៀនរហូតដល់ឫសគល់នៃរបៀបបែបផែនផ្សេងៗនៃប្រជុំជនក្នុងបច្ចុប្បន្ននេះ ទើបធ្វើឲ្យសិស្សចូលចិត្តសេចក្ដីច្បាស់លាស់ល្អឡើង ។ តែការបង្រៀនលក្ខណៈវិជ្ជាដែលខ្ញុំជាអ្នកបង្រៀននេះ ត្រឹមតែជាប្រវត្តិនៃច្បាប់សៀមប៉ុណ្ណោះ មុខគួរឲ្យស្ដាយពន់ពេក នៅប្រទេសសៀមនេះអ្នកយកចិត្តទុកដាក់នឹងប្រវត្តិនៃច្បាប់មានចំនួនតិចណាស់ ថែមទាំងការស្រាវជ្រាវរកលក្ខ័ណ្ឌដ៏ពិតប្រាកដនៃច្បាប់សៀមបុរាណក៏ធ្វើបានដោយលំបាកណាស់ផង ទើបជាហេតុធ្វើឲ្យការបង្រៀនប្រវត្តិច្បាប់សៀម មិនមានសេចក្ដីពិស្ដារទូលាយប៉ុន្មានទេ តែមានសង្ឃឹមទុកថា ក្នុងឆ្នាំតៗទៅមុខទៀត ជនជាតិសៀមនឹងយកចិត្តទុកដាក់ខាងប្រវត្តិសាស្ត្រច្បាប់កាន់តែក្រាស់ក្រែលឡើង ទាំងការស្រាវជ្រាវក៏គង់មានឡើងច្រើនដែរ ទើបការបង្រៀនប្រវត្តិច្បាប់សៀមក៏កាន់តែរីកធំឡើងទៀតមិនខាន ។

២- ការសិក្សាប្រវត្តិសាស្ត្រច្បាប់មានប្រយោជន៍ធ្វើឲ្យយើងស្គាល់វិធីផ្សេងៗ ដែលមនុស្សគិតបង្កើតឡើងក្នុងអតីតកាល ដើម្បីកែសម្រួលឧបសគ្គផ្សេងៗ ឬដើម្បីតបស្នងចំណង់ដែលកើតឡើងរឿយៗ របស់

ជំនុំជនក្នុងកាលតមក ៗ យើងបានដឹងហើយថា ការបង្រៀនច្បាប់នេះ មិនមែនគ្រាន់តែអប់រម្យមនុស្សដែលមាននាទីប្រើច្បាប់ដូចជាចៅក្រម ឬ ស្នាក្តីជាដើម ឲ្យចេះដឹងយល់ការច្បាស់លាស់ក្នុងវិធីប្រើច្បាប់ប៉ុណ្ណោះទេ ត្រូវតែអប់រម្យឲ្យមានចំណេះចេះដឹងស្គាល់ដល់ដំឡៃនៃរបៀបជំនុំជន និង ការជួយចាត់ចែងធ្វើរបៀបផ្សេង ៗ របស់ជំនុំជននោះឲ្យកាន់តែបរិបូណ៌ឡើងទៀតផង ហេតុនេះទើបឃើញប្រវត្តិសាស្ត្រច្បាប់នេះ ទុកដូចជាគ្រឿងបន្ថែមដ៏សំខាន់ ទុកជាឃ្លាំងចំណេះនៃអ្នកប្រាជ្ញនីតិសាស្ត្រដ៏ពិតប្រាកដ ៗ ដោយអាស្រ័យប្រវត្តិសាស្ត្រនៃច្បាប់នេះឯង ទើបអ្នកប្រាជ្ញនីតិសាស្ត្រ អាចយល់ដល់គំនិតចំពោះសេចក្តីព្យាយាមរបស់មនុស្សជាន់ដើមក្នុងការរួបរួមចាត់លំដាប់ច្បាប់ចងក្រងជាវិជ្ជាមួយឡើង ទាំងធ្វើឲ្យដឹងបានទៀតថា សេចក្តីព្យាយាមរបស់មនុស្ស ជួនក៏ធ្វើបានសំរេច ជួនក៏មិនសំរេច ៗ អាស្រ័យការសិក្សាទំនងនេះ ទើបធ្វើឲ្យឃើញ ឲ្យយល់សេចក្តីពិត ទាំងខាងល្អ ទាំងខាងអាក្រក់ ៗ មានហេតុការណ៍ប្រការខ្លះ គោងខូចពេលវេលាជាច្រើនសតវត្សរ៍ ទើបសំរេចប្រយោជន៍បរិបូណ៌ក៏មាន ៗ ហេតុការណ៍ដែលកើតឡើងតាមសេចក្តីពិតនេះហើយ ដែលអ្នកប្រាជ្ញនីតិសាស្ត្រគួរទទួលយកមកសិក្សា ដើម្បីញុំាងប្រយោជន៍ឲ្យកើតឡើងដល់ប្រទេសជាតិរបស់ខ្លួន ៗ

៦ – ប្រសិនបើយើងចាប់យកប្រយោជន៍អំពីប្រវត្តិសាស្ត្រនៃច្បាប់

ដូចពោលមកនេះ យើងនឹងឃើញថា ការសិក្សាប្រវត្តិច្បាប់ចំពោះប្រទេសមួយ ៗ មិនអាចឲ្យសំរេចប្រយោជន៍ដូចបំណងបានទេ យើងគោងសិក្សាស្រាវជ្រាវរកប្រវត្តិច្បាប់របស់នានាប្រទេស ដែលសំខាន់ ៗ មកសិក្សាថែមទៀត ប៉ុន្តែសភាពនៃវិជ្ជាច្បាប់ឬនីតិសាស្ត្រក្នុងសព្វថ្ងៃនេះ នៅឆ្ងាយពីចំណង់របស់យើងនៅឡើយ ហើយត្រូវតែយើងប្រមូលយកតែច្បាប់របស់ជំនុំជនដែលសំខាន់ ៗ ណាមួយ ដែលល្បីឈ្មោះក្នុងលោក មកសិក្សាសិន តាមទំនងនេះច្រើនតែរើសយកច្បាប់របស់ប្រទេសរ៉ូម មកសិក្សា សូម្បីប្រទេសដទៃ ៗ ដូចអង់គ្លេស បារាំងសែស អាមេរិក ជប៉ុនទាំងស្រុកក៏និយមសិក្សាច្បាប់រ៉ូមដែរ តអំពីនេះទៅនឹងសំដែងឲ្យឃើញថា ការសិក្សាច្បាប់រ៉ូមមានទម្ងន់ច្រើនជាងគេ ។

## សេចក្តីសង្ខេបអំពីវិជ្ជាច្បាប់របស់ជាតិសំខាន់ ៗ ដែលបង្កើតអារ្យធម៌ឡើងក្នុងលោក ។

៧— ក្រៅអំពីច្បាប់រ៉ូម នៅមានច្បាប់របស់ជនជាតិសំខាន់ ៗ ដទៃទៀត ទាំងមានកំណើតមុនច្បាប់រ៉ូម ទាំងមានល័ក្ខខ័ណ្ឌជាងច្បាប់រ៉ូមទៅទៀតផង ។

**ក្រុងបាប៊ីឡូន** ទីក្រុងរបស់ប្រទេសសាលដេ (Chaldée) ហើយជាទីប្រជុំរួមអារ្យធម៌ជាន់ចាស់បំផុតតំបន់មួយក្នុងលោក ក្នុងរយៈកំណត់

១.៩០០ ឆ្នាំមុនពុទ្ធកាល ។ ក្រុងបាប៊ីឡូនធ្លាប់មានច្បាប់ប្រកបដោយ សេចក្ដីចំរើនជាច្រើនមកហើយដូចជាច្បាប់ដែលនិយាយពីខសន្យា ច្បាប់ ពាណិជ្ជទីងការចាត់របៀបក្រឹត៍ ។ យើងបានស្គាល់ច្បាប់អស់នេះ ដោយច្រើនបានមកអំពីច្បាប់របស់ហ័មូរ៉ាបៃ (Hammourabè) ដ៏មានកេរ្ដិ៍ ឈ្មោះល្បីល្បាញ ។ ដែលហៅថាច្បាប់ហ័មូរ៉ាបៃនោះ គឺដុំសិលា កំពស់ ២ ម,២៥ មានបាទក្រោមមូលវាស់ដោយជុំវិញ ១ ម,៩០ ដុំថ្ម សិលាចារិកនេះគេបានរកឃើញក្នុងទីក្រុងចាស់នគរស៊ុស (Suse) កាល ព.ស.២.៤៤៥ ដុំសិលានេះមានចារិករូបព្រះអាទិត្យ ដែលអ្នកក្រុងបា-ប៊ីឡូនជឿប្រកាន់ថាជាព្រះនៃយុត្តិធម៌កំពុងមានព្រះឱង្ការ ដល់ស្ដេច នៃក្រុងបាប៊ីឡូនអំពី «បញ្ញត្តិនៃយុត្តិធម៌» មានបទបញ្ញត្តិឆ្លាក់ដោយ ជុំវិញដុំសិលានោះ ។ បុរាណវត្ថុនេះចាប់ធ្វើឡើងក្នុងរវាងឆ្នាំទី ៤០ ដល់ ៤៣ នៃរជ្ជកាលព្រះបាទហ័មូរ៉ាបៃ ដ៏ជាក្សត្រសំខាន់នៃក្រុងបាប៊ីឡូន ពោលគឺក្នុងរវាងឆ្នាំ១.៩៤០មុនពុទ្ធសករាជ គួរកត់ថាជាល័ក្ខខ័ណ្ឌនៃច្បាប់ ចាស់បំផុតដែលយើងបានដឹងមក ដុំសិលាចារិកដែលមាននៅក្នុងសព្វថ្ងៃ នេះ ល្មមយើងមើលបទបញ្ញត្តិដែលចារិកទុកនោះបាន ២៩០ មាត្រា គិតរួមជាបន្ទាត់ប្រមាណ ៣.៦០០ បន្ទាត់ ។ បទបញ្ញត្តិក្នុងមាត្រាផ្សេងៗ ទាំងនេះ មានបញ្ញត្តិអំពីលក្ខណៈផ្សេងៗ រៀងលំដាប់គ្នាដូច្នេះ គឺការធ្វើ ស្នេហ៍អប្បទេស - ទីងធ្វើសាបធ្នប់ - ការដេរបន្ទាល់សាក្សី - ការសូកបន្ទាល់

សាក្សី - ការលើកលែងពាក្យដំនុំដំរះ - ការលួចទ្រព្យមានលក្ខណៈផ្សេងៗគ្នា - ឋានៈនឹងនាទីរបស់ពួកខ្ញុំរាជការ - ការដាំដំណាំ - ការបង់ការ សញ្ញាខាងជំនួញ - ការបំណាយសុកទឹងមេរ៉ៃ - បំណុលនិងវិធីបង្គាប់ឲ្យសងបំណុល - សញ្ញាផ្ញើទ្រព្យសម្បត្តិ - គ្រួសារ - ការប្រទូសរ៉ាយកងកាយ ជាងធ្វើការកសាងនឹងអ្នកធ្វើទូក - សត្វខ្ញុំប្រុស - ស្រីនឹងគ្រឿងកសិកម្ម - តាមដែលថ្លែងមកនេះឃើញបានថា គួបទបញ្ញត្តិដែលចារឹកទុកនឹងសិលាចារឹកនេះ មិនមែនមានលក្ខណៈជាទីប្រមូលច្បាប់តាមដែលយើងប្រុលចិត្តក្នុងវេលានេះទេ ពោលគឺមិនមែនប្រមូលច្បាប់របស់ប្រទេសសាលដែរមានរបៀបរៀបរយឡើងទេ គ្រាន់តែប្រមូលពាក្យវិនិច្ឆ័យរបស់ក្សត្រនិងព្រះរាជប្រ-កាសរឿងផ្សេងៗ សុទ្ធតែមានលក្ខណៈប្លែកៗគ្នាជាច្រើនយ៉ាងយកមកបង្ក្រងប្រមូលរៀបរៀងឡើងប៉ុណ្ណោះ ទាំងមានសេចក្ដីបញ្ញត្តិដាច់ៗដោយដុំៗមិនជាប់គ្នាឡើយ ។ ក្រៅអំពីនេះនៅមានឯកសារសំដែងឲ្យស្គាល់វិធីប្រតិបត្តិកិច្ចការផ្សេងៗទៀតជាច្រើន សំដែងឲ្យឃើញសេចក្ដីប្រែប្រួលរៀងៗរហូតមកជារយៈវេលាជាច្រើនសតវត្សរ៍ ។ យើងនៅមានក្បួនច្បាប់ប្រពៃណីរបស់ជនជាតិអស្សិរី ដែលគេបានប្រមូលទុកក្នុងរវាងឆ្នាំ ៨៥០ និងឆ្នាំ ៦៥០ មុនពុទ្ធកាល តាមចរិតប្រពៃណីអស់នេះមិនបានសំដែងឲ្យឃើញសេចក្ដីចំរើនកើនឡើងនៃបទបញ្ញត្តិអ្វីឡើយ តែត្រឡប់បែរជាបញ្ញត្តិក្នុងសម័យក្រោយតមកមានសេចក្ដីចំរើនតិចជាងបទបញ្ញត្តិជាន់ដើមទៅវិញ ។

(មានតទៅទៀត)



៥ — អំពីការព្យាករណ៍ ៖

អាល្បែរម៉ាលេត៍ ដែលជាអ្នកប្រាជ្ញពង្សាវតាររបស់បារាំងសេសមួយ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ៗ ហេតុនេះ យើងសូមអរគុណលោកអ្នកប្រាជ្ញពង្សាវតារទាំងពីរនាក់ដ៏ពន្ទឹក ដែលយើងបានពឹងពាក់អាស្រ័យសតិបញ្ញារបស់លោក ក្នុងការរៀបរៀងប្រវត្តិសាស្ត្រសកលលោកឡើងនេះ ៗ

ញ៉ុក - ថែម
អ្នកតែងសេចក្តីនៅមន្ទីរព្រះរាជបណ្ណាល័យបេ
កម្ពុជា ក្រុងភ្នំពេញ
ថ្ងៃ ១ ណោវែមប្រ៏ ១៩៣៩

ពង្សាវតារប្រទេសអេស៊ីប្ត៍

# មហា ញ៉ុក-ថែម

ប្រែចេញពីប្រវត្តិសាស្ត្រសាកល

របស់ហ្លួងវិចិត្រវាទការ រដ្ឋមន្ត្រី នៃប្រទេសថៃ

(តនឹងចប់)

ពួកអ្នកចម្បាំងតាំងជាក្រុមកងនៅក្នុងកន្លែងដែលស្តេចកំណត់ព្រះរាជទាន ហើយតែងទៅប្រជុំឲ្យព្រមគ្នាតាមកំណត់ណាត់ បើមិនមកនឹងមានទោសត្រូវរឹបជាន់ទ្រព្យសម្បត្តិ កូនចៅរបស់អ្នកចម្បាំង ត្រូវតែបានទទួលការសិក្សាខាងចម្បាំងដែរ ។ តាមធម្មតាមានកងទ័ពធំមានច្រើនតែទាហានថ្មើរជើង បែងចេញជាកងទ័ពតូចពីរកងទ័ព កងទ័ពមួយ ប្រើលំពែងនឹងពូថៅជាអាវុធ កងទ័ពមួយទៀតប្រើធ្នូនឹងកាំបិតជាអាវុធ ពាក់អាវក្រោះ កាន់ខែល តមកដល់កងទ័ពរទេះ ។ លោកហេរ៉ូដូទុស អ្នកប្រាជ្ញជាតិក្រិកពោលថា ទាហានអេស៊ីប្តមានចំនួនច្រើនជាង៤០១.០០០ នាក់ តែមិនមានល្បីថាជាអ្នកខ្លាំងពូកែយ៉ាងណាទេ ដោយហេតុជនជាតិអេស៊ីប្តមិនមាននិស្ស័យជាអ្នកចម្បាំង ស្តេចអេស៊ីប្តក្នុងសម័យក្រោយ ៗ មក តោងទៅជួលទាហានផ្សេងជាតិមកបន្ថែមជាជំនួយផង ។

ពួកអ្នកជំនួញជាតិអេស៊ីប្តមានទំនង ប្រហែលនឹងអ្នកជំនួញដែលនៅបូព៌ាប្រទេសក្នុងសម័យនេះដែរ គឺតាំងកនប្តៀមតូច ៗ ហើយលក់ដូររបស់ដែលធ្វើកើតខ្លួនឯង ជំនួញដែលល្បីឈ្មោះជាបំផុតនោះ គឺគ្រឿងកែវ ពេជ្រ, ត្បូង, សំពត់នឹងស្បែក ។

ពួកកម្មករទទួលធ្វើការងារគ្រប់យ៉ាង ស្រេចតែស្វែងរកបាន តាំងជាសមាគមរួបរួមពួកក្រុមដែលធ្វើការមានប្រភេទដូចគ្នា តាមដែលបាន

សង្កេតឃើញរូបគំនូរនោះ មនុស្សពួកនេះក្នុងវេលាធ្វើការងារស្លៀកសំ-ពត់បែបសំពត់ក្រមា ហើយច្រើនរួមគ្នាធ្វើការច្រើនៗនាក់ នៅក្រោមក្បឃុំ ឬអ្នកត្រួតត្រាម្នាក់ មានដៃកាន់ដំបង ក្នុងឈ្នួលអស់នេះបានអាហារ ទទួលបានទាំងគ្រឿងស្លៀកពាក់ជាថ្លៃឈ្នួល ឯពួកដែលធ្វើការកប់សព គេប្រកាន់ថាជាពួកមិនស្អាត ទើបគេចាត់ជាពួកមួយដោយឡែក ឲ្យទៅនៅខាងក្រៅស្រុក ។

ពួកអ្នកស្រែតែងច្រូតស្រូវដោយកណ្ដៀវខ្លីៗ ស្ទាត់ជំនាញខាងការទប់ទឹក ទាំងវិធីស្រោចដំណាំ ៗ តាមរូបដែលគេសូនឡើងទាំងរូបគំនូរ ដែលមើលឃើញវេលានេះឃើញថា ពួកនេះមិនសូវព្រមបង់កាស៊ីងាយៗទេ ទាល់តែចៅភ្នាក់ងារយកឈើគាបក៏មាន ។

នៅប្រទេសអេស៊ីប្ដិ៍គ្រានោះ មានមនុស្សមួយពួកទៀតមានលក្ខណៈប្លែកពីមនុស្សពួកដទៃៗ មានគេជឿស្ដាប់ពួកនេះច្រើន គឺពួកស្មៀនៗនេះជាពួកអ្នករៀនសូត្រ ចេះមើលអក្សរបាន សរសេរកើត ហើយចេះធ្វើបញ្ជី មាននាទីជាអ្នកទារយកពន្ធកាស៊ីផ្សេងៗ ជាអ្នករក្សាឃ្លាំងជំនួញ ជាអ្នកកេណ្ឌមនុស្សធ្វើទាហាន ទាំងបែកគ្រឿងអាវុធ ក្រៅពីកិច្ចការរបស់រដ្ឋ-បាល ពួកស្មៀននៅធ្វើការនឹងអ្នកមានម្នាក់ៗក៏មាន ពួកនេះមាននៅស្មើរតែគ្រប់កន្លែង ក្នុងហាងលក់ទំនិញ, កេងស្រែ ឬក្នុងព្រះរាជវាំង

ស្ដេច ។ វេលាពួកនេះទៅណាមកណា មានពួកនៃក្រំ (ឬទ័ក្រុប) កាន់ជាងស្នោតជាអាវុធដើរតាមទៅផង សម្រាប់ធ្វើការតាមបង្គាប់ ។ ពួកនេះច្រើនតែក្អេងក្អាងប្រកាន់ថា មិនមានអ្នកណាប្រៀបផ្ទឹមស្មើនឹងខ្លួន មើលទៅអ្នកដទៃហាក់ដូចជាមានសក្តិយសតូចជាងខ្លួនទាំងអស់ និយាយបំអកពួកជាងដែកថា នៅផ្ទាលមុខតែនឹងភ្លើង បំអកពួកជាងថ្នាក់ថ្មថា គិតតែងប់មុខតាំងពីព្រលឹមទល់ព្រលប់ទាល់តែបាក់ខ្នងកោងកូក់ បំអកឲ្យពួកជាងកោរពុកមាត់ថា ដើរសុំទានតាមផ្ទះនេះផ្ទះនោះ (ពួកជាងកោរពុកមាត់ដើរស៊ីឈ្នួលកោរតាមផ្ទះគេ មិនមានតាំងរានកោរកាត់ដូចស្រុកយើងទេ) បំអន់ពួកជាងជ្រលក់សំពត់ថា ពួកនេះដៃស្អុយដូចត្រីស្អុយ ដៀលពួកជាងដេរថា ពួកនេះរកស៊ីដូចត្រីខ្លាក់ ។

តាមសេចក្ដីដែលពោលមកនេះ មានលក្ខណៈដូចជាតិចិន គឺព្រមបោះបង់ទ្រព្យសម្បត្តិជាច្រើន ដើម្បីឲ្យកូនខ្លួនប្រឡងប្រណាំងប្រជែងដំណែងស្មៀនឲ្យតែខាងបាន ។

ព្រះរាជាធិបតីនោះ គេតែងគោរពកប់អានថា ទ្រង់ជាព្រះឱរសរបស់ព្រះជាម្ចាស់ផ្សេងៗ ជនជាតិអេស៊ីប្តទើបគោរពព្រះរាជាធិបតី ដូចជាព្រះជាម្ចាស់លើស្ថានសួគ៌ដែរ អនុស្សាវរីយ៍សម្រាប់ក្សត្រនោះ គេធ្វើជារូបសិង្ហ មុខជាមុខមនុស្ស ជាគ្រឿងសំគាល់កំលាំងខ្លាំងពូកែនឹងសេចក្ដីឆ្លៀវឆ្លាស ។

រូបចម្លាក់ផ្សេងៗដែលមានតមកក្នុងសម័យនេះ មានសំដែងពីហេតុការណ៍ផ្សេងៗក្នុងរាជសំណាក់អស៊ីប្ដសម័យបុរាណបានយ៉ាងច្បាស់លាស់ គឺយើងអាចបានឃើញព្រះចៅផែនដីគង់ក្នុងព្រះរាជវាំង ហោមរោមដោយមេទាហាននឹងរាជបរិពារជាចំនួនច្រើន មានចៅភ្នាក់ងារបក់រុយ បាំងក្លស់ មនុស្សចាំយាមទ្វារព្រះរាជវាំង មេទាហានឃាម ទាហានរក្សាវាំង ភ្នាក់ងាររក្សាព្រះរាជទ្រព្យ បណ្ណារក្ស ពួកតន្ត្រី ភ្នាក់ងាររក្សាជង្រុកស្រូវនឹងចិញ្ចឹមសត្វ ។ កាលមហាក្សត្រស្ដេចយាងចេញទៅទីតំបន់ណា មានរាជបរិពារហែហមតាមស្ដេច មានភ្នាក់ងារពរព្រះអង្គឡើងគង់លើទីនឹងដែលមានមនុស្សសែង ១២ នាក់ មានមនុស្សចាំបក់ផ្លិតថ្វាយនៅជុំវិញ ។ វេលាប្រពាតតាមផ្លូវទឹកមានទូកព្រះទីនឹង មានគ្រឿងប្រដាប់ប្រដាយ៉ាងល្អប្រពាតទៅតាមដងទន្លេនីល ។

ព្រះចៅផែនដីទ្រង់មានអំណាចដាច់ស្រេច (គឺនៅលើច្បាប់) ព្រោះគេប្រកាន់ថា ព្រះអង្គជាព្រះឱរសរបស់ព្រះអង្គធំ ត្រូវមានអំណាចលើផែនដីនិងជីវិតរបស់ប្រជាជនទូទៅ តែគេនៅក្រោមសណ្ដាប់របស់រាជប្រវេណី ពោលគឺកំណត់ប្រើពេលវេលា និងកំណត់ការងារក្នុង ១ ថ្ងៃ ៗ ស្ដេចគ្រងរាជ្យអេស៊ីប្ដមិនសូវមានក្សត្រដែលខ្ជិលច្រអូសទេ រាល់ៗវេលាព្រឹក ទ្រង់ស្ដេចទៅស្ដាប់សេចក្ដីរាយការណ៍ផ្សេង ៗ ដែលចៅភ្នាក់ងារនាំក្រាបបង្គំទូល ។

បណ្ដាព្រះចៅផែនដីអេស៊ីបទាំងអស់ មានក្សត្រមួយអង្គទ្រង់មានកេរ្តិ៍ឈ្មោះល្បីល្បាញជាងគេ គឺព្រះបាទរ៉ាមសេសទីពីរ ដែលទ្រង់គ្រងរាជសម្បត្តិនៅក្រុងថែប នៅក្នុងរាជ្យចំនួន ៦៧ ឆ្នាំ គួររាប់ថាក្សត្រអង្គនេះជាក្សត្រដែលម៉ត់ចត់បំផុត ក្នុងពួកក្សត្រទាំងអស់របស់អេស៊ីប ក្សត្រអង្គនេះព្រះអង្គជាក្សត្រសឹក ជាអ្នកគ្រប់គ្រង ជាអ្នកកសាង ព្រះអង្គធ្លាប់លើកកងទ័ពទៅច្បាំងដល់ស្រុកស៊ីរីនិងអេធ្យូពី ហើយទ្រង់បានចាត់ការសាងវិហារធំ ៗ ជាច្រើនអន្លើ ៗ ព្រះបាទរ៉ាមសេសនេះមានមនុស្សស្រឡាញ់រាប់អានជាចំនួនច្រើនណាស់ ទើបមានពាក្យពោលសរសើរព្រះអង្គហួសពីសេចក្តីពិតទៅខ្លះក៏មាន ដូចមន្ទីរឬអនុស្សាវរីយ៍ផ្សេង ៗ ដែលព្រះអង្គគ្រាន់តែជួសជុលប៉ុណ្ណោះ អ្នកដែលធ្វើការជួសជុលក៏លុបឈ្មោះអ្នកធ្វើដើមចេញ ហើយចុះព្រះនាមព្រះបាទរ៉ាមសេសជាអ្នកកសាងវិញ ៗ

សឹកសង្គ្រាមនោះ ប្រទេសអេស៊ីបតែងតែតាំងទទួលជាដកប មានតែក្សត្រវង្សធូម៉ាស និងរ៉ាមសេស ដែលទ្រង់គ្រងរាជ្យនៅក្រុងថែបប៉ុណ្ណោះ មានកំឡាំងធ្វើសឹកសង្គ្រាមដល់ទៅ ២ ផ្លូវ ជួនកាលលើកទ័ពច្រាសទឹកទន្លេនីលឡើងទៅធ្វើការប្រាបប្រាម ពួកនៃគ្រ ជួនកាលឆ្លងទៅខាងតំបន់ព្រែកស៊ូអេស ចូលទៅតាមស្រុកប៉ាលេស្ទីន និងស្រុកស៊ីរី

ឬចុះទៅខាងស្រុកអារ៉ាប និងក្នុងស៊ីណាអ៊ី ចូលទៅតស៊ូនឹងពួកដែលនៅសមុទ្រខ្សាច់ និងពួកចោរសមុទ្រទៅសមុទ្រមេឌីទែរ៉ាណេ ពួកដែលចាញ់ក៏ត្រូវនៅជាចំណុះ ពួកឈ្លើយនៃក្រ ឬឈ្លើយជាតិឯទៀតនៅអាស៊ី ក៏ត្រូវប្រើឲ្យធ្វើការកសាង ស្ដេចជាម្ចាស់ផែនដីអេស៊ីប្ដ៍ ច្រើនតែទ្រង់យកទាហានដែលព្រះអង្គចាប់បានមកនោះបញ្ចូលក្នុងកងទ័ពរបស់ព្រះអង្គ ។

ការគ្រប់គ្រងប្រទេសអេស៊ីប្ដ៍ ចែកចេញជាខេត្ត ៗ និមួយ ៗ មានចៅហ្វាយខេត្ត ១ ដែលស្ដេចអេស៊ីប្ដ៍ទ្រង់រើសតាំងឡើងឲ្យទៅនៅគ្រប់គ្រង ហើយស្ដេចចេញទៅប្រពាតគ្រប់ៗស្រុក ទ្រង់ចេញច្បាប់ ទ្រង់ប្រទានយុត្តិធម៌ ទ្រង់ឲ្យប្រជាជនធ្វើការងារជាសាធារណប្រយោជន៍ ទ្រង់ធ្វើនឹងជួសជុលទំនុកបំរុងទំនប់ទឹកព្រែក និងធ្វើកិច្ចដ៏សំខាន់ គឺកសាងជាវត្តជាគ្រឿងប្រដាប់កិត្តិយស ហេតុនេះក្នុងរាជ្យស្ដេចមួយអង្គ ៗ ទើបមានជាវត្តនីមួយ ៗ ដែលទ្រង់កសាងឡើង ដើម្បីជាគ្រឿងប្រដាប់ព្រះកិត្តិយសរបស់ព្រះអង្គ ហើយជាប្រយោជន៍ដល់ប្រជាជនជាតិរបស់ព្រះអង្គផង ដូចជាព្រះបាទមេណេស ទ្រង់កសាងទំនប់នៅស្រុក ម៉មហ្វិស ព្រះបាទអាមេនេម៉ុត ទ្រង់បានជីកទន្លេសាបមេរិស ហើយព្រះបាទនេកោ ទ្រង់បានជីកព្រែកចេញពីទន្លេនិលទៅធ្លុះដល់មុទ្រក្រហម ព្រះបាទរ៉ាមសេសទី ២ ទ្រង់បានកសាងវិហារ លុក្សរនិងអិបស៊ីម្ប៊ុល ។

ដំបូងការទុកព្រះសពរបស់ស្ដេចជាម្ចាស់ផែនដី គេច្រើនដឹក ៗ មង្គ ចូលទៅក្នុងក្ដំ ហើយតាក់តែងខាងក្នុងឲ្យមានរបៀបរៀបរយល្អមើល លុះមកដល់សម័យស្រុកម៉មហ្វិសជាទីក្រុង ទើបកើតគំនិតគិតកសាងពីរ៉ា-មិតឡើង ពីរ៉ាមិតគឺចេតិយមានសណ្ឋាន ៤ ជ្រុង មានកំពូលស្រួច ពីរ៉ាមិតមានច្រើនអន្លើ នៅកន្លែងកប់ព្រះសពស្ដេចមួយអង្គគេក៏កសាងពីរ៉ាមិតមួយទុក ៗ មានពីរ៉ាមិត ៣ ដែលមានខ្នាតធំសំបើមគួរអស្ចារ្យ សាងឡើងក្នុងសម័យវង្សទី ៤ នៃក្សត្រអេស៊ីប្ដ ដែលធំជាងគេបង្អស់នោះមានកំពស់ ១៤៤ ម៉ែត្រ ប្រើសុទ្ធថ្មពណ៌ស ចាត់ចែងយ៉ាងផ្ចិតផ្ចង់ មិនបាច់ប្រើស៊ីម៉ង់ត៍ឡើយ ថ្មដែលប្រើក្នុងការកសាងនេះ ជនជាតិអេស៊ីប្ដទៅនាំយកមកពីអណ្ដូងថ្ម នៅដងក្នុងអារប៊ិក ៗ នៅខាងក្នុងពីរ៉ាមិតអស់នេះមានផ្លូវដើរនឹងបន្ទប់ផ្សេងៗ ជាច្រើន មានរឿងដំណាលថា ពីរ៉ាមិតដែលធំបំផុតនោះ គេបានប្រើកំឡាំងមនុស្សធ្វើដល់ ១ សែននាក់ អស់ពេលធ្វើ ២០ ឆ្នាំ ទើបហើយស្រេច ៗ

វិធីសរសេរអក្សររបស់ជាតិអេស៊ីប្ដនោះ ចែកចេញជា ៣ ចំណែកគឺ ក្នុងសម័យដំបូង តាំងពីបុរាណកាលមកគេសរសេរជារូបមនុស្ស, សត្វស្លាប, ផ្អក ជំនួសពាក្យនិយាយ ដូចជាគូររូបមនុស្សយកដៃចង្អុលត្រង់មាត់ ប្រែថា "ឃ្លាន" ដូច្នេះជាដើម វិធីសរសេរបែបនេះ សរសេរមិនបាន

ច្រើនមាត់ទេ ហើយបើជាអសាធារណនាមជនមិនមានវិធីសរសេរបាន ឡើយ តមកជនជាតិអេស៊ីព្ទចេះប្រើរូបផ្សេងៗមកកែប្រែជាគ្រឿងសំគាល់ ជំនួសតួអក្សរឲ្យត្រឹមល្មមនឹងសំដីនិយាយ មានរូបប្រើជំនួសពាក្យនិយាយ ប្រមាណ ៦០០រូប នេះរាប់ថាជាសម័យទី ២ ក្នុងសម័យនេះមានការធ្លាក់ ចារិកសេចក្ដីបានច្បាស់លាស់ សរសេរឈ្មោះមនុស្សក៏បាន អក្សរបែប នេះហើយដែលជួយស្រាវជ្រាវរកពង្សាវតារប្រទេសអេស៊ីព្ទបានច្រើន តែលុះកាលកន្លងមកក្នុងកាលមុនពុទ្ធសករាជប្រហែល១០០០ឆ្នាំ ជនជាតិ អេស៊ីព្ទទើបបញ្ញត្តិតួអក្សរថ្មី មានចំនួន ២៤ តួ ផ្សំគ្នាមើលយកសេចក្ដី បាន ទើបត្រូវរាប់ថាជាសម័យទី ៣ មកដល់សម័យនេះ គួររាប់ថាអក្សរ សាស្ត្ររបស់ជាតិអេស៊ីព្ទ ចំរើនដល់ថ្នាក់បំផុតក្នុងគ្រានោះ តែមានផ្លូវខូច ខាតជាច្រើន គឺកាលបើនាំយកអក្សរថ្មីអស់នេះមកប្រើយូរៗទៅរាប់ទាំង ពាន់ឆ្នាំ មនុស្សដែលមើលអក្សរបែបចាស់បានក៏ស្លាប់អស់ទៅ ពាក្យចារិក ផ្សេងៗ ក៏រកមនុស្សមើលមិនដាច់ អ្នកប្រាជ្ញដែលស្រាវជ្រាវរកពង្សាវ-តារប្រទេសអេស៊ីព្ទក្នុងសម័យក្រោយតមកក៏រាយសេចក្ដីមិនបែក មិនអាច ត្រូវរកឲ្យបានជ្រៅទៅទៀត រហូតមកដល់ពុទ្ធសករាជ ២៣៦៥ ទើបមាន បុរសកំឡោះជាតិបារាំងសេសម្នាក់ឈ្មោះសម្ប៉ូលីអុង ជាប់ចិត្តស្រ-ឡាញ់ក្នុងលំអរបស់ព្រះនាង គ្លេអូប៉ាត្រ (ប្រវត្តិរបស់នាងគ្លេអូប៉ាត្របាន

ពោលទុក(ត្រង់បញ្ចប់មុនលំដាប់សកកដ) ខំព្យាយាមរៀនមើលរឿងក៉ាវរបស់ព្រះនាងដែលមានរូបអក្សរបែបសម័យទី២ ទាល់តែមើលសេចក្ដីបានដឹងរឿងក៉ាវរបស់ព្រះនាងបាន កប់ជាវេលាច្រើន ក្នុងទីបំផុត អាចមើលព្រះនាមរបស់ព្រះនាងបាន អាស្រ័យបែបអក្សរក្រិកជួយជាកំឡាំងក្នុងការរៀនមើលផង ហើយអានព្រះនាមរបស់ក្សត្រអេស៊ីប្ដ៍មួយអង្គទៀតបាន ទើបប្រែទះកូនសោរបស់អក្សរបែបនេះសម្រេច អាចអានពាក្យឯទៀតៗចេញទៅបាន ត្រាតែបានតែងគម្រាវេយ្យាករណ៍ភាសានេះឡើងបានសម្រេច លោកសម្ប៉ូលីអុងទើបមានកេរ្ដិ៍ឈ្មោះល្បីល្បាញ ថាជាអ្នកអង់អាចរៀនមើលអក្សរបុរាណបានសម្រេច មហាជនជាតិបារាំងសែសប្រកាន់ថាជាមនុស្សសំខាន់ ១ ដល់មកឥឡូវនេះ បានយកឈ្មោះលោកនោះមកតាំងជាឈ្មោះកប៉ាល់ហោះធំសំបើម ១ ដែលដើរទៅមកក្នុងរវាងស្រុកម៉ារ្សី នឹងអាលេក្សង់ដ្រ៍ ។

ក្នុងការសេពគប់នឹងជនជាតិតាងប្រទេស នោះមានទំនងដូចជាចិនដែរ គឺមិនត្រូវការឲ្យជាតិដទៃចូលមកនៅក្នុងស្រុកទេសរបស់ខ្លួន ជនជាតិហ្វីនីសៀនជាជាតិដំបូងដែលចូលទៅតាំងនៅក្នុងស្រុកអេស៊ីប្ដ៍បាន ដោយបានធ្វើការជាទីសព្វព្រះទ័យរបស់ព្រះចៅផែនដីអង្គមួយ ទើបបានទទួលអនុញ្ញាតឲ្យទៅតាំងលក់ដូរបាន តមកមានពួកដទៃទៀត ដូចជា

សិក្សាកាមកថា

សម័យនេះជាសម័យដែលជនជាតិខ្មែរភ្ញាក់គំនិត គិតស្វែងរកចំណេះឲ្យកូនចៅកាន់តែមានច្រើនឡើងៗជាលំដាប់ នៅក្រុងភ្នំពេញសព្វថ្ងៃនេះមានចំនួនកុមារ កុមារីលើសបន្ទុកសាលា រកកន្លែងរៀនពុំបានក៏សឹងមានចំនួនច្រើន ដោយសាលារកកន្លែងអង្គុយគ្មាន ដូចមានសេចក្ដីសាសព្ទក្នុងកាសែតនគរវត្តលេខ .... ខែសេបតម្ប្រ៍ ឆ្នាំ ១៩៣៨ ។

ក្នុងកាសែតប្រមូលសារចុះថ្ងៃទី ៣ ខែឧកតូប្រ៍ ១៩៣៨ ដែលព្រះរាជបណ្ណាល័យបានទទួលនោះ មានសេចក្ដីនិយាយអំពីការសិក្សាថា:

តាមដោយសេចក្ដីពិត មនុស្សចាប់ផ្ដើមការរៀនសូត្រតាំងអំពីថ្ងៃកើតមក ដូចយើងបានឃើញទារកដែលចេះសំឡឹងមើលមុខម្ដាយរបស់ខ្លួន ដើម្បីរៀនមើលលក្ខណៈមុខមាត់ម្ដាយរបស់ខ្លួន ដែលជាអ្នកបីបាច់ព្យាបាលឲ្យទឹកដោះខ្លួនបៅជាដើម ។ មួយវិញទៀត ប្រសិនបើយើងពិនិត្យមើលក្នុងខ្លួនមនុស្សយើងក៏គង់ឃើញច្បាស់ថា មនុស្សយើងមានចិត្តជាគ្រឿងដឹង មានប្រសាទទាំង ៥ ជាគ្រឿងប្រាប់ ប្រសាទប្រាប់មកយ៉ាងណា ចិត្តក៏ដឹងយ៉ាងនោះដែរ ប្រសិនបើចិត្តត្រូវការចង់ដឹងឲ្យច្រើនជាងនេះ ក៏ប្រើប្រសាទពិនិត្យត្រួតត្រាតទៅទៀត ឬយកចំណេះដែលបានមកតាមផ្លូវប្រសាទ (សេចក្ដីចាំ) មកញែកវែកមើលឲ្យជាក់លាក់តទៅទៀត ដែលជាផ្លូវរកចំណេះបានមួយផ្លូវទៀតដែរ ។

ហើយនាំគ្នាចូលទៅនៅជាចំនួនច្រើន ដោយហេតុប្រទេសអេស៊ីបមាន ដីជាតិជាដំណាំមានផលចំរើនជាងដែនដីរបស់ពួកនេះ ការដែលពួ អេស៊ីបបណ្ដោយឲ្យពួកអស់នេះចូលទៅ ព្រោះមិនអាចនឹងកំនឹងទប់ទ ដូចម្ដេចបាន គ្រាន់តែព្យាយាមការពារខាងក្នុង គឺបំបែកពួកតាំងជាតិ ទៅនោះដោយឡែក មិនឲ្យប្រឡូកប្រឡំនឹងស្រុករបស់ខ្លួន ។

ដោយហេតុប្រទេសអេស៊ីបមានដីដ៏ជាតិល្អ ហើយជាតិអេស៊ី មិនមែនជាជាតិទាហាន ទើបធ្វើឲ្យប្រទេសឯទៀតៗកល្លុកល្លុយចូលទ រឿយៗ ទើបប្រទេសអេស៊ីបធ្លាក់ទៅនៅក្នុងអំណាចរបស់អស្ស៊ីរី កាលពី ១៤៨ ឆ្នាំមុនពុទ្ធសករាជ គេមកបានអាស្រ័យកំឡាំងទាហា ឈ្មួលជាតិក្រិក ទើបរួចរបូតពីខ្ញុំគេបានជាង ១០០ ឆ្នាំ ។ ដោយហេ ប្រទេសអេស៊ីបការពារខ្លួនឯងមិនបាន បានជាពង្សវង្សអេស៊ីបផុតរល អស់ទៅកាលពីពុទ្ធសករាជ ១៨ ឆ្នាំ គឺធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃពែរ្ស មកផ្លាស់ប្ដូរគ្នាដូចជាសិ គឺផុតរបូតពីពែរ្សបានទៅក្រិក ហើយបានមក ព កាលពីពុទ្ធសករាជ ៥០៣ តមកទៀតបានទៅអារ៉ាប ហើយផ្លាស់ទៅនៅ ក្នុងអំណាចទួរគី អេស៊ីបនៅក្រោមអំណាចប្រទេសទាំងពីរនេះដរាបម ដល់ព. ស. ២៣៤៨ ទើបជនជាតិឱរុប ដូចជាអង់គ្លេស, បារាំងសែ ដែលព្យាយាមកំចាត់បំផ្លាញអំណាចទួរគីចេញ ទើបជួយជ្រោមជ្រែង

អេស៊ីប្ដក៏តាំងខ្លួនជាឯករាជបានយ៉ាងស្មើរៗ កន្ទះៗ ពេលគឺត្រូវនៅក្នុងការទំនុកបំរុងត្រួតត្រារបស់អង់គ្លេស បាកំងសែស លុះតមកក្នុង ព. ស. ២៤២៤ ទើបអង់គ្លេសចូលទៅធ្វើជាអាណាព្យាបាល.ពញទី ៗ លុះតមកដល់ ព. ស. ២៤៦៤ នេះឯង ទើបពួកអេស៊ីប្ដ តាំងបះបោរបលាបលឡើង អង់គ្លេសក៏ដកដៃបណ្ដោយឲ្យអេស៊ីប្ដមានឥស្សរភាព តែមិនទាន់បានឥស្សរភាពពេញលេញទេ ព្រោះនៅមានមន្ត្រីអង់គ្លេសខ្លះត្រួតត្រានៅឡើយ ។

ការសិក្សាពង្សាវតារប្រទេសអេស៊ីប្ដនេះមានរឿង ១ ដែលយើងមិនគួរវៀរចោល គឺរឿងព្រះនាងគ្លេអូប៉ាត្រ ។

ពាក្យថា "គ្លេអូប៉ាត្រ"នេះ ជាព្រះនាមរបស់ក្សត្រីជាតិអេស៊ីប្ដច្រើនអង្គ តែអង្គដែលល្បីល្បាញជាងគេនោះ គឺក្សត្រីដែលប្រសូតក្នុង ព. ស. ៤៧៤ ជាព្រះរាជធិតារបស់ព្រះបាទប៉ះតូលេមីអូលេទិស ក្នុងរាជវង្សដែលបានធ្វើជានាយទៅហ្វាយធំក្នុងប្រទេសអេស៊ីប្ដ ក្នុងសម័យក្រោយស្ដេចអាលេក្សង់ដ្រឹមហារាជ ។ ព្រះជនកក្ស័យព្រះជន្មទៅកាលព្រះនាងមានព្រះជន្មាយុបាន១៧ឆ្នាំ ព្រះនាងជារជ្ជទាយាទរួមជាមួយនឹងព្រះអនុជា តាមទំនៀម ព្រះនាងគោងអភិសេករួមជាមួយនឹងព្រះអនុជា ។ (ខត្តិយប្រវេណីរបស់អេស៊ីប្ដ គោងតែអភិសេកសមរស (អាពាហ៍ពិពាហ៍)

ជាមួយនឹងព្រះញាតិដែលជំនិត ហើយមានសក្តិយសស្មើគ្នាផង ឯព្រះអង្គម្ចាស់ក្សត្រិយនោះ បើមិនមានព្រះជេដ្ឋា ឬមានតែព្រះជេដ្ឋា មិនត្រូវបានរាជសម្បត្តិ (ព្រះនាងគោងអភិសេកនឹងព្រះអនុជា ដែលត្រូវបានរាជសម្បត្តិ) តមកមិនយូរប៉ុន្មាន មានព្រះជេដ្ឋាមួយអង្គរបស់ព្រះនាងមកដណ្តើមយករាជសម្បត្តិទៅបាន ទើបព្រះនាងរត់ទៅប្រថាប់នៅប្រទេសស៊ីរី ដើម្បីប្រុងប្រៀបរៀបកងទ័ពទៅដណ្តើមយករាជសម្បត្តិមកវិញ ក្នុងរវាងនេះ យុលិយុស សេសារ៍ មហាបុរសរបស់ក្រុងរោម កំពុងរកទាស់ទែងនឹងប៉ុមប៉ី (មើលត្រង់រឿងកាលពីក្រុងរោម) ហើយប៉ុមប៉ីចាញ់ រត់ទៅនៅប្រទេសអេស៊ីប្ត សេសារ៍ក៏ដេញតាមទៅទៀត ហើយតាំងខ្លួនធ្វើជាតុលាការជម្រះក្តី រឿងដណ្តើមរាជសម្បត្តិគ្នា រវាងព្រះជេដ្ឋានឹងព្រះនាងក្លេអូប៉ាត្រ ព្រះនាងទ្រង់បានប្រឡោមលួងសេសារ៍ ត្រាតែវង្វេងកាន់តាំង ហើយចូលដៃនឹងព្រះនាង ទាល់តែដល់ទៅសេសារ៍សំឡាប់ព្រះជេដ្ឋារបស់ព្រះនាងក្លេអូប៉ាត្របង់ទៅ ហើយតាំងព្រះនាងជាព្រះរាជិនីរួមជាមួយនឹងព្រះអនុជា ដែលបានរៀបអភិសេកត្រឹមត្រូវតាមខត្តិយប្រវេណី តមកព្រះនាងក្លេអូប៉ាត្រនឹងសេសារ៍កាន់តែស្និទ្ធស្នាលនឹងគ្នាច្រើនឡើង ទៅមកកាន់គ្នាជានិច្ច ទាល់តែមនុស្សទាំងពួងដឹងឮសុសសាយ ៗ កាលសេសារ៍ត្រឡប់ទៅក្រុងរោម ព្រះនាងក៏ជាប់តាមទៅផង

ឯព្រះអនុជាជារាជស្វាមីក៏តាមទៅជាមួយផងដែរ តែអំណើះតមកព្រះនាងបានដាក់ថ្នាំបំពុលសំឡាប់ព្រះអនុជាជាព្រះស្វាមីនោះចេញ ដើម្បីមិនឲ្យមកទទឹងទាស់ ក្នុងការដែលព្រះនាងទៅមកសេពសមាគមនឹងសេសារ៍ ៗ រឿងសេសារ៍នឹងព្រះនាងក្លេអូប៉ាត្រនេះ ទៅជារឿងមុខគួរអាម៉ាស់បំផុតនៅក្រុងរ៉ូម លុះតមកមានគេសំឡាប់សេសារ៍ (មើលរឿងត្រង់ដែលនិយាយពីរ៉ូម) ពួកក្រុងរ៉ូមក៏នាំគ្នាស្អប់ខ្ពើមព្រះនាងក្លេអូប៉ាត្រ ទើបព្រះនាងតោងត្រឡប់ទៅប្រទេសអេស៊ីប្ត ៗ តមកព្រះនាងបានប្រគល់ខ្លួនដល់ម៉ារកអែនតូនី នៅរួមគ្នាអស់កាលយូរ កាលម៉ារកអែនតូនីច្បាំងចាញ់អកតាវ្យុសហើយ ព្រះនាងក៏ត្រឡាស់ព្រះទ័យមកស្រឡាញ់អកតាវ្យុស ៗ ទើបប្រើព្រះនាងឲ្យសំឡាប់អែនតូនីស្វាមីរបស់ព្រះនាងចេញ វិធីដែលព្រះនាងសំឡាប់អែនតូនីនោះ គឺបញ្ឆោតឲ្យអែនតូនីចូលទៅក្នុងវិហារ ប្រាប់អែនតូនីថា ឥឡូវនេះយើងទាំងពីរនេះអស់បុណ្យវាសនាហើយ ចូរមកផឹកថ្នាំពិសឱ្យស្លាប់ទៅជាមួយគ្នាចុះ ៗ អែនតូនីក៏ជឿហើយផឹកចូលទៅមុនអនិច្ចកម្មទៅ ទើបព្រះនាងមកជួបនឹងអកតាវ្យុសវិញ តែអកតាវ្យុសមិនចូលដៃនឹងព្រះនាង ៗអន់ព្រះទ័យខ្លាំងណាស់ ទើបទ្រង់ផ្តាច់ព្រះជន្មឲ្យក្ស័យទៅ ៗ មានសេចក្តីដំណាលថា វិធីផ្តាច់ព្រះជន្មនោះ ព្រះនាងទ្រង់រើសរកវិធីច្រើនយ៉ាង តើស្លាប់ដោយវិធីណាទើប

ស្រួលបំផុត ព្រះនាងឲ្យចាប់យកមនុស្សមកសម្លាប់ចំពោះមុខនាងជាច្រើននាក់ ដោយវិធីផ្សេងៗគ្នា ដូចជាឲ្យផឹកថ្នាំពុល, ច្របាច់ក, កាត់ក ។ល។ តែក្នុងទីបំផុតទ្រង់យល់ថា ឲ្យពស់ចឹកស្លាប់ជាវិធីដែលសប្បាយបំផុត ទើបទ្រង់រើសយកវិធីនេះ ហើយក្ស័យព្រះជន្មកាលពីអាយុបាន ៣៩ ឆ្នាំ រាជវង្សប៉ះតូលេមី ក៏ផុតរលត់ទៅត្រឹមណោះឯង ។ ក្រៅពីលំអកនិងនឹងជាគ្រឿងចាប់ចិត្តហើយ ព្រះនាងគួរអួតថាត្រូវទ្រង់ចេះប៉ិនប្រសប់ទាំងចេះអក្សរសាស្ត្រយ៉ាងជ្រៅជ្រះ មានសេចក្តីដំណាលថា ព្រះនាងចេះភាសាផ្សេងៗជាច្រើន អាចនិយាយបានដល់ទៅ ៧ ភាសា ទ្រង់មានព្រះរាជឱរសនឹងសេសារម្នាក់ ហើយមានព្រះឱរសនឹងអង់តូនីយុស ៣ នាក់ ។



៤ — អំពីសេចក្ដីសុខសម្រាន្តនៃព្រះពោធិសត្វ ។

## ពុទ្ធប្បវត្តិចិន
(តពីលេខ ៣ មក)

### ៥ — អំពីពាក្យព្យាករណ៍

អសិតតាបសបានពិនិត្យមើលព្រះពោធិសត្វដោយសព្វគ្រប់ហើយ បានព្យាករទុកថា ព្រះរាជកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ មិនខាន ។

### ៦ — អំពីសេចក្ដីសុខសម្រាន្តនៃព្រះពោធិសត្វ

ព្រះពោធិសត្វ ស្ដេចតែងយាងក្រសាលជាមួយនឹងកុមារចំនួន ១០.០០០ នាក់ នឹងកុមារីចំនួន ១០.០៤០ នាក់ សឹងមានដៃកាន់ក្បួនពេជ្របំភ្លឺផ្លូវថ្វាយព្រះអង្គ ។

### ៧ — អំពីការទ្រង់សិក្សាអក្សរសាស្ត្រ

នៅវេលាដែលពួកក្មេងៗផងគ្នារៀនមើលអក្សរ ព្រះពោធិសត្វដ៏ទ្រង់បុទ្ធិ ទ្រង់មានប្រាជ្ញាឈ្លៀសយល់យ៉ាងជ្រៅទូលាយ ទ្រង់អាចសំដែងធម៌បានជាច្រើនប្រការ ។

### ៨ — អំពីការច្រត់ព្រះនង្គ័ល

ក្នុងខណៈនោះ ម្លប់របស់ដើមឈើឯទៀតៗ ងាកជ្រេប្រែស្រមោល

ទៅតាមថ្ងៃអស់ហើយ ប៉ុន្តែម្លប់ដើមជម្ពូព្រឹក្សមិនព្រមឆាកស្រមោល ហោលម្លប់ចេញចាកព្រះកាយព្រះពោធិសត្វឡើយ ៗ

៩ — អំពីការទ្រង់សិក្សាក្បួនពិជ័យសង្គ្រាម

លុះព្រះពោធិសត្វបានទតវិធីក្បួនពិជ័យសង្គ្រាម ដែលគ្រូបានសំដែងដល់ព្រះអង្គ ៗ ទ្រង់មានព្រះបន្ទូលថា ប៉ុណ្ណឹងល្មមហើយ ហើយពួកគ្រូអស់នោះក៏បង្រៀនក្បួនចម្បាំងដល់ពួកកុមារជាបរិវាររបស់ព្រះអង្គតទៅ ៗ

(មានតទៅទៀត)

# ព្រះពុទ្ធសាសនាបាត់ទៅពីប្រទេសឥណ្ឌា ដោយហេតុយ៉ាងណា?

ខេមររង្សី

ប្រែនិងរៀបរៀង

(៩៦ក)



៨ — អំពីការទ្រង់សិក្សាអក្សរសាស្ត្រ ។

ដែលពោលមកនេះល្មមយល់ថា ផលនៃការសិក្សា គឺសេចក្តីចេះដឹង ឯចំណេះចេះដឹងរបស់មនុស្សយើងនេះអ្នកប្រាជ្ញផ្នែកចិត្តវិទ្យាពោលថា ជាវិស័យរបស់មនុស្សយើងដែលមាននៅតាមប្រក្រតីធម្មតា តែការចង់ចេះចង់ដឹងនេះមានមិនស្មើគ្នា គឺអ្នកខ្លះចង់ចេះចង់ដឹងមានកំឡាំងទន់ខ្សោយ អ្នកខ្លះមានការចង់ចេះចង់ដឹងយ៉ាងខ្លាំងក្លា ។ ពោលចំពោះមនុស្សដែលចង់ចេះចង់ដឹងយ៉ាងខ្លាំងប៉ុណ្ណោះ ដែលបានឈ្មោះថា ជាមេសិក្សាមែនៗ ពួកមេសិក្សាមែនៗនេះឯង ជាអ្នកធ្វើគុណប្រយោជន៍យ៉ាងធំក្រៃលែងដល់លោក ត្រាតែលោកសន្មតនាមថាជាមហាបុរស ឬបុរសរត្នក្នុងលោកនេះ ។

ដូចជាមានមនុស្សរាប់ជាចំនួនលាន បានឃើញផ្លែឈើទុំនៅលើដើមហើយជ្រុះចុះមកដល់ដី ក៏យល់ត្រឹមតែថាផ្លែឈើដែលជ្រុះពីមែកមកដល់ដីប៉ុណ្ណោះ ហើយក៏ហួសទៅ គឺស្រេចត្រឹមប៉ុណ្ណឹង មិនគិតស្រាវជ្រាវរកហេតុផលអ្វីទៀត ចំណែកឯលោកសឺរអៃសែកនីវតាន់មិនមែនដូច្នោះទេ កាលបើលោកបានឃើញហើយ ក៏ចង់ចេះចង់ដឹងតទៅទៀតថា ចុះហេតុអ្វីទើបផ្លែឈើជ្រុះ? លោកនេះខំប្រឹងសិក្សាជាច្រើនឆ្នាំទើបបានដឹង ហើយបានចំណេះបន្តិចតទៅទៀត គឺជាច្បាប់ឬគំនិតនៃការយឹតយោងរបស់លោក និងច្បាប់ឬគំនិតនៃការវិលប្រទក្សិណនៃដួងផ្កាយ ។

ដូចជាបុគ្គលសំខាន់ៗ នេះមានចំនួនច្រើន តែបុគ្គលដែលសំខាន់

# ប្រវត្តិលោកមីលរេប៉ៈ

(តពីលេខ ៣ មក)

លោកមីលរេប៉ៈ បានដំណាលប្រវត្តិដ៏ចំឡែករបស់លោកឲ្យសិស្សស្តាប់ហើយសិស្សនោះបានរៀបរៀងចងក្រងទុកជាពាក្យកាព្យ ។

មុនដំបូង លោកដំណាលពីបុព្វបុរសរបស់លោក នឹងជាតិកំណើតរបស់លោក នឹងប្អូនស្រីរបស់លោក គឺតាំងអំពីកាលលោកមានអាយុ ៧ ឆ្នាំ ឪពុកក៏អនិច្ចកម្មទៅ កុមារមីលរេប៉ៈត្រូវទៅនៅនឹងឪពុកធំ ម្តាយធំ ដែលជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិកេរ្តិ៍មត៌ក លុះដល់មីលរេប៉ៈធាត់ធំចំរើនឡើង ឪពុកធំម្តាយធំមិនព្រមចែកកេរ្តិ៍មត៌កនោះឲ្យ ដោយមានហេតុធំកើតឡើង ហើយគេបណ្តេញមីលរេប៉ៈព្រមទាំងម្តាយនឹងប្អូនស្រីឲ្យចេញពីផ្ទះនោះទៅ ។ ខណៈនោះ ម្តាយរបស់កុមារមីលរេប៉ៈបានបញ្ជូនខ្លួនឲ្យទៅនៅរៀនអក្សរនៅសំណាក់គ្រូម្នាក់ ឯប្អូនស្រីត្រូវទៅនៅស៊ីឈ្នួលក្នុងផ្ទះឯទៀត ដើម្បីឲ្យមានអាហារចិញ្ចឹមជីវិតនឹងសំពត់អាវស្លៀកពាក់ ។ តអំពីនោះទៅ មីលរេប៉ៈទៅនៅសំណាក់នឹងលោកឡាមៈ ១ អង្គ (លោកសង្ឃទីបេតាំង) ដើម្បីរៀនអាគមគាថា លុះរៀនមន្ត ១

បានហើយ ទើបនាំយកមន្តនោះទៅសែកផ្លុំដើម្បីបំផ្លាញវង្សត្រកូលរបស់ឪពុកធំ ជាការសងសឹកធ្វើឲ្យអ្នកអស់នោះដឹងច្បាស់ អំពីការសងសឹកទឹងយុត្តិធម៌របស់ខ្លួន ប៉ុន្តែការសងសឹក នេះមិនឲ្យត្រូវទៅលើរូបម្តាយធំទឹងឪពុកធំទេ ។

(នៅមានត)



នេះត្រង់ដែលលោកមិលរេប៉ះ ដំណាលប្រវត្តិដ៏ចំឡែករបស់លោកឲ្យពួកសិស្សស្ដាប់ ។

ឯក្សត្រក្នុងវង្សមៅរ្យៈនេះ មិនមែនមានត្រឹមតែព្រះបាទធម្មាសោក មួយអង្គទេ ដែលទ្រង់ទំនុកបំរុងផ្សាយព្រះពុទ្ធសាសនា សូម្បីក្សត្រអង្គឯទៀតៗ តៗ មកក្នុងវង្សនេះក៏ទ្រង់ទំនុកបំរុងកសាងស្តូប វិហារនៅតំបន់នានាទឹងទ្រង់ឧបត្ថម្ភសង្ឃទូទៅ ។ ក្សត្រអង្គក្រោយបង្អស់ក្នុងវង្សមៅរ្យៈ នោះទ្រង់ព្រះនាមថា ព្រឹហទ្រថ មានអមាត្យជំនិតម្នាក់របស់ទ្រង់ ហៅថា បុស្សមិត្រ លបលួចផ្តាច់ព្រះជន្មៈហើយតមកបានឡើងសោយរាជ្យ បញ្ញត្តតាំងវង្សថ្មីថា សុង្គៈ ក្សត្រអង្គថ្មីនេះផ្លាស់ចិត្តទៅកាន់សាសនាព្រាហ្មណ៍វិញ តាំងខ្លួនជាសត្រូវនឹងពុទ្ធសាសនាផង ។ ក្នុងរជ្ជសម័យនៃក្សត្រនេះ សាសនាព្រាហ្មណ៍ក៏ចំរើនរុងរឿងឡើងជាអនេក ពួកព្រាហ្មណ៍ក៏ខំប្រឹងប្រែងទំនុកបំរុងសាសនារបស់ខ្លួនយ៉ាងមាំមួន ប្រជាជនក៏បែរមុខទៅរកសាសនាព្រាហ្មណ៍ជាច្រើន នាំឲ្យបានសេចក្តីលំបាកដល់ពួកពុទ្ធបរិសទ្យជាច្រើនក្នុងជាន់នោះ ពួកពុទ្ធបរិសទ្យទ្រាំនៅក្នុងទីនោះពុំបាន ក៏នាំគ្នាទៅរកទីកន្លែងឯទៀតខាងក្រៅនគរមគធៈ ។ ពួកនិកាយ អារ្យស្ថវិរវាទ នាំគ្នាលើកទៅតាំងនៅស្រុក សញ្ចី (Sanchi) ពួក វេទិសគិរិ ទឹង សព៌ស្តិវាទ ទៅតាំងនៅតំបន់ ឧត្តរ ក្នុងស្រុកមថុរា (Mathura សព្វថ្ងៃនេះ) ឯនិកាយឯទៀត ៗ ក៏នាំគ្នាទៅតាំងនៅទីដទៃ ៗ ដែរ ។

និកាយ អារ្យស្ថវិរវាទ ជានិកាយចាស់ទុំ ហើយជឿជាក់ក្នុងសាសនាយ៉ាងខ្លាំង ឯនិកាយឯទៀតៗ ក៏កែប្រែគម្ពីររបស់ខ្លួនឲ្យប្រែប្រួលទៅតាមហេតុការណ៍ក្នុងគ្រានោះ ដូចជាពួក សព៌ាស្តិវាទ លុះលើកទៅតាំងនៅក្នុងស្រុកមថុរ៉ា ក៏ផ្លាស់ប្រែព្រះត្រៃបិដកជាភាសាបាលី ទៅជាភាសាសំស្ក្រឹតវិញ ដែលជាភាសាជាទីគោរពរបស់ពួកព្រាហ្មណ៍ ដែលកំពុងមានអំណាចក្នុងគ្រានោះ ប៉ុន្តែពួកអារ្យស្ថវិរវាទ នៅរក្សាថែទាំធម្មវិន័យរបស់ព្រះបរមសាស្តាទុកក្នុងភាសាបាលីដូចដើម ។

ក្រោយដែលមហាអាណាចក្រ មោរ្យៈ ដល់នូវសេចក្តីវិនាសទៅ មានក្សត្រមួយអង្គទ្រង់ព្រះនាម មេណានដេរ (Menander) ឬ មិលិន្ទ ជាក្សត្រជាតិក្រិក ១ អង្គ មកមានអំណាចគ្រប់គ្រងផែនដី ( ស់ណ្ឌូ ) នៅទិសខាងលិចឆៀងខាងជើង ហើយទ្រង់តាំងទីក្រុងនៅសាគលនគរ (Sagala ឥឡូវនេះហៅថា Sialkot) ហើយទ្រង់តាំងឧបរាជឲ្យទៅនៅគ្រប់គ្រងស្រុកឧជ្ជេន (Ujjain) និងស្រុកមថុរ៉ា ដែលទ្រង់វាយយកបាននោះទៀតផង ។ បណ្តាក្សត្រក្រិកអស់នោះ ច្រើនតែទ្រង់កាន់ព្រះពុទ្ធសាសនា ទើបទ្រង់សំឡឹងមើលព្រះពុទ្ធសាសនាក្នុងគ្រានោះ ដោយព្រះទ័យមេត្តាករុណាចំពោះពួកនិកាយ សព៌ាស្តិវាទ នៃស្រុកមថុរ៉ា និងពួកអារ្យស្ថវិរវាទ នៃស្រុកសញ្ចី មានទឹកព្រះទ័យចង់ជួយទំនុកបម្រុងពន់ពេក ។

ឯនគរមថុរ៉ាក្នុងគ្រានោះ មិនមែនគ្រាន់តែជាទីប្រថាប់របស់ឧបកជ ប៉ុណ្ណោះទេ គឺជាស្រុកជាទីប្រជុំការលក់ដូរខាងពាណិជ្ជកម្មរបស់ពួកការ៉ាវ៉ាន (Caravan) ទាំងពួកតូច ទាំងពួកធំ សឹងនាំគ្នាតែងដើរកាត់ស្រុកនេះជានិច្ច មិនសូវដាច់ខាតក្នុងរវាងទិសទក្សិណ, ទិសបូព៌ា, និងនគរតក្កសិលាក្នុងទិសឧត្តរទៀតផង ៗ មួយវិញទៀត ព្រះពុទ្ធសាសនារបស់ពួកនិកាយ សព៌ាស្តិវាទ តាំងនៅជាខ្ជាប់ខ្ជួនក្នុងស្រុកនេះ ដែលជាស្រុកចំរើនដោយផ្លូវជំនួញ ទើបធ្វើឲ្យព្រះពុទ្ធសាសនានិកាយនេះផ្សាយចេញទៅសព្វទិសសព្វផ្លូវដោយងាយ ហើយឆាប់រហ័សផង ៗ

លុះកាលវេលាកន្លងយូរបន្តិចទៅ ពួកនិកាយ សព៌ាស្តិវាទ ដែលបានមកតាំងសំណាក់ថ្មីនៅនគរមថុរ៉ា ក៏កាន់តែបែកជ្រែងចេញទៅបន្តិចៗ អំពីនិកាយ សព៌ាស្តិវាទ ដែលមានឫសគល់ដើមនៅក្នុងនគរមគធៈនោះ កាលបើមានការបែកខ្ញែកចេញជា ២ ពួកដូច្នេះ ពួកដែលមកតាំងនៅនគរមថុរ៉ាទើបសន្មតហៅថា អារ្យៈសព៌ាស្តិវាទ តរៀងៗមក ៗ

លុះក្សត្រក្រិកអស់អំណាចហើយ ទើបមានក្សត្រវង្ស យុចេ (Yuchee) មានអំណាចឡើង ៗ ព្រះបាទ កនិស្កៈ (Kanishka) នៃនគរកុសាណ (Kushan) ជាកដវង្សនេះ ទ្រង់តាំងរាជធានីនៅស្រុកប៉េស្វា (Péshwar) ព្រះអង្គទ្រង់គោរពពុទ្ធសាសននិកាយ សព៌ាស្តិវាទ

លោកអ្នកប្រាជ្ញដែលជាកំពូលពុទ្ធបរិសទ្យក្នុងគ្រានោះ គឺវសុមិត្រ នឹងអស្សឃោស ក៏កើតឡើងក្នុងរជ្ជសម័យនៃក្សត្រអង្គនេះ ។ ដោយសេចក្តីទំនុកបំរុងនៃមហាក្សត្រអង្គនេះ ទើបមហាមុនីទាំង ២ អង្គនេះហៅប្រជុំគណៈសង្ឃដែលមានយោបល់យល់ទាស់គ្នាអំពីពុទ្ធសាសនា សំណាក់គន្ធារៈ (Gandhàra) នឹងសំណាក់ កស្មិរៈ (Kashmira) ឲ្យមកចូលប្រជុំសម្រេចសេចក្តីដាច់ស្រេចតែម្តង ។ ក្នុងការប្រជុំគ្រានេះកើតគម្ពីរ១ថ្មីទៀតសម្រាប់អធិប្បាយព្រះគម្ពីរ ហៅថា វិភាស ហេតុនេះបានជានៅកន្លែងខ្លះគេហៅពួកពុទ្ធបរិសទ្យនិកាយ សព្វាស្តិវាទ ថា វៃភាសិក តាមឈ្មោះគម្ពីរថ្មីនោះ ។

នៅសតវត្សរ៍ទីបួននៃគ្រិស្តសករាជ កាលពួក វៃភាសិក កំពុងមានអំណាចនៅចំណែកទិសខាងជើង ។ លោកនាគារជុន (Nagarajuna) ក៏បានមកចាប់កំណើតកើតឡើងនៅចំណែកទិសខាងត្បូង នៅនគរវិទ្រក (ឥឡូវនេះ គឺ Berar) លោកអ្នកប្រាជ្ញនេះ តមកបានតែងគម្ពីរមួយសំដែងពិសេសផ្សេងៗ នេះហើយបំណោរតមកទៅជាគ្រឿងទំនុកបំរុងនាំឲ្យមានសេចក្តីចំរើនដល់ព្រះពុទ្ធសាសនាប៉ែកខាងមហាយានជាអនេក ។ គម្ពីរប្រាជ្ញាបារមិតាជាគម្ពីរសំខាន់នឹងស័ក្តិសិទ្ធិសម្រាប់ពួកមហាយានប្រហែលនឹងព្រះត្រៃបិដក (របស់ហីនយាន) ដែរ ។

ក្នុងសតវត្សរ៍ទី ៤ នៃគ្រិស្តសករាជ លោកអ្នកប្រាជ្ញឈ្មោះ វសុពន្ធុ

(Vasubandhu) បានតែងគម្ពីរឈ្មោះ អភិធម្មកោស ដែលជាគោលសំខាន់ (Principle) របស់ពួកនិកាយសព្វាស្តិវាទទៀត. គម្ពីរអធិប្បាយសេចក្តី (ភីអដ្ឋកថាដីកា) របស់គម្ពីរនោះលោកក៏បានចាត់បែងតែងទៀតដោយខ្លួនលោកដែរ ។ តែពួកអ្នកសិក្សា តែងពោលថា គម្ពីរនោះនិយាយសេចក្តីខ្ពស់ហួសបំណងយោបល់របស់ពួក សៅត្រន្តិក (Sautrantika) ឯ អសង្គ ជាប្អូនរបស់លោក វសុពន្ធុ ជាអ្នកចាត់របៀបរៀបចំប្រាជ្ញា យោគាចារ (Yogacara) ។

នៅចុងសតវត្សរ៍ទី ៤ នៃគ្រិស្តសករាជ មានគម្ពីរនិយាយពីពុទ្ធប្រាជ្ញាដែលខ្ពស់ៗ មាន ៤ របៀបផ្សេងគ្នា គឺ: សៅត្រន្តិក (Sautrantika) ១ វៃភាសិក (Vaibhàsika) ១ មធ្យមិក (Madhyamika) ១ និងយោគាចារ (Yogâcar) ១ ។ ឯគម្ពីរអធិប្បាយសេចក្តី (commantaire) បរិភាសា (Terminology) និងកលវិធី (Techniques) ផ្សេងៗនៃវិមុត្តិ ប្រាជ្ញានានារបៀបអស់នេះ បានកែប្រែអធិប្បាយសេចក្តីខុសប្លែកចេញទៅពីគម្ពីរដើមជាច្រើន ។

បណ្តាប្រាជ្ញាទាំង៤របៀបដែលមានសេចក្តីប្លែកគ្នាយ៉ាងច្បាស់នោះ គឺនិយាយពីវិធីទៅកាន់វិមុត្តិភាព (Liberation) ពួកសំណាក់ វៃភាសិក និង សៅត្រន្តិក នោះមាន ៣ វិធីគឺ ១- សម្រេចដល់ថ្នាក់ពុទ្ធភូមិ ២- សម្រេចដល់បច្ចេកពុទ្ធភូមិ ៣- សម្រេចជាព្រះអរហន្ត ។ ឯពួក

សំណាក់ មជ្ឈិមៈ និងយោគាចារៈ នោះមានតែវិធីមួយ គឺសម្រេចដល់ថ្នាក់ពុទ្ធភូមិតែម្តង ពួកក្រោយនេះហៅខ្លួនឯងថា មហាយាន ប្រកាន់ថាពួកខ្លួនវិសេសជាង ២ ពួកខាងដើម តាំងសន្មតហៅពួកដើមថា ហីនយាន ដែលប្រែថាមានយានតូចឬថោកទាប ៗ ពួកមហាយាននេះមានសេចក្តីគោរពចំពោះវិធីរបស់ខ្លួនប៉ុណ្ណោះ ហើយនាំគ្នាព្យា-យាមឲ្យបានសម្រេចដល់ថ្នាក់ពុទ្ធភូមិ ពួកនេះព្យាយាមផ្តួលយោបល់របស់អ្នកឯទៀតដែលមិនត្រូវនឹងខ្លួនចេញអស់ ៗ សេចក្តីមេត្តាករុណាមិនមានខែត្រកំណត់ នឹងបញ្ហាដ៏ខ្ពង់ខ្ពស់ដែលជាសេចក្តីត្រាស់ដឹងរបស់ព្រះសម្មា-សម្ពុទ្ធនោះ បានចូលមកគ្របសង្កត់គំនិតយោបល់របស់ពួកនេះយ៉ាងខ្ជាប់ខ្ជួន ដើម្បីសំដែងលំអជាយោបល់របស់គេ ៗ នាំគ្នាតែងព្រះសូត្រថ្មីឡើងទៀតជាច្រើនសូត្រ ដូចជា វៃបុល្យៈ និង រតនកូដ ដើម្បីផ្សាយគំនិតយោបល់ថ្មីនេះ ទើបគេនាំគ្នាចាត់តាំងលទ្ធិមួយឡើងថ្មីទៀត ហៅថាលទ្ធិពោធិសត្វ ក្រៅអំពីនេះគេសន្មតតាំងទេព្តាឡើងទៀតជាច្រើនអង្គមាន អវលោកិតេស្វរៈ អាកាសគ្រភ មញ្ជុស្រី និងឯទៀតៗ ៗ ឯបណ្តាព្រះអរហន្តដូចព្រះមោគ្គល្លាននឹងព្រះសារីបុត្រ ពួកនេះបន្ថយស័ក្តិរបស់លោកចុះមកនៅត្រឹមថ្នាក់ព្រះពោធិសត្វទាំងអស់ ៗ ពួកមហាយាននេះ ត្រូវការឲ្យមនុស្សគ្រប់គ្នាបានសម្រេចដល់ថ្នាក់ពុទ្ធភូមិ ទើបនាំគ្នាតែប្រែសូត្រផ្សេង ៗ ដម្រូវទៅតាមចំណង់របស់ខ្លួនជាច្រើនសូត្រ ៗ

នៅមានត

# គំនូរថ្មីពីរបែបរបស់ព្រះរាជបណ្ណាល័យ

(តនិងចប់)

ឯរូបគំនូរមួយទៀតនោះ យើងអាចមើលឃើញពីរចំណែកៗ ខាងលើ មើលឃើញព្រះពុទ្ធជាម្ចាស់ទ្រង់គង់សំដែងធម្មទេសនា មានព្រះភិក្ខុសង្ឃគង់ស្ដាប់ត្រៀបត្រា គំនូរខាងក្រោម មើលឃើញភិក្ខុទាំងឡាយកំពុងធ្វើកិច្ចវត្តផ្សេងៗគ្នា អង្គខ្លះគក់បោកលាងស្បង់ចីពរ អង្គខ្លះដុតបាត្រ អង្គខ្លះកាត់ក្រចក អង្គខ្លះកោរព្រះកេសា អង្គខ្លះស្រង់ទឹកជម្រះកាយជាដើម ។

កិច្ចវត្តអស់នេះមានសេចក្ដីពិស្ដារក្នុងគម្ពីរចុល្លវគ្គវិនយបិដកភាគ ១០ និង ១១ ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយរួចហើយទាំងបាលីទាំងសម្រាយ ក្នុងទីនេះ យើងមិនបាច់ស្រង់សេចក្ដីយកមកថ្លែងឲ្យសព្វគ្រប់ទេ គ្រាន់តែស្រង់យករឿងខ្លះមកថ្លែង ដើម្បីឲ្យយល់ដំណើរនិងហេតុផលដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តនិងទ្រង់អនុញ្ញាត ។

## ហេតុដែលទ្រង់អនុញ្ញាតឈើស្ទន់

ក្នុងសម័យនោះ ភិក្ខុទាំងឡាយមិនទំពាំឈើស្ទន់ មាត់លោកក៏មានក្លិនស្អុយ ទើបនាំគ្នាក្រាបបង្គំទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិន

ជាន់ឯកនោះ គួរពោលចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដ្បិតកាលមុន
ស្តេចចេញទ្រង់ព្រះផ្នួស ទ្រង់បានទតឃើញមនុស្សកើត-មនុស្សស្លាប់
ហើយទ្រង់មានព្រះបំណងចង់ជ្រាបថា មនុស្សកើតអ្វី? ហេតុអ្វីបានជាមាន
កើតមានស្លាប់? ដោយទ្រង់មានព្រះបំណងយ៉ាងខ្លាំងអំពីហេតុនេះ ទើប
ព្រះអង្គទ្រង់លះបង់សុខសម្បត្តិស្រគ្គារដែលយើងពល់គ្នាតែងជាប់ចិត្តពប់
អានណាស់នេះចោលចេញហើយទ្រង់ព្រះផ្នួស ស្តេចត្រាច់ចារិកទៅកាន់
សំណាក់គ្រូអាចារ្យដែលមានឈ្មោះល្បីល្បាញក្នុងសម័យនោះ ទ្រង់ព្យា-
យាមសិក្សាគ្រប់ៗ សំណាក់ហើយ មិនបានសម្រេចដូចព្រះបំណង ហើយ
ទ្រង់ស្វែងរកដោយព្រះអង្គឯងគ្រប់វិធី ក្នុងទីបំផុតទើបបានជួបប្រទះនឹង
សេចក្តីពិតដែលហៅថាព្រះអង្គបានត្រាស់ គឺទ្រង់ជ្រាបសេចក្តីពិតថា
មនុស្សកើតអ្វី? ហើយទ្រង់ព្រះត្រិះរិះទៅទៀតថា ត្រូវធ្វើដូចម្តេចទើប
បានដល់បរមសុខដែលហៅថានិព្វានបាន ប៉ុន្តែយើងពល់គ្នាមិនអាចដឹង
ដល់កន្លែងនេះទេ ព្រោះមិនអាចនឹងធ្វើសេចក្តីចូលចិត្តបានថា ព្រះនិព្វាន
នេះមានទុជាសេវិសេសជាងស្ថានសួគ៌ដូចម្តេច ដ្បិតក្នុងស្ថានសួគ៌មាន
សេចក្តីដំណាលថា មានទាន់ទេពអប្សររូបរាងឆើតៗ សុទ្ធតែក្រមុំៗ ដូចជា
ក្រមុំព្រហ្មចារីយ៍កប់ឃុពាន់នៅចាំបំរើ ប្រគំនូវតូរ្យតន្ត្រីទិព្វគ្រប់ទិនទិក
ពត្រី មានអាហារឆ្ងាញ់ពិសាទុកជូនបរិភោគមិនចេះខ្វះខាត មិនព្រួយ

ទំពាឈើស្ទននេះមាន ៥ ប្រការ គឺ នាំឲ្យថយកំឡាំងភ្នែក ១ មាត់មានក្លិនស្អុយ ១ សរសៃសម្រាប់នាំរសអាហារមិនបរិសុទ្ធ ១ ប្រមាត់នឹងស្លេស្មរួបរឹតបាយ ១ ភិក្ខុនោះឆាន់ចង្ហាន់មិនឆ្ងាញ់ ១ ៗ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទនមាន ៥ ប្រការ គឺ នាំឲ្យមានកំឡាំងភ្នែក ១ មាត់មិនមានក្លិនស្អុយ ១ សរសៃសម្រាប់នាំរសបរិសុទ្ធ ១ ប្រមាត់នឹងស្លេស្មមិនរួបរឹតបាយ ១ ភិក្ខុនោះឆាន់ចង្ហាន់ឆ្ងាញ់ ១ (ហេតុនេះ) ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន ៗ

## ហេតុដែលទ្រង់ហាមមិនឲ្យទុកសក់វែង

ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទុកសក់វែង មនុស្សទាំងឡាយបានឃើញក៏នាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុអស់នេះទុកសក់វែងដូចពួកគ្រហស្ថអ្នកបរិភោគកាម ៗ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលពាក្យតិះដៀលដូច្នោះ ក៏នាំគ្នាយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ៗ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកសក់វែងទេ ភិក្ខុណាទុកសក់វែង ត្រូវអាបត្តិទុក្កដ ៗ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យទុកសក់កំណត់កាលត្រឹមពីរខែឬកំណត់ត្រឹមពីរធ្នាប់ ៗ

គមកពួកឆព្វគ្គិយភិក្ខុសិតសក់ដោយស្និត សិតសក់ដោយក្រាស ជ្រង សក់ដោយម្រាមដៃ លាបសក់ដោយក្រមួនទឹកប្រេង ។ មនុស្សទាំងឡាយក៏ពោលទោសដូចមុនទៀត ទើបភិក្ខុទាំងឡាយក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសិតសក់ដោយស្និត មិនត្រូវសិតសក់ដោយក្រាស មិនត្រូវជ្រងសក់ដោយដៃធ្វើជាក្រាស មិនត្រូវលាបដោយប្រេងទឹកក្រមួនទេ ភិក្ខុណាសិត (ឬលាប) ត្រូវអាបត្តិទុក្កដ (វិនយបិដកចុល្លវគ្គខ្សែ ១០) ។

## ហេតុដែលទ្រង់ហាមមិនឲ្យទុកក្រចកវែង

មានសេចក្តីដំណាលថា សម័យនោះឯង មានភិក្ខុ ១ រូបទុកក្រចកវែងដើរទៅបិណ្ឌបាត មានស្រីម្នាក់ឃើញលោកនោះហើយនិយាយដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកនិមន្តមកសេពមេថុនធម្ម នឹងខ្ញុំចុះ ។ ភិក្ខុនោះពោលឃាត់ថា នែនាង កុំឡើយ អំពើនេះមិនសមគួរទេ ។ ស្រីនោះនិយាយទៀតថា បពិត្រលោកដ៏ចំរើន បើលោកមិនសេពទេ ខ្ញុំនឹងខ្ញាំក្រចៅខ្លួនខ្ញុំដោយក្រចករបស់ខ្ញុំ ហើយនឹងស្រែកថា ភិក្ខុនេះធ្វើវិប្បការដល់ខ្ញុំ ។ ភិក្ខុនោះក៏និយាយបណ្តោយថា តាមចិត្តនាងចុះ ។ ទើបស្រីនោះខ្ញាំក្រចៅពងកាយខ្លួនដោយក្រចកខ្លួនហើយស្រែកថា ភិក្ខុនេះធ្វើវិប្បការដល់ខ្ញុំ ។ មនុស្សទាំងឡាយក៏ស្ទុះទៅចាប់ភិក្ខុនោះ ហើយបែរជាបាន

ឃើញស្បែកឈាមជាប់នឹងក្រចកស្រីនោះវិញ ទើបយល់ច្បាស់ថា ភិក្ខុនេះមិនបានធ្វើកម្មនេះដល់ស្រីនោះទេ ហើយក៏លែងភិក្ខុនោះទៅ ។ ភិក្ខុនោះលុះត្រឡប់ទៅអារាម ទើបប្រាប់ដំណើរនោះដល់ភិក្ខុផងគ្នា ៗ ភិក្ខុទាំងឡាយក៏សួរថា ម្នាលអាវុសោ ចុះលោកទុកក្រចកវែងឬ ។ ភិក្ខុនោះប្រាប់ថា អើអាវុសោ ។ ភិក្ខុអស់នោះក៏ពោលទោស តិះដៀល បន្ទុះបន្អាប់ថា មិនសមបើភិក្ខុទុកក្រចកវែងសោះ ទើបនាំគ្នាក្រាបបង្គំទូលដំណើរនោះដល់ព្រះដ៏មានព្រះភាគ ៗ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកក្រចកវែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។ (វិនយបិដក ចូឡវគ្គភាគ ១១) ។

តាមរឿងរ៉ាវដែលពណ៌នាមកនេះ ជាសេចក្តីពន្យល់រូបគំនូរថ្មីទាំងពីរបែបដែលព្រះរាជបណ្ណាល័យទើបនឹងបោះពុម្ពផ្សាយនោះ ដើម្បីជាប្រយោជន៍ដល់លោកអ្នកជាវរូបទាំងពីរនោះទៅមើល នឹងបានជ្រាបរឿងរ៉ាវដោយពិស្តារ ដោយសារបានត្រួតត្រាមើលសេចក្តី ដែលបានពណ៌នាមកនេះ ។ ឯគំនូរទាំងពីរបែបនេះជាស្នាដៃរបស់ព្រះលេខានុវត្ត តិក ជាង គំនូររបស់ព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ ។

សេចក្ដីអធិប្បាយរបស់ទេមរង្សី



៨ — អំពីការទ្រង់ច្រត់ព្រះនង្គ័ល ។

# ប្រជុំពាក្យកាព្យ

## ភាគទី ៤

របស់គ្រូកិរម្យ ស៊ួង
ប៊ុមព្រៃ មហាឡិក

◎ ថ្មើរណោះម៉្លេះសំផ្ទុំសុខស្កល់
ឬមួយទ្រង់ខ្វល់ក្នុងវៃយា
ទុក្ខមករៀមដែលឃ្លាតឃ្លា
ជាច្រើនទិវាក្រយង់យល់ ។

ឬមួយក្សាន្តសោះអស់ទឹកនា
កម្មធំក្នុងគ្រានេះអកុសល
រិះគិតតែកើតចិត្តឆ្អិតឆ្អល់
រវល់ញឹកញាប់ពប់មិនបាន ។

គិតសព្វថប់ណែនហើយថែមព្រួយ
ស្មើរទឹករលួយថ្លើមប្រមាត់
មើលទៅជាជាំនំព្រោះគ្មាន
ទឹកក្សាន្តតាំងតែប្រាសថ្លើមថ្លៃ ។

ថ្លៃបងចូរកែវទ្រង់អាណិត
មកចិត្តដែលពិតគិតអាល័យ
កុំឲ្យអសារសោះទីទៃ
រិះរើសសេចក្ដីឲ្យសព្វសាយ ។

ចិត្តអើយគង់ចាំពាក្យសន្ទត
ក្រែងអត់អំពើទេចិត្តាយ

ព្រះទ័យកំពប់រុសរក់កាយ
ដោយឆ្ងាយបង់បាត់ខ្ចាត់ពា ។
សព្វថ្ងៃយកព្រះជាទីពឹង
ពំនឹងដោយទិព្វចក្ខា
ឲ្យប្រាប់រឿងថ្ងៃចេញមដិវ៉
គ្រាន់ស្ងប់ទុក្ខាស្ងប់ស្ងៀមនៅ ។
មួយគិតប្រណីមកតាមយង់
ឲ្យគង់កេរ្ដិ៍យ បតគៀងទៅ
ចិត្តចង់ឲ្យល្អពង្សវង្សផៅ
កុំឲ្យអ្នកក្រៅគេនិន្ទា ។
មួយដូចខ្ញុំបង់គួបទាបសក្តិ
វរល័ក្ខណ៍ខ្ពង់ខ្ពស់ដូចមេឃា
កុំគួរបើហ៊ានខ្ទឹងពុះពោ
ប៉ុន្តែចិន្តាស្នេហាសល់ ។
មួយពុំចង់ឲ្យមនុស្សទាំងឡាយ
គេដឹងខ្ចរខ្ចាយកើតកន្ទល់
អប្រិយ៍ព្រោះក្ដីចិត្តអកុសល

ថ្ងៃរះឲ្យដល់កេក្បាអង្គ ។
មួយកុំរេរល់ទឹងចិត្តបង
ថ្វាយសក្តិដែលប៉ងគិតបំរុង
ក្រែងតែព្រះទ័យថ្ងៃតោមយង់
ពុំគង់ដូចព្រះបន្ទូលឡើយ ។
ស្ងួនអើយចិត្តរៀមដូចកល់ក្នុំ
សុមេរុធាធំនៅឯញ
សង្កត់ទ្វីបប្អូនជួនសព្វថ្ងៃ
អាស្រ័យកំរើកចេញមិនបាន ។
កុំព្រួយព្រះទ័យឡើយធីតា
បើវះទុកាវៀមក៏ហ៊ាន
វះថ្វាយទ្រដ៏ទតដាក់ស្មោះស្មាន
កល្យាណជឿចុះកុំសង្ស័យ ។
ប្រសិនបើវាស្នាយើងមាន
គង់ជួយឲ្យបានដូចបច្ច័យ
ដ្បិតយើងបន់ព្រះតែសព្វថ្ងៃ
អាស្រ័យឲ្យបានដូចប្រាថ្នា ។

ដឹងហើយជាក្រដាបផ្អៀត
ហើយទ្រង់ខំឆ្លៀតដល់ជេដ្ឋា
ជឿហើយជាព្រះទ័យមេត្តា
ជេដ្ឋាក៏ឥតមានសង្ស័យ

ទោះមនុស្សនាំញុះញង់ដូចម្តេច
នៀមក៏ពុំភ្លេចក្តីអាល័យ
តាមបុណ្យតាមព្រេងតាមនិស្ស័យ
សេចក្តីអាល័យកាត់មិនបាន ។

ថ្ងៃមុនមានបុតម៉ាយមួយច្បាប់
ថ្លែងប្រាប់ថាអផ្សុកក្នុងកាយ
កើតគ្រុនស្រៀវស្រាញមិនសប្បាយ
ប្រែក្លាយឈឺដល់ព្រះកេសា ។

នោះនៀមបានតបសារមកវិញ
ថាដ្បិតនៀមម្នេញក្នុងចិន្តា
បើជាអផ្សុកដូចម្តេចខ្តា
ឲ្យសារតបទៅជាប្រញាប់ ។

បុតម៉ាយមកនោះគេតអំពើ

បំរើក៏កុំឃើញទៅប្រាប់
ក្មេងដើរចេញចូលដូចគេសាប់
គ្មានប្រាប់ឱ្យឮក្មេងនុក ។
ជាទុក្ខទ្ងឹងដំណឹងស្ងួន
ប្រឈួនព្រះពេកតើហ៊ានណា
បន្តិចលោចក្មេងទៅប្រាប់ថា
ដីភាគស្រុកបីថ្ងៃហើយ ។
ឱជ្រើមតែមួយជាត្រួយចិត្ត
រៀមគិតគ្មានក្មេចផល់តិចឡើយ
រឹងរឹតរោមនស្រពុំមានស្បើយ
កែវអើយបើម៉្លះសមរៀមក្ស័យ ។
ទោះដើរទោះដេកអង្គុយលេង
សព្វល្បែងតែងទឹកពេកថ្ងៃ
សមបាត់ដំណើររឹងសង្ស័យ
ទាំងយប់ទាំងថ្ងៃដេកមិនលក់ ។

ធ្វើការឱ្យនឿយហត់រហូតដល់ស្លាប់ ។ ចំណែកឯព្រះនិព្វានមិនមានពោលដូច្នោះឡើយ ទុកជាដូច្នោះក៏ដោយ យើងជាពុទ្ធសាសនិកជននៅតែនាំគ្នាប្រាថ្នាសុំឱ្យសម្រេចដល់ព្រះនិព្វានជាដរាប ទើបឃើញថាមុខគួរតែពិចារណាពិនិត្យរកហេតុផលខ្លះចុះថា និព្វានគឺអ្វី? ប្រសិនបើយើងគិតមើលសើៗត្រឹមសំបកក្រៅ គង់ឃើញថា ខាងទេពអប្សរក្តី អាហារទិព្វក្តី គ្រឿងប្រើប្រាស់ដទៃ ក្នុងស្ថានសួគ៌នេះក្តី អស់នេះសុទ្ធតែជាគ្រឿងឧបករណ៍ដល់ពនកាយជាសេចក្តីត្រេកអររបស់ពនកាយ កាលបើគិតមើលពីពនកាយនឹងឃើញថា ពនកាយនេះគ្រាន់តែជាវត្ថុមួយ កាលបើដល់ពេលកើតក៏កើតឡើង ដល់ពេលវិនាសក៏វិនាសទៅ ដូចជាផ្លែឈើដែលកើតឡើង កាលដល់រដូវត្រូវជ្រុះរមែងជ្រុះពីដើមបាត់ទៅជាធម្មតា កាលយើងពិនិត្យមើលតាមទំនងនេះ ក្រែងអាចសំឡឹងទៅកាន់ព្រះនិព្វាននេះបានខ្លះដែរ? ព្រោះថាបើយើងអាចដំរះចិត្តឱ្យភ្លឺច្បាស់ជ្រះស្រឡះបានហើយ សេចក្តីយល់ដល់ខ្លួន គឺឃើញតែប្រយោជន៍ខ្លួន គង់នឹងសន្សឹមៗរសាយចេញពីចិត្តបន្តិចៗទៅ ហើយមានចិត្តមេត្តាករុណា នឹងយល់ដល់ចិត្តនៃគ្នានឹងគ្នាជាមិនខាន មនុស្សយើងបើជួយទុក្ខធុរៈទៅវិញទៅមក មិនមានអ្នកណាគិតព្យាបាទគ្នាទៅវិញទៅមកទេ សង្គ្រាមគង់តែមិនមានកើតឡើង លោកនេះនឹងពោរពេញដោយសន្តិភាព ។



៩ — អំពីការទ្រង់សិក្សាក្បួនពិជ័យសង្គ្រាម ។

# ដំណឹងផ្សេងៗ

## ក្នុងនានាប្រទេស

សេចក្តីអធិប្បាយតាមសៀវភៅ ដែលគេទើបនឹងផ្ញើមកជូនព្រះរាជបណ្ណាល័យ ។

ជាតិអាមេរិកាំងដែលមានសេចក្តីពេញចិត្តនឹងលទ្ធិព្រះពុទ្ធសាសនា ទើបនឹងផ្ញើសៀវភៅភាសាអង់គ្លេសមួយច្បាប់មកជូនយើង សេចក្តីក្នុងសៀវភៅនោះ គេបាននិយាយរួមពុទ្ធភាសិតដែលស្រង់មកអំពីគម្ពីរព្រះពុទ្ធសាសនា ដែលគេប្រែពីភាសាបាលី ភាសាសំស្ក្រឹត ភាសាចិន ភាសាទីបេតាំង នឹងរបៀបសម័យដែលប្រែពីភាសាឥរុបផ្សេងៗ តពីនោះមកមានជាតិឥរុបម្នាក់ឈ្មោះលោកគោដា បានបំប្រួញពុទ្ធភាសិតនោះជាសេចក្តីខ្លីៗ ដើម្បីឲ្យងាយស្តាប់ ក្នុងអារម្ភកថារបស់លោកគោដានោះ លោកបានអធិប្បាយថា ហេតុអ្វីបានជាលោកខំប្រឹងជ្រើសរើសភាសិតនោះមកប្រែ ហើយរួមធ្វើទៅជាសៀវភៅមួយដោយឡែក លោកមិនមែនធ្វើភាសិតនោះឲ្យទៅជារឿងរ៉ាវផ្សេងៗទេ គឺធ្វើឲ្យទៅជារឿងមួយសំរាប់ពន្យល់បង្ហាញផ្លូវល្អដល់អ្នកមើល ។ អំពីផលប្រយោជន៍នៃសៀវភៅនោះ លោកសង្ឃឹមថា សៀវភៅនេះគង់មានប្រយោជន៍យ៉ាងសំខាន់ អាចនឹង

ជាស់គំនិតអ្នកមើលឲ្យមានផលប្រយោជន៍ ដែលអាចនឹងបំពេញកិច្ចយ៉ាងខ្ពស់ក្នុងលទ្ធិសាសនា ដឹងសេចក្ដីសុខក្សេមក្សាន្តដល់មនុស្សលោក ។

## អំពីការរកឃើញព្រះពុទ្ធរូបបុរាណនៅកោះសុម៉ាត្រា

កោះសុម៉ាត្រានេះនៅខាងត្បូងស្រុកសិង្គបូរ ហើយនៅជាខាងលិចកោះជ្វា ។ កាលពីពុទ្ធសករាជ ១.២០០ ដល់ពុទ្ធសករាជ ១.៧០០ នោះ កោះសុម៉ាត្រានេះជាអាណាចក្រដ៏សំខាន់មួយ ដែលមានទីក្រុងហៅថាស្រីវិជ័យ ដែលមានកេរ្តិ៍ឈ្មោះល្បីតាំងអំពីស្រុកឥណ្ឌា រហូតទៅស្រុកចិន ជាស្រុកស្ដុកស្ដម្ភទៅដោយការហត្ថកម្មនឹងបែបរចនាយ៉ាងល្អៗ ។

កេរ្តិ៍ដំណែលដែលល្បីល្បាញនេះ តាំងនៅមាត់ស្ទឹងមូស៊ី ដែលជាទីសំខាន់បំផុតនៃកោះនេះ ។ ពួកអ្នកស្រាវជ្រាវបុរាណវត្ថុបានរកឃើញបុរាណវត្ថុផ្សេងៗនៅទីក្រុងចាស់នេះ ។ ដូចជាវត្ថុវិហារយ៉ាងល្អឆើត មានដំកល់ព្រះពុទ្ធរូបសំរិទ្ធិ៍ និងព្រះពុទ្ធរូបថ្មជាច្រើន អាទិគឺព្រះពុទ្ធរូបទ្រង់គង់ (ឬអង្គុយបែបពួកឧរូប) ដាក់ព្រះបាទលើផ្កាឈូក ទ្រង់ប្រទានធម្មទេសនា មានព្រះពុទ្ធរូប ១ អង្គទៀតទ្រង់ព្រះស្ថិត (ឈរ) តែព្រះហស្ដបាក់អស់ទៅហើយ មានរូបជាដំណាងព្រះពុទ្ធរូបមហាយានយ៉ាងស្រស់ ១ អង្គ ទ្រង់ពត់ព្រះភ្នែនតែនព្រះបាទលើផ្កាឈូកមួយ ។

# អំពីពិធីអន្នប្រាស័ន

ក្នុងទស្សនាវដ្ដីឥណ្ឌូ ចេញផ្សាយជាភាសាអង់គ្លេសៈឈ្មោះ (Modern revuiw) កាលពីខែសេបតម្ប្រ៍ ឆ្នាំ ១៩៣៨ មានសេចក្ដីសាសព្ទអំពីពិធីបុណ្យមួយ ដែលមានប្រយោជន៍ដល់ជនជាតិខ្មែរនៅស្រុកអាយនេះ ។

គេបានធ្វើពិធីសម្ពោធបុណ្យនេះ នៅក្នុងព្រះរាជវាំងមួយនៃស្រុកទ្រីវ៉ានទ្រុម ក្នុងខែត្រត្រាវ៉ានគួរ នៅស្រុកឥណ្ឌូខាងត្បូង ។ ពិធីនេះហៅថា "ពិធីអន្នប្រាស័ន" ជាពិធីដែលគេដំកល់ដំកើងស្ដ្រីមានសេចក្ដីត្រៀវត្រាសក្នុងកិច្ចនៃមាតា ឬហៅថាពិធីពំនូតបាយមួយដុំដែលគេជូនដល់ទារកដែលទើបប្រសូតៈចេញពីទ្រូងនៃមាតា ។ ពិធីនេះគេបានចាត់ធ្វើឡើង ដើម្បីជាកិត្តិយសដល់រាជបុត្ររបស់នាងក្សត្រីជាមហេសីទី ១ នៃខែត្រត្រាវ៉ានគួរ ។

ក្នុងថ្ងៃពិធីនេះ រាជមាតានៃព្រះកុមារនេះជាបុគ្គលមានកិត្តិយសបំផុត ព្រោះគេបានសំដែងឲ្យឃើញថា ព្រះនាងជាអ្នកទទួលភារៈធុរៈដ៏ធ្ងន់ជាកិច្ចដ៏កម្របំផុត គឺព្រះនាងបានប្រគល់ឲ្យនូវសេចក្ដីចំរើនដល់ជីវិត និងកិច្ចចិញ្ចឹមបំបៅដោះចំពោះរាជកុមារនេះ ក្នុងរវាង ៦ ខែដំបូង ។ ក្នុងថ្ងៃដែលគេធ្វើពិធីថ្វាយដុំបាយដល់រាជកុមារនេះ ជាថ្ងៃជាមួយគ្នានឹងថ្ងៃដែលគេថ្វាយព្រះនាម (ដល់រាជកុមារនេះ) ពិធីនេះគេចាត់ធ្វើជារបៀបរាជការ

ជាមុនបង្អស់ ចំពោះមកុដរាជកុមារដែលគួរដល់រាជបល្ល័ង្កនៃស្រុកត្រា-វ័នកូរ ។

រាជពិធីនេះ គេធ្វើនៅទីកណ្ដាលវាល មានទាហានរបស់ក្សត្រប្រមាណ ២៥០ នាក់ សុទ្ធតែជួតសំពត់ពណ៌ខៀវ ឈរជាជួរ ៗ ជម្រៀបគ្នាតាមបណ្ដោយផ្លូវ ហើយមានពួករាជបំរើនៃប្រទេសមានគ្រឿងសំគាល់ផ្សេង ៗ គ្នា ពួកដែលនៅខាងដើមគេ គឺពួកព្រាហ្មណ៍ សុទ្ធតែស្លៀកពាក់ស មើលឃើញប្លែកផ្សេងពីរបៀបសំលៀកបំពាក់របស់នាយទាហានដែលមានខ្សែស្រយមាស (កាឡុងមាស) ប្រដាប់នៅទឹងអាវពណ៌ក្រហម ។

នៅខាងក្នុងព្រះរាជវាំងនេះ មុនដំបូងបង្អស់គេរៀបធ្វើមង្គលអង្ករ តាមដោយព្រះរាជមាតារបស់ព្រះរាជកុមារ បានរៀបចំធ្វើជាមណ្ឌបរៀបទទួលភ្ញៀវមានតាំងអង្ករផង អង្ករនេះហើយដែលគេនាំយកទៅដាំចំអិនតាមទំនៀមប្រវេណី ។ កន្លែងនេះហើយដែលពួកនាយទាហាននាំហែចេញទៅនៅខាងមុខបង្អស់ រួចពួកស្រីស្នំក្នុងរាជត្រកូល រួចព្រះជននីមាតាទ្រង់ពរាជកុមារដើរទៅតាមក្រោយព្រះអយ្យកោ និងព្រះអយ្យិកានៃរាជត្រកូល រួមជា ៤ ក្រុមរបស់ត្រកូលដ៏ខ្ពង់ខ្ពស់នេះ ។

ចំណែកព្រាហ្មណ៍បុរោហិត ឈរនៅខាងក្រៅចាំទទួលព្រះវរជននីមាតា រាជកុមារ និងព្រះអយ្យកោ-អយ្យិកា ។ ឯពួកស្រី ៗ ដែលចូលក្នុង

ក្បួនហែនេះ គេគ្រាន់ស្លៀកពាក់សំពត់ស ដើរជើងទទេ សំយាកសក់ទៅក្រោយខ្នង ប៉ុន្តែពួកកុមារី (ស្រីក្រមុំ) សុទ្ធតែមានគ្រឿងសំលៀកបំពាក់មានព័ណ៌ក្លៃក្លូតៗ ផ្សេងៗ ពីគ្នា មានផ្កាព័ណ៌ផ្សេងៗ នៅលើសក់ ហើយកាន់គ្រឿងប្រដាប់សម្រាប់ពិធីបុណ្យនេះគ្រប់គ្នា ។ ក្សត្រីជាមាតាទៅគង់ (អង្គុយ) នៅមុខព្រាហ្មណ៍បុរោហិត ជាមួយនឹងព្រះរាជកុមារដែលគង់លើព្រះឧរុ (ភ្លៅ) របស់ព្រះនាង ។ លុះសូត្រធម៌រួចហើយ គេប្រគល់ព្រះរាជកុមារទៅព្រះអយ្យិកាជាទីជំនិតបំផុត ព្រះអយ្យិកាទទួលយកទៅដប់ឱបក្រសោបដោយព្រះទ័យស្នេហា រួចទើបប្រគល់ព្រះរាជកុមារទៅព្រះមាតាវិញ ហើយឲ្យដើរប្រទក្សិណ ៣ ជុំ ជុំវិញដើមឈើមង្គលដ៏ស័ក្តិសិទ្ធិតាមពិធី ដើម្បីឲ្យព្រះរាជបុត្រានឹងព្រះរាជមាតាបានទទួលជ័យមង្គលអំពីធម្មជាតិដែលប្រកបដោយផ្លែផ្កា វិធីនេះធ្វើឲ្យព្រះរាជកុមារនឹងព្រះវរមាតាមានគុណសម្បត្តិ (ដ៏ខ្លាំងពូកែឡើងអំពីដើមឈើមង្គលនេះ) ។

ពួកស្រីក្នុងគ្រួសារតែងធ្វើពិធីបុណ្យនេះ ដើម្បីជាកិត្តិយសដល់ពួកស្រីផងគ្នា ជាអ្នកមានមុខក្រសួងយ៉ាងសំខាន់ជាមាតានៃទារកទារិកា ។

ឯព្រះរាជពិធីតាំងព្រះនាម ស្រេចតែក្សត្រាជាព្រះបិតារបស់ព្រះរាជកុមារនោះ ពិធីនេះទ្រង់ខ្សឹបប្រាប់ឈ្មោះញុងនឹងត្រចៀកព្រះរាជបុត្រដែលទ្រង់ប្រទាននាមរួចហើយ ទើបទ្រង់ប្រកាសនាមយ៉ាងខ្លាំង

៣ ដងថែមទៀត ទើបព្រះរាជមាតានឹងព្រះអយ្យកោអយ្យិកាបានស្រែកប្រកាសថែម ៣ ដងទៀត ។ ប៉ុន្តែពិធីនេះមិនមានធ្វើនៅក្នុងទីប្រជុំជនទេ ពិធីនេះជាពិធីដែលមាតាត្រូវបានទទួលកិត្តិយសជាដ.ប ។ រឿងនេះសំដែងឲ្យឃើញថា ពួកឥណ្ឌូនៅតែប្រតិបត្តិតាមទំនៀមរបស់មនុនៅឡើយ ក្នុងទំនៀមនេះមាននិយាយថា មាតាជាអ្នកមានកិច្ចការសំខាន់ជាងបិតា ១.០០០ ភាគ ។

(ច្បាប់ម៉នុស្ម្រិតិ ប១ ១១)

CAMBODGE
04 .

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ៥

កុម្ស៊ីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨៣
គ. ស. ១៩៤០

# បញ្ជីរឿង


១ — អំពីពុទ្ធសាសនានៅអាស៊ីកណ្ដាលនិងអាស៊ីខាងកើត របស់លោកដេម៉ារវែត . ៣

២ — ព្រះពុទ្ធសាសនាបាត់ទៅពីប្រទេសឥណ្ឌាដោយហេតុយ៉ាងណា ? ខេមររង្សី ប្រែចេញពីទស្សនាវដ្ដីធម្មចក្ក (តនឹងចប់) . . . . . . . . . . . . . . . . ១៥

៣ — ពុទ្ធប្បវត្តិបិន (នៅមានត) . . . . . . . . . . . . . . . . . . . . . ២៩

៤ — ប្រវត្តិលោកមីលរេប៉ះ តាមសេចក្ដីប្រែពីភាសាទីបេតាំងមកជាបារាំងសែស របស់ ស៊ុកបាកូត៍ (នៅមានត) . . . . . . . . . . . . . . . . . . . . ៣៣

៥ — ពង្សាវតារសង្ខេបប្រទេសសាលដេនិងអស្ស៊ីរីតាមប្រវត្តិ ហេស្ត្រសាកលថៃ របស់ ហ្លួងវិចិត្រវាទការ អ្នកមហាថែម ប្រែនិងរៀបរៀង . . . . . . . . . . ៣៧

៦ — អំពីកំណើតនៃមនុស្សជាតិ ខេមររង្សីស្រង់និងប្រែពីការសែតថៃវិទ្យាចារ្យ(តនឹងចប់) ៥៥

៧ — វេយ្យាករណ៍សំស្ក្រឹតភាគទី ៦ របស់ព្រះសាក្យវង្ស (មានត) . . . . . . . ៧៣

៨ — ប្រជុំពាក្យកាព្យ ភាគទី ៤ របស់រក្សភិរម្យ អ៊ូង (ត) . . . . . . . . . ៨៥


## រូបក្រោយរឿង


១ — អំពីការទ្រង់ប្រឡងធ្នូសរ . . . . . . . . . . . . . . . . . . . . ១

២ — អំពីអាវាហវិវាហមង្គល . . . . . . . . . . . . . . . . . . . . ១៣

៣ — អំពីទ្រង់ជួបប្រទះនឹងមនុស្សជរា . . . . . . . . . . . . . . . . . ២៧

៤ — អំពីទ្រង់ជួបប្រទះនឹងមនុស្សឈឺ . . . . . . . . . . . . . . . . . ៣៥

៥ — អំពីទ្រង់ជួបប្រទះនឹងមនុស្សស្លាប់ . . . . . . . . . . . . . . . . ៥៣

៦ — ផ្ទះរបស់ឪពុកធំនិងម្ដាយមីងរបស់មីលរេប៉ះ រលំបាក់បែកដោយអំណាចមន្ត . . ៣១

# TABLE DES MATIÈRES


Pages

1° Extrait d'un article sur le Bouddhisme en Asie centrale et orientale par Démarquette ........................ 3

2° Pourquoi le Bouddhisme a-t-il disparu des Indes ? extrait de la revue thailandaise DHAMMACHAKSU et traduit en Cambodgien par KHEMARARANSI (suite et fin).......... 15

3° La Vie du Bouddha d'après des documents chinois (suite)... 29

4° La Vie de MILARÉPA d'après la traduction du Tibétain en Français de Monsieur Jacques Bacot (suite)............. 33

5° Histoire sommaire de Chaldée et Assyrie, extrait de l'histoire générale thailandaise par Luong-Vichit vâdakar et traduit en Cambodgien par MAHA THÈM...................... 37

6° Origine des êtres humains, extrait de la revue VIDHYACHAR et traduit en Cambodgien par KHEMARARANSI (suite et fin).. 55

7° Grammaire sanscrite 6e partie par Préas SAKYAVONG (H. TATH). 73

8° Recueil de Poèmes cambodgiens 4e partie par RAK-PHIROM Uong (suite)........................... 85


HORS-TEXTES:


1° Concours du tir à l'arc..................... 1

2° Le mariage......................... 13

3° La rencontre du vieillard.................. 27

4° La rencontre du malade................. 35

5° La rencontre d'un mort................. 53

6° La maison de l'oncle et de la tante de Milarépa s'écroule. 31

ការបានសម្រេចរបស់ព្រះពុទ្ធជាម្ចាស់ក្តី របស់សឹរអៃសុកទិតាន់ក្តី របស់បុគ្គលសំខាន់ៗដទៃទៀតក្តី សុទ្ធតែមានមូលមកអំពីចតុប្រសាទ កាលបើឃើញហើយមិនបណ្តោយឲ្យហួសទៅដូចជាមនុស្សសាមញ្ញទេ ទើបធ្វើឲ្យយើងសង្កេតបានថា បុគ្គលសំខាន់ៗនោះ សុទ្ធតែមនុស្សមេរៀន - មេគិត កាលបើមានវត្ថុអ្វីមកប៉ះចំពាប់ទីផ្នែករមែងកើតសេចក្តីបំណងចង់ចេះដឹងយ៉ាងខ្លាំងក្លា ពិចារណាករកហេតុផលដោយវិរិយៈឧស្សាហៈដ៏មាំមួន ទើបបានសម្រេចផលសមតាមបំណងគ្រប់ប្រការៗ

ទេមររង្សី



១ — អំពីការទ្រង់ប្រឡងធ្នូសរ

(មើលសេចក្តីពន្យល់ទំព័រ ២៩)

## អំពីពុទ្ធសាសនា

## របស់លោកដេម៉ារកែត (Démarquette)

យើងបានមើលទស្សនាវដ្ដីរបស់បាកំងសៀសមួយ មានរឿងមួយនិយាយអំពីព្រះពុទ្ធសាសនា ជាសេចក្ដីអធិប្បាយអំពីដំណើរព្រះពុទ្ធសាសនារបស់លោកដេម៉ារ៉ែគត លោកនេះធ្លាប់មកស្រុកខ្មែរយើងកាលពីឆ្នាំ ១៩៣១ ។ ឯសេចក្ដីអធិប្បាយរបស់លោក ដូចមានសេចក្ដីសារសេរតទៅនេះ:

គ្រប់ៗ ប្រទេសនៅទ្វីបអាស៊ីកណ្ដាល ទិសខាងកើតនេះ ព្រះពុទ្ធសាសនាមិនមែនត្រឹមតែជាសាខាដ៏ប្រសើរមួយ ក្នុងការប្រកាសធម្មចរិយានឹងចិត្តវិទ្យាប៉ុណ្ណោះទេ ពុទ្ធសាសនាជួយជ្រោមជ្រែងសុវិជ្ជាគ្រប់ប្រការនឹងសាសនធម៌ឲ្យកាន់តែរីកធំចំរើនឡើងទៀតផង បែករំលែកផ្សាយដល់ប្រជាជនក្នុងទ្វីប ព្រមទាំងចរិយត្តិធម៌របស់ព្រះអង្គ ។ បណ្ដាក្បួនច្បាប់បែបក្បាច់រចនាដ៏មានដំឡៃ ដែលថាមានកំណើតមកពីអារ្យធម៌របស់ឥណ្ឌា ក៏រីកធំឡើងយ៉ាងសំបើម ។ បែបរចនាដែលកាន់តែរីកធំឡើងនេះ ប្រព្រឹត្តទៅតាមចិត្តវិជ្ជារបស់បណ្ដាពស្ដ្រ ដែលកាន់ព្រះពុទ្ធសាសនាសព្វកន្លែងសព្វអន្លើ ដែលមានព្រះពុទ្ធសាសនា ចាប់ផ្ដើមតាំងអំពីស្រុកគន្ធារៈ ដែលជារចនាបែបក្រិក — ពុទ្ធសាសន៍ ជារចនាដ៏ល្អមួយ

ក្នុងលោក រហូតមកដល់ស្រុកជប៉ុន ដែលជាប្រទេសមានប្រជាជនជាពុទ្ធសាសនិក ៗ ក្នុងសម័យណារ៉ា (Nara) និងហៃយ៉ង់ (Héïan) រចនានៅក្នុងបូព៌ាប្រទេសស្ទុះចំរើនឡើងដល់លំអជាកំពូលនៃរចនា ៗ

ពុទ្ធសាសនិកដែលមានអំណាចក៏ខំផ្សាយធម៌អាចដល់ប្រជាជនមានចំនួនជាអនេក សេចក្តីចំរើនរុងរឿងនៃពុទ្ធសាសនាផ្សាយហៀរចេញទៅក្នុងលោកដ៏ធំទូលាយស្មើរតែផុតរស្មីនៃដួងអាទិត្យ ៗ

ព្រះពុទ្ធសាសនាដែលផ្សាយចេញក្នុងប្រទេសផ្សេង ៗ ក្នុងលោកនេះដោយមិនត្រូវគេធ្វើទោស ឬបៀតបៀន ឬមានឧបសគ្គមកកំហិតមិនឲ្យសាសនាដើរចេញទៅរួចស្មើរតែមិនមានសោះឡើយ ៗ ដោយកាលមិនយូរប៉ុន្មាន ប្រជាជនជាតិផ្សេង ៗ និងផ្លាស់ចិត្តគំនិតនិងទំនៀមទម្លាប់ដែលខ្លួនធ្លាប់កាន់មកនោះចោលចេញ ហើយនាំគ្នាបែរមុខមកកាន់តាមច្បាប់ព្រះពុទ្ធសាសនាជាសាសនាបុរាណនេះ ៗ នៅសម័យបច្ចុប្បន្ននេះ ព្រះសាសនារបស់ព្រះសាក្យមុនីសម្មាសម្ពុទ្ធកាន់តែរីកធំទូលាយចេញទៅក្រៃលែងជាងគណៈសាសនាមហាហ្ម័ត ឬសាសនាគ្រិស្តទៅទៀត ៗ

ឯពុទ្ធសាសនានេះ យើងអាចសង្កេតឃើញចំណែកធំ ៗ នៃពុទ្ធ-សាសនាមាន ២ ចំណែក គឺព្រះពុទ្ធសាសនានៅចំណែកខាងត្បូង ផ្សាយចេញទៅតាំងនៅលើកោះស៊ីឡង់ (កោះលង្កា) ស្រុកភូមា, ស្រុកសៀម,

នឹងស្រុកខ្មែរ បែបនេះមានឈ្មោះថា ហីនយាន ឬ "រទេះតូច" ឬ "យាន ជំនិះតូច" ។ ឯពុទ្ធសាសនានៅចំណែកខាងជើង ផ្សាយចេញទៅតាំងនៅស្រុកជប៉ុន, ស្រុកកូរេ, ស្រុកចិន, ស្រុកម៉ាញជូគូរ៍, ម៉ុងគូលី, ស្រុកទីបេត៍, នឹងជួរខាងជើងភ្នំហិម៉ាល័យ៉ា (ហេមពាន្ត) រហូតដល់ស្រុកជាចំណែកទ្វីបជាប់តមកកាលពួកម៉ុងកុលលើកខ្លួនចូលទៅស្រុកទ្វីប ។ ពួកពុទ្ធសា-សនិកជនចំពួកនេះមាននាមថា ពួកពុទ្ធសាសនាខាងជើង ឬពួកមហា-យាន "យានជំនិះធំ" "ឬផ្លូវធំ" ។ បទទី ៣ នៃសៀវភៅលោតុស (lotus) មាននិយាយពីមហាយានសូត្រមួយពោលប្រៀបធៀបថា ពាក្យថា "មហាយាន" សំដៅដល់រទេះគោធំសម្រាប់ផ្ទុកគំនរសត្វៈជាចំនួនច្រើន ហើយថា សំណាក់ហីនយានទាំងពីរក្នុងសម័យនោះ គឺពួកថេរវា-ទិននឹងពួកសារិស្តិវាទិន សំដៅដល់រទេះទឹមដោយពពែញី ឬទឹមដោយកូនម្រឹគ ។ ការដែលហៅថា "ហីនយាន" ឬយានជាន់ទាបនេះ មិនសូវមានប្រយោជន៍ក្នុងគម្ពីរព្រះពុទ្ធទេ នៅសម័យកាលជាន់កណ្ដាល ។ ពួកអ្នកដំណើរជាតិចិនបានធ្វើការផ្សាយនឹងកែប្រែគម្ពីរដីកា ធ្លាក់មកដល់ពួកអ្នកប្រាជ្ញទិសខាងលិច (ទ្វីប) ។ ប៉ុន្តែពុទ្ធសាសនានៅទិសខាងជើងចាញ់ពុទ្ធសាសនានៅខាងត្បូងស្ទើរតែមិនមានខ្លឹមសារជាគោលចារិកសោះឡើយ ព្រោះមានសេចក្ដីប្លែកៗ ផ្សេងៗជាច្រើន ៗ មិនត្រឹមតែប៉ុណ្ណោះថែមទាំង

បានទទួលយកលទ្ធិសាសនាផ្សេង ៗ ឬរឿងប្លែក ៗ ឲ្យមានលើសពីលទ្ធិពុទ្ធសាសនាមហាយានទៅទៀត នាំឲ្យកាន់ប្រឡំឃ្លាងសេចក្តីខុសឆ្ងាយពីព្រះពុទ្ធដីការបស់ព្រះតថាគត ។

ឥឡូវនេះ យើងជ្រើសរើសយកតែគោលសំខាន់ ៗ នៃព្រះពុទ្ធ-សាសនាខាងត្បូងមកនិយាយ ។

ប៉ុន្តែមុននឹងធ្វើការពិចារណារាវរកគោលសំខាន់ ៗ នៃពុទ្ធសាសនាត្រូវតែធ្វើដោយសេចក្តីសុចរិតយុត្តិធម៌ អំពីសេចក្តីខុសភ្លាត់កាន់ប្រឡំអស់នោះ បើមិនធ្វើដូច្នេះទេ សេចក្តីពិចារណានេះនឹងទៅជាពោលបង្អាប់ពុទ្ធសាសនាទៅវិញ ដែលតែងតែមានមកហើយ ៗ តាមសេចក្តីពិនិត្យនៅទិសខាងលិច ។

គេនិយាយប្រាប់យើងថា ពួកដែលមិនចូលចិត្តនឹងពុទ្ធសាសនាច្រើនពោលបន្ទោសថា ពុទ្ធសាសនាជាលទ្ធិសូន្យភាពថាជីវិតអត្តភាពរបស់សត្វក្នុងសកលលោកនេះជារបស់ឥតខ្លឹមសារគ្មានដំឡៃអ្វីទេ ទូន្មានឲ្យមនុស្សនាំគ្នាចៀសវាងចាកសង្សារវដ្ត ដើម្បីនាំជីវិតឲ្យប្រព្រឹត្តទៅតាមផ្លូវនាំទៅកាន់ព្រះនិព្វាន ឬធ្វើឲ្យអត្តភាពជាមនុស្សសាបសូន្យទៅ ។

ពាក្យពោលដូច្នេះមិនយុត្តិធម៌ទេ ជាពាក្យពោលដោយសេចក្តីងងឹតងងល់ខុសពីគន្លងធម៌ ។ ព្រះពុទ្ធសាសនាជាសាសនាដ៏សំខាន់បំផុតទើបមិនរលត់បាត់ទៅកប់ជាចំនួនជាងពីរពាន់ឆ្នាំហើយ មានចំនួនពុទ្ធ-

បរិសទ្យក្រប់ដោយយោណានឡើងទៅ ជាសាសនាដ៏ធំសំបើមអស្ចារ្យមួយក្នុងលោក ទើបឃើញថា មិនមានលទ្ធិដូចពាក្យអ្នកខ្ពមលោកហើយសម្លាប់ខ្លួនឯងនោះទេ ។ បើនឹងនាំពុទ្ធសាសនាទៅប្រៀបធៀបមិនត្រូវប្រៀបធៀបនឹងពុទ្ធសាសនាជាន់ក្រោយ ៗ នេះទេ ។ ត្រូវតែប្រៀបធៀបនឹងសាសនាជាន់ដើមកើតឡើងក្នុងជំនាន់ជាមួយគ្នា ទើបយុត្តិធម៌ត្រឹមត្រូវល្អ ។ លើកលែងតែលទ្ធិ សូរោអាស្ត្រីយ៉ានិស្ម៍ (Zoroastrianisme) ចេញពួកអ្នកប្រកាន់សៃវព្រេនមុនពុទ្ធសាសនានោះ សុទ្ធតែជាអ្នកប្រកាន់ថាជាសាសនាសម្រាប់ជាតិរបស់ខ្លួន ដោយគ្រាន់តែមានវេទមន្តបន្តិចបន្តួចតាមលទ្ធិសាសនាបុរាណ ៗ មានមនុស្សជំនាន់ដើមពួកខ្លះប្រកាន់គោរពរូបបុគ្គលឬសត្វជាសរណៈដោយមានសង្ឃឹមថា នឹងជួយស្រោចស្រង់គេឱ្យផុតពីសេចក្ដីលំបាកឬគ្រោះថ្នាក់បាន ។

ឯពុទ្ធសាសនាមិនមែនដូច្នោះទេ ជាសាសនាធំមួយនៅក្នុងលោកនេះប្រកាសផ្សាយដល់មនុស្សគ្រប់ជាតិ នឹងគ្រប់ៗប្រទេស មិនរើសជាតិមិនរើសស្រុក សុទ្ធសឹងនៅក្រោមច្បាប់តែមួយ ស្មើភាគគ្នាហើយឱ្យយុត្តិធម៌យ៉ាងខ្ពង់ខ្ពស់ ជាសាសនាបន្ទោបង់នូវសេចក្ដីទុក្ខសោកដល់អ្នកគោរពប្រតិបត្តិគ្រប់ជាន់គ្រប់ថ្នាក់ ទុកជាមានជាតិនឹងវណ្ណៈផ្សេងគ្នាក៏ដោយហើយមនុស្សទាំងអស់ អាចធ្វើខ្លួនឱ្យរួចស្រឡះពីគំនរទុក្ខដោយគោរពប្រតិបត្តិតាមព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រោះសាសនានេះ

មិនមែនទូន្មានត្រឹមតែធ្វើកាយវាចាឲ្យស្អាតបរិសុទ្ធប៉ុណ្ណោះទេ ជាសាសនាជម្រះខាងផ្លូវចិត្តឲ្យបរិសុទ្ធទៀតផង ជាសាសនាមិនប្រកាន់យកទេវតាមារព្រហ្មយមយក្សស្ថានសួគ៌ បេតក្កូតជាគោលចារិក ប៉ុន្តែជាសាសនាបង្កើតឲ្យមានការរាប់អានជាបងប្អូនក្នុងចំណោមមនុស្សជាតិ ហើយឲ្យមានមេត្តាចិត្តមិនមានកំណត់ ជាសាសនាប្រកាសសេចក្តីរំលត់ទុក្ខ និងបដិបទានាំទៅកាន់ទីរំលត់ទុក្ខដល់សត្វលោកទូទៅ ។

ការដែលនឹងរកដើមគំនិត ដែលពុទ្ធសាសនាគិតបង្កើតឲ្យមានវិជ្ជាខាងព្រះអភិធម្ម និងចិត្តវិជ្ជារបស់ពុទ្ធសាសនាឡើងនេះនឹងនាំឲ្យមានសេចក្តីតវែងឆ្ងាយទូលាយណាស់ ។ ក្នុងទីនេះ គ្រាន់តែពន្យល់ថា វិជ្ជាទាំងពីរនេះកកើតប្រភពឡើង មានទំនងទាក់ទងមកអំពីគម្ពីរឧបនិស័ទ (និយាយអំពីព្រហ្មវិទ្យា) និងលទ្ធិម៉ាតេរីយ៉ាលិស្មសង្ខ្យា (Matérialisme de la Sankhya) ប៉ុន្តែពុទ្ធសាសនាមិនទទួលយកលទ្ធិសែនព្រេនដែលជាទំនៀមទម្លាប់និងលទ្ធិសាសនាហិណ្ឌូ (ព្រាហ្មណ៍) នោះឡើយ ពុទ្ធសាសនារើសយកតែវិជ្ជាជាន់ខ្ពស់ ជារបស់លទ្ធិសាសនាទាំងនេះមកប្រើប្រាស់រៀបចំជាវិជ្ជាព្រះអភិធម្ម និងវិជ្ជាដែលនិយាយពីចិត្ត ។

សេចក្តីប្រកាសជាដម្បូងរបស់ព្រះពុទ្ធសាសនា គឺសេចក្តីពិតដ៏ប្រសើរ ៤ ប្រការ ឬអរិយសច្ច ៤ ដែលពោលពីកំណើតនៃសេចក្តីទុក្ខ គឺ

១ — សេចក្ដីទុក្ខត្រូវមានប្រចាំនឹងជីវិតសត្វក្នុងលោក ។

២— ជីវិតបុរសបុគ្គលកើតមកក្នុងលោកជាប់ទាក់ទងមកអំពីតណ្ហា ។ នេះតែងចងភ្ជាប់ជីវិតបុគ្គលនឹងកង់កាំនៃសង្សារចក្រ ។

៣ — ការលះបង់តណ្ហានេះចេញបាន ជាហេតុផ្ដាច់ជីវិតនេះ (មិនឲ្យទៅកាន់ភពថ្មី ) ។

៤ — ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាសផ្លូវរំលត់ទុក្ខ ។

ព្រះពុទ្ធសាសនានិងព្រះធម៌តែងប្រកាសបើកផ្លូវនាំទៅកាន់ទីរំលត់ ដល់ពុទ្ធបរិស័ទទូទៅ ។ ចំណែកឯអ្នកទើបចូលមកកាន់ពុទ្ធសាសនា ត្រូវប្ដេជ្ញាខ្លួនជាឧបាសក ចំពោះព្រះសក្យមុនី ដោយបញ្ចេញពាក្យ ប្រគល់ខ្លួនដល់ព្រះរត្នត្រ័យថា ខ្ញុំព្រះករុណាសូមចូលជ្រកកោនចំពោះ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរឭក ។

ព្រះសង្ឃ ឬក្រុមជនទុំដ៏សុចរិតនេះហើយ ដែលលោកទ្រទ្រង់ពុទ្ធ-សាសនាទុកឲ្យគង់វង្សស្ថិតស្ថេរហូតមក ហើយដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិតាមច្បាប់ព្រះពុទ្ធសាសនា-មិនឲ្យកើតកើនផ្ដេសផ្ដាស ដែលនាំឲ្យខូចខាតដល់ក្រឹត្យវិន័យឬក្រុមពួកពុទ្ធបរិស័ទ ។ ហេតុនេះបានជាពួកសាវករបស់ព្រះសិទ្ធត្ថមានកំឡាំងកសាងវិហារ សាលា វត្តក៏ឡើងជាចំនួនច្រើន ។ ប៉ុន្តែបើពោលតាមយោបល់របស់លោកប៊ែរស៊ុង (Mr. Bergson)

វិញ លោកអ្នកប្រាជ្ញធំនេះយល់ថា សាសនាគ្រិស្ដជាសាសនាជាន់ខ្ពស់ ៗ ជាងសាសនាទាំងអស់ ព្រោះគ្រិស្ដសាសនាប្រកបដោយវត្តបដិបត្តិដ៏ធំទូលាយហើយដោយមានបន្ទាល់សាក្សីដែលឃើញច្បាស់ គឺការកសាងអារាមឡើងជាចំនួនច្រើន ។ បើលោកបែរសុំឃើញដំខ្សែសាសនានៅទឹងចំនួនវត្តអារាម ពុទ្ធសាសនាក៏មិនចាញ់គ្រិស្ដសាសនា ឯចំនួនពុទ្ធបរិស័ទក៏មានច្រើន នៅប្រទេសខ្លះដូចជាស្រុកទីបេត៍ មានចំនួនបរិស័ទចូលទៅនៅកប់រៀនសូត្រក្នុងវត្តដល់ទៅ ១ ភាគក្នុង ៣ ភាគនៃបណ្ដាប្រុសក្នុងស្រុក ចំណែកឯស្រុកដទៃទៀតដូចជានៅស្រុកសៀមនិងស្រុកខ្មែរ មានចំនួនក្មេងកំលោះចូលទៅនៅបួសរៀនក្នុងវត្តស្ទើរតែគ្រប់រូប (យើងយល់ថាមិនចាញ់គ្រិស្ដសាសនាត្រង់កន្លែងណាសោះឡើយ)។

ព្រះពុទ្ធជាម្ចាស់ក៏ដូចជាព្រះយេស៊ូដែរ មិនគត់ត្រាឬសរសេរក្បួនខ្នាតទុកដោយខ្លួនលោកឡើយ ។ ឯក្បួនច្បាប់ដែលបានតរតរិកទុកដល់សព្វថ្ងៃនេះ ដោយពួកសាវ័ករបស់លោកបានរួបរួមចងក្រងទុកមកជាក្បួនច្បាប់ សម្រាប់ជនជាន់ក្រោយរៀនសូត្ររហូតមក ។ ឯក្បួនច្បាប់ពុទ្ធសាសនា នៅចំណែកខាងត្បូងរំលែកចែកចេញជារឿងធំៗ មាន ៣ ចំណែកហៅថា ត្រៃបិដក ប្រែថា "កញ្ជើបី" ។

១— វិនយបិដក ជាច្បាប់សម្រាប់ព្រះសង្ឃចែកចេញជា ៣ ក្រុមគឺ

ក— បាតិមោក្ខ ច្បាប់ព្រះភិក្ខុសង្ឃ ។

១ — មហាវគ្គ ច្បាប់បំបួសនឹងច្បាប់សិក្ខាសាជីវៈរបស់ភិក្ខុទាំងឡាយ ។

គ --ចុល្លវគ្គ ច្បាប់សម្រាប់ប្រើប្រាស់គ្រឿងបរិក្ខារទូទៅ ។

២ — ព្រះសូត្រជាចំនួនច្រើនជាព្រះឱវាទរបស់ព្រះសម្ពុទ្ធ តាំងអំពីទ្រង់សំដែងព្រះបឋមទេសនានៅក្រុងពារាណសី រហូតដល់ចូលព្រះនិព្វានជាទីបំផុត ។

៣ — អភិធម្ម បែបរៀនខាងបរមត្ថវិជ្ជា ។

គម្ពីរដីកាអស់នេះហើយដែលជាគោលសំខាន់សក្តិសិទ្ធិនៃព្រះពុទ្ធសាសនា នាំឲ្យកើតក្បួនច្បាប់អក្សរសាស្ត្រយ៉ាងស្តុកស្តម្ភឡើងទៀតផង ។

# ដំណឹងផ្សេងៗ



៤១ — អំពីអាភាហវិភាហមង្គល

(មើលសេចក្ដីពន្យល់ទំព័រ ២៩)

# ព្រះពុទ្ធសាសនាបាត់ទៅពីប្រទេសឥណ្ឌា
# ដោយហេតុយ៉ាងណា?

*ខេមររង្សី ប្រែនិងរៀបរៀង*

( តនិងចប់ )

លទ្ធិមហាយានបានចាប់ចំរើនឡើងយ៉ាងរួសរាន់នេះ បានកសាងបដិមាឡើងជាច្រើន តាមដោយពិតនោះ ព្រះពុទ្ធបដិមាអង្គដំបូងនោះបានចាប់កសាងឡើងតាំងអំពីក្នុងសម័យនៃព្រះបាទកនិស្កៈនៃនគរកុសាណ តាំងអំពីលទ្ធិមហាយានចាប់ផ្សាយឡើងៗ កាលណា ការសាងព្រះរូបបដិមា ព្រះពោធិសត្វឡើងមានចំនួនច្រើនស្ទើកស្ទាស់ នៅឱកាសដែលកំពុងនិយមសាងព្រះបដិមាពោធិសត្វអស់នោះ ក៏កើតគំនិតគិតកសាងរូបទេវធីតាផ្សេងៗថែមទៀតជាដំណាង ដូចជា "ប្រជ្ញាបារមិតា" "តារា" និង "វិជយ" ដើម្បីជាទីគោរពក្រាបសំពះ ៗ ឯវិហារ, សាលាសម្រាប់ពោធិសត្វអស់នេះ គេក៏កសាងឡើងនៅស្ថានទីខ្ពស់ ទាំងទ្រព្យសម្បត្តិជាចំនួនច្រើនបានចាយរាយទៅក្នុងការប្រកបពិធីផ្សេងៗ ព្រះសូត្រវែងៗ ចំពួក "បានបុណ្យ" ក៏មានចំនួនច្រើនជាងខាងពួកហីនយាន គេក៏បានតែងឡើងជាចំនួនច្រើនសូត្រ បណ្ដាសូត្រអស់នេះសុទ្ធតែសូត្រវែងៗ ហើយលំបាកសូត្រផង ទើបបង្រួមសូត្រនីមួយៗ ឲ្យសល់នៅត្រឹម ២-៣ បន្ទាត់ប៉ុណ្ណោះ លុះតមកព្រះសូត្រដែលនៅសល់ត្រឹម ·៣ បន្ទាត់នោះក៏នៅតែយល់ថាវែងពេក ទើបគេនាំគ្នាកាត់ព្រះសូត្រអស់នោះទៅជាមន្ត មានត្រឹម ២-៣ តួអក្សរវិញ ដើម្បីឲ្យស្រួលទន្ទេញ (ដូចជាក្នុងវេលានេះ "ឱម មណីបទ្មេហ៊ុំ" សម្រាប់ពួកទីបេតាំង "នមោ

ហូ វេង កេ ក្យូ" សម្រាប់ពួកជប៉ុននិកាយ និជិរេន-អ្នកប្រែ) ។ បណ្ដាមន្តទាំងអស់នេះដល់តមកក្នុងវេលាក្រោយ ក្លាយទៅជាទីកើតនៃលទ្ធិវិធីមួយទៀតហៅថា "មន្តយាន" ឬជាវិធីមួយដែលធ្វើឲ្យបានសម្រេចនូវវិមុត្តិភាពដោយការទន្ទេញត្រឹម "មន្ត" នោះប៉ុណ្ណោះ ។

បានពោលមកពីខាងដើមរួចហើយថា ពួកហីនយានទទួលកាន់វិធី ៣ យ៉ាង ដែលជាឧត្តមគតិនាំឲ្យបានសម្រេចវិមុត្តិតាមចំណង់របស់អ្នកដែលប្រាថ្នា ។ ឧត្តមគតិរបស់និកាយនេះជាទំនាស់គ្នានឹងនិកាយមហាយានដែលទូន្មានថា មនុស្សគ្រប់ៗរូបទុកជាមាននិស្ស័យ ឬឥតនិស្ស័យក៏ដោយ កាលបើខំបំពេញតាមលំអានរបស់គេហើយ តែងបានសម្រេចដល់វិមុត្តិទាំងអស់ ក្រៅអំពីនេះលទ្ធិមហាយានទូន្មានទៀតថាអ្នកដែលខំបំពេញសេចក្ដីព្យាយាមដើម្បីឲ្យបានសម្រេចដល់ពុទ្ធភូមិនោះ មិនបាច់ប្រតិបត្តិតាមវិន័យសិក្ខាសព្វគ្រប់ទេ ហេតុនេះហើយបានជាការប្រតិបត្តិតាមធម្មវិន័យក៏កាន់តែខ្ជីខ្ជាឡើងជាលំដាប់ដរាបដល់ការផឹកទឹកស្រវឹងនឹងប្រព្រឹត្តអបាយមុខផ្សេងៗក៏មានឡើង ។ ពួកដែលស្ម័គ្រចិត្តចូលជាសមាជិកក្នុងលទ្ធិនេះ គេត្រូវពួកនេះពិនិត្យល្បងជាច្រើនជាន់ច្រើនថ្នាក់ ទើបចូលទៅនៅក្នុងពួកគេបាន ។ ពួកនេះក្នុងកាលដែលមានមនុស្សគោរពរាប់អានតិច គេនាំគ្នាផ្សាយលទ្ធិរបស់គេដោយឧបាយស្ងាត់ៗហើយប្រកាស

ខ្លួនឲ្យគេដឹងថា ខ្លួនជាអ្នកកាន់លទ្ធិមហាយាន ឬទឹងពោលថា ពួកនេះយកលទ្ធិមហាយានជាគ្រឿងបំបាំងមុខក្នុងការប្រកាសផ្សាយលទ្ធិរបស់ខ្លួន ហើយនាំគ្នាប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ ដូចមានពណ៌នាមកនេះ ។

ពួកមហាយាននេះមិនមានវិន័យជារបស់ខ្លួនទេ ទើបទទួលយកវិន័យរបស់ពួក "សព៌ាស្តិវាទ" មកប្រើ ហើយនាំគ្នាបព្វជាឧបសម្បទាតាមវិន័យអស់នេះ ក្រៅពីប្រតិបត្តិតាមលទ្ធិពោធិសត្វដូចពោលរួចមកហើយ ពួកនេះនាំយកលទ្ធិទំនៀមរបស់ពួក "តន្ត្រិក" (Tantric) និង "វជ្រយាន" (vajrayana) ដែលជាលទ្ធិអាក្រក់ៈថាកទាបយកមកប្រើប្រាស់ទៀតផង ។ កាលព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌាចូលមកប្រឡូកប្រឡំនឹងលទ្ធិទាំងពីរនេះ រមែងញុំាងព្រះពុទ្ធសាសនាឲ្យដល់នូវសេចក្តីវិនាសដោយងាយ ។

ក្នុងសតវត្សរ៍ទី ៨ នៃគ្រិស្តសករាជ ពុទ្ធសាសនាគ្រប់ៗនិកាយប្រែប្រឡប់មកកាន់លទ្ធិមហាយានៗនេះ ក្នុងខណៈនោះគ្រាន់តែជាឈ្មោះ ១ របស់លទ្ធិ "វជ្រយាន" ប៉ុណ្ណោះ ។ ឯកាទជម្ពូទ្វាន ឬធម៌អាថ៌ផ្សេងៗរបស់ព្រះពុទ្ធ គេនាំគ្នាបោះបង់ចោលអស់ បែរជានាំគ្នាយកចិត្តទុកដាក់គោរពលទ្ធិផ្តេសផ្តាសអស់នោះ ។ ព្រះភិក្ខុសង្ឃក្នុងខណៈនោះទុកជាស្លៀកដណ្តប់សំពត់កាសាវពស្ត្រតាមព្រះពុទ្ធក៏ដោយ តែចិត្តគំនិតរបស់

លោកអស់នោះពេញទៅដោយសេចក្ដីជ្រះថ្លាក្នុងលទ្ធិវជ្រយាន ។ អ្នកផ្សាយលទ្ធិនេះ ទុកជាអ្នកប្រាជ្ញឬជាគរឯកក៏មានទំនងមិនខុសឆ្ងាយពីមនុស្សឆ្កួតលេលាប៉ុន្មានទេ ភាសាសំដីដែលគេនិយាយនោះជាភាសាអាថ៌កំបាំង (កម្រនឹងចូលចិត្តសេចក្ដីបាន) ឬដែលហៅថា “សន្ធយភាសា” ជាសំដីដែលមានសេចក្ដីប្រែបានជា ២ ផ្លូវ ទាំងខាងផ្លូវកាមារម្មណ៍ ទាំងខាងផ្លូវចិត្តវិជ្ជា ។

ក្នុងសតវត្សរ៍ទី ៧ នៃគ្រិស្តសករាជព្រះបាទ “ឥន្ទ្រភូតិ” ទ្រង់គ្រងនគរឧរិស្ស (Orissa) នឹងអ្នកប្រាជ្ញឯទៀតនាំគ្នាព្យាយាមធ្វើឲ្យប្រជាជនយល់ថា វិធីរបស់លទ្ធិ “តន្ត្រិក” នេះអាចប្រសិទ្ធីញុំាងអ្នកប្រតិបត្តិឲ្យសម្រេចបានគ្រប់ផ្លូវ ។ ក្នុងការសរសេរសេចក្ដីអ្វីមួយ ពួកនេះនិយមប្រើពាក្យប្លែក ៗ ដែលមានសេចក្ដីជ្រៅកំបាំងលាក់លៀបដាប់តាមក្រោយផង ដូចជាប្រើពាក្យថា “ឧបាយ” សម្រាប់បុរស “ប្រាជ្ញា” សម្រាប់ស្ត្រី “អម្ឫត” សម្រាប់សុរា ដូច្នេះជាដើម ។ លុះតអំពីសតវត្សរ៍ទី ៨ ដល់ទី ១២ នៃគ្រិស្តសករាជ ពុទ្ធសាសនានៅប្រទេសឥណ្ឌានោះក៏ដល់នូវសភាពស្មោកគ្រោកគ្រខ្វក់ ទាំងពុលស្រវឹងជាទីបំផុត ។

ក្នុងលទ្ធិ “វជ្រយាន” នេះមានលោក “អ្នកសម្រេច” ឬដែលហៅថា “សិទ្ធ” ចំនួន ៨៤ អង្គ អស់លោកអ្នកសម្រេចនេះហើយដែល

មានការចិញ្ចឹមជីវិតប្លែកៗ ច្រើនតែនៅក្នុងព្រៃហើយមិនប្រើគ្រឿងបិទបាំងកងកាយ ប្រើលលាក្បាលខ្មោចជាភាជនៈសម្រាប់ដាក់ទឹកស៊ុក ពួកនេះនៅរួមគ្នាដោយឡែក ប្រសិនបើអ្នកណាមួយរំលងចូលទៅក្នុងដែនជាលំនៅរបស់គេហើយ គេខឹងជាពន្លឹក ។

## អំពីប្រជាជនឥណ្ឌៀក្នុងសម័យនោះ

លុះនាំគ្នាគោរពក្នុងលទ្ធិតន្ត្រិកនេះទៅ រំលងប្រព្រឹត្តតាមធម្មក្រិត្យ ឬសីលធម៌ល្អតទៅទៀត ប្រែចិត្តគំនិតទៅនិយមរាប់អានក្នុងអំពើអាក្រក់នានាប្រការវិញ ។

ពួកលទ្ធិតន្ត្រិកនេះមានឥទ្ធិពលធំណាស់ក្នុងជាន់នោះ ទើបធ្វើឲ្យស្តេចអង្គខ្លះនៅសម័យនោះគាំទ្រទទួលទំនុកបម្រុង ផប់លៀងពួក "អ្នកសម្រេច" ព្រមទាំងបរិសទ្យបរិវារជាសិស្សានុសិស្ស ពួកនេះវាត់ធ្វើពិធីកម្មផ្សេងៗ តាមលទ្ធិតន្ត្រិក ដើម្បីស្តេចជាម្ចាស់ផែនដី ចួនកាលមានស្តេចអង្គខ្លះលើកកូនក្រមុំឲ្យទៅ "អ្នកសំរេច" អស់នោះក៏មាន ។

ក្នុងខណៈដែលប្រជាជនឥណ្ឌៀកំពុងពុលស្រវឹង ប្រាសចាកសីលធម៌ទីពឹងអប់រំចិត្ត ថែមទាំងលទ្ធិសាសនាព្រាហ្មណ៍ ដែលមានការប្រកាន់វណ្ណៈជាធំនោះ បានគ្របសង្កត់ពួកនេះ ឲ្យកាន់តែថោកថយចុះទៅ

ទៀតជាលំដាប់ ៗ ក្នុងខណៈដែលពួកនេះកំពុងពុលស្រវឹងនឹងលទ្ធិតន្ត្រិក នោះ កងទ័ពដ៏ធំសំបើមរបស់ពួកមុស្លិមក៏លើកពលមកពីទិសខាងលិចឆៀងខាងជើង ប្រហែលនឹងខ្យល់ព្យុះមួយយ៉ាងធំ បក់បោកសំអាតផ្ទៃមេឃឲ្យស្រឡះទៅដោយឆាប់រហ័ស បណ្ដាវិហារសាលា កុដិ និងទ្រព្យសម្បត្តិជាគ្រឿងបូជាដ៏មានដំឡៃក្រៃលែងក្នុងគ្រានោះ ដែលពុទ្ធបរិស័ទបានសន្សំទុកមកកប់ដោយរយឆ្នាំឡើងទៅ ក៏ត្រូវពួកមុស្លិម (មហាហ្មុត) បំផ្លាញខ្ទេចខ្ទីអស់ រូបព្រះពោធិសត្វនិងទេវតាប្រុស-ស្រីគេក៏បោះចោល ហើយដុតបំផ្លាញអស់ឥតមានសល់ មិនមានវត្ថុអ្វីជាគ្រឿងស័ក្តិសិទ្ធិសំរាប់តទល់ឬការពារពួកអ្នកចម្បាំងមុស្លិមអស់នោះបានឡើយ មន្តអាគមឬពិធីកម្មផ្សេង ៗ តាមលទ្ធិ "តន្ត្រិក" ដែលតែងប្រកាន់ថាខ្លាំងពូកែនោះ ក៏មិនអាចជួយការពារទប់ទល់បានឡើយ ៗ ឯពួក "អ្នកសម្រេច" ឬ "អាចារ្យ" សំខាន់ៗ អស់នោះត្រឡប់ជានាំគ្នាកោតខ្លាចបារមីនៃពួកបច្ចាមិត្រអស់នោះ នៅទីបំផុតក្នុងខណៈដែលពួក "តន្ត្រិក" កំពុងធ្វើពិធីពលិកម្មនឹងសូត្រមន្តយ៉ាងក្អេនក្អេចខ្លួនទៅនោះ ផ្ទៃផែនដីនៅប្រទេសឥណ្ឌាខាងជើងក៏ធ្លាក់របូតទៅនៅក្នុងកណ្ដាប់ដៃពួកមុស្លិមយ៉ាងងាយៗ ៗ

ឧទាហរណ៍ដែលមើលឃើញច្បាស់ក្នុងការប្រកាន់លទ្ធិផ្ដេសផ្ដាសឥតហេតុផលនោះ យើងបានមើលឃើញករណីយកិច្ចរបស់ពួកក្សត្រវង្ស

“ប៉ាល:” នៃក្រុងពិហារ (Bihar) ក្សត្រអស់នេះនាំគ្នាជឿប្រកាន់ថា ទេព្តាប្រុស-ស្រីក្នុងលទ្ធិ “តន្ត្រិក” អាចជួយការពារឲ្យផុតពីភ័យអន្តរាយទាំងពួងបានជាប្រាកដ ទើបទ្រង់កសាងវិហារធំមួយសម្រាប់លទ្ធិ “តន្ត្រិក” ក្នុងនគរ “ឧទន្តបុរី” តែតមកមុខគួរឲ្យសង្វេគណាស់ ដោយមានក្សត្រអង្គមួយចុងព្រះរាជវង្សនេះព្រមចុះចាញ់យ៉ាងរាបទាប ចំពោះមុខមេទ័ពមូស្លីមម្នាក់ ដែលមានពលទាហានសេះត្រឹម ២០០ នាក់ប៉ុណ្ណោះ ៗ ឯរូបបដិមារបស់ទេពធីតាឈ្មោះ “តារា” ដែលធ្លាប់ប្រកាន់ថាជារូបស័ក្តិសិទ្ធិណាស់ ក៏ត្រូវដៃពួកមូស្លីមទំលាយចោលអស់ទៅ ភិក្ខុ-សង្ឃរាប់ជាចំនួនពាន់ ក៏ត្រូវពួកមហាហ៊ុតកាប់សម្លាប់ចោលឥតត្រាប្រណី វិហារសាលាកុដិក៏ត្រូវដុតបំផ្លាញចោលអស់រលីង ៗ ទុកជាមានការបង់ខាតនាំឲ្យវិនាសយ៉ាងធំ ស្ទើរតែមិនមានអ្វីទុកជាកេរ្តិ៍ដំណែលរបស់ពុទ្ធសាសនាក៏ពិតមែន ប៉ុន្តែបានប្រយោជន៍ដោយយ៉ាងដែរ គឺធ្វើឲ្យប្រជាជនដឹងខ្លួនថាខ្លួនអាល័យតែរវើរវាយជឿផ្កាប់មុខក្នុងលទ្ធិ “តន្ត្រិក” នឹងជាហេតុឲ្យប្រជាជនភ្ញាក់រឭកអំពីសន្លប់មកជាយូរអង្វែងនោះឡើងវិញបាន ៗ

មុននឹងបញ្ចប់ប្រវត្តិសាស្ត្រដោយសង្ខេប ដែលពេញទៅដោយសេចក្ដីចំរើនរុងរឿងខ្ពង់ខ្ពស់ នឹងការសាបសូន្យទៅមុខគួរឲ្យអាណោច

អាធម្ម នៃព្រះពុទ្ធសាសនាក្នុងរយៈកាលដែលពោលមកហើយខាងដើម នេះ យើងឱកាសបន្តិចស្រង់យកប្រស្នាមួយមកវិនិច្ឆ័យជាមុនសិន មុននឹងបញ្ចប់រឿងនេះ ដើម្បីដោះសេចក្ដីសង្ស័យទៀងផ្ទាល់ទាំងខាងពួកព្រាហ្មណ៍ទាំងខាងពួកពុទ្ធសាសនិកជន ទាំងពីរពួកនេះត្រូវពួកមុស្លិមបៀតបៀនដូចគ្នាហើយត្រូវកាប់សម្លាប់មិនរើសមុខដូចគ្នា ចុះហេតុអ្វីខាងសាសនាព្រាហ្មណ៍នៅមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ចំណែកខាងពុទ្ធសាសនាមិនមានអ្វីសេសសល់នៅសោះឡើយ ។ ។

ការឆ្លើយដោះប្រស្នានេះមិនសូវជាលំបាកប៉ុន្មានទេ គឺពួកសាសនាព្រាហ្មណ៍ សូម្បីខ្លួនជាឃរាវាសក៏មាននាទីជាអ្នកការពារសាសនាយ៉ាងម៉ឺងម៉ាត់ រីឯចំណែកខាងពួកពុទ្ធសាសនិកជនវិញ ករណីយកិច្ចដ៏សំខាននេះធ្លាក់នៅក្នុងបន្ទុករបស់ពួកសមណៈតែប៉ុណ្ណោះ ៗ មួយវិញទៀតការបរិភោគ និងការស្លៀកពាក់របស់ពួកព្រាហ្មណ៍មិនមែនជាគ្រឿងប្លែកភ្នែកដូចជាពួកស្រមណៈក្នុងព្រះពុទ្ធសាសនា ដែលជាអ្នកទ្រទ្រង់សំពត់ព័ណ៌លឿង ហើយនៅរួបរួមគ្នាក្នុងអារាមតែមួយ ៗ ពិតមែននៅក្នុងឱកាសនោះ មានពួកព្រាហ្មណ៍ខ្លះជាអ្នកកាន់លទ្ធិ "តន្ត្រិក" ខ្លះដែរ តែនៅមានពួកព្រាហ្មណ៍ ដែលតាំងនៅក្នុងសីលធម៌ល្អជាទីគោរពរបស់ប្រជាជនទាំងឡាយក៏គង់នៅមាន ឯពួកភិក្ខុក្នុងសម័យនោះ ជាអ្នកទម្រន់

# អំពីស្រុកចិន

ពិតមែនតែមានជាតិចិនច្រើននៅស្រុកខ្មែរយើង ប៉ុន្តែយើងស្គាល់ស្រុកនេះតិចណាស់ ។ ព្រះកជបណ្ណាល័យទើបនឹងបានទទួលសៀវភៅកូម៉ិសាស្ត្ររបៀបជំនួញនៅស្រុកចិន ដែលលោករ៉េណោយុន បានរៀបរៀង ហើយបោះពុម្ពនៅក្រុងសៀងហៃ ។ យើងសូមអធិប្បាយអំពីអាណាខេត្តខ្លះដែលនៅក្នុងនគរធំនេះ ជូនលោកអ្នកដែលមើលសៀវភៅកម្ពុជសុរិយា ទាំងអម្បាលម៉ាន សេចក្តីអធិប្បាយ គឺយើងដកស្រង់អំពីសៀវភៅកូម៉ិសាស្ត្ររបស់លោករ៉េណោយុននេះ ។

តាំងពី គ. ស. ១៩១៦ ស្រុកចិននៅជាស្រុករេពុយព្លិក មានខេត្ត ២៨ មានស្រុកឯទៀតនៅក្រោមឱវាទ មានស្រុកមង្គូលីនឹងស្រុកទីបេតជាដើម នគរចិនបានជាឈ្មោះដូច្នេះ មកអំពីចង់ទុកកេរ្តិ៍ឲ្យដល់ពង្សមហាក្សត្រមួយផ្សេងនៅស្រុកខ ប៉ុន្តែគេហៅស្រុកចិនថា ស្រុកព្រៃឬ អាណាចក្រកណ្តាល ។

ពីខាងត្បូងស្រុកចិននៅជាប់នឹងស្រុកដែលយើងបានស្គាល់ទាំងអស់គ្នា គឺស្រុកភូមាដែលជាស្រុកចំណុះអង់គ្លេស ហើយនឹងស្រុកតុងកឹង ដែលនៅប្រទេសឥណ្ឌូស៊ិនខាងជើង ពីខាងលិចស្រុកចិនជាប់នឹងស្រុកឥណ្ឌៀរបស់អង់គ្លេស ពីខាងកើតជាប់នឹងមហាសមុទ្រមួយយ៉ាងធំ គឺសមុទ្រចិន ។

ពន់ពេកក្នុងការប្រព្រឹត្តប្រតិបត្តិតាមសីលធម៌ ហើយនាំគ្នានិយមលទ្ធិ “តន្ត្រិក” ហេតុនេះបានជាគមកសម័យក្រោយ ពួកភិក្ខុសង្ឃដែលចាំ ព្យាយាមកសាងវិហារ សាលា ដែលវិនាសខូចខាតទៅដោយស្នាដៃ បច្ចាមិត្រ ទើបឥតមានទាយកទាយិកាជួយទំនុកបំរុងសោះឡើយ ព្រោះ គេអស់សេចក្ដីជ្រះថ្លានឹងខ្លួនដែលជាអ្នកប្រព្រឹត្តអាក្រក់ ខូចកេរ្តិ៍ឈ្មោះជា យូរអង្វែងមកហើយ ។

បណ្ដាបុរាណវត្ថុផ្សេង ៗ ដែលជីកទៅប្រទះឃើញនៅម្រឹគទាយវន (ឥឡូវនេះហៅសារណាថ) មិនមានបុរាណវត្ថុដែលចាប់កសាងក្នុងសម័យ ក្រោយសតវត្សរ៍ទី ១២ នៃគ្រិស្តសករាជឡើយ ។ វិហារដែលកសាង ឡើងនៅសម័យក្រោយបង្អស់ក្នុងព្រះពុទ្ធសាសនា ជារបស់ព្រះរាជិនី “កុមារទេវី” ដល់មកសម័យនេះ ក៏គប់លិចនៅទីដីព្រមទាំងសំណាក បុរាណវត្ថុឯទៀត ៗ ជាធម្មតា តែចំណែកឯវិហារ “វិសូនាថ” ដ៏មានដំឡៃ របស់ពួកហិណ្ឌូ ដែលតាំងនៅមិនសូវឆ្ងាយពីសារណាថប៉ុន្មានគីឡូម៉ែត្រ ទេ តាំងធ្លាប់ត្រូវពួកមូស្លីមកំទេចចោលដល់ទៅ ៣ លើក តែគេបាន រៀបចំកសាងឡើងវិញដល់ទៅ ៣ ដងដែរ ដល់មកឥឡូវនេះក៏នៅគង់ ទ្រង់ល្អ ។

លោកសង្ឃឡាម៉ា “តារានាថ” (Târânatha) បានសរសេរទុក ក្នុងសៀវភៅ “ប្រវត្តិសាស្ត្រពុទ្ធសាសនា” របស់លោកថា “បណ្ដាពួក

សង្ឃ (ពុទ្ធសាសនា) កាលត្រូវពួកមុស្លិមសម្លាប់នឹងប្រទូសរ៉ាយ កាលពីសតវត្សរ៍ទី ១២ នោះ ក៏នាំគ្នារត់ទៅនៅស្រុកទីបេត៍ខ្លះ នឹងប្រទេសឯទៀតៗខ្លះ ក្រៅប្រទេសឥណ្ឌា ។ កាលបើពួកព្រះសង្ឃមិនមានហើយ ឯវិហារសាលាផ្សេងៗ ក៏ត្រូវគេកំទេចបោលអស់ទៅ ពួកពុទ្ធសាសនិកជនគោរពតែនាំគ្នាប្រែប្រួលទៅតាមហេតុការណ៍ក្នុងជាន់នោះ ហើយមានចំនួនច្រើនដែលនាំគ្នាទៅចូលកាន់លទ្ធិសាសនាព្រាហ្មណ៍ ព្រោះពួកព្រាហ្មណ៍ក៏ជាជាតិជាមួយ ទាំងមានការទាក់ទងគ្នាតាំងពីដើមរហូតមក បំណែកពួកដែលសេសសល់ ក៏ប្រែត្រឡប់ប្ដូរត្រូវបង្គាប់ឲ្យកាន់សាសនាមហាហ្មត់ទាំងអស់ ដែលជាសាសនាមានឫទ្ធិអំណាចធំក្នុងសម័យនោះ ហេតុនេះហើយបានជាពុទ្ធសាសនារលត់សាបសូន្យទៅពីប្រទេសឥណ្ឌា រលីងដែលជាស្រុកកំណើតរបស់ខ្លួន ។

ទេសរង្សី

ប្រែចេញពីកាសែតធម្មចក្ក ប្រចាំខែអាព្រិល - ម៉េ ១៩៣៩ ដែលសាមណេរសៀម ១ រូប នៅស្រុកសារណាថ ប្រទេសឥណ្ឌាប្រែចេញពីភាសាអង់គ្លេស ដែលមានចុះផ្សាយក្នុងទស្សនាវដ្ដីស្រុកលង្កា ។



១២ — អំពីទ្រង់ជួបប្រះនឹងមនុស្សជរា

(មើលសេចក្ដីពន្យល់ទំព័រ ២៩)

## ១០ — អំពីការទ្រង់បាញ់ប្រឡងធ្នូសរ

ព្រះបរមពោធិសត្វទ្រង់ចាប់ធ្នូនឹងកូនសរដែលគេដំឡើងថ្វាយ ហើយព្រះអង្គទ្រង់បាញ់ទៅ កូនសរនោះបានទម្លុះស្គរដែក ៧ ជាន់ ដែលគេធ្វើជាយន្តរូបជ្រូកព្រៃ ហើយបានទម្លុះដីបាត់ទៅទៀត ។

(រឿងនេះមិនមានសេចក្ដីដំណាលក្នុងគម្ពីរប៉ែកខាងហីនយានទេ) ។

## ១១ — អំពីអាវាហវិវាហមង្គល

លុះដល់ថ្ងៃជាមង្គល ទើបគេនាំព្រះរាជកុមារីដែលបំរុងផ្គុំឲ្យធ្វើជាព្រះជាយារបស់ព្រះសិទ្ធត្ថរាជកុមារនោះមកចូលក្នុងព្រះរាជវាំង ។

## ១២ — អំពីការទ្រង់ប្រទះនឹងមនុស្សជរា

ក្នុងខណៈនោះ ព្រះពោធិសត្វស្ដេចយាងចេញពីក្រុងទៅ ព្រះអង្គបានទតឃើញមនុស្សចាស់ជរាម្នាក់មានស្បែកជ្រីវជ្រួញ យារសក់ស្កូវស្រពោន ខ្នងកោងកុក មានជង្គង់ទន់រវៀច ដៃកាន់ឈើច្រត់ មានធ្មេញរបំប្រប់ សព្វសព៌ាង្គកាយ ។

## ១៣– អំពីការទ្រង់ប្រទះនឹងមនុស្សជម្ងឺ

ក្នុងសម័យមួយទៀត ព្រះពោធិសត្វស្តេចចេញទៅ ទ្រង់ទតឃើញមនុស្សឈឺម្នាក់នៅទីនគរ មានជម្ងឺជាទម្ងន់ មានទុក្ខវេទនាយ៉ាងខ្លាំង ដកដង្ហើមចេញចូលបានដោយលំបាកពន់ពេក ។

## ១៤– អំពីការទ្រង់ប្រទះនឹងមនុស្សស្លាប់

ក្នុងសម័យមួយទៀតនោះ ព្រះពោធិសត្វស្តេចយាងចេញទៅតាមទ្វារទិសខាងលិច បានទ្រង់ទតឃើញមនុស្សស្លាប់ ។

( នៅមានត )



ផ្ទះរបស់ឪពុកធំនឹងម្ដាយមីងរបស់មីលរេប៉ះរលំបាក់បែកដោយអំណាចខ្យល់

## ប្រវត្តិមីលរេប៉ះ

(តពីខ្សែ ៤ មក)

ឯពួកកូនប្រុសនឹងកូនប្រសាស្រីនឹងមនុស្សដទៃទៀត សឹងត្រូវគ្រឿងផ្ទះដែលបាក់រលំធ្លាក់មកនោះសង្កត់ស្លាប់ជាច្រើន ។ ឯម្ដាយរបស់មីលរេប៉ះ មានចិត្តត្រេកអរណាស់ ក្នុងកាលដែលបានឃើញមន្តអាគមរបស់កូនខ្លាំងពូកែ ល្មមតទល់ផល់នឹងពួកចាស់ ៗ នៅក្នុងស្រុកបាន ។

ចំណែកខាងឪពុកធំ មានបំណងនឹងសម្លាប់ប្អូនស្រីដែលជាម្ដាយរបស់មីលរេប៉ះ ក៏ប៉ុន្តែអ្នកស្រុកបាននាំគ្នាហាមប្រាមនឹងស្ដីបន្ទោសថា ពីព្រោះអ្នកឯងមិនស្មោះត្រង់នឹងសំដីរបស់ខ្លួន កាលពីមុននេះ បានជាគ្រោះថ្នាក់នេះធ្លាក់មកលើខ្លួនអ្នក ។ ពួកអ្នកស្រុកទាំងអស់បាននាំគ្នាបំបែកអ្នកវិសេសនេះ ព្រមទាំងម្ដាយនឹងប្អូនស្រីរបស់លោកឲ្យទៅនៅដោយឡែកទៅ ។ ខណៈនោះម្ដាយរបស់មីលរេប៉ះ បាននិយាយបញ្ជាក់ឲ្យកូនបានដឹងរឿងនោះ ហើយនិយាយសុំឲ្យកូនកំទេចស្រុកនោះបង់ទៅដោយវិធីបង្អុរភ្លៀងមានព្រឹលធំ ៗ ធ្លាក់ចុះមក ។ លុះអំណើះកាលតមក

ម៉ីលរេប៉ៈ ដឹងខ្លួនហើយផ្លាស់ចិត្តគំនិតជាថ្មី មានសេចក្ដីទឹកស្ដាយក្រោយ ដែលខ្លួនបានធ្វើអំពើអាក្រក់មកជាច្រើននោះ មានសេចក្ដីរំពឹងពិចារណា ចង់ប្រតិបត្តិធម៌ដែលល្អបរិសុទ្ធវិញ ។ លុះម៉ីលរេប៉ៈរិះគិតដូច្នេះហើយ ទើបចេញទៅរកលោកអ្នកប្រាជ្ញធំម្នាក់ឈ្មោះម៉ារប៉ៈ ដើម្បីធ្វើខ្លួនធ្វើជាសិស្សរបស់លោក បានទៅជួបនឹងលោកអ្នកប្រាជ្ញនោះនៅទីកាលមួយ ។

( នៅមានត )



១៣ — អំពីទ្រង់ជួបប្រទះនឹងមនុស្សជម្ងឺ

( មើលសេចក្ដីពន្យល់ទំព័រ ៣០ )

# អំពីពង្សាវតារ

## របស់ប្រទេសសាលដេនិងអស្ស៊ីរី

## (CHALDÉE ET ASSYRIE)

ក្នុងខណៈដែលពួកអេស៊ីប្ត៍ កំពុងខ្វល់ខ្វាយស្វែងរកចំណេះខាងការកសាង ការគ្រប់គ្រង និងចម្រកិត្យា នៅលើមាត់ទន្លេនីលនោះ ៗ ពួកសាលដេយ៉ាំងនិងអស្ស៊ីរីយ៉ាំង តាំងច្បាំងគ្នាមិនស្ងប់មានវេលាឈប់ខាន ហើយនៅទីបំផុតបានប្រទះឃើញវិជ្ជាលេខម្យ៉ាង ដែលហៅថា ក្បួនទន្ទួន ៗ

ហេតុដែលឲ្យយើងដឹងថា ពួកនេះនៅទីណា: យើងគ្រាន់តែស្គាល់ឈ្មោះទន្លេ ២ អន្លើជាមុនសិន គឺទន្លេអឺយហ្វ្រាតេ (Euphraté) មានបណ្តោយ ២.៨០០ គីឡូម៉ែត្រ ១ ទន្លេទីគ្រ៍ (Tigre) បណ្តោយ ២.០០០ គីឡូម៉ែត្រ ១ ទាំង ២ អន្លើនេះ មានដើមទឹកហូរធ្លាក់ពីទួលខ្ពស់ក្នុងប្រទេសអារម៉ានី (Armanie) មានផ្លូវទឹកហូរធ្លាក់ទៅមួយផ្លូវម្នាក់ គឺទន្លេអឺយហ្វ្រាតេញែកពន្លូទៅខាងស៊ីរី ទន្លេទីគ្រ៍ញែកពន្លូទៅខាងប៉ែក្ស ហើយហូរទន្ទឹមគ្នាធ្លាក់ទៅក្នុងសមុទ្រមេឌីទែរ៉ាណេ ជិតដល់ទៅសមុទ្រ មានសណ្ឋានបត់បែរកគ្នាស្ទើរតែប៉ូលប៉ុមខគ្នា នៅចន្លោះទន្លេទាំងពីរនេះមានដីកបធំមួយអន្លើប្រមាណ ២,៧០.០០០ គីឡូម៉ែត្រក្រឡា នៅ

ភ្នំទាំងឡាយនៅស្រុកចិន ដែលមានបរិបូណ៌ដោយលោហធាតុ ដែលយើងបានឮគេនិយាយញយៗនោះ គឺជង់ភ្នំហិមាល័យជាព្រំប្រទល់ស្រុកកុកនូរនឹងស្រុកទីបេត៍ ហើយភ្នំដែលខ្ពស់ជាងគេនោះមានកំពស់ដល់ ៨.០០០.ម៉ែត្រ មានជួរទួលខ្ពស់ៗនៅខេត្រយុនណាន់ ដែលជាប់មកស្រុកតុងកឹង ជួរទួលនោះមានកំពស់ ២.៣០០ ម៉ែត្រពីសមុទ្រ ។

សត្វព្រៃ — នៅស្រុកចិនមានខ្លាខិន ឃ្មុំ ខ្លាធំ រមាំង សេះលាព្រៃ ជ្រូកព្រៃ ។

សត្វស្រុក — សេះ លា ឧដ្ឋ ចៀម ពពែ សេះម្រេប (អំពេស) មានសត្វបក្សីចំនួន ១.០៣១ ពួក មានពស់និងមច្ឆាសត្វទាំងឡាយដ៏ច្រើន ។

រុក្ខជាតិ — នៅភាគខាងជើងស្រុកចិនមានគេប្លាស ស្រូវ ល្ង ស្រូវពោធិ-សាលី ម្ទេ ថ្នាំ ស្រូវមីយៀត ស្រូវអាសី (millét, arge) ឫស្សី ហើយទាំងរុក្ខផលាឯទៀតជាច្រើន ៗ នៅខាងត្បូងស្រុកនេះមានដើមត្រី អំពៅ ក្រូច តែ ចេក ហើយទាំងឈើយ៉ាងល្អៗ ។

នៅក្នុងស្រុកចិនគេឃើញមានត្បូង ដែក សំណប៉ាហាំងច្រើន មាននៅខាងត្បូងខេត្រយុនណាន់ មានមនុស្សធ្វើការលោហធាតុចំនួន ៣០.០០០ នាក់ មានស្ពាន់ សំណ អំបិល សំណមួយបែបទៀត ដែលគេយកមកសិទ្ធធ្វើជាពុម្ពអក្សរ ឯទន្លេដែលនៅក្នុងស្រុកចិនខាងទិស

តំបន់នេះ មានឈ្មោះថា "មេសូប៉ូតាមី" (Mésopotamie) ប្រែថា នៅចន្លោះទន្លេទាំងពីរ ។ ផែនដីចំណែកនេះពាសពេញទៅដោយបឹង ជ្រោះ ជ្រលង ផងអូរ តែដល់មកក្នុងកាលឥឡូវនេះជាទីក្រៀមក្រោះស្ងួតក្រទាំង តែពីដើមមកជាលំនៅនៃមនុស្សរាប់លានបានអាស្រ័យចិញ្ចឹមជីវិតក្នុងគ្រានោះ ដោយមានទឹកមានដីដ៏ជាតិល្អ ស្រូវសាលីក៏ដុះលូតលាស់ល្អ ជួនកាលនៅតំបន់ខ្លះ គេអាចដាំដំណាំក្នុង ១ ឆ្នាំ ៣ ដង ដើមឈើធំៗ មិនសូវសំបូរណ៍ទេ មានច្រើនតែដើមត្នោត តែគេប្រើការបានសព្វគ្រប់ ៗ អាកាសក្តៅណាស់ក្នុងរដូវក្តៅ រងាខ្លាំងក្នុងរដូវរងា ដោយមានខ្យល់ទិសខាងជើងបក់មកពីខ្ពួលខ្ពស់នៃប្រទេសអារម៉េនី ធម្មជាតិដីនៅតំបន់នោះធ្វើឲ្យប្រជាជនជាអ្នកមានគំនិត ហើយទឹកដីអាកាសបង្គាប់ឲ្យក្រោកធ្វើការងារជានិច្ច ។

មនុស្សដំបូងដែលមកនៅក្នុងដែននេះ គឺពួកជាតិសាលដេយ៉ាំងតាំងភូមិប្រទេសនៅជិតមាត់ទឹកចិញ្ចឹមជីវិតយ៉ាងស្ងប់ស្ងាត់ ជីកព្រែក, ទប់ទឹក, សាងក្រុង, តាំងរដ្ឋបាល, ស្វែងរកចំណេះខាងផ្លូវសាសនានិងវិជ្ជាការផ្សេងៗ កាលមនុស្សពួកនេះកាន់តែមានចំនួនច្រើនឡើងក៏នាំគ្នាឡើងមកលើបន្តិចម្តងៗ តាមបណ្តោយទន្លេទីគ្រីហើយនាំគ្នាទៅអាស្រ័យនៅតាមភូមិប្រទេសដែលដេរដាសដោយភ្នំ ទើបក្លាយទៅជាពួកមួយទៀត ហៅថា "អស្ស៊ីរីយ៉ាង" (Assyrien) តែភូមិប្រទេសដែលពួកនេះមកតាំង

នៅមិនមានដីជាតិល្អដូចរបស់ពួកសាលដេយ៉ាំង ដែលជាកន្លែងចាស់នោះទេ ពួកអស្ស៊ីរិយាងតោងអាស្រ័យពួកជាតិដទៃជួយទំនុកបំរុងដោយបច្ច័យជាគ្រឿងចិញ្ចឹមជីវិត ដោយហេតុនេះ ជនពួកនេះទើបក្លាយទៅជាអ្នកចម្បាំង ប្រកាន់ការច្បាំងជាកិច្ចមួយយ៉ាងសំខាន់ ហេតុនេះបានជាពួកសាលដេយ៉ាំងនឹងពួកអស្ស៊ីរិយាង សាងវិជ្ជាការទុកក្នុងលោកមួយផ្លូវម្នាក់ គឺពួកសាលដេយ៉ាំងបានសាងវិជ្ជាការសន្តិភាព ឯពួកអស្ស៊ីរិយាងជាពួកសាងវិជ្ជាការសង្គ្រាម ។

ប្រវត្តិសាស្ត្ររបស់ពួកសាលដេយ៉ាំងនឹងអស្ស៊ីរិយាងនេះបែកចេញជា ៥ វគ្គ គឺ ១ ពួកសាលដេយ៉ាំង ២ បាប៊ីឡោនពួកដំបូង ៣ ពួកអស្ស៊ីរិយាង ៤ ពួកនីនីវ៉ នឹង ៥ ពួកបាប៊ីឡោនធំ ៗ មានសេចក្ដីដែលគួរកត់សំគាល់ទុកមួយយ៉ាង គឺថាសេចក្ដីចំរើនរបស់មនុស្សពួកនេះមានដំណើរទៅតាមដងទន្លេពីទិសខាងត្បូងឡើងទៅទិសខាងជើង ។

ក្នុងវគ្គទី ១ ផែនដីរបស់ពួកសាលដេយ៉ាំងពេញទៅដោយស្រុកតូច-ធំ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ មានគេស្គាល់ដឹងឮច្រើននោះគឺស្រុកស៊ីប៉ួរឡា (Sirpourla) មានព្រះរាជវាំងនឹងបុរាណវត្ថុជាចំនួនច្រើន ការត្រួតត្រាស្រុកទេសចាត់តាមរបៀបស្ដេចត្រាញ់ (Monarchie féodale) ទីក្រុងច្រើនតែផ្លាស់កន្លែងរឿយៗ សេចក្ដីចំរើនរបស់មនុស្សពួកនេះផ្សាយទៅដល់សមុទ្រ មេឌីទែរ៉ាណេ ។

វគ្គទី ២ ស្រុកតូច-ធំ ដែលតាំងនៅតាមដងទន្លេអ៊ុយហ្វ្រាតនោះ កាន់តែរីកធំឡើងទាល់តែជាប់ទាក់ទងគ្នា នៅចន្លោះកណ្ដាល មានស្រុកបាប៊ីឡោនជាទីក្រុង មានព្រះចៅផែនដីគ្រប់គ្រងត ៗ មកជាច្រើនអង្គ ដែលមានព្រះកេរ្តិ៍ល្បីល្បាញជាងគេ គឺព្រះបាទហ័ម្មូរ៉ាប៊ី (Hammourabi) ទ្រង់បានតាក់តែងតែងច្បាប់សម្រាប់ស្រុកឡើង ទ្រង់បានឲ្យជីកព្រែកទប់ទំនប់ទំនុកបំរុងប្រទេសឲ្យមានសេចក្តីចំរើនរុងរឿង ។

វគ្គទី ៣ ពួកសាលដេយ៉ាំង ដែលនៅខាងជើងបានរួបរួមគ្នាជាពួកធំមួយឡើងឲ្យឈ្មោះខ្លួនថា អស្ស៊ីរីយាំងមានអំណាចផ្សាយរហូតដល់ដីកបនៅចន្លោះទន្លេទីគ្រីងទន្លេអ៊ុយហ្វ្រាត ពួកនេះបានផ្លាស់លក្ខណៈដើមរបស់ខ្លួន ដែលនៅជាជាតិសាលដេយ៉ាំងស្រឡាញ់សន្តិភាពនោះ ក្លាយទៅជាអ្នកចម្បាំងយ៉ាងអង់អាចក្លាហាន ។

## បាប៊ីឡោន

វគ្គទី ៤ ពួកអស្ស៊ីរីយាំងមានអំណាចធំបំផុត ក្នុងសម័យក្សត្រដែលគ្រងរាជ្យនៅស្រុកនីនីវ បានធ្វើចម្បាំងយ៉ាងសាហាវសំបើម ។ ក្សត្រដែលសំខាន់ៗនោះគឺសារកុង (Sargon) សេន្នាសេរិប (Sennachéribe) និងអស្សុរបានិប៉ាល (Assurabanipal) បានវាយយកផែនដីខាងឈូងសមុទ្រ

ប៉ែក្ស, សមុទ្រកាស្ពៀន, ប្រទេសអារម៉ានី, ស៊ីរី, ប៉ាលេស្ទីន, និងអេស៊ីប្ត មកនៅក្រោមអំណាចទាំងអស់ តែក្សត្រអស់នេះធ្វើឲ្យគេស្អប់ច្រើនពេក ទើបពួកបាប៊ីឡោននិងពួកម៉ែត (Mède) រួមកម្លាំងជាមួយគ្នាទំលាយអាណាចក្រអស្ស៊ីរី បំផ្លាញទីក្រុងត្រាតែកបេងទៅ កាល ៦៣ ឆ្នាំមុនពុទ្ធសករាជ ចប់វគ្គទី ៤ ដោយសង្ខេបតែប៉ុណ្ណេះ ។

វគ្គទី ៥ ពួកក្សត្រមានអំណាចពេញទីដោយបានទទួលមត៌កមកអំពីពួកអស្ស៊ីរិយាង ។ មានអំណាចគ្រប់គ្រងប្រទេសមិនបានយូរប៉ុន្មានទេ តែបានកសាងសេចក្តីចំរើនទុកជាច្រើន ។ មានក្សត្របាប៊ីឡោនមួយអង្គទ្រង់ព្រះនាមថា ណាប៊ុសូដូណូសរ (Nabuchodonosor) បានកែតព្រឹកស្រុកបាប៊ីឡោនឲ្យធំទូលាយឡើង និងធ្វើឲ្យល្អឡើងជាច្រើន តមកក្រោក្រោយធ្លាក់ទៅនៅក្រោមអំណាចរបស់ប៉ែក្ស (កាលពីពុទ្ធសករាជ ៥ ) តែបានរក្សានូវទំនៀមប្រពៃណីរបស់ខ្លួនទុកបានដោយល្អ មិនបាត់បង់ទៅណា ។

សៀវភៅដែលពួកគ្រិកតែងក្តី ព្រះគម្ពីររបស់គ្រិស្តសាសនាក្តី រូបស្នាចម្លុរូបចម្លាក់ផ្សេង ៗ ក្តី ដែលមានសល់នៅកង្ខណៈនេះ ជាសាក្សីបញ្ជាក់ឲ្យឃើញថា ពួកអស្ស៊ីរីជាពួកសាហាវបំផុត កិច្ចធុរៈដ៏សំខាន់របស់មនុស្សអស់នេះ គឺតែធ្វើចម្បាំង ។ មនុស្សពួកនេះមានរូបកាយរឹងប៉ឹង

ខែងរែងមានដុំសាច់កំឡាំងច្រើន, ច្រមុះកោង, ភ្នែកធំ, បបូរមាត់ក្រាស់, ទុកសក់វែង, ពុកមាត់ពុកចង្កាក្រញាញ់ ។ លក្ខណៈមុខមាត់ជាមនុស្សឧស្សាហ៍ម៉ឺងម៉ាត់មានចិត្តសាហាវដូចសត្វសាហាវ ។ ពួកនេះប្រកាន់ថាព្រះរបស់គេជាម្ចាស់របស់លោក ហើយមនុស្សផ្សេងជាតិគេទុកជាមនុស្សក្បត់នឹងព្រះរបស់គេទាំងអស់ ហេតុនេះបានជាគេធ្វើបាបដល់មនុស្សផ្សេងជាតិផ្សេងភាសាឥតមានចិត្តអាណិតអាសូរសោះឡើយ មនុស្សពួកនេះបានធ្វើបាបដល់ពួកអារម៉ាទីនោះ មុខគួរឲ្យស្ញប់ស្ញែងពន់ពេកជាប់នៅក្នុងពង្សាវតារលោកដរាបដល់សម័យសព្វថ្ងៃនេះ ។

មនុស្សពួកនេះយកចិត្តទុកដាក់នឹងការតែងខ្លួនណាស់ ដោយប្រើសំពត់អាវច្រើនថ្នាក់ ហើយមានផាយរកាយមានគ្រឿងប្រដាប់ មានគ្រឿងក្រអូបនឹងលាបព៌ណមុខផង ។ លំនៅច្រើនសាងដោយដីមានរូបរាង ៤ ជ្រុង មិនសូវមានបង្អួចទេ ព្រោះតាមធម្មតាមានតែពន្លឺថ្ងៃប៉ុណ្ណោះចុះចូលទៅបានតាមទ្វារ ។

ព្រះចៅផែនដីជាដំណាងព្រះ តែងស្ដេចចេញធ្វើសង្គ្រាមដោយព្រះអង្គឯង ប្រសិនបើមានពេលទំនេរពីចម្បាំងតែងស្ដេចចេញទៅបរបាញ់សត្វ ដូចជាខ្លឹង សិង្ហឬលាព្រៃ សត្វអស់នេះទុកដូចជាទន្សាយសម្រាប់ក្សត្រអស់នេះ ។ បើមិនមានចម្បាំងនឹងនេសាទសត្វព្រៃទេ ក៏មានការដប់លៀងគ្នាយ៉ាងអឹកៈធឹក ពោរពេញដោយភពបរិភោគនឹងស្រីស្នំ

ធំតូចទាំងពួង អស់នេះជាកិច្ចវត្តរបស់ពួកក្សត្រអស្សុរី មានក្សត្រមួយអង្គ ទ្រង់ព្រះនាមជាអស្សុរៈបានិប៉ាល បានឆ្លាក់ចារឹកកិត្តិគុណរបស់ទ្រង់ទុកថា យើងអស្សុរៈបានិប៉ាល ជាចោមទ័ព ជាចៅហ្វាយនៃអស្សុរៈ យើងបានសម្លាប់សត្វសិង្ហតោ ២ ដោយបាញ់សរដ៏មានកំឡាំងរបស់ព្រះមេ-ម្ចាស់នៃសង្គ្រាម យើងបានយកសិង្ហតោនោះបូជាព្រះអង្គ ហើយផឹកស្រាយ៉ាងអឹកធឹក ។

រាល់ ៗ ឆ្នាំក្នុងរដូវស្លឹកឈើជ្រុះ ព្រះចៅផែនដីអស្សុរីតែងស្តេចចេញទៅប្រាបប្រាមពួកដែលមិនរាប់អានព្រះរបស់ខ្លួន កងទ័ពរបស់ព្រះអង្គសុទ្ធតែស្ទាត់ជំនាញក្នុងក្បួនពិជ័យសង្គ្រាម ទាំងចំបាំងចំពោះមុខ ទាំងកំបាំងមុខ គឺលើកទ័ពចោមរោមមិនឲ្យសត្រូវដឹងខ្លួន ពួកដែលបាញ់ឬត្រូវចាប់បានជាឈ្លើយនោះ ត្រូវធ្វើបាបឲ្យបានវេទនាជាពន្ទឹក មុខគួរឲ្យស្ញប់ស្ញែងពន់ពេក គឺធ្វើបាបដោយវិធីចោះភ្នែក កាត់ច្រមុះកាត់ត្រចៀក កាត់បបូរមាត់ ចាប់កន្ត្រាក់ពុកមាត់ ដកក្រចក បើអាណិតណាស់ប្រហារចក់សម្លាប់មួយរំពេចទៅ ។ មានព្រះចៅផែនដីអស្សុរីមួយអង្គទៀត ព្រះនាមថា អស្ស៊ីរណាសុរបាល បានចារឹកកិត្តិគុណរបស់ព្រះអង្គទុកថា យើងបានពូនដីឡើងជាទួលខ្ពស់ នៅត្រង់មុខទ្វារស្រុក យើងបានប្រហារចក់នាយចៅហ្វាយ (ជាតិដទៃ) ដែលជាមនុស្សអកតញ្ញូនឹងព្រះ

ជាម្ចាស់ ដោយមិនមានត្រាប្រណី (ម្នាក់ឡើយ) យើងបានបកស្បែករាបិទក្រាលលើខ្លួលនោះ ១ ពួក មានមួយពួកទៀតយើងយកលំពែងដោតទុកដោយជុំវិញខ្លួល ឯមនុស្សក្នុងស្រុករបស់យើងៗក៏បានប្រចាប់កស្លាប់អស់ជាច្រើនហើយបកស្បែកបិទគ្រប់កំផែង ។

ពួកអស្ស៊ីរីមានទំនងដូចមនុស្សព្រុកណជាតិឯទៀតៗដែរ គឺកាលបើវាយយកស្រុកបានហើយមិនទោត្រួតត្រាទេ បណ្ដោយឲ្យម្ចាស់ស្រុកត្រួតត្រាស្រុកខ្លួនឯងតាមទម្លាប់របស់ខ្លួន គ្រាន់តែបង្គាប់ឲ្យនាំសួយសាអាករទៅឲ្យតាមកំណត់ប៉ុណ្ណោះ កាលបើឈប់ខានឬមិនបានថ្នាទឹងថ្វាយសួយដោយប្រឹងទឹងតាំងរបឹងរឹងរូសឡើង ពួកអស្ស៊ីរីក៏លើកទ័ពទៅប្រាបប្រាមទៀត ទើបសឹកសង្គ្រាមមិនសូវមានពេលចំនេរទេ ចួនកាលឡើងទៅលើច្បាំងនឹងពួកស៊ីរីនឹងពួកម៉ែត គពីនោះទៅនាំគ្នាឆ្លងទន្លេអ៊ុយប្រា-តេ ចុះទៅក្រុកពនទន្ទ្លានដល់ប្រទេសអេស៊ីប្ដ ហើយគទៅរហូតដល់ទៅសមុទ្រខ្សាច់អារ៉ាប ដោយហេតុនេះ មិនបាច់ឆ្ងល់ទេប្រទេសអស្ស៊ីរីជាប្រទេសមួយយ៉ាងស្ដុកស្ដម្ភសំបូរជាងប្រទេសឯទៀតៗ ក្នុងសម័យនោះ ។

ឯប្រទេសអេស៊ីប្ដ ក៏មានសេចក្ដីភ្ញាក់ផ្អើលព្រួយចិត្តខ្លាចក្រែងមានភ័យដល់ខ្លួន ទើបញុះញង់ស៊ីរី (Syrie) នឹងអិសរ៉ាអែល (Israël) ឲ្យតាំងជាសត្រូវនឹងពួកអស្ស៊ីរីហើយច្បាំងគ្នា លុះពួកអស្ស៊ីរីបានជ័យជំនះហើយ

ទើបតាមទៅច្បាំងនឹងអេស៊ីប្ដទាល់តែបានក្រុងថែប៍ ហើយវាយប្ញូរអេ-ដ្យូពីមួយទៀត តាំងពីពេលនោះមក អំណាចរបស់អេស៊ីប្ដនៅទ្វីបអាស៊ីក៏ផុតលេតអស់ទៅ ហើយក្នុងទីបំផុត ទាំងអេស៊ីប្ដនឹងសាលដេនឹងអស្ស៊ីរី ធ្លាក់ទៅនៅក្រោមអំណាចរបស់ប្រទេសប៉ែក្ស ។

## អំពីលទ្ធិទំនៀមសាសនា

មូលហេតុនៃលទ្ធិទំនៀមសាសនារបស់ពួកសាលដេយ៉ាំងនឹងអស្ស៊ីរីយ៉ាំងនោះ ប្រកបដោយសេចក្ដីកោតខ្លាចតែមួយយ៉ាង គឺជនពួកនេះខ្លាចអំណាចស្ថានសួគ៌ អំណាចដួងផ្កាយនឹងអំណាចពួកយក្ខមារ ដោយហេតុនេះ លទ្ធិសាសនារបស់មនុស្សពួកនេះចែកចេញជា ៣ ប្រភេទ គឺគោរពរាប់អានព្រះអង្គធំ ១ ភាកសាស្ត្រ ១ វេទមន្តគាថា ១ ។

ដំបូង ពួកសាលដេយ៉ាំងក៏មានទំនងដូចពួកអេស៊ីប្ដដែរ គឺស្រុកនីមួយៗ មានព្រះមួយអង្គៗ ហើយព្រះគ្រងនគរតូចជាបំណុះព្រះគ្រងនគរធំ គឺទីក្រុង លទ្ធិសាសនានេះប្រព្រឹត្តទៅតាមបែបពងការ ត្រួតត្រាស្រុកទេស ។ ឯព្រះអង្គធំៗនោះស្ថិតនៅលើស្ថានសួគ៌ ។ អង្គដែលធំបំផុតឈ្មោះស៊ិន (Sin ព្រះចន្ទ) បន្ទាប់ពីព្រះចន្ទ គឺសាម៉ស (Chamach ព្រះអាទិត្យ) (សុំឲ្យសង្កេតមើលឲ្យល្អពួកនេះប្រកាន់ព្រះចន្ទធំជាង

ព្រះអាទិត្យ ) តអំពីនោះទៅគឺនេរគ័ល (Nergal ព្រះអង្គារ ) ជាព្រះសង្ហិត្ប, នេបូ, (Nébo ព្រះពុធ ) ជាព្រះនៃវិជ្ជាការតាំងខ្លាយ, ម៉ារឌុក (Mardouk ព្រះព្រហស្បត៍ ) ជាព្រះប្រចាំស្រុកបាប៊ីឡោន នីនីប (Ninip ព្រះសៅរ៍) ជាព្រះនៃកំឡាំង (មិនមានព្រះសុក្រ ) អិស្តារ៍ (Istar) ជាព្រះប្រចាំស្រុកនីនីវ ជាព្រះខាងចម្បាំង នឹងសេចក្ដីស្នេហា, អេអា (Éa) ជាព្រះសាងប្រទេសសាលដេចាស់ អស្សុរ:ជាព្រះរបស់ពួកអស្ស៊ីរី, រ៉ាមម៉ុន (Ramman) ជាព្រះផ្លូវមេឃ ភ្លៀង ផ្គរ ។ ឯបណ្ដាព្រះរបស់ពួកសាលដេនឹងអស្ស៊ីរីនោះ មិនមានព្រះទ័យមេត្តាករុណាដល់មនុស្សឡើយទេ ជាព្រះចាំប្រទូសរ៉ាយអ្នកដែលមិនរាប់អានខ្លួន កាលបើព្រះមិនអាចទៅប្រទូសរ៉ាយគេបាន ត្រូវក្សត្រគ្រងរាជ្យអស្ស៊ីរី ដែលប្រកាសខ្លួនជាអ្នកដំណាងព្រះទៅធ្វើការជំនួសព្រះ កាលបើប្រទូសរ៉ាយឬធ្វើបាបជាតិដទៃបានច្រើនត្រឹមណា ព្រះនឹងសព្វព្រះទ័យច្រើនឡើងត្រឹមណោះ ដូចមានសេចក្ដីពាក្យរបស់ក្សត្រអស្សុរបានិប៉ាលមួយអន្លើទៀតថា "មនុស្សដែលលួចជេរលត្ថះពួកអស្សុរឬខ្លួនយើង វាត្រូវចាប់ដកអណ្ដាតចេញពីមាត់ ហើយយើងចាប់បោះចោលក្នុងល្ហក (សំអុយ ) កាត់ជើងវាចេញ យកខ្លួនវាឲ្យឆ្កែស៊ី, ការធ្វើដូច្នេះ យើងបានធ្វើឲ្យព្រះអង្គធំរបស់យើងសព្វព្រះទ័យជាពន្ទឹក" ។

ក្រៅពីព្រះអង្គធំៗ អស់នេះហើយ ជនពួកនេះជាប់ចិត្តពពួកផ្កាយ ដោយយល់ថា ដួងផ្កាយជាគ្រឿងសញ្ញារបស់ព្រះ ហើយតាមផ្លូវគោចររបស់ដួងតារានោះជាគ្រឿងសំដែងអំពីបំណងរបស់ព្រះ ជាទីបណ្តាលឲ្យកើតហេតុការណ៍ឯណានីមួយឡើង តាមទំនងនេះទើបគេអាចកំណត់យកដំណើររបស់ដួងផ្កាយ ជាគ្រឿងទំនាយហេតុការណ៍ផ្សេងៗរបស់មនុស្ស នេះហើយជាឫសគល់ខាងដើមនៃវិជ្ជាហោរាសាស្ត្រក្នុងកាលតមក ៗ

ក្រៅពីនេះ ពួកសាលដេយល់ថា ក្នុងលោកនេះមានពួកមារបិសាចចាំតែប្រទូសរ៉ាយមនុស្ស ទើបមានមនុស្សបំពួកខ្លះ គិតរកឧបាយបង្ការអន្តរាយបែបនេះ ហើយតាំងខ្លួនជាអ្នកបណ្តេញ ឬបំបាត់ពួកមារបិសាចដោយវិធីសែកមន្តអាគមប្រោះព្រំទឹកមន្ត យកស្មៅវិសេសម្យ៉ាងមកដាក់ក្នុងទឹកក្តៅផឹក ចុះលេខយន្តនឹងផ្លាំងសំពត់ អស់នេះសុទ្ធតែជាវិធីកប់អានតៗមកដល់ឥឡូវនេះ ៗ

ខាងវិជ្ជារចនា ពួកនេះក៏ធ្វើបានល្អមិនចាញ់ពួកអេស៊ីប្ដ៍ បើធ្វើវត្ថុអ្វីនីមួយដោយទន់ដៃវិញ ដូចជារូបព្រះឬរូបអ្វីៗ ពួកនេះធ្វើបានពូកែជាងពួកអេស៊ីប្ដ៍ទៅទៀត ការកសាងក៏ធ្វើបានល្អណាស់ដែរ ហើយនៅកន្លែងខ្លះដូចជានគរបាប៊ីឡោនដល់មកសម័យនេះ មិនមានសល់សំណាកទុកសោះនោះ នៅមានពោលទុកក្នុងសៀវភៅរបស់ក្រិក តែងសរសេរ

ទិរតី គឺទន្លេមេគុង (ទន្លេធំ) ហើយនឹងទន្លេសាល្វូអាន់ ដែលហូរធ្លាក់មកប្រទេសឥណ្ឌូស៊ីនយើងនេះ ខែត្រយូនណាន់ ដែលជាប់នឹងស្រុកតុងកឹង មានទីក្រុងឈ្មោះយូនណាន់ហ្វូ ។ នេះតាំងនៅក្នុងទីវាលមួយដ៏មានដីជាតិល្អណាស់ ហើយអាកាសស្ងួតហែងផងនៅទីនោះ នៅខាងត្បូងខែត្រនេះមានសត្វដំរីខ្លះដែរ ។

កន្លែងដែលគេយកថ្មកែវនៅខែត្រតាលីហ្វូ ល្បីដោយសារថ្មកែវដែលគេយកមកនោះ មានសរសៃសណ្ឋានដូចជាគំនូរល្អ ៗ ណាស់ ភ្លៅសត្វជ្រូកនៅខែត្រយូនណាន់ ល្បីថាមានឱជារសឆ្ងាញ់ពិសាណាស់ ។

កំពង់ផែជំនួញសំខាន់ ៗ នៅស្រុកចិនរៀបរាប់តាមរបៀបធំតូចគឺសៀងហៃ ទៀនស៊ីន-ហាន់គីវ-ស៊ីងតាវ-កង់តុង ។

* *
✡

## អំពីកាសែតដែលមាននៅក្នុងផែនដីរបស់ជប៉ុន

តាមសៀវភៅកត់ហេតុរបស់ជប៉ុនដែលចេញផ្សាយក្នុង ព. ស. ២.៤៧៨ មានសេចក្ដីថា ចំនួនកាសែតដែលបោះពុម្ពផ្សាយ ក្នុងឆ្នាំនេះមានចំនួន ៨.៣១០ ឈ្មោះ - ញែកចេញជាកាសែតប្រភេទខែ-ត្រីមាសមានចំនួន ៦.៦៧៤ ឈ្មោះ - ប្រភេទដែលចេញផ្សាយរាល់អាទិត្យ ៤៦១ ឈ្មោះ ប្រភេទដែលចេញផ្សាយរាល់ថ្ងៃ ១.១៧៥ ឈ្មោះ ។

លំអថា នគរនោះល្អះល្អណាស់ សង់កសាងឡើងដោយមេជាងមានថ្វីដៃពូកែៗ នៅទីកន្លែងខ្លះ អ្នកប្រាជ្ញពង្សាវតារបានព្យាយាមស្រាវជ្រាវគូរគំសរូបកង់ឡើងដែលយល់ថាមានបែបផែនដូច្នេះមែន ក៏មានជាច្រើនអន្លើៗ យើងអាចសំគាល់ឃើញថា បុរាណវត្ថុរបស់ពួកនេះច្រើនតែកសាងជារូបកំផែង មិនមានសសរខ្ពស់ៗ ដូចរបស់ពួកអេស៊ីប្ទ័ទេ ដោយហេតុពួកសាលដេនឹងអស្ស៊ីរីមិនមានថ្មល្អៗ នៅក្នុងស្រុករបស់ខ្លួន ។

ដោយហេតុដែលខំពិនិត្យមើលដួងផ្កាយច្រើនៗ ទៅធ្វើឲ្យពួកនេះមានចំណេះខាងវិជ្ជាលេខ (Mathématique) ហើយជនពួកនេះជាពួកដំបូងដែលចេះបែងឆ្នាំចេញជា ១២ ខែ ហើយធ្វើគ្រឿងសញ្ញារបស់ខែទាំង ១២ ខែ ជារូបផ្សេងៗ ហើយចែកខែចេញជាអាទិត្យថ្ងៃ ម៉ោងនឹងមីនុត ចេះបែងចែងរង្វង់មូលចេញជាដឺក្រេ បែងចែកវិធីកំសចេញជាចំអាមជាហត្ថ (តែមួយចំអាមរបស់ពួកនេះកំណត់យកចន្លោះមេដៃនឹងកូនដៃ មិនមែនកំណត់យកពីមេដៃទៅម្រាមកណ្តាលដូចយើងទេ)។ ពួកនេះចេះបែងទម្ងន់ជាចំណែកៗផង ដែលគួររាប់ជាថ្នាក់ដំបូងនឹងថ្នាក់សំខាន់របស់វិជ្ជាលេខនព្វន្ត ។

តួអក្សររបស់ជនពួកនេះ មានរូបជាដ្រុងៗ (ស្រដៀងអក្សរចិន) លំបាកអានជាបំផុត តែដែលអ្នកប្រាជ្ញពង្សាវតារស្រាវជ្រាវយកមកអានបានដោយប្រៀបធៀបនឹងអក្សរប៉ែក្ស ។

# សករាជនឹងហេតុការណ៍ដោយ
# សង្ខេបរបស់ជនពួកនេះ

## យុគទី ១ ក្សត្រសាលដេខាងក្រោម

ប្រហែល ៥០០ ឆ្នាំមុនពុទ្ធសករាជ មានក្សត្រ ២ អង្គគឺ ព្រះបាទសារកុងនឹងព្រះបាទណារ៉ាមស៊ីអ៊ូរ៍ ទ្រង់គ្រប់គ្រងប្រទេសសាលដេ ។

## យុគទី ២ ក្សត្របាប៊ីឡោន

ប្រហែល ១.៦០០ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទហ័ម្មូរ៉ាប៊ីទ្រង់ជីកព្រែកផ្សេងៗ ក្នុងផែនដីមេសូប៉ូតាមី ហើយរៀបចំធ្វើច្បាប់ឡើងជាដំបូងៗ

## យុគទី ៣ ក្សត្រអស្ស៊ីរ

ប្រហែល ៦០០ ឆ្នាំមុនពុទ្ធសករាជ ក្នុងផែនដីព្រះបាទតេគ្លាតហ្វា-ឡាសារ៍ ពួកអស្ស៊ីរីបានចាប់ផ្ដើមធ្វើសង្គ្រាមវាតអាណាខេត្តលុកលុយចូលទៅ អាម៉ានី ស៊ីរីនឹងសាលដេ ។

## យុគទី ៤ ក្សត្រនីនីវ

កាល ១៧៩ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទសារកុង (មានព្រះនាមដូចអង្គមុន) វាយយកទីក្រុងរបស់ពួកអ៊ីសរ៉ាអែលបាន ។

កាល ១៧៤ ឆ្នាំមុនពុទ្ធសករាជ ក្សត្រដដែលនេះទៅវាយដល់ស្រុកអេស៊ីប្ដ៍ ។

កាល ១៦៥ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទសេនណាឈេរីបទៅលុកលុយដល់ពួកស៊ីហ្វទីនពួកអេស៊ីប្ដ៍ ។

កាល ១៤៩ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទអេសារហាត់ដុន វាយយកស្រុកអេស៊ីប្ដ៍បានហើយហួសទៅវាយដល់តាប៊ែ ។

កាល ១១៩ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទអេស្សុរបានិប៉ាល វាយយកស្រុកថែប្បាន ។

កាល ១០០ ឆ្នាំមុនពុទ្ធសករាជ ក្សត្រដដែលនេះប្រាបប្រាមការបលាចលស្រុកសាលដេហើយរៀបស្រុកនីនីវឲ្យល្អរុងរឿងឡើង ។

## យុគទី ៤ សម័យក្សត្រិយាបីឡោន

កាល ៨៣ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទណាបូប៉ូឡាស្សារក្បត់ដល់ក្សត្រនីនីវ ។

កាល ៦៣ ឆ្នាំមុនពុទ្ធសករាជ ក្សត្រដដែលនេះបានពួកម៉ែតជួយដាក់កំឡាំង ទើបវាយយកក្រុងនីនីវបាន ។

កាល ៦១ ឆ្នាំមុនពុទ្ធសករាជ ព្រះបាទណាប៊ូសូដូណូស័របានចាត់តាំងអាណាចក្របាប៊ីលោនឡើងជាថ្មីយ៉ាងមាំមួន ហើយចាត់ការប្រាបប្រាមពួកអេស៊ីប្តដែលបះបោរ ។

កាល ៥៤ ឆ្នាំមុនពុទ្ធសករាជ ក្សត្រដែលវាយយកស្រុកសេរូសាលេមបានហើយច្បាំងឈ្នះពួកហេព្វទិសៀង ។

កាល ព. ស. ៥ ក្នុងផែនដីក្សត្រណាបូនិត អាណាចក្របាប៊ីលោនធ្លាក់ទៅនៅក្រោមអំណាចប្រទេសប៉ែរ្ស ។



១៤ — អំពីទ្រង់ជួបប្រទះនឹងមនុស្សស្លាប់

(មើលសេចក្តីពន្យល់ទំព័រ ៣០)

# អំពីដើមកំណើតនៃមនុស្សជាតិ

*របស់ខេមរឫស្សី ប្រែនិងរៀបរៀងពីទស្សនាវដ្ដីវិទ្យាចារ្យ*

# អំពីកំណើតមនុស្សជាតិ

បណ្ដាមនុស្សជាតិដែលមាននៅលើផ្ទៃពិភពនេះ សឹងមានដំណែង នាទីទីឋានៈខុសប្លែកៗគ្នា ស្គាល់ខុស-ត្រូវ ល្អ-អាក្រក់ គ្រប់យ៉ាង ឬ ធ្វើការផ្សេងៗ ទាំងមានគុណប្រយោជន៍ ទាំងមានទោស ហើយមាន ចំរើន មានវិនាសតៗមក តាមយុគតាមសម័យដរាបមកដល់ឥឡូវនេះ ៗ វិជ្ជាការនិងសិល្បសាស្ត្រទាំងឡាយចំរើនឡើង ដោយហេតុមនុស្សបាន ប្រឹងប្រែងស្រាវជ្រាវរកនឹងគិតប្រឌិតឡើង ដើម្បីជាប្រយោជន៍តាម សេចក្ដីត្រូវការរបស់មនុស្ស របស់ដែលអស្ចារ្យនឹងស្ងាត់កំបាំង ក៏បាន ស្រាវជ្រាវរកព្រមទាំងល័ក្ខឋាន នាំមកផ្សាយឲ្យឃើញប្រាកដច្បាស់ ដល់ក្នុងមនុស្សលោក តែរឿងដែលតាំងឈ្មោះខាងលើនេះ ដើម្បីចង្អុល ប្រាប់អំពីកំណើតដើមរបស់មនុស្ស តើមនុស្សជាន់ដើមកើតមកអំពីអ្វី? ចំណោទនេះនៅតែងងឹតងងល់ដល់វិជ្ជាការទាំងឡាយក្នុងលោក ៗ បណ្ដា អ្នកប្រាជ្ញទាំងឡាយតាំងអំពីបុរាណសម័យរហូតមកដល់អ្នកប្រាជ្ញសម័យ វិទ្យាសាស្ត្រក្នុងសព្វថ្ងៃនេះ បានព្យាយាមស្រាវជ្រាវរកមូលហេតុមក ច្រើនណាស់ហើយ មើលទៅហាក់ដូចជាមិនអាចដោះប្រស្នានេះឲ្យជ្រះ ស្រឡះបាន បើកាន់តែរកទៅហើយកត់ត្រាទុកមកសម្រាប់ឲ្យមនុស្ស ដងគ្នាពិចារណាមើល ក៏កាន់តែឃើញស្មុគស្មាញរឹតហើយខុសតែង

ខ្វែងគំនិតគ្នាកាន់តែច្រើនឡើង គ្រាន់តែមិនអាចសន្និដ្ឋានឲ្យជាទីពិតប្រាកដបានថា យ៉ាងណារបស់អ្នកណាជាសេចក្ដីពិតល្មមប្រកាន់យកជាល័ក្ខឋានបាន ។

យើងនឹងប្រមូលយករឿងរ៉ាវរបស់បណ្ដាអ្នកប្រាជ្ញ ឬគន្ថរបទាពារ្យនឹងអ្នកប្រាជ្ញវិទ្យាសាស្ត្រដែលបានរៀបរៀងទុកនោះមកថ្លែង ដើម្បីជាទីសណ្ដាប់ ឬជាគ្រឿងពិនិត្យរកហេតុផលសម្រាប់អ្នកត្រូវការចង់ជ្រាបរឿងនេះតទៅ ។

កាលមិនប៉ុន្មានឆ្នាំមកនេះ មានគណៈអ្នកស្រាវជ្រាវ ១ ក្រុមហៅថា "គ្រីក្រី" បានគិតស្មានគ្នាន់គ្នេរអំពីកំណើតមនុស្សជាតិថា លោកដែលមនុស្សជាតិបានអាស្រ័យនៅនេះមានអាយុច្រើនលានឆ្នាំ ប្រហែល ១៨ លានឆ្នាំមកហើយ កំណត់វេលាជា ៨ យុគ គឺយុគទី ១ មនុស្សមានកំណើតជាសត្វត្រីហែលនៅក្នុងទឹកជាដំបូង តែសត្វត្រីកើតមកអំពីអ្វីមិនមានសំដែងទុកឲ្យច្បាស់លាស់ ហើយថាក្បាលត្រីនេះឯងដែលក្លាយមកជាក្បាលមនុស្ស ក្នុងវេលាក្រោយ ៗ ក្នុងយុគទី ២-៣ សត្វត្រីនេះក្លាយមកជាសត្វគោក មានអាការកិរិយាជាសត្វលូន-វារ ៗ ក្នុងយុគទី ៤-៥ អវយវៈរបស់សត្វ-លូនវារនេះក៏មានជើងដុះថែមឡើងទៀតតាមចំណង់របស់ធម្មជាតិនៃសត្វគោក ៗ ដល់មកក្នុងយុគទី ៦-៧ ក៏ប្រែត្រឡប់ក្លាយមកជាសត្វពានរត្រាច់រន្ធាត់លើមែកឈើ ហេតុដែល

ក្លាយមកជាសត្វស្វាបាននេះ ដោយសេចក្ដីអន្ទះអន្ទែងស្វែងរកអាហារ ដោយបានល្បងភ្លក់សេជាតិផ្លែឈើដើមទាប ៗ ជាដំបូង ហើយព្យាយាមប្រតែងប្រតោងមែកឈើ លុះអំណើះជាអន្លើងឆ្នាំទៅ ពង្សកាយក៏ក្លាយទៅជាពានរ ៗ គ្រប់ៗ យុគនៃការប្រែប្រួលនេះ ខួរក្បាលក៏កាន់តែត្រូវការប្រើឲ្យមានប្រយោជន៍ច្រើនឡើងជាលំដាប់ ទើបក្លាយភាពមកជាមនុស្សយ៉ាងបរិបូណ៌ ៗ ក្នុងយុគទី ៨ ពង្សកាយក៏ក្លាយមកជាមនុស្សបរិបូណ៌តាមសេចក្ដីដែលពោលមកនេះ មានល័ក្ខឋានបានមកអំពីបុរាណ-វត្ថុនឹងកងឆ្អឹងសត្វសម័យព្រេងនាយដ៏លុងជាច្រើនបំពួក ល័ក្ខឋានអស់នេះ មានប្រយោជន៍សម្រាប់ជាគ្រឿងពិចារណាអំពីគ្រឿងបរិភោគរបស់មនុស្សដែលប្រែប្រួលទៅតាមយុគតាមសម័យអស់នោះ ៗ

ក្រៅអំពីគណៈ “គ្រិគ្រី” នៅមានគណៈស្រាវជ្រាវឯទៀតៗដែលនាំគ្នាត្រួតត្រាពិនិត្យមើលរឿងនេះ ក៏បានពោលអាងថា ធ្លាប់ស្រាវជ្រាវពិនិត្យរឿងនេះជាច្រើនប្រទេសមកហើយនៅទ្វីបអាស៊ី បានប្រទះឃើញពង្សឆ្អឹងសត្វជាច្រើនពួកដែលបានសន្និដ្ឋានទុកថា ទ្វីបអាស៊ីជាទីប្រជុំកើតនៃកំណើតសត្វបំពួកផឹកទឹកដោះ នឹងសត្វជើង ៤ មុនទីដទៃៗ ទាំងអស់ក្នុងលោក ៗ សេចក្ដីស្រាវជ្រាវដែលបានពោលមកនេះ គឺការត្រេកត្រកូលសម័យវិទ្យាសាស្ត្រដែលមានយោបល់ដោយសរុបថា មនុស្សយើងកើតមកអំពីការប្រែប្រួលនៃសត្វ ៗ

យើងលើកបែរទៅពិចារណាមើលតាមយោបល់ក្នុងលទ្ធិសាសនាខ្លះល្បងមើល តែយើងទឹងពោលតាមលទ្ធិព្រាហ្មណ៍ជាមុន ព្រោះជាសាសនាចាស់បំផុតក្នុងលោកនេះ ដូចមានរឿងពោលទុកថា ហេតុដែលមានមនុស្សកើតឡើងនេះដោយអំណាចរិទ្ធានុភាពរបស់ព្រះព្រហ្ម ក្នុងជាន់ដំបូងបង្អស់នោះ ព្រះព្រហ្មកើតឡើងក្នុងស៊ុត តែគម្ពីរនេះមិនបានពោលទុកដោយល្អិតល្អថា ហេតុអ្វីទើបព្រះព្រហ្មទៅនិម្មិតខ្លួនឲ្យស្ថិតនៅក្នុងស៊ុតដូច្នោះ ឬមួយអ្នកណាជាអ្នកនិម្មិតព្រះព្រហ្មឡើង ស៊ុតដែលព្រះព្រហ្មនិម្មិតឡើងនេះជាស៊ុតវិសេស ទើបអាចអណ្តែតនៅត្រង់កណ្តាលអាកាសបាន ១ ហ្មឺនកល្ប ព្រះព្រហ្មដែលទ្រង់ស្ថិតនៅតែក្នុងស៊ុតអស់វេលាយូរដល់ម្ល៉េះ ទ្រង់មានសេចក្តីនឿយណាយពេកស្រពន់ឬមួយមានព្រះទ័យរំខានធុញថប់តប់ប្រមល់ ក្នុងការប្រថាប់នៅក្នុងទីតែមួយកន្លែងដូច្នេះតទៅទៀត ទើបទ្រង់បណ្តាលឲ្យស៊ុតនោះបែះបែកចេញជាពីរចំណែក ស៊ុតទាំងពីរចំណែកនេះធំសំបើមមហិមាផុតវិស័យទឹងរាស់វែងកើត ទើបព្រះព្រហ្មទ្រង់កំណត់យកមួយចំហៀងខាងលើជាផ្ទៃមេឃ មួយចំហៀងខាងក្រោមជាផ្ទៃលោក ។ លុះតមកកើតភ្លើងឆេះកល្បឆេះអស់ទាំងលោកគ្មានសល់អ្វី តែអ្នកណាជាអ្នកបណ្តាប់ឲ្យផុតបំផ្លាញលោកនេះមិនមានសំដែងទុក លុះអំណើះតពីនោះមកទើបមានព្រះឥស្សរជាម្ចាស់មកសាងមនុស្សលោកឡើងវិញទៀត មានដីរ ៤

ចំពោះកាសែតតូក្បទិឈិទិឈិឈិមបួន នោះបោះពុម្ពផ្សាយរាល់ថ្ងៃ ប្រមាណ ១ ថ្ងៃ ១៥.០០០.០០០ ច្បាប់ ជាកាសែតមានដើមទុនច្រើនបំផុតក្នុងជប៉ុន មានដើមទុន ១០ លានរៀលយេន មានយន្តហោះនាំដំណឹងយ៉ាងទាន់សម័យ មានអ្នកឲ្យដំណឹងទៅតាមប្រទេសក៏ច្រើន មានអ្នកដំណាងកាសែតក្នុងស្រុកតាមសន្និបាតជាតិផង ។

តាមធម្មតាកាសែត បើមានទៅក្នុងប្រទេសណាច្រើន ប្រទេសនោះរមែងចំរើនដោយការសិក្សាពិតប្រាកដមែន ព្រោះកាសែតជាគ្រឿងរាស់សេចក្ដីចំរើនខាងការសិក្សាបានមួយផ្លូវដែរ ។ ស្រង់អំពីកាសែតប្រមូលសារចុះថ្ងៃ ១២ ដេសឹម្ប្រ៍ ឆ្នាំ ១៩៣៩ ។

* * *

## អំពីភូមា - អង់គ្លេស

ដោយហេតុមានការផ្លាស់ប្ដូរក្បួនច្បាប់នៃប្រទេសភូមា ស្រុកមណីបុរៈ ដែលជាស្រុកភ្ជាប់ចំណុះភូមា ក៏ប្រែត្រឡប់រឹងទទឹងមិនព្រមចំណុះភូមាតទៅទៀត ទើបព្រះបាទថាក់កាយមែងប្រទេសភូមា ទ្រង់បង្គាប់ឲ្យចាត់បញ្ជូនកងទ័ពទៅប្រាបប្រាមស្រុកមណីបុរៈ លុះប្រាបប្រាមរាបទាបហើយក៏លើកកងទ័ពលុកចូលទៅក្នុងខេត្តដែនរបស់អង់គ្លេស គឺដែនអស្សាំ, ដែនចិត្តកង់, ដែនកៈសា ។ ចំណែកខាងរាជការអង់គ្លេស

ទីងសសារ ៩ ដើមសម្រាប់ទ្រទួល ព្រះឥស្សរជាម្ចាស់ទ្រង់តាំងព្រះទ័យទំ-នុកបម្រុងលោកនេះឲ្យកាន់តែរុងរឿងឡើងជាលំដាប់ ទើបទ្រង់សែកព្រះសេទោឲ្យហូរចេញក្លាយមកជាទឹក ទ្រង់សែកព្រះមេទោឲ្យក្លាយមកជាផែនដី ហើយទ្រង់ត្រិះរិះថា ស្ថានសួគ៌នឹងស្ថានមនុស្សលោកយើងនេះមិនទាន់មានជាន់ថ្នាក់ជាទីគួរពិតពិលរមិលមើល ទើបទ្រង់យកព្រះចូឡា-មណីជាគ្រឿងអម្ពរបស់ទ្រង់ៗ បណ្ដាលឲ្យកើតជាភ្នំព្រះសុមេរុ តាំងនៅកណ្ដាលពិភពមនុស្សនេះ ហើយទ្រង់ចាប់យកព្រះសង្វារមកសាងជាភ្នំព័ទ្ធជុំវិញភ្នំព្រះសុមេរុជា ៧ ជាន់ គឺភ្នំយុគន្ធរ ភ្នំឥសិន្ធរ ភ្នំករវីក ភ្នំសុទស្សន ភ្នំនេមិន្ធរ ភ្នំវិន្តក នឹងភ្នំអស្សកណ្ណ រួមជា ៧ ភ្នំ ហៅថាភ្នំសត្តបរិភណ្ឌ ជាភ្នំព័ទ្ធជុំវិញពិភពលោក តមកទើបទ្រង់សាងព្រះអាទិត្យព្រះចន្ទ្រនឹងបណ្ដាផ្កាយផ្សេងៗទុកសម្រាប់ប្រដាប់លោក ហើយទ្រង់សាងព្រះឧម្មាភគវតី ព្រះនារាយណ៍នឹងព្រះព្រហ្មធាតាឡើង ដើម្បីឲ្យជួយសាងសត្វសារពើដែលមិនទាន់បរិបូណ៌ ។ កាលបើកើតលោកឡើងហើយ វត្ថុនានាដែលមាននៅលើផ្ទៃផែនដីនេះ សុទ្ធតែជាទីរីករាយគួរពិតពិលរមិលមើល ផ្ទៃផែនដីក៏មានក្លិនក្រអូបឈ្ងុយឆ្ងាញ់ជាពន្ទឹក ពួកព្រះព្រហ្មក៏មានចិត្តចង់សោយឱជារសផែនដីដែលឆ្ងាញ់នោះ ទើបទ្រង់ហោះចុះមកពីស្ថានសួគ៌ ហើយទ្រង់សោយដោយកំសាន្តព្រះ

ទ័យ លុះយូរបន្តិចទៅក៏ទ្រង់ក្បួចស្ពានសួគ៌ ហើយអស់ប្អូនទាំងនោះត្រឡប់ទៅកាន់ទីដើមវិញ ទើបនាំគ្នារួមភេទផ្សំដំណេកជាមួយគ្នា ជាដើមកំណើតនៃមនុស្សទាំងឡាយតរៀងមក ។

ចំណែកឯគម្ពីររបស់គ្រិស្តសាសនាដែលចាស់ៗនោះ មាននិយាយថា មូលហេតុដែលនឹងកើតមានមនុស្សឡើងនេះ ព្រះដ៏ជាម្ចាស់សួគ៌អង្គមួយ ទ្រង់សាងមនុស្សឡើងមុនបង្អស់ ព្រះជាម្ចាស់សួគ៌នេះមានតែមួយអង្គប៉ុណ្ណោះ គ្រិស្តសាសនិកជនតែងហៅថា "ព្រះបិតា" ព្រះអង្គបានសាងលោកឡើងនេះ មានកំណត់ទុកជា ៧ គ្រា ក្នុង ១ គ្រាៗ អស់វេលាជាយូរអង្វែងកំណត់មិនបាន តែពោលទុកក្នុងគម្ពីរថា គ្រាទី ១ ទ្រង់សាងពន្លឺឡើង គ្រាទី ២ ទ្រង់សាងមេឃហើយញែកចេញមកជាផែនដីនិងទឹក គ្រាទី ៣ ទ្រង់សាងដីដោយឡែក ទឹកដោយឡែក ព្រឹក្សជាតិដោយឡែក គ្រាទី ៤ បានទ្រង់សាងព្រះអាទិត្យ ព្រះចន្ទនិងដួងផ្កាយ (នេះឃើញថាមានពន្លឺមុនទើបមានដួងអាទិត្យជាក្រោយ) គ្រាទី ៥ បានទ្រង់សាងសត្វស្លាបនិងមច្ឆជាតិ តមកក្នុងគ្រាទី ៦ បានទ្រង់សាងសត្វចតុប្បាទ-ទ្វេបាទ និងមនុស្ស ហើយទ្រង់សម្រាកព្រះអង្គដែលរាប់ថាជាគ្រាទី ៧ ។ ឯមនុស្សដែលទ្រង់សាងឡើងនេះ តាមគម្ពីរពោលថា មានរូបរាងប្រហែលនឹងព្រះអង្គដែរ តែរាងកាយរបស់មនុស្សប្រកបដោយដីផង់និងវិញ្ញាណ វិញ្ញាណនេះមិនមែនសាងឡើង

ដោយធាតុអ្វីឡើយ គឺជាអភិនិហាររបស់ព្រះជាម្ចាស់សាងឡើងជាដំបូងនេះ ជាមនុស្សប្រុសឈ្មោះថា អាដាំ ៗ នេះកើតមកក្នុងលោកតែម្នាក់ឯង តមក ទ្រង់មានព្រះទ័យគិតថា អាដាំកើតមកក្នុងលោកតែម្នាក់ឯង ហាក់ដូចជា ស្រងេះស្រងោចពន់ពេក ទើបទ្រង់សណ្តំអាដាំឲ្យលក់ទៅ ហើយទ្រង់ កាត់យកឆ្អឹងជំនីរខាងឆ្វេងធុតរបស់អាដាំដោយពុទ្ធានុភាព យកតែឆ្អឹងជំនីរ មួយមកហើយ រុំស្រោបដោយមំសៈធ្វើជារូបស្ត្រីឡើងប្រកបព្រមដោយ វិញ្ញាណ ឲ្យឈ្មោះថានាង អេវ ជាគូរួមសុខរួមទុក្ខជាមួយនឹងអាដាំតរៀង មក ៗ បុរសស្ត្រីគូនេះ តែងអាក្រាតកាយនៅក្នុងសួនស្ថានសួគ៌ជា បរមសុខ ឥតមានធ្វើការអ្វីឡើយ មានផលាផលនឹងធញ្ញាហារសម្រាប់ បរិភោគគ្រប់យ៉ាងមិនមានខ្វះខាត បណ្តាសព្វសត្វក៏មូលមកជាមិត្រមិន ប្រទូសរ៉ាយដល់គ្នាទៅវិញទៅមក តមកផលកម្មដែលជាអំពើអាក្រក់មក បណ្តាលចិត្តរបស់អាដាំនឹងនាងអេវឲ្យទៅបរិភោគផ្លែឈើ ដែលព្រះជា-ម្ចាស់ទ្រង់ហាមផ្តាច់នោះ ដោយផលបាបនេះហើយទើបព្រះជាម្ចាស់ទ្រង់ បណ្តេញអាដាំនឹងនាងអេវចេញពីសួនស្ថានសួគ៌ដោយទោសល្មើសព្រះ ឱង្ការ ហើយទ្រង់ផ្តាច់សេចក្តីសុខទាំងពួងដែលធ្លាប់ទទួលមកអំដើម ៗ អាដាំនាងអេវក៏កាន់តែមានសេចក្តីអៀនខ្មាសដែលខ្លួនជាមនុស្សអាក្រាត ដូច្នោះ ទើបបេះស្លឹកឈើយកមកបិទបាំងកាយ ហើយមានភារៈដូចជា

មនុស្សធម្មតាក្នុងសម័យតមក  គឺត្រូវធ្វើការចិញ្ចឹមជីវិត  មានទុក្ខ មានសុខ  មានឈឺមានស្លាប់  អាដាំនឹងនាងអែវនេះហើយមានកូនមាន ចៅតៗគ្នារៀងមកដល់សព្វថ្ងៃនេះ ។

ចំណែកខាងគម្ពីរកូរ៉ានរបស់សាសនាឥស្លាមឬមហាហ៊្មត់មានសេចក្ដី ដំណាលប្រហែលគ្នាគ្រប់អន្លើ  ពោលគឺព្រះអាឡា ឬអាឡោះបានទ្រង់ សាងអាដាំនឹងនាងហាវ៉ាឡើង  ហើយទ្រង់ប្រទានឧទ្យានអល្យ៉ាម៉ុតជា លំនៅ ថ្ងៃមួយនាងហាវ៉ាទៅបេះផ្លែឈើអម្រឹតដែលព្រះជាម្ចាស់ទ្រង់ហាម ផ្តាច់មិនឱ្យបរិភោគនោះ  សេចក្ដីនេះទ្រង់ជ្រាបដល់ព្រះអាឡាជាម្ចាស់ ទើបទ្រង់បណ្ដេញចេញពីឧទ្យាន ហើយត្រូវផ្តាសាឲ្យរងទុក្ខវេទនាផ្សេងៗ ហើយព្រះអាឡាទ្រង់ប្រោសឲ្យទេវតាមកនៅថែរក្សាឧទ្យាននោះវិញ ។

ឯប្រវេណីនិយមរបស់ជនជាតិជប៉ុនមានសំដែងថា  មុននឹងមាន មនុស្សកើតឡើងក្នុងពិភពនេះ  មានទេវបុត្តនឹងទេវធីតាពីរអង្គទ្រង់ទត មើលឃើញខាងក្រោមទីប្រជាប់មានលក្ខណៈទន់ជាតាហ្លួយ  ទើបចុះមក ពីស្ថានសួគ៌ទៅកាន់ទីនោះ  ហើយទ្រង់កូរទឹកតាហ្លួយនេះដោយអាវុធធ្នូ ខណៈដែលទ្រង់លើកធ្នូឡើង  ទឹកតាហ្លួយដែលជាប់នៅចុងធ្នូនោះ ក៏ស្រក់ចុះមកជាដំណក់ៗ ដំណក់តាហ្លួយនេះហើយដែលក្លាយមកជាផែនដី ហើយជាកោះផ្សេងៗរបស់ប្រទេសជប៉ុននៅសព្វថ្ងៃនេះ ។

តមកទេវបុត្តទេវធីតាទាំងពីរអង្គនោះក៏គង់នៅលើកោះដែលសាងឡើងថ្មីនេះ ហើយទ្រង់កសាងសត្វសាហាវទាំងពួង មានមេយ រុក្ខជាតិ តិណជាតិ មនុស្សទើងក្មេង ៗ បួនជាក្មេងដែលសាងឡើងដោយឫទ្ធានុភាពនោះបណ្ដាលផេះទេវធីតានោះស្លាប់ទៅ ទេវបុត្តមានចិត្តអាឡោះអាល័យដល់នាងទេវធីតាពន់ពេក ទើបស្ដេចទៅតាមនាងរហូតដល់ស្រុកមនុស្ស ឯនាងពោលថា ខ្ញុំនាងបានសេពរសជាតិរបស់មនុស្សហើយមិនអាចត្រឡប់ប្រែជាសភាពដើមវិញបានទេ លុះថារួចហើយក៏បាត់ពងកាយចូលទៅក្នុងដែនមនុស្សនោះវិញ ។ ឯទេវបុត្រ បានរង់ចាំនាងទេពធីតាអស់កាលយូរហួសកំណត់នឹងអត់ទ្រាំនៅចាំតទៅទៀតបាន ក៏ទ្រង់ដើរចូលទៅក្នុងអាណាខេត្តរបស់មនុស្ស ពិភពនេះងងឹតពេកណាស់ទើបទ្រង់កាច់ក្រាសសិតសក់ ១ បំរៀកអុជជាគប់ភ្លើង ក្នុងមួយរំពេចនុ៎ះឯងពន្លឺភ្លើងផ្ទុះភ្លឺឡើងចាំងទៅត្រូវពងកាយ នៃនាងទេវធីតាដែលកំពុងមានដង្វរនៅពាសពេញទាំងខ្លួន ហើយមានពន្លឺព្រោងព្រាតដោយជុំវិញ ទេវបុត្រនោះក៏រត់ចេញពីទីនុ៎ះ ។ ការដែលស្វាមីនាងដើរកន្ទួងចូលទៅក្នុងដែននោះដូច្នោះ ធ្វើឲ្យទេវធីតានោះមានចិត្តក្រេវក្រោធជាពន្ទឹក ទើបប្រើបម្រើស្រីជពម្នាក់ ជាពជទូតឲ្យដេញចាប់ព្រះស្វាមីមកឲ្យបាន កាលស្រីមនុស្សដេញប្រកិតមកជិតទាន់ ទេវបុត្រក៏បោះសរសៃសូត្រពោលទៅ

ក្លាយទៅជាបំការទំពាំងជូរ ធ្វើឲ្យពជនូតមឫត្យុនោះភាន់ភាំងភ្លេចស្មារតី គិតតែបេះផ្លែទំពាំងជូរបរិភោគយ៉ាងក្រេមក្រព្ធ លុះមានស្មារតីនឹករឭកឃើញក៏ចំដេញតាមគេទៅទៀត ទេវបុត្រក៏កាប់ក្រាសពោយទៅជាទំពាំងឫស្សីខ្ចី ៗ យ៉ាងឆ្ងាញ់ ស្រីមឫត្យុក៏គិតតែសពទំពាំងឫស្សីខ្ចីនោះ ដោយចិត្តលោភម្តងទៀត ៗ ខណៈនោះទាហានមឫត្យុក្នុងអាណាចក្រទាំងមូលក៏លើកគ្នាដេញតាមមក ទេវបុត្រក៏ដកព្រះខ័នពេជ្រចេញមកគស្ងួងរត់ផង រហូតដល់ដែនមនុស្សលោក ទើបទេវបុត្រសែកផ្តុំផ្លែអម្ពុត ៣ បោះចោលទៅត្រូវទាហានមឫត្យុមានអន្តរាយបាលបាញ់រត់ខ្ចាត់ខ្ចាយអស់ទៅ ៗ ក្នុងខណៈនោះ នាងទេវធីតាក៏ដេញតាមប្រកិតមកទៀត បង្ខំនឹងផ្តាច់យកជីវិតឲ្យតែខាងបាន ៗ ឯទេវបុត្រដល់មកខណៈនេះក៏អស់សេចក្តីស្នេហាអាល័យក្នុងខ្លួននាងទេវធីតា ទើបទេវបុត្រដាក់ថ្ម ១ ដុំធ្វើជាព្រំប្រទល់ខុកត្រង់ចន្លោះនៃពិភពទាំងពីរ ហើយពោលហាមផ្តាច់ថា នាងឯងធ្លាប់ជាភរិយារបស់យើង តាំងអំពីថ្ងៃនេះទៅដាច់ស្រឡះពីស្វាមីភរិយាគ្នាចុះ ឯនាងទេវធីតាមានចិត្តខ្ញាញ់ណាស់ទើបពោលពាក្យព្យាបាទថា កាលបើខ្លួនយើងសម្លាប់អ្នកមិនបានទេ យើងនឹងសម្លាប់បរិវាររបស់អ្នកមួយថ្ងៃ ១.០០០ នាក់ ទេវបុត្រក៏ពោលពាក្យផ្ចាលតបទៅវិញថា យើងនឹងសាងបរិវារសងវិញមួយថ្ងៃ ១.៥០០ នាក់ ៗ តាំងអំពីថ្ងៃនោះមក នាងទេវធីតាដែលជាអ្នកគ្រប់គ្រងពិភពមឫត្យុក៏គិតតែបំផ្លាញជីវិតមនុស្សមួយថ្ងៃ

១.០០០ នាក់តាមប្រកាស ឯទេវបុត្រក៏ទ្រង់សាងមនុស្សឡើងមួយថ្ងៃ ១.៥០០ នាក់រាល់ថ្ងៃដែរ ដោយហេតុនេះនៅប្រទេសជប៉ុនមានមនុស្សកើតច្រើនជាងស្លាប់ ហើយមានភ័យវិបត្តិធ្វើឱ្យប្រជាជនបង់ជីវិតក្នុងមួយគ្រាៗជាចំនួនច្រើន ដូចទឹកជោរជន់មកលិចស្រុក ភ្នំភ្លើងផ្ទុះ ផែនដីកម្រើក តាមពាក្យផ្ដាសារបស់នាងទេវធីតាជាដើមកំណើតអគ្គីនោះ ។

ក្នុងគម្ពីរបុរាណរបស់ចិន ក៏មានរឿងដំណាលទុកថា មនុស្សដែលបានមកចាប់កំណើតឡើងក្នុងលោកនេះ ជាដើមដំបូងមានព្រះមួយអង្គនៅក្នុងលោកនេះទ្រង់ព្រះនាមថា សែកកៀមូនីហ៊ុតទ្រង់ទតមើលលោកដែលមានទ្វីប៤ គឺទ្វីបខាងកើត, ទ្វីបខាងលិច, ខាងជើង, ខាងត្បូង ។ ទ្វីបខាងត្បូងមានឈ្មោះថា ណាំជៀងប៉ូជីវនៅមានពពកអ័ព្ទមីរងងឹត (ព្រះសែកកៀមូនីហ៊ុត) ប្រាថ្នានឹងធ្វើទៅជាមនុស្សលោក ទើបទ្រង់បង្គាប់ឃុនតប៉ែងឆាណា ឬដែលហៅថា ប៊ុទ្ធះកាដី ឬដែលហៅក្លាយមកថាស្ដេចកោសី ព្រាហ្មណ៍ហៅថាវិស្សុកម្មឬវិស្ណុកម្មឲ្យចុះមកបើកដីនឹងមេឃ ទើបស្ដេចព័ទ្ធកោសីនិម្មិតពង់កាយជាផ្លែឈើ ១ យ៉ាង មានគ្រាប់ខាងក្នុងជារូបទារកធ្លាក់ចុះពីមេឃវិលវៀលធ្លាក់មក ៤៩ ដង (ត្រឡប់) ទើបផ្លាស់ប្រែជាពង់កាយមនុស្ស ត្រង់ក្បាលដុះស្នែងងស្មើត ស្នើងក្លែកមូលធំ មានចង្កូមលៀនចេញមកក្រៅមាត់ មានរោមដុះពេញខ្លួន នៅដៃឆ្វេងកាន់ពន្លាក ដៃស្ដាំកាន់ពូថៅធំ ហើយបោះដាប់ទីងងឹតអ័ព្ទនេះដោយកម្លាំងឥទ្ធិរិទ្ធិ

បែកចេញជាពីរចំណែក ៗ ដែលមានលក្ខណៈថ្លានោះក្លាយទៅជាមេឃ ចំណែកដែលកករល្អក់នោះធ្លាក់ចុះទៅក្រោម ក្លាយទៅជាផែនដី ។ វេលាដែលស្តេចព័នកោសីទ្រង់កសាងមេឃនឹងផែនដីនោះ ស្មានមើលប្រហែលជាពីរហ្មឺនឆ្នាំ លុះកន្លងកាលមកជាយូរអង្វែង ចំហាយមេឃនឹងចំហាយដីប៉ះសម្ពស្សគ្នាទៅកើតជាដុំសិលាមូលមានទំហំធំ ហើយបែកចេញជាដុំតូច ៗ ទៀត ១២ ដុំ ដុំសិលាដែលកើតឡើងអំពីចំហាយដីមេឃទាំង ១៣ ដុំនេះ ប្រែក្លាយជាមនុស្សឡើងចំនួន ១៣ នាក់ ដុំមុនដំបូងជាបងប្រុសច្បង បានធ្វើជាហង់តេ គឺមហាក្សត្រ តាមតម្រារបស់ចិនខាងសំដែងទុកថា មនុស្សទាំង ១៣ នាក់នេះជាអំបូរព្រះឥស្សរ ទើបមានពូជពង្សវង្សមនុស្សជាប់គ្នារៀង ៗ មកជាលំដាប់ ដោយនិយមឧតុនិយមនឹងឧបបាតិកកំណើត ដោយហេតុចំហាយមេឃជាភេទប្រុស ចំហាយដីជាភេទស្រី ។ តមកទៀត ព្រះសែកកៀមូនីហ៊ុត ទ្រង់ប្រើព័នកោសីឲ្យទៅអញ្ជើញស៊ុំង៍ខ័យ យ៉ីហដីជិន គឺព្រះអាទិត្យនឹងថាំងប៉ីយ៉ីហាធៀនហៀន គឺព្រះចន្ទ្រ ឯតំបន់ហាំទីឲ្យមកដើរជុះលោកតាមបក្រពសី ។ មនុស្សដែលកើតឡើងក្នុងសម័យជាន់ក្រោយមកបានអាស្រ័យពន្លឺនេះជាគ្រឿងញ៉ាំងជីវិតនឹងញ៉ាំងសេចក្តីចំរើនឲ្យកើតឡើងដរាបមក ។

ក្នុងតម្រាបុរាណរបស់ក្រិក បានកត់ត្រាទុកដោយជនជាតិសាលដេឈ្មោះប៊ីរ៉ូស័សកាលមុនគ្រិស្តសករាជប្រហែល ៣០០ ឆ្នាំ មានសេចក្តី

ថ្ងៃពីកំណើតមនុស្សយ៉ាងចំឡែកទុកជា ក្នុងអតីតកាលជាអង្វែងមកហើយ
នោះ មានទីយ៉ាងធំទូលាយសំបើមណាស់ មានតែងងឹតស្អាប់អ័ព្ទអួរដេរ-
ដាសហើយមានទឹកពាសពេញខ្លួនទៅ ជាលំនៅរបស់សត្វនានាមានរូបពង
មុខគួរឲ្យខ្ពើម ឯមនុស្សនោះសោត មានស្លាបមួយក៏មាន មានមុខមួយ
ក៏មាន មានមុខពីរក៏មាន ទាំងប្រុសទាំងស្រី អ្នកខ្លះមានគូថជាពពែ មាន
ស្នែងដុះនៅលើក្បាល អ្នកខ្លះមានជើងមានក្រចកដូចសេះ អ្នកខ្លះមាន
ខ្លួនជាសេះមានមុខជាមនុស្ស និងសត្វស្លាបផ្សេង ៗ សត្វលូនវារនិងសត្វ
ឯទៀត ៗ ច្រើនជាអនេក ។ ព្រះជាម្ចាស់ដែលទ្រង់គ្រប់គ្រងនោះទ្រង់
ព្រះនាមថាបែល ហើយមានស្រីឈ្មោះអូមូ៌រកា ដែលជាអ្នកគ្រប់គ្រង
មនុស្សនិងសត្វទាំងពួង ៗ លុះកាលតមក ព្រះជាម្ចាស់ដែលទ្រង់ព្រះ
នាមព្រះបែលនោះបានទ្រង់ញែកបំបែកងងឹតចេញហើយ ទ្រង់បណ្ដាល
ឲ្យនាងអូម៌រកាដាច់ខ្លួនជាពីរកំណាត់ គឺមួយកំណាត់ទ្រង់បណ្ដាលឲ្យកើត
ឡើងជាលោក មួយកំណាត់ទៀតទ្រង់សាងឡើងជាព្រះអាទិត្យព្រះចន្ទ
និងជាពពួកផ្កាយ ហើយទ្រង់បណ្ដាលឲ្យទឹកហូរចូលទៅក្នុងពសុធា ។
សព្វសត្វដែលមានជីវិតទាំងពួងដែលមានមកពីដើម មិនអាចនឹងធន់កំ-
ដៅរបស់ដួងអាទិត្យបាន ក៏អន្តរធានបាត់បង់សាបសូន្យអស់ទៅ ទើបព្រះ
បែលកាត់ព្រះសិររបស់ព្រះអង្គចេញ ហើយទ្រង់បង្គាប់ឲ្យទេវតាមួយអង្គ
យកព្រះលោហិតដែលហូរចេញពីព្រះសិរនោះទៅផ្សំនឹងដីហើយឲ្យសាង

ដីផ្សំនឹងលោហិតនេះជាមនុស្ស នឹងសត្វក្នុងលោក ឲ្យមានរូបរាងដូចគ្នាជាពួក ៗ តាំងអំពីកាលណោះមក ទើបមនុស្សមានពូជពង្សវង្សត្រកូលមកតាំងអំពីប្រទេសសាលដេរហូតមកដល់សម័យសព្វថ្ងៃនេះ ។

ពោលអំពីកំណើតរបស់មនុស្សជាតិ ដែលអ្នកប្រាជ្ញបុរាណទាំងសម័យបច្ចុប្បន្ននេះបានពោលអាងនោះ សុទ្ធតែមានសេចក្តីផ្សេង ៗ គ្នាដូចបានសំដែងខាងដើមនេះ ត្រង់សេចក្តីដែលថ្លែងថាមនុស្សកើតពីធាតុគឺចំហាយមេឃនឹងចំហាយដី ក៏មានសេចក្តីល្មមស្តាប់បានតាមគោលវិជ្ជាការ ដែលអាចសន្និដ្ឋានថាជាសេចក្តីពិតក៏សឹងថាបាន ។

តាមយោបល់របស់មនុស្សក្នុងបុរាណសម័យ ចែកធាតុចេញជា ៤ ផ្នែក គឺបឋវីធាតុ (ធាតុដី)១ អាបោធាតុ (ធាតុទឹក)១ វាយោធាតុ (ធាតុខ្យល់)១ តេជោធាតុ (ធាតុភ្លើង)១ ប្រកបផ្សំគ្នាសមសួនជួនល្មមតាមធម្មតានិយម ធ្វើឲ្យកើតជារាងកាយមានរូបរាងចំរើនឡើងតាមលំដាប់ ដោយមានការដឹងខ្លួន ស្គាល់រស ដឹងសេចក្តី ដឹងគំនិតគិតគូរបេះត្រិះរិះកិច្ចការទាំងពួង កាលបើមានចំណែកណាមួយខ្វះខាតនឹងទ្រុឌទ្រោមទៅ ក៏កើតជម្ងឺឈឺចាប់ ចំណែកផ្សេងៗ របស់រាងកាយក៏មិនធ្វើការទាក់ទងគ្នា ហើយឈប់ស្ងៀម មានអាការស្ពឹកស្គឹងទៅ ក្នុងកាលណោះ យើងហៅថាស្លាប់ រាងកាយក៏ត្រជាក់ស្រេង អវយវៈផ្សេងៗក៏

ឃើញអាការភូមាកប្រើបអង់អាចលើករំលងចូលមកក្នុងខែត្រដែនដូច្នេះ ទើបកើតច្បាំងគ្នាឡើង ជាដំបូងក្នុងថ្ងៃទី ៥ ខែម៉ារ្ស ព. ស. ២៣៦៦ ក្នុងទីបំផុតភូមាដែលចេះប្រើវិធីចម្បាំងបែបបុរាណតែមួយយ៉ាង ក៏ចាញ់កងទ័ពអង់គ្លេសដែលមានយោធាទាហានស្ទាត់ជំនាញក្នុងវិធីចម្បាំងសម័យថ្មី ហើយភូមាសុំធ្វើសញ្ញាសន្តិភាពព្រមចុះចាញ់អង់គ្លេសក្នុងថ្ងៃ ២៤ ហ្វេវ្រិយេ ព.ស. ២៣៦៨ ដោយភូមាព្រមប្រគល់ខែត្រម្រិត, ខែត្រថ្វាយ, ខែត្រតៈ-ណាវសី នឹងខែត្រយៈខែឲ្យដល់អង់គ្លេស ហើយព្រមបង់ថ្លៃបង់ខាតឲ្យអង់គ្លេស ១០ លានរូពីយ៍ ហើយក៏ប់រេងថានឹងមិនចូលទៅបុករុកដល់ខែត្រមណីបុរៈ, ចិត្តកង់, កៈសា តទៅទៀតឡើយ ។

រលួយរលាយពុកផុយអស់ទៅ មានទំនងដូចគ្នាគ្រប់រូប តាំងអំពីបុព្វបុរសមុនបង្អស់ដរាបមកដល់ឥឡូវនេះ ។

ឯអ្នកដែលជឿប្រកាន់ថា មនុស្សកើតមកពីព្រះជាម្ចាស់សួគ៌នោះ យល់ថាព្រះជាម្ចាស់សួគ៌ទ្រង់មានឫទ្ធានុភាពច្រើនណាស់ ទ្រង់សាងអ្វីៗបានតាមប្រាថ្នា តែប្រសិនបើសួរថា ព្រះជាម្ចាស់កើតមកពីអ្វី គង់មិនមានអ្នកឆ្លើយដោះដោយច្បាស់លាស់បាន ។

ប្រសិនបើយល់ថា ព្រះជាម្ចាស់ទ្រង់សាងលោកនឹងមនុស្សឲ្យកើតមកសម្រាប់ប្រដាប់លោក ម្ដេចក៏មិនទ្រង់សាងមនុស្សល្អៗ មកប្រដាប់លោក ហេតុអ្វីក៏ទ្រង់សាងមនុស្សដែលមានតណ្ហា ឈ្លានីសរំលោភលើអ្នកដទៃដែលមានលក្ខណៈជាមនុស្សពាល ជាចោរ ជាដើម ។

ដែលថាមនុស្សកើតមកពីសត្វតិរច្ឆាននោះហាក់ដូចជាមិនសមហេតុផលដែរ ព្រោះមនុស្សជាសត្វមួយពួកដែលមានសតិបញ្ញា ទឹងគំនិតគិតគូរដ៏ខ្ពង់ខ្ពស់ មិនគួរយល់ថាជាពូជពង្សវង្សត្រកូលរបស់សត្វតិរច្ឆានសោះឡើយ ។

ហេតុនេះបរិយាយដែលនិយាយថាមនុស្សជាតិកើតមកពីអ្វី នៅតែងងឹតងងល់មិនទាន់ដាច់ស្រេចនៅឡើយ ។

(អំពីទស្សនាវដ្ដីវិទ្យាចារ្យ ព. ស. ២.៤៨១) ។

អ្នកប្រែនិងរៀបរៀង ខេមរវ័ង្ស

# សំខ្យាសព្ទ(១)

(៨៥) សព្ទសម្រាប់រាប់ចំនួនហៅថា សំខ្យា ។ នេះមាន ២ យ៉ាងគឺ ប្រកូតិសំខ្យា ១ បូរណសំខ្យា ១ ។ សំខ្យាដែលរាប់តាមប្រក្រតី គឺរាប់ថា មួយ, ពីរ, បី, បួន, ប្រាំ ជាដើម ហៅថា ប្រកូតិសំខ្យា ។ សំខ្យាដែលរាប់តាមលំដាប់តាមថ្នាក់ជាផ្នាន់ៗ គឺរាប់ថា ទីមួយ, ទីពីរ, ទីបី, ទីបួន, ទីប្រាំ ជាដើម ហៅថា បូរណសំខ្យា ។

## ប្រកូតិសំខ្យា

(៨៦) វិធីរាប់ប្រកូតិសំខ្យា តាំងពី ១ ដល់ ១០

| អក្សរ | | | ពាក្យប្រែ | លេខ | | |
|---|---|---|---|---|---|---|
| ទេវនាគរី | ខ្មែរ | បារាំង | | ទេវនាគរី | ខ្មែរ | បារាំង |
| एक | ឯក | eka | មួយ | १ | ១ | 1 |
| द्वि | ទ្វិ | dvi | ពីរ | २ | ២ | 2 |
| त्रि | ត្រិ | tri | បី | ३ | ៣ | 3 |
| चतुर् | ចតុរ៑ | catur | បួន | ४ | ៤ | 4 |
| पञ्च | បញ្ច | pañca | ប្រាំ | ५ | ៥ | 5 |
| षष् | ឞឞ៑ | ṣaṣ | ប្រាំមួយ | ६ | ៦ | 6 |
| सप्त | សប្ត | sapta | ប្រាំពីរ | ७ | ៧ | 7 |
| अष्ट | អដ្ឋ | aṣṭa | ប្រាំបី | ८ | ៨ | 8 |
| नव | នវ | nava | ប្រាំបួន | ९ | ៩ | 9 |
| दश | ទស | daça | ដប់ | १० | ១០ | 10 |

១ សំខ្យាសព្ទដែលពោលក្នុងទីនេះដោយសង្ខេប, អ្នកសិក្សា បើត្រូវការចង់ដឹងដោយពិស្ដារ ចូរមើលសៀវភៅកច្ចាយនូបត្ថម្ភភាគទី ១ តាំងពីលេខ ៩០ ដល់ ១១០ ។

## (៨៣) វិធីបំបែកប្រកួតិសំខ្យាតាំងពី ១ ដល់ ១០

### एक ឯក[1], "មួយ"

| | បុំ. | | នបុំ. | | ស្ត្រី. | |
|---|---|---|---|---|---|---|
| ប្រ. | एकस् | ឯកស៑ | एकम् | ឯកម៑ | एका | ឯកា |
| ទុ. | एकम् | ឯកម៑ | " | " | एकाम् | ឯកាម៑ |
| ត. | एकेन | ឯកេន | एकेन | ឯកេន | एकया | ឯកយា |
| ច. | एकस्मै | ឯកស្មៃ | एकस्मै | ឯកស្មៃ | एकस्यै | ឯកស្យៃ |
| ប. | एकस्मात् | ឯកស្មាត៑ | एकस्मात् | ឯកស្មាត៑ | एकस्यास् | ឯកស្យាស៑ |
| ឆ | एकस्य | ឯកស្យ | एकस्य | ឯកស្យ | " | " |
| ស. | एकस्मिन् | ឯកស្មិន៑ | एकस्मिन् | ឯកស្មិន៑ | एकस्याम् | ឯកស្យាម៑ |

### द्वि ទ្វិ, "ពីរ"

| | បុំ. | | នបុំ. | | ស្ត្រី. | |
|---|---|---|---|---|---|---|
| ប្រ. ទុ. | द्वौ | ទ្វៅ | द्वे | ទ្វេ | द्वे | ទ្វេ |
| ត. ច. ប. | द्वाभ्याम् | ទ្វាភ្យាម៑ | द्वाभ्याम् | ទ្វាភ្យាម៑ | द्वाभ्याम् | ទ្វាភ្យាម៑ |
| ឆ. ស. | द्वयोस् | ទ្វយោស៑ | द्वयोस् | ទ្វយោស៑ | द्वयोस् | ទ្វយោស៑ |

---

១ ឯកនេះ បើប្រែថាមួយ បំបែកបានតែជាឯកវចនៈ. បើប្រែថា "ពួកមួយ" ត្រូវបំបែកបានជាពហុវចនៈ: បុំ. ប្រ. ឯកេ, នបុំ. ឯកានិ, ស្ត្រី ឯកាយោ (ម. ល ៩៣ ត្រង់ល.៤១) ។

## त्रि ត្រិ, "បី"

| | បុ. | | នបុ. | | ស្ត្រី. | |
|---|---|---|---|---|---|---|
| ប្រ. | त्रयस् | ត្រយស៑ | त्रीणि | ត្រីណិ | तिस्रस् | តិស្រស៑ |
| ទុ. | त्रीन् | ត្រីន៑ | " | " | " | " |
| ត. | त्रिभिस् | ត្រិភិស៑ | त्रिभिस् | ត្រិភិស៑ | तिसृभिस् | តិស្ឫភិស៑ |
| ច. | त्रिभ्यस् | ត្រិភ្យស៑ | त्रिभ्यस् | ត្រិភ្យស៑ | तिसृभ्यस् | តិស្ឫភ្យស៑ |
| ប. | " | " | " | " | " | " |
| ឆ. | त्रयाणाम् | ត្រយាណាម៑ | त्रयाणाम् | ត្រយាណាម៑ | तिसृणाम् | តិស្ឫណាម៑ |
| ស. | त्रिषु | ត្រិឞុ | त्रिषु | ត្រិឞុ | तिसृषु | តិស្ឫឞុ |

## चतुर् ចតុរ៑, "បួន"

| | បុ. | | នបុ. | | ស្ត្រី. | |
|---|---|---|---|---|---|---|
| ប្រ. | चत्वारस् | ចត្វារស៑ | चत्वारि | ចត្វារិ | चतस्रस् | ចតស្រស៑ |
| ទុ. | चतुरस् | ចតុរស៑ | " | " | " | " |
| ត. | चतुर्भिस् | ចតុភ៌ិស៑ | चतुर्भिस् | ចតុភ៌ិស៑ | चतसृभिस् | ចតស្ឫភិស៑ |
| ច. | चतुर्भ्यस् | ចតុភ៌្យស៑ | चतुर्भ्यस् | ចតុភ៌្យស៑ | चतसृभ्यस् | ចតស្ឫភ្យស៑ |
| ប. | " | " | " | " | " | " |
| ឆ | चतुर्णाम् | ចតុណ៌ាម៑ | चतुर्णाम् | ចតុណ៌ាម៑ | चतसृणाम् | ចតស្ឫណាម៑ |
| ស. | चतुर्षु | ចតុឞ៌ុ | चतुर्षु | ចតុឞ៌ុ | चतसृषु | ចតស្ឫឞុ |

(តាំងពី បញ្ច "ប្រាំ" ដល់ ទស "ដប់" ត្រូវបំបែកដូចគ្នាតាំងបីលិង្គ)

## ៧៨ បញ្ច, "ប្រាំ"

ប. ទុ. បញ្ច, ត្ប. បញ្ចកិសិ, ច. ប. បញ្ចក្យសិ, ឆ. បញ្ចនាមិ, ស. បញ្ចសុ.

## ៧៩ ឆឡ, "ប្រាំមួយ"

ប. ទុ. ឆឡ, ត្ប. ឆឡិសិ, ច. ប. ឆឡ្យសិ, ឆ. ឆណ្ណាមិ, ស. ឆឡសុ.

## ៨០ សត្ត, "ប្រាំពីរ"

ប. ទុ. សត្ត, ត្ប. សត្តកិសិ, ច. ប. សត្តក្យសិ, ឆ. សត្តនាមិ, ស. សត្តសុ.

## ៨១ អដ្ឋ, "ប្រាំបី" មានវិធីបំបែកពីរយ៉ាងៈ

១. ប. ទុ. អដ្ឋោ, ត្ប. អដ្ឋាកិសិ, ច. ប. អដ្ឋាក្យសិ, ឆ. អដ្ឋានាមិ ស. អដ្ឋាសុ.

២. ប. ទុ. អដ្ឋ, ត្ប. អដ្ឋកិសិ, ច. ប. អដ្ឋក្យសិ, ឆ. អដ្ឋានាមិ, ស. អដ្ឋសុ.

នវ, "ប្រាំបួន" ទស, "ដប់" ត្រូវបំបែកដូច បញ្ច ៗ

## (៨៨) វិធីរាប់ប្រក្រតិសំខ្យា តាំងពី ១១ ដល់ ៩៩

| | | |
|---|---|---|
| एकादश | ឯកាទឝ | ១១ |
| द्वादश | ទ្វាទឝ | ១២ |
| त्रयोदश | ត្រយោទឝ | ១៣ |
| चतुर्दश | ចតុទ៌ឝ | ១៤ |
| पञ्चदश | បញ្ចទឝ | ១៥ |
| षोडश | ឞោឌឝ | ១៦ |
| सप्तदश | សប្តទឝ | ១៧ |
| अष्टदश | អឞ្ដទឝ | ១៨ |
| नवदश | នវទឝ | ១៩ |
| विंशति | វឹឝតិ | ២០ |
| एकत्रिंशति | ឯកវឹឝតិ | ២១ |
| द्वात्रिंशति | ទ្វាវឹឝតិ | ២២ |
| त्रयोत्रिंशति | ត្រយោវឹឝតិ | ២៣ |
| चतुर्त्रिंशति | ចតុវ៌ឹឝតិ | ២៤ |
| पञ्चत्रिंशति | បញ្ចវឹឝតិ | ២៥ |
| षड्त्रिंशति | ឞឌ៍វឹឝតិ | ២៦ |
| सप्तत्रिंशति | សប្តវឹឝតិ | ២៧ |

| | | |
|---|---|---|
| अष्टविंशति | អដ្ឋវិំឝតិ | ២៨ |
| नवविंशति | នវវិំឝតិ | ២៩ |
| त्रिंशत् | ត្រិំឝត៑ | ៣០ |
| एकत्रिंशत् | ឯកត្រិំឝត៑ | ៣១ |
| द्वात्रिंशत् | ទ្វាត្រិំឝត៑ | ៣២ |
| त्रयस्त्रिंशत् | ត្រយស្ត្រិំឝត៑ | ៣៣ |
| चतुस्त्रिंशत् | ចតុស្ត្រិំឝត៑ | ៣៤ |
| पञ्चत्रिंशत् | បញ្ចត្រិំឝត៑ | ៣៥ |
| षट्त्रिंशत् | ឞដ៑ត្រិំឝត៑ | ៣៦ |
| सप्तत्रिंशत् | សប្តត្រិំឝត៑ | ៣៧ |
| अष्टत्रिंशत् | អដ្ឋត្រិំឝត៑ | ៣៨ |
| नवत्रिंशत् | នវត្រិំឝត៑ | ៣៩ |
| चत्वारिंशत् | ចត្វារិំឝត៑ | ៤០ |
| एकचत्वारिंशत् | ឯកចត្វារិំឝត៑ | ៤១ |
| द्वाचत्वारिंशत् | ទ្វាចត្វារិំឝត៑ | ៤២ |
| त्रयश्चत्वारिंशत् | ត្រយឝ្ចត្វារិំឝត៑ | ៤៣ |
| चतुश्चत्वारिंशत् | ចតុឝ្ចត្វារិំឝត៑ | ៤៤ |
| पञ्चचत्वारिंशत् | បញ្ចចត្វារិំឝត៑ | ៤៥ |

| | | |
|---|---|---|
| षट्चत्वारिंशत् | ឞដ៑ចត្វារិំឝត៑ | ៤៦ |
| सप्तचत्वारिंशत् | សប្តចត្វារិំឝត៑ | ៤៧ |
| अष्टचत्वारिंशत् | អឞ្ដចត្វារិំឝត៑ | ៤៨ |
| नवचत्वारिंशत् | នវចត្វារិំឝត៑ | ៤៩ |
| पञ्चाशत् | បញ្ចាឝត៑ | ៥០ |
| एकपञ्चाशत् | ឯកបញ្ចាឝត៑ | ៥១ |
| द्वापञ्चाशत् | ទ្វាបញ្ចាឝត៑ | ៥២ |
| त्रयःपञ्चाशत् | ត្រយះបញ្ចាឝត៑ | ៥៣ |
| चतुःपञ्चाशत् | ចតុះបញ្ចាឝត៑ | ៥៤ |
| पञ्चपञ्चाशत् | បញ្ចបញ្ចាឝត៑ | ៥៥ |
| षट्पञ्चाशत् | ឞដ៑បញ្ចាឝត៑ | ៥៦ |
| सप्तपञ्चाशत् | សប្តបញ្ចាឝត៑ | ៥៧ |
| अष्टपञ्चाशत् | អឞ្ដបញ្ចាឝត៑ | ៥៨ |
| नवपञ्चाशत् | នវបញ្ចាឝត៑ | ៥៩ |
| षष्टि | ឞឞ្ដិ | ៦០ |
| एकषष्टि | ឯកឞឞ្ដិ | ៦១ |
| द्विषष्टि | ទ្វិឞឞ្ដិ | ៦២ |
| त्रिषष्टि | ត្រិឞឞ្ដិ | ៦៣ |

| | | |
|---|---|---|
| चतुःषष्टि | ចតុះឞឞ្ដិ | ៦៤ |
| पञ्चषष्टि | បញ្ចឞឞ្ដិ | ៦៥ |
| षट्षष्टि | ឞដ៑ឞឞ្ដិ | ៦៦ |
| सप्तषष्टि | សប្តឞឞ្ដិ | ៦៧ |
| अष्टषष्टि | អឞ្ដឞឞ្ដិ | ៦៨ |
| नवषष्टि | នវឞឞ្ដិ | ៦៩ |
| सप्तति | សប្តតិ | ៧០ |
| एकसप्तति | ឯកសប្តតិ | ៧១ |
| द्विसप्तति | ទ្វិសប្តតិ | ៧២ |
| त्रिसप्तति | ត្រិសប្តតិ | ៧៣ |
| चतुःसप्तति | ចតុះសប្តតិ | ៧៤ |
| पञ्चसप्तति | បញ្ចសប្តតិ | ៧៥ |
| षट्सप्तति | ឞដ៑សប្តតិ | ៧៦ |
| सप्तसप्तति | សប្តសប្តតិ | ៧៧ |
| अष्टसप्तति | អឞ្ដសប្តតិ | ៧៨ |
| नवसप्तति | នវសប្តតិ | ៧៩ |
| अशीति | អឝីតិ | ៨០ |
| एकाशीति | ឯកាឝីតិ | ៨១ |

| | | |
|---|---|---|
| द्वाशीति | ទ្វាសីតិ | ៨២ |
| त्रयोऽशीति | ត្រយោ'សីតិ | ៨៣ |
| चतुरशीति | ចតុរសីតិ | ៨៤ |
| पञ्चाशीति | បញ្ចាសីតិ | ៨៥ |
| षडाशीति | ឆឡាសីតិ | ៨៦ |
| सप्ताशीति | សត្តាសីតិ | ៨៧ |
| अष्टाशीति | អដ្ឋាសីតិ | ៨៨ |
| नवाशीति | នវាសីតិ | ៨៩ |
| नवति | នវុតិ | ៩០ |
| एकनवति | ឯកនវុតិ | ៩១ |
| द्वानवति | ទ្វានវុតិ | ៩២ |
| त्रिनवति | ត្រិនវុតិ | ៩៣ |
| चतुर्नवति | ចតុនវុតិ | ៩៤ |
| पञ्चनवति | បញ្ចនវុតិ | ៩៥ |
| षणवति | ឆណ្ណវុតិ | ៩៦ |
| सप्तनवति | សត្តនវុតិ | ៩៧ |
| अष्टनवति | អដ្ឋនវុតិ | ៩៨ |
| नवनवति | នវនវុតិ | ៩៩ |

# បកិណ្ណកកថា

របស់

# ខេមរង្សី

(៨៩) សេចក្ដីពន្យល់ដោយសង្ខេប អំពីប្រកូតិសំខ្យា តាំងពី១១ដល់៩៩ចំពោះកន្លែងខ្លះដែលគួរចំណាំៈ

១. សំខ្យាសព្ទតាំងពីចំនួន ១១ ដល់ ៩៩ សុទ្ធតែជាបទសមាសទាំងអស់ គឺសព្ទ ២ រួមទៅជាមួយ សព្ទខាងដើមប្រាប់ចំនួនរាយ តាំងពី ១ ដល់ ៩ សព្ទខាងចុងប្រាប់ចំនួនដុំ ៗ ដែលគត់ ៗ ដូច ១០, ២០, ៣០ ជាដើម ។

២. ឯក "១" ដែលធ្វើជា ឯកា- ចំពោះតែត្រង់ ឯកាទស "១១" ក្រៅពីនោះតាំងពី ២១ ដល់ ៩១ នៅជា ឯក- គ្រប់អន្លើ ។

៣. ទ្វិ, "២", ត្រិ, "៣" ដែលផ្សំជាមួយនឹងចំនួន ១០, ២០, ៣០ ត្រូវធ្វើទៅជា ទ្វា-, ត្រយស៑-;- ដែលផ្សំជាមួយនឹងសំខ្យាសព្ទតាំងពីចំនួន ៤០ ដល់ ៩០ នោះអាចធ្វើបានតាមប្រាថ្នា ទ្វិ-ឬទ្វា-, ត្រិ-ឬត្រយស៑- (ត្រង់ អសីតិ "៨០" បើផ្សំដោយ ទ្វិ, ត្រិ ត្រូវធ្វើតាមរបៀបស្វរសន្ធិ គឺ ទ្វិ + អសីតិ > ទ្វ្យាសីតិ, ត្រិ + អសីតិ > ត្យាសីតិ, ទ្វ្យ- នឹង ត្យ- ដែលជម្រួត ៣ តួដូច្នេះ នាំឲ្យលំបាកដល់ការអានពេកណាស់ បើផ្សំដោយ ទ្វា- នឹង ត្រយស៑- ទៅជា ទ្វាសីតិ, ត្រយោ'សីតិ នេះស្រួលជាង)

៤. អដ្ឋ "៨" ដែលផ្សំជាមួយនឹងចំនួនគត់ តាំងពី ១០ ដល់ ៩០, គេ

អាចធ្វើបាន ២ យ៉ាង ជា អដ្ឋ- ក៏បាន អដ្ឋា ក៏បាន ដូចចំនួន ២៨ ជា អដ្ឋ- ឬ អដ្ឋាវីសតិ, ចំនួន ៣៨ ជា អដ្ឋ-ឬ អដ្ឋាត្រឹំសតិ ជាដើម ប៉ុន្តែត្រង់កន្លែងនេះ គេអាចប្រើបានដោយទំនងផ្សេង ៗ ដូច្នេះក៏បានដូចគ្នា គឺ: ទ្វូនា វីសតិ, ២០ ខ្វះ ២ គឺ ១៨ (២០-២=១៨); ទ្វូនា ត្រឹំសតិ, ៣០ ខ្វះ ២ គឺ ២៨ (៣០-២=២៨); ទ្វូនា ចត្តាលីសតិ, ៤០ ខ្វះ ២ គឺ ៣៨ (៤០-២=៣៨) ។

៥. ត្រង់ចំនួន ១៩ គឺ ឧនវីស គេអាចប្រើដោយទំនងផ្សេងពីនេះ នៅតែបានសេចក្តីដូចគ្នា គឺយក ឩន "ខ្វះ" ឬ ឯកោន "ខ្វះ ១" មកផ្សំនឹង វីសតិ "២០" ជា ឩនវីសតិ "២០ ខ្វះ" ឬ ឯកោនវីសតិ ឬ ឯកោនាវីសតិស៑ ២០ ខ្វះ ១ គឺ ១៩ (២០-១=១៩ ។ តាំងពីចំនួន ២៩ ដល់ ៩៩ គេអាចប្រើដោយទំនងខាងលើនេះដូចគ្នា ត្រង់ ៩៩ ត្រូវយក ឯកោន មកផ្សំនឹង សត "រយ" ជា ឯកោនសត ឬ ឯកោនំ សតម៑ ១០០ ខ្វះ ១ គឺ ៩៩ (១០០-១=៩៩) ។

៦ ត្រង់ចំនួន ២១ ឯកវីសតិ គេអាចធ្វើជា ត្រិសប្ត បី៧ ផង (៣×៧=២១) ដូច្នេះក៏បាន; ពុំនោះយក អធិក, ឧត្តរ ដែលប្រែថា "លើស" មកផ្សំនឹង វីសតិ ទៅជា ឯកាធិកវីសតិ ឬ ឯកោត្តរវីសតិ "២០ លើស ១ គឺ ២១ ដូចគ្នា ។ (ក្រៅពីនេះទៅអ្នកសិក្សាគប្បីចូលចិត្តថា មានទំនងដូចគ្នា) ។

# ប្រជុំពាក្យកាព្យ

## ភាគទី ៤

របស់រក្យក្រិមៀ អួង

ហ៊ុម៍ព្រ មហាតឡៀក

បីប្អូនប្រាំថ្ងៃនេះមកហើយ
ព្រលឹងកែវអើយរៀមគ្មានសុខ
គ្មានក្សាន្តដោយខានបានឃើញមុខ
ជាទុក្ខរន្ធត់ស្លុតស្មារតី ៗ
ទឹកពីយើងកើតរួមពសុជា
ក្រុងកម្ពុជាពជបូរី
ម្តេចឡើយមកឆ្ងាយអស់សេចក្តី
គួរអ៊ើមិនដឹងដំណឹងអ្នក ៗ
ព្រះពេគតើប្រែយ៉ាងដូចម្តេច
ជាតិចឬច្រើនថ្ងៃឲ្យជាក់
ឬមួយគ្រាន់បើហើយវរលក្ខណ៍
រៀមចង់ឲ្យជាក់ថ្ងៃនេះឯង ៗ
ដ្បិតចិត្តគិតថប់បារម្ភណាស់
ចង់ច្បាស់ព្រះពេគនោះបំបែង
ក្សត្រីមេត្តាចូរថ្លាថ្លែង

សូរិធាយសាយសែងឲ្យដល់ទៅ ។
ស្រងូតស្រងល់ខ្វល់ពន់ពេក
ដូចមេឃនឹងទឹកអ័ព្ទទិសា
ក្ដួលក្ដុកចុកណែនក្នុងឧរា
អនិច្ចាចៅកម្មនាំបំភ្លាត់ ។
កាលនៅក្នុងអសោកឧទ្យាន
ដ្បិតមានអ្នកធំគេពង្រាត់
បង្រាសឲ្យប្រាសឲ្យព្រាកព្រាត់
បំភ្លាត់ដោយនៅអំណាចគេ ។
យើងក៏រងកម្មទ្រាំវេទនា
រាល់ម៉ោងពេលាឥតទំនេរ
ពេលស៊ីៗ សុទ្ធតែទុក្ខទេ
ខ្វេសខ្វាយបេសព្វសរពើផង ។
ឃ្លាតគ្នាខានយល់មកពីរខែ
ឃើញតែពុកម៉ាយ ឡាយម្ដង ៗ

ម្ល៉ោះហើយអម្ពល់សល់សែនម៉ង
ចិត្តចងចង់ជាប់តែទោសា ៗ
ក្តៅក្តួលរំជួលដូចភ្លើងឆេះ
របេះរបោចខ្លោចចុក
ទ្រូងត្រួតតជំរួតតែទុក្ខា
អនិច្ចាមុខគួរគោសូរកាយ ៗ
ឥឡូវគិតស្មានថាបានជិត
ព្រោះដៀតបែកបាត់មកឃានកាយ
ទៅកម្មដែលចាំក៏អន្តរាយ
ខ្ចាត់ខ្ចាយដោយគុណបុណ្យបារមី ៗ
គិតស្មានបានជួបជួនស្នេហស្និទ្ធ
រួមចិត្តរួមខ្លួនស្ងួនប៉ែតី
មិនមានអន់អាក់ថ្នាក់ទឹងអ្វី
តែក្ដីឥតទីទឹងអាស្រ័យ ៗ
ទឹងសុំសំណាក់ដោយផ្ទះគេ

ចាស់ជួរខឹងខេរខួបពេកក្រៃ

បណ្ដាញទន្ទេញស្ដីកុំរ៉ៃ

អាស្រ័យដែកកោនផងពុំបាន ។

ឯរៀមតាំងពីត្រឡប់ទៅ

សុបសៅល្ហែល្ហិតឥតវិញ្ញាណ

ស្រមៃឃើញថ្ងៃនៃបដិប្រាណ

ទើបបានប្រុងប្រែបែរប្រែ ។

លើកហត្ថបីបមហើយថ្នមថ្នាក់

អង្អែលឱបដាក់លើឱរា

ឱបទៅពានខ្នើយនៃបកាយា

នេត្រាហូរល្ហែងស្រក់សស្រាក់ ។

សមស្បូរផ្គរលាន់ព្រងំ

រៀមកើតទុក្ខធំក្រំអួលអាក់

ចំបែងកណ្ដែងម្នេញតែម្នាក់ (មានត)

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

## កម្ពុជសុរិយា

សៀវភៅទស្សនាវដ្តីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ៦

6

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្តេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨៣
គ. ស. ១៩៤០

# បញ្ជីរឿង


១ — ហោរាសាស្ត្រនឹងពុទ្ធសាសនា របស់ហ្លួងសារានុប្រពន្ធ ស្រង់យកអំពីទស្សនាវដ្ដីពុទ្ធសាសនាថៃ . . . . . . . . . . . . . . . . . . . . ៣

២ — ប្រវត្តិសាស្ត្រនៃច្បាប់ របស់លោក រ.ឡាំងកាត់ ទីប្រឹក្សាច្បាប់ស្រុកបាងកក (តនឹងចប់) . . . . . . . . . . . . . . . . . . . . ១៧

៣ — ពុទ្ធប្បវត្តិបិដ (តមក) . . . . . . . . . . . . . . . . . . . . ៣៣

៤ — ប្រវត្តិមីលរេប៉ៈ របស់លោកស៊ុកបាក្វត់ ប្រែពីភាសាទីបេតាំង (តមក) . . . ៣៧

៥ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . ៤១

៦ — វេយ្យាករណ៍សំស្ក្រឹត ភាគទី ៦ របស់ព្រះសាក្យវង្ស ហ. តាត (តនឹងចប់) . . . ៤៩

៧ — ប្រជុំពាក្យកាព្យ ភាគទី ៤ របស់រក្សភិរម្យ (អ៊ួង (មាឌត) . . . . . . . . . ៦៧


## រូបក្រៅរឿង


១ — ទ្រង់ជួបប្រទះនឹងលោកសង្ឃ ១ រូប . . . . . . . . . . . . . . . . . ១

២ — ទ្រង់មហាភិនេស្ក្រមណ៍ . . . . . . . . . . . . . . . . . . . ១៥.

៣ — ទ្រង់កាត់ព្រះកេសា . . . . . . . . . . . . . . . . . . . ៣១

៤ — ព្រះពោធិសត្វគង់នៅក្នុងព្រៃ . . . . . . . . . . . . . . . . . . ៣៥

៥ — ទ្រង់បំពេញទុក្ករកិរិយា . . . . . . . . . . . . . . . . . . . ៣៩

៦ — កាលមីលរេប៉ៈបានជួបនឹងអ្នកប្រាជ្ញធំម្នាក់ឈ្មោះម៉ារប៉ៈនៅទីចំការមួយ. . . . ៤៧

# TABLE DES MATIÈRES

Pages.

1° Astrologie et Bouddhisme par Loung Sarâ extrait de la Revue BOUDDHASĀSANĀ en Thailandais .................. 3

2° Histoire des droits par R. Lingat Conseiller Juriste à Bangkok, traduit du Thailandais en Cambodgien par KHEMARARANSI (suite et fin) .................. 17

3° La Vie du BOUDDHĀ d'après les documents Chinois (suite).. 33

4° La Vie de Milarépa d'après la traduction du Tibétain en Français de Monsieur JACQUE BACOT (suite) .................. 37

5° INFORMATIONS DIVERSES .................. 41

6° GRAMMAIRE SANSCRITE 6ᵉ partie par Vénérable Préas SAKYAVONG (H-TATH) (suite et fin) .................. 49

7° RECUEIL DE POÈME cambodgiens, 4ᵉ partie par RAK-PHIROM UONG (suite) .................. 67

HORS TEXTES :

1° La rencontre avec un religieux .................. 1

2° Le grand départ .................. 15

3° La coupe des cheveux .................. 31

4° BODHISATTVA dans la forêt .................. 35

5° La grande pénitence .................. 39

6° Milarépa rencontre un grand sage Marpa dans un champ. 47

## បកិណ្ណកកថា

# ឧបាយរបស់ស្ត្រីចាស់ដែលមានប្ដីកំឡោះ

មានព្រះរាជាមួយអង្គ គង់រាជ្យនៅប្រទេសមួយស្ដេចទិវង្គតទៅ ព្រះរាជបុត្រច្បងបានសោយរាជ្យជាជំណាតមក ស្ដេចថ្មីនេះមានរាជបុរសម្នាក់ជាមិត្តរបស់ទ្រង់ នៅក្មេងកំឡោះ ទ្រង់ប្រោសប្រាណណាស់ ទ្រង់តាំងជាទីមហាមាត្យ វេលាស្ដេចទ្រង់ព្រះរាជដំណើរទៅតំបន់ណានីមួយ ៗ មហាមាត្យកំឡោះក៏ឡើងជិះក្រែសែងតាមស្ដេចជាដរាប ៗ ថ្ងៃមួយ ព្រះរាជានេះស្ដេចប្រទក្សិណព្រះនគរ មហាមាត្យក៏តាមស្ដេចទៅផង ចួនជាថ្ងៃនោះព្រះវររាជជននីទតព្រះនេត្រឃើញមហាមាត្យកំឡោះ ក៏មានព្រះទ័យស្នេហាខ្លាំងរង្វើងរង្វាន់កាន់កាំងព្រះស្មារតី ទើបមានបន្ទូលទៅនឹងព្រះរាជារាជបុត្រ ឲ្យបានជ្រាបដំណើរនុ៎ះសព្វគ្រប់ ៗ

ព្រះរាជាមានព្រះទ័យទន់តាំងអាណិតព្រះវរជននី ហើយសព្វព្រះទ័យនឹងមហាមាត្យផង ទើបទ្រង់ប្រោសប្រាណបណ្ដោយតាមប្រាថ្នារបស់ព្រះរាជមាតា ដូច្នេះមហាមាត្យក៏ក្លាយទៅជាបិតាធម៌របស់ព្រះរាជានេះ ៗ

ព្រះវររាជជននីនឹងមហាមាត្យក៏បានរួមសេអភិរម្យជាមួយគ្នា តាំងអំពីពេលនុ៎ះមក ៗ សម័យមួយ ព្រះវររាជជននីមានព្រះទ័យគិតថា មហាមាត្យនេះនៅក្មេងកំឡោះ គង់តែនឹងបោះបង់ទ្រង់ចោលមិនខាន



១៨ — អំពីការទ្រង់ជួបប្រទះនឹងលោកសង្ឃ ១ រូប

លោកសាស្ត្រនិងព្រះពុទ្ធសាសនា

# បាឋកថារបស់ហ្លួងសារានុប្រពន្ធ

ខេមរ៉ង្សី

ប្រែចេញពីទស្សនាវដ្តី

ពុទ្ធសាសនាថៃ

# ហោរាសាស្ត្រនិងពុទ្ធសាសនា

នេះជាឈ្មោះបាឋកថាមួយរបស់កុម្ម៉ង់ដង់ហ្វូងសាពនុប្រពន្ធដែលបានសំដែងតាមវិទ្យុក្នុងក្រុងបាងកក ហើយកាសែតពុទ្ធសាសនាបាននាំបាឋកថានេះមកចុះផ្សាយ មានទាំងថ្លែងយោបល់របស់គណៈបណ្ណាធិការប្រៀតប្រែកក្នុងបាឋកថានេះផង យើងយល់ថាជាសេចក្ដីប្លែកដល់ត្រចៀករបស់ពុទ្ធសាសនិកជន គួរនាំមកថ្លែងដើម្បីជាគ្រឿងពិនិត្យតទៅ ។

ផលកម្ម គឺសេចក្ដីសុខនិងទុក្ខដែលមនុស្សយើងបានទទួលសព្វថ្ងៃនេះ ហ្វូងសាពនុប្រពន្ធអ្នកប្រាជ្ញហោរាសាស្ត្រពោលថា សម្រេចមកពីដួងផ្កាយទាំងឡាយ នៃសកលចក្រវាឡដែលមានអំណាចធ្វើឲ្យយើងបានទទួលផលឬមិនឲ្យបានទទួលផលនៃកម្មអាក្រក់-ល្អដែលយើងបានកសាងទុកមក ។ ឯកម្មមានអំណាចជូនផលដល់អ្នកធ្វើឬមិនជូននោះស្រេចតែពពួកផ្កាយទាំងនុ៎ះ ។ ឯការចេះដឹងអំពីកិច្ចទាក់ទងគ្នារវាងផ្កាយនឹងមនុស្សផងទាំងឡាយ ឬដែលហៅថា "ហោរាសាស្ត្រ" នោះ ដើម្បីឲ្យដឹងច្បាស់ការបង្គាប់បញ្ជាអំពីដួងផ្កាយទាំងឡាយមានមកលើពួកមនុស្សពល់រូប ។ ឯផលកម្មទាំងពួងនោះគ្រាន់តែជាគ្រឿងសណ្ដាន ឬជាដើរក្រោយទេ ។

កាលៈបើបានស្តាប់ បាឋកថាមកដល់ត្រឹមណេះនឹងឃើញថា ក៏ប៉ះទង្គិចនឹងលទ្ធិកម្មរបស់ពុទ្ធសាសនាយ៉ាងខ្លាំង ដែលមានសំដែងទុកថា "អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកា" ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯផ្កាយទាំងឡាយលើអាកាសនឹងជួយធ្វើប្រយោជន៍អ្វីឲ្យមិនបានឡើយ ៗ ពាក្យនេះជាលទ្ធិកម្មរបស់ពុទ្ធសាសនាដែលមានទំនាស់យ៉ាងខ្លាំងនឹងលទ្ធិតារាសាស្ត្រឬហោរាសាស្ត្រ ដែលប្រកាន់ថាផលនៃសេចក្តីប្រព្រឹត្តល្អ-អាក្រក់របស់មនុស្សស្រេចនៅលើមេឃ គឺអំណាចនៃដួងផ្កាយ ហេតុនេះបានជាបណ្ណាធិការកាសែតពុទ្ធសាសនាឆ្លើយដោះថា

គ្រូពេទ្យថា ជម្ងឺកើតពីរោគរបស់ខ្លួន
គ្រូហោរាថា បាបគ្រោះរបស់ខ្លួន
គ្រូអាគមថា ខ្មោចឲ្យទោសឬខ្មោចធ្វើ
អ្នកប្រាជ្ញថា ផលកម្មរបស់ខ្លួន

ដោយហេតុជំនឿរបស់មនុស្សយើងប្រព្រឹត្តទៅតាមចំណេះវិជ្ជាដែលខ្លួនបានរៀនឬបានដឹងឮមក ទើបមានយោបល់ខុសខ្វែងគ្នាជាច្រើន អំពីគោលតែមួយ គឺសេចក្តីសុខទុក្ខរបស់យើងគ្រប់រូប ប៉ុន្តែហោរាសាស្ត្រដែលហ្លួងសារានុប្រពន្ធបានសំដែងមកនេះ ជាវិទ្យាសាស្ត្រមួយ (Science) មិនមែនហោរាគន់គូរនៅក្បែរចិញ្ចើមថ្នល់នុ៎ះទេ គឺជាពាក្យអធិប្បាយសម

ហេតុសមផលតាមវិជ្ជាការខាង Scientifique ឬ Logique ទើបលោកហ៊ានពោលថា ជីវិតរបស់មនុស្សយើងនៅក្រោមអំណាចនៃដួងផ្កាយតាំងឡាយ ។

លោកអធិប្បាយតាមគោលវិជ្ជាតារាសាស្ត្រ (Astronomie) ថា បណ្ដាផ្កាយទាំងឡាយរួមទាំងពិភពលោកយើងនេះនឹងព្រះចន្ទផង ដែលត្រាច់គោចរទៅជុំវិញដួងអាទិត្យ អណ្ដែតនៅក្នុងវេហាស៍ដោយមិនបាច់មានអ្វីជាគ្រឿងទ្រ នៅកណ្ដាលវេហាស៍ដ៏ស្រឡះល្វឹងនោះរមែងមានអាការស្រូបទាញប្រទង់គ្នាតាមកំឡាំងច្រើនតិចតែរៀងខ្លួន ទើបចណ្ដាលឲ្យមានអាការប្រែប្រួលឡើងក្នុងលោកយើងនេះ ដូចជាការស្រូបបូមនៃដួងចន្ទ ជាហេតុធ្វើឲ្យសមុទ្រក្នុងលោកយើងនេះ មានទឹកជោរទឹកនាចជាដើម វិធីស្រូបគ្នាទៅវិញទៅមកនេះ មានអាការប្រែប្រួលជានិច្ច ដោយហេតុដួងផ្កាយមានដំណើរគោចរផ្លាស់កន្លែងផ្លាស់ផ្លូវដើរជានិច្ច ៗ មានផ្កាយខ្លះគោចរមកជិតលោកយើងនេះហើយ មានកំឡាំងស្រូបជាហេតុធ្វើឲ្យលោកយើងវិបត្តិអន្តរាយដោយជម្ងឺរោគាឬ ទុ-ក្ខភ័យក៏មាន កាលផ្កាយនេះគោចរផុតទៅ សេចក្ដីវិបត្តិក៏បាត់អស់ទៅដែរ ។ នេះសំដែងឲ្យឃើញថា ការស្រូបនៃដួងផ្កាយ រមែងធ្វើឲ្យកើតផលចំពូកខ្លះឡើងហើយការស្រូបបូមនេះ រមែងប្រែប្រួលទៅតាម

ការគោចររបស់ផ្កាយគ្រប់ៗ វិនាទី (សីក្កន៍) ហេតុនេះ ការដែលលោកយើងបានទទួលការស្រូបប្រានប្រទាញអំពីដួងផ្កាយគ្រប់ៗ វិនាទីនោះមិនដូចគ្នាទេ ។ កាលសត្វមកចាប់បដិសន្ធិក្នុងគភ៌មាតាក្នុងវិនា-ទីណា មានកិរិយាស្រូបបូមក្នុងចក្រវាឡដូចម្តេច ទើបសត្វនេះមានរូបកំណើតប្លែកពីសត្វទាំងឡាយដែលមកចាប់កំណើតក្នុងវិនាទីដទៃ ហេតុនេះ ទើបមានការកើតបដិសន្ធិឡើងក្នុងលោកនេះហើយចំរើនឡើង មានបែបភាពនិងសេចក្តីប្រព្រឹត្តិមិនដូចគ្នា ដោយហេតុទទួលយកអំណាចពិសេសអ្វីមួយ ឬត្រូវស្រូបត្រូវប្រានចេញដោយអំណាចពិសេសណាមួយ នៃសកលចក្រវាឡដោយឡែកៗពីគ្នា ទើបសត្វត្រូវបង្ខំឲ្យប្រព្រឹត្តិទៅតាមអំណាចពិសេសដូចពោលមកហើយ យ៉ាងជាប់ស្រេចស្លាប់ក្រឡា ។ ចំណែកឯកម្មឬអំពើអ្វីមួយរបស់សត្វ គ្រាន់តែជាបរិការចូលមកជ្រែកជ្រែក មិនអាចលុបលាងកំរិត ឬគំនូសធំនៃ "គាពលិខិត"នោះបានឡើយ ព្រោះជាអំណាចនៃធម្មជាតិដែលមានសម្ពន្ធពាក់ទងនឹងមនុស្សនេះហើយដែលយើងបានសន្មតហៅថា "ហោរាសាស្ត្រ" (Astrologic) នេះជាសេចក្តីនៃបាឋកថារបស់ហ្វូងសាពន្ធប្រពន្ធនោះ ។

បើពោលតាមទំនងនេះនឹងយល់ថា បណ្តាសត្វទាំងឡាយ មិនបានប្រព្រឹត្តទៅតាមអំណាចកម្មដែលខ្លួនបានកសាងមកនោះទេ គឺប្រ-ព្រឹត្តទៅតាមអំណាច "គាពលិខិត" (គំនូសនៃដួងផ្កាយ) ឬអំណាច

ដែលបណ្ដាលមកពីដួងផ្កាយ តាមឡាក់ហោរាសាស្ត្រនោះគួរយើងនាំគ្នាពិចារណាមើលឲ្យម៉ត់ចត់ កុំឲ្យកាន់គំនិតច្រឡំបល់ នាំឲ្យខូចចិត្តអសារ ៗ តែមុននឹងពិចារណា គួរទទួលស្ដាប់សំដី ដែលមាននិយាយប៉ះពាល់ដល់ពុទ្ធសាសនា ដើម្បីឲ្យស្គាល់មតិរបស់លោកអ្នកសំដែង ទុកជាគ្រឿងពិចារណាតរៀងទៅ:

បាឋកថាលើកទី ១

(ស្រង់យកសេចក្ដីខ្លះ)

លោក-អ្នកធ្លាប់បានសង្កេតខ្លះឬទេ ថា នាយ ក. និងនាយ ខ. (ឈ្មោះសន្មត) រៀនអក្សរក្នុងសាលាជាមួយគ្នា ពេលជាមួយគ្នា ថ្នាក់ជាមួយគ្នា ប្រឡងបានសញ្ញាបត្រដូចគ្នា មានចំណេះនឹងការប៉ិនប្រសប់ដូចគ្នា លុះ ១០ ឆ្នាំតមក ឈ្មោះ ក. បានធ្វើជាចាងហ្វាង មានប្រាក់ខែ ៤០០ ឯឈ្មោះ ខ. នៅតែធ្វើស្មៀន មានប្រាក់ខែត្រឹម ៨០ ប៉ុណ្ណោះ បើដូច្នេះតើលោកអ្នកបានជ្រាបឬទេ ព្រោះហេតុអ្វីបានជាខុសគ្នា?

លោក-អ្នកធ្លាប់បានសង្កេតខ្លះឬទេថា ឈ្មោះ គ. និងឈ្មោះ ឃ. ដើរកាន់ដៃគ្នាទៅកណ្ដាលវាលស្រែ វេលាមានភ្លៀងធ្លាក់ ស្រាប់តែរន្ទះបាញ់ផាំងចុះមកត្រូវឈ្មោះ ឃ. ស្លាប់មួយរំពេចទៅ ឯឈ្មោះ គ. មិនមានអ្វីឡើយ តើលោក-អ្នកជ្រាបឬទេថា ចុះហេតុអ្វីបានជាឈ្មោះ គ. មិនស្លាប់?

មានពុទ្ធភាសិតសំដែងទុកថា "បុគ្គលធ្វើល្អតែងបានល្អ ធ្វើអាក្រក់តែងបានអាក្រក់" ដូច្នេះ តើលោក-អ្នកធ្លាប់បានសង្កេតខ្លះឬទេ ថាឈ្មោះ ង. ទៅលួចគេហើយគេចលាក់ខ្លួនពួនបាត់ ចៅនាទីចាប់មិនបាន ក៏ទៅជារួចខ្លួនទទេទៅ ៗ ឯឈ្មោះ ច. មិនបានលួចគេសោះ ត្រូវប៉ូលិសចាប់ខ្លួនដោយមានសង្ស័យថាជាចោរ ហើយត្រូវឃុំខ្លួនទុកជាច្រើនថ្ងៃ តើអ្នកជ្រាបខ្លះឬទេថា ព្រោះហេតុអ្វីបានជាមនុស្សធ្វើល្អត្រឡប់បានផលអាក្រក់ មនុស្សធ្វើអាក្រក់បែរជារួចខ្លួនវិញ ?

តាមដោយពិត អ្នកប្រាជ្ញវិទ្យាសាស្ត្រ ឬម៉ាតេរីយ៉ាលិស្ត៍ (Matérialiste) តែងព្យាយាមស្រាវជ្រាវរកហេតុផលដែលល្មមមើលឃើញច្បាស់នឹងភ្នែក ដូចជារឿងឈ្មោះ ក. នឹង ខ. ខាងលើនេះ អ្នកប្រាជ្ញវិទ្យាសាស្ត្រតែងពន្យល់ថា ព្រោះឈ្មោះ ក. ប្រព្រឹត្តល្អត្រូវទំនងនឹងកាលសម័យ គ្រាន់តែចៅហ្វាយនាយពិនិត្យឃើញច្បាស់ថាជាមនុស្សគួរលើកដំកើងឲ្យធ្វើជាធំបាន ៗ ឯឈ្មោះ ខ. មានសេចក្ដីប្រព្រឹត្តល្អដែរ តែមិនត្រូវទំនងដូច ក. ៗ បើនឹងសួរសឹកតទៅទៀតថា ក. នឹង ខ. កើតមកជាមនុស្សដូចគ្នា មានចំណេះប៉ុនប៉ោដូចគ្នា ចុះហេតុអ្វីទើប ខ. ធ្វើមិនត្រូវទំនងដូច ក. ៗ បើដូច្នេះតើលោកអ្នកនឹងអធិប្បាយដូចម្ដេចទៀត ?

គ. នឹង ឃ. ដើរកាន់ដៃគ្នានោះ ទុកដូចជាមានខ្សែក្ងើងជាប់តគ្នា ចុះហេតុអ្វី រន្ទះបាញ់ត្រូវចំពោះឈ្មោះ ឃ. ឯ គ. រួចខ្លួនទទេ ៗ

អ្នកប្រាជ្ញវិទ្យាសាស្ត្រគង់ពន្យល់ហេតុផលថា ព្រោះត្រង់កន្លែងដែលឈ្មោះ ឃ. ត្រូវទ្រុះបាញ់ស្លាប់នោះមានលោហធាតុដែលទទួលខ្សែភ្លើងអគ្គិសនីក្នុងអាកាសកំពុងស្ទុះចុះមកក្រោម ហើយស្រូបទៅត្រង់កន្លែង ឃ. នោះមួយរំពេច បើសួរទៀតថា ចុះកម្មអ្វីធ្វើឲ្យ ឃ. ត្រូវទ្រុះបាញ់ស្លាប់នៅទីនោះ គង់តបថាដោយចួនជាដើរទៅដល់ .... ចុះហេតុអ្វីបានជាចួនជាត្រូវទ្រុះបាញ់តែឈ្មោះ ឃ. ម្នាក់ឯង ឯឈ្មោះ គ. មិនត្រូវទ្រុះបាញ់ផង? ដូច្នេះតើយើងនឹងឆ្លើយដូចម្តេច?

ឧទាហរណ៍នេះ តាមផ្លូវវិទ្យាសាស្ត្របើដេញដោលឲ្យជ្រៅទៅនឹងមិនមានផ្លូវតបកាន់តែច្រើនឡើង គួរនឹកឲ្យខ្លាចដែរ បើមានការសួរដេញដោលមែន ៗ ហើយអ្នកសួរអាចរំពៃរកមើលទ្វារចេញជាមុនសិនទើបរួចខ្លួន ។

តែប្រស្នាអស់នេះ បើបែរមករកខាងផ្លូវបរមត្ថវិជ្ជា (Philosophie) តាមផ្លូវសាសនាជាដើម រមែងមានពាក្យឆ្លើយទូលាយជាងខាងផ្លូវវិទ្យា-សាស្ត្រ ឯហេតុកើតអស់នេះ បើពោលតាមគ្រិស្តសាសនា នឹងមានពាក្យតបថា ដោយអំណាចដៃនៃព្រះជាម្ចាស់សួគ៌ ឯសាសនាព្រាហ្មណ៍នឹងតបថាដោយអំណាចព្រហ្មលិខិត គឺព្រហ្មបានចារិកដំណើរជីវិតនៃមនុស្សមកហើយគ្រប់រូប គោលទាំងពីរនេះមានសេចក្តីតបដូចគ្នា គាងអំ-ណាចព្រះដូចគ្នា ឯព្រះទាំងពីរអង្គក្នុងសាសនាទាំងពីរនេះ មានសេចក្តី

សំដៅដល់វត្ថុស័ក្តិសិទ្ធិអ្វីមួយ ដែលបណ្តាលឲ្យមានសត្វ, មនុស្សនិងវត្ថុធាតុក្នុងលោកនេះ តែតាមផ្លូវព្រះពុទ្ធសាសនារបស់យើងមានហេតុផលល្អជាងនេះទៅទៀត ហេតុកើតអស់នេះតាមគតិពុទ្ធសាសនារបស់យើងពោលថា កើតអំពីកម្ម គឺអំពើដែលមនុស្សបានធ្វើមកហ្នឹងឯង ។

កម្មនេះ ជាពាក្យកណ្តាល តាមផ្លូវព្រះពុទ្ធសាសនាចែកចេញជា ២ យ៉ាងគឺ កុសលកម្ម និងអកុសលកម្ម ឬកម្មល្អនិងកម្មអាក្រក់ លក្ខណៈនៃកម្មបានដល់កម្មជារបស់ខ្លួន, កម្មជាផៅពង្ស, កម្មជាទីកើត, កម្មជាទីអាស្រ័យ យើងបានធ្វើកម្មយ៉ាងណា តោងតែទទួលផលនៃកម្មយ៉ាងនោះ ។

តែផលនៃកម្មនេះ ក៏មានកំណត់កំរិតពេលវេលាតាមកំឡាំងរបស់កម្ម មិនមែនធ្វើអាក្រក់ភ្លាម បានទទួលផលអាក្រក់ភ្លាមគ្រប់កម្មទៅកាលណា ដូចជាឧទាហរណ៍រឿងឈ្មោះ ង. នឹង ច. ដែលបានពោលមកហើយខាងដើមនេះ គឺឈ្មោះ ង. ទៅលួចទ្រព្យគេតែមិនត្រូវចាប់ ឈ្មោះ ច. មិនបានលួចទេតែត្រូវចាប់ ។ តាមគតិពុទ្ធសាសនាប្រកាន់ថា ព្រោះកុសលកម្មរបស់ ង. ដែលបានធ្វើទុកមកមានច្រើន ហើយតាមជូនផលមិនទាន់អស់ ទើបទុកដូចជាគ្រឿងបង្ការអកុសលកម្មក្នុងខណៈនោះ បានជាបណ្តោះអាសន្ន ។ ចំណែកឯ ច. មានអកុសលកម្មចាស់ច្រើន

ព្រោះទ្រង់ចាស់ជរាហើយ  នៅឱកាសដែលមហាមាត្យដេកដាក់ក្បាលលើព្រះភ្លៅព្រះរាជនទី ។ ក៏លបលួចដកព្រះកេសាស (សក់ស្កូវ) របស់ទ្រង់ ១ សរសៃ  ហើយដកសក់របស់មហាមាត្យចេញ ១ សរសៃផងហើយចោលទៅ  ទើបព្រះនាងយកសរសៃព្រះកេសារបស់ព្រះនាងលើកបង្ហាញហើយត្រាស់ថា "យីអើ  អ្នកឯងនេះចាស់ណាស់ហើយ  មើលចុះសក់ស្កូវហើយតើ" ។

ក្នុងខណៈនោះ  គួរតែមហាមាត្យគិតថា  អញនេះចាស់ជរាហើយ  គួរតែនៅជាគូគ្រងនឹងព្រះរាជនទីតរៀងទៅ  តែមហាមាត្យបែរជាគិតថា "អញចាស់ណាស់ហើយតើ! អញនេះល្ងង់ខ្លៅណាស់តើ! នៅឈ្លក់ជ្រ-មុជនឹងកាមរបស់លោកិយ  ដោយមិនបានធ្វើប្រយោជន៍អ្វីដល់ខ្លួនសោះឡើយ" ។

លុះគិតដូច្នេះហើយ  មហាមាត្យក៏រត់ទៅបួសទៅ  មហាមាត្យនេះហើយដែលជាព្រះពោធិសត្វ ។

## ជើងឈើពូកែជាងជើងកំណើត

យើងនៅក្នុងលោកវេលានេះ  គឺនៅក្នុងកណ្ដាលឧបាយកលផ្សេង ៗ ទុកជាយើងមានគំនិតគិតគូរប៉ុនប៉ៅប្រសប់យ៉ាងណា ៗ ក៏ដោយយើងនៅតែមិនអាចចៀសវាងឬគេចឲ្យផុតពីសេចក្ដីពិតបានឡើយ ។

ជាង ង. ទាំងមិនទាន់បានសងផលកម្មឲ្យអស់ទៅផង ៗ តាមគតិពុទ្ធ-សាសនាមានវិធីចែកកម្មដូច្នេះ :

១ – ទិដ្ឋធម្មវេទនីយកម្ម បានដល់កុសលនិងអកុសលមានផលឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្នជាតិនេះ ពោលគឺធ្វើក្នុងជាតិនេះតាមជូនផលក្នុងជាតិនេះដែរ ។

២ – ឧបបជ្ជវេទនីយកម្ម បានដល់កុសលអកុសលដែលបុគ្គលធ្វើទុកក្នុងជាតិនេះ តែតាមជូនផលដល់ទៅជាតិមុខ គឺតាមទាន់ក្នុងជាតិណាក៏ឲ្យផលក្នុងជាតិនោះ ។

៣ – អបរាបរវេទនីយកម្ម បានដល់កុសលអកុសលដែលបុគ្គលធ្វើទុកក្នុងជាតិនេះ តាមឲ្យផលច្រើនៗជាតិទៅមុខទៀត តាមទាន់វេលាណាក៏ឲ្យផលក្នុងវេលានោះ ។

៤ – អហោសិកម្ម បានដល់កុសលអកុសលដែលតាមជូនផលមិនទាន់ ហើយរលាយសាបសូន្យទៅ មិនមានផល រម្ងាប់ទៅឯង ។

មានប្រស្នាសួរឡើងទៀតថា ចុះអ្វីជាគ្រឿងចក្រដែលបង្វិលឲ្យកុសលអកុសលកម្មអស់នោះមកប៉ះទង្គិចអ្នកធ្វើ មានផលតាមអំណាចកម្មដែលធ្វើធ្ងន់ស្រាលដូច្នោះ។ ពាក្យតបប្រស្នានេះគាត់ប្រគល់ឲ្យលោក-សាស្ត្រ ព្រោះលោកសាស្ត្រប្រាប់ពន្យល់វិធីវិលវល់នៃគ្រឿងចក្រនេះ

គ្រឿងចក្រនេះហើយដែលសាសនាគ្រិស្តាំងប្រកាន់ថា ព្រះយ:ហូវ៉ា មហាហ្ម័តថា ព្រះអ់:ឡា ព្រាហ្មណ៍ថា ព្រះព្រហ្ម តែតាមគតិព្រះពុទ្ធសាសនាមិនបានសន្មតជាបុគ្គលាធិដ្ឋានដូច្នេះទេ តែពោលសំដៅដោយអត្ថថា "ធម្មជាតិ" ហេតុនេះ ទើបឃើញថា គ្រប់ៗ សាសនា សឹងមានសេចក្ដីពិតរួមគ្នាទាំងអស់ ដែលវិទ្យាសាស្ត្រមិនអាចជជែកបានឡើយ ហើយតាមដោយពិតនោះ គឺ "មនុស្សគ្រប់គ្នាក្នុងលោកនេះ នៅក្រោមអំណាចទឹងបង្គាប់នៃធម្មជាតិ ដោយអាស្រ័យកម្មជាកំឡាំងជូន" វិជ្ជាលោកសាស្ត្រជាវិជ្ជាប្រាប់ពន្យល់អំពីកំឡាំងអំណាចនៃធម្មជាតិ ឬកំឡាំងនៃព្រះនេះឯង ។

(មានត)



១៦— អំពីមហាភិនេស្ក្រមណ៍

# ប្រវត្តិសាស្ត្រនៃច្បាប់
# របស់លោកលង្កាត់ទីប្រឹក្សាច្បាប់ស្រុកសៀម

(តនឹងចប់)

៨ — ប្រទេសអេស៊ីប្ត៍ មានឯកសារក្នុងច្បាប់បញ្ញត្តិចំរើនគ្រាន់បើជាងមុនសម័យក្រុងរោមមកយូរដែរ តែថាបណ្ដាអ្នកបញ្ញត្តច្បាប់ទៅឈប់នៅត្រឹមការប្រមូលប្រមូលទុកនូវបញ្ញត្តិផ្សេងៗ ទាំងមិនបានចាត់រៀងលំដាប់ច្បាប់អេស៊ីប្ត៍ឲ្យរៀបរយទាំងអស់ ឬតែបំពួកខ្លះឲ្យមានសេចក្ដីទាក់ទងជារបៀបមួយឡើយ ។ ច្បាប់ដែលប្រកាសចេញមកមានសេចក្ដីមិនទូលាយឡើយ មិនឲ្យឱកាសពង្រីកចេញទៅតាមឡាក់នៃហេតុផលឬអាស្រ័យប្រើជាសម្ដានសម្រាប់កែប្រែឲ្យជាបទបញ្ញត្តិឡើងថ្មីក៏ពុំបាន ។ ពួកអ្នកបុរាណគតិក្នុងប្រទេសអេស៊ីប្ត៍មិនទាន់បានជួបប្រទះតម្រាច្បាប់សូម្បីមួយច្បាប់ ឬសៀវភៅណាមួយដែលអ្នកតែងបានព្យាយាមចាត់ច្បាប់បញ្ញត្តិអស់នេះធ្វើជាពួកជាក្រុម ឬចាត់ញែកប្រភេទចេញពីគ្នាឡើយ ។ ហេតុនេះ ច្បាប់ប្រទេសអេស៊ីប្ត៍ ទើបមិនមានវិសេសយ៉ាងណានីមួយលើច្បាប់នៃជំនុំជនដែលនៅជិតខាង ។

ប្រទេសក្រិក ក៏មានទំនងដូចគ្នា មានអ្នកប្រាជ្ញបញ្ញត្តច្បាប់សំខាន់ៗ មកមុនក្រុងរោម តែក្នុងប្រទេសក្រិកនេះប្រកាន់ថា ច្បាប់ជាចំណែកមួយនៃវិជ្ជាសុន្ទរកថាឬធម្មចរិយា មិនបានញែកចេញជាវិជ្ជាមួយដោយឡែកទេ តែពួកក្រិកយកចិត្តទុកដាក់ចំពោះការចាត់របៀបខាងរដ្ឋប្រសាសនោបាយច្រើនជាង ។ អ្នកបញ្ញត្តច្បាប់របស់ក្រិកបើនឹងយកចិត្ត

ទុកដាក់ទឹងរបៀបផ្សេងៗ របស់ជំនុំជន តែចំពោះរឿងដែលទាក់ទងនឹងរដ្ឋ គ្រាន់តែជាការសម្រួលប៉ុណ្ណោះ ព្រោះហេតុនេះ ប្រទេសក្រិកជាប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់ក៏ដោយ តែច្បាប់បញ្ញត្តិសម្រាប់ឯកជនគង់តែនៅថ្នាក់ទាបមិនទាន់សម័យ ៗ មួយវិញទៀត ចំណែកដែលល្អគួរប្រកាន់តាមនឹងអាចឲ្យផលប្រយោជន៍បានល្អ ដែលអ្នកប្រាជ្ញជាតិក្រិកបានស្រាវជ្រាវតាក់តែងរបៀបទុកនោះ អ្នកប្រាជ្ញនីតិសាស្ត្រនៃក្រុងរោមបានរួបរួមប្រមូលទុកជាច្បាប់រោមទាំងអស់ ៗ

៩ — នៅមានច្បាប់របស់ប្រទេសដែលបង្កបង្កើតអារ្យធម៌សំខាន់ទៀត ២ ប្រទេស ដែលយើងនឹងរំលងហួសទៅមិននិយាយដល់សោះខ្លះនោះមិនទំនងទេ ៗ ច្បាប់របស់ប្រទេសទាំងពីរនេះជារឿងដែលយើងត្រូវសិក្សាស្រាវជ្រាវពេរេក ដូចជាច្បាប់រោមដែរ ឯច្បាប់របស់ប្រទេសទាំងពីរនេះ គឺចិននឹងហិណ្ឌូ ៗ

ប្រទេសចិន មានសេចក្ដីចំរើនរុងរឿងមករាប់រយ ៗ ឆ្នាំមុនសាងក្រុងរោមទៅទៀត តែជាឡាក់ហានដ៏ពិតប្រាកដដែលយើងល្មមអាស្រ័យប្រើសម្រាប់សិក្សាច្បាប់ចិននេះ ហាក់ដូចជាគេរកបានដោយកម្រ មិនសមនឹងចំណាស់របស់ប្រទេសនេះឡើយ ប្រជុំច្បាប់ចិនដែលយើងបានឃើញជាច្បាប់ចាស់មុនគេនោះ កើតឡើងក្នុងរវាង ព. ស. ១៤០ ប្រជុំ

ច្បាប់នេះនិយាយពីច្បាប់ព្រហ្មទណ្ឌ តែម្យ៉ាងបែងចេញជា ៦ ភាគ ។ លុះពីររយឆ្នាំតមកទើបមានបន្ថែមបទបញ្ញត្តិឡើងក្នុងប្រជុំច្បាប់នេះទៀត ៣ ភាគ ។ ក្នុង ៣ ភាគនេះមានភាគ ១ និយាយពីរបៀបជំនុំជនតាមច្បាប់រដ្ឋ-ប្បវេណី ពោលគឺច្បាប់និយាយពីបញ្ជីក្បាលភូមិដែលមានបទបញ្ញត្តិពីកិច្ចអាពាហ៍ពិពាហ៍ផ្សេងៗ ប្រជុំច្បាប់នេះហៅថា "ប្រជុំច្បាប់ ៩ ក្បាល" ច្បាប់នេះប្រើជាគោលដើមសម្រាប់ព្រាងឬរៀបចំច្បាប់សំខាន់ៗ របស់ចិនក្នុងកាលតមក ប្រជុំច្បាប់ដែលសំខាន់បំផុតដែលកើតឡើងក្នុងកាលតមក គឺច្បាប់ដែលកើតឡើងក្នុង ព. ស. ១១៩៧ ក្នុងសម័យរាជវង្សថាំង រាជវង្សនេះ គេទុកជាគោលដើម ក្រត្រក្នុងរាជវង្សត ៗ មករបស់ចិនយកមកកែប្រែប្រែកាន់តាមគ្នាជាលំដាប់មក អាស្រ័យជាតិចិនចេះស្ងួនត្រង់ថែរក្សាអារ្យធម៌របស់ខ្លួនទុកមិនបាត់សាបសូន្យទៅ បណ្ដាប្រជុំច្បាប់ដែលកើតឡើងក្នុងសម័យរាជវង្សផ្សេងៗ ទើបមានបទបញ្ញត្តិជាប់ទាក់ទងតគ្នាមក ព្រមទាំងច្បាប់ចាស់វិញចូលគ្នា យ៉ាងមាំមួនស្ទើរតែសព្វគ្រប់រហូតមកដល់សម័យឥឡូវនេះ ការកែខៃដែលបានធ្វើក្នុងរជ្ជកាលតមកមានៈតែបន្តិចបន្តួច ៗ ច្បាប់ចិនដែលកើតឡើងក្នុងសម័យផ្សេងៗ គ្នាអស់មានរស្មីផ្សាយចេញទៅយ៉ាងធំទូលាយមានឥទ្ធិពលនៅលើច្បាប់របស់យួន, កៅលី, ជប៉ុនជាដើម ។ ជនជាតិម័ញ្ជូដែលបានមកមានអំណាចឡើងក្នុង

ប្រទេសចិនកាល ព.ស. ២១៨៦ រហូតមកដល់ ព.ស. ២៤៥៥ នោះទើបតែប្រកាសប្រើប្រជុំច្បាប់ថ្មីក្នុង ព. ស. ២១៨៩ ប្រជុំច្បាប់នេះបានជម្រះនឹងចាត់បោះពុម្ពឡើងនៅវេលាក្រោយបង្អស់ក្នុង ព.ស. ២៤៣៣ ជាកិច្ចការយ៉ាងធំសំបើមតាមផ្លូវច្បាប់គ្របដណ្តប់ដល់កិច្ចការរបស់រដ្ឋបាលនឹងរបស់ឯកជនគ្រប់ចំណែក ប៉ុន្តែប្រជុំច្បាប់នេះ ក៏មានទំនងដូចក្នុងប្រជុំច្បាប់មុនៗនេះដែរ ។ អ្នកបញ្ញត្តច្បាប់ចិនបានធ្វើតាមគំនិតយោបល់ ឲ្យសមនឹងសភាពយេះបុលរបស់ចិនដោយឡែក គឺជនជាតិចិននោះ ប្រកាន់ថាច្បាប់នឹងញែកបំបែកឲ្យដាច់ពីការធ្វើទោសតាមផ្លូវអាជ្ញាកម្ម ច្បាប់នឹងអាជ្ញាកម្មគោងនៅជាមួយគ្នាជាដរាប ៗ មួយវិញទៀត ច្បាប់នេះបានដល់វិធីកំណត់ទោសសម្រាប់បុគ្គលដែលមិនមែនជាសមាជិកជាតិចិន ជាអ្នកនៅដែនក្រៅ គោងប្រព្រឹត្តរៀបរយម៉ឺងម៉ាត់ ៗ ចំណែកខាងប្រជាជនជាតិចិនជាមនុស្សល្អស្រាប់ មិនបាច់មានច្បាប់សម្រាប់ពួកគេទេ ព្រោះចរិតប្រវេណីផ្សេងៗដែលមានមកពីបុរាណនោះគេប្រកាន់ជាច្បាប់ធម្មជាតិតែម្តង តែធម្មជាតិនោះសុទ្ធតែជាប្រជ្ញាវិទ្យា ៗ នេះឯង ប្រដៅឲ្យជនជាតិចិនស្គាល់របង្គាប់របស់ធម្មជាតិ ប្រជ្ញាវិទ្យាទើបទុកជាច្បាប់មួយបាន ឬធ្វើឲ្យច្បាប់ឥតប្រយោជន៍ទៅវិញ ដោយទំនងគំនិតនេះប្រជុំច្បាប់ចិនទើបមានលក្ខណៈសំខាន់ជាប្រជុំច្បាប់អាជ្ញា ៗ ដោយពិត

នោះ ច្បាប់របស់ជំនុំជននានាក្នុងសម័យបុរាណរមែងមានលក្ខណៈជាច្បាប់ក្រមព្រហ្មទណ្ឌទាំងអស់ តែក្នុងច្បាប់ចិន មានលក្ខណៈជាច្បាប់ក្រមព្រហ្មទណ្ឌដែលមើលឃើញប្រាកដច្បាស់ជាងក្នុងច្បាប់របស់ជំនុំជនឯទៀត ៗ ទាំងអស់ ។ នៅក្នុងប្រជុំច្បាប់ចិនចុងក្រោយដែលពោលមកនេះ មាននិយាយអំពីលក្ខណៈបំណុល នឹងមាននិយាយអំពីរបៀបនៃការប្រាក់ដោយគិតយកការប្រាក់ហួសប្រមាណ ការចំណាយនឹងប្រើប្រាស់របស់ទ្រព្យដែលគេយកមកផ្ញើទុក ការជួបប្រទះនឹងរបស់ដែលជ្រុះ របស់បាត់ប៉ុណ្ណោះ ។ នៅខាងចុងនៃប្រជុំច្បាប់នេះមានលក្ខណៈជាច្បាប់ក្រមព្រហ្មទណ្ឌដោយពិត ៗ ក្នុងសម័យបុរាណ ចិនមិនប្រាកដថា មានតម្រាប់តម្រាដែលនិយាយពីវិជ្ជាច្បាប់ ១ ក្បាលឡើយ ចិនមិនដែលញែកច្បាប់ចេញដោយឡែកទេ លុះមកដល់សម័យនេះ ទើបចិនដឹងខ្លួនថា តោងតែតាក់ការធ្វើឲ្យរបៀបផ្សេងៗ នៃជំនុំជនរបស់ខ្លួនមានលក្ខណៈល្អៈល្អ ទាន់សម័យតាមជំនាន់អារ្យធម៌ទំនើបថ្មី ការរៀបចំទំនងនេះតោងតែចិនដាក់ទៅពឹងរបៀបតាក់ជំនុំជនដោយឡែក ដែលខ្លួនមិនធ្លាប់យល់មិនធ្លាប់ចូលចិត្តមកពីមុនៗ នេះឡើយ ។ ឯជប៉ុនក៏មានទំនងដូចជាចិនដែរ គឺត្រូវតែបោះបង់ច្បាប់របស់ខ្លួនចេញខ្លះ បែរទៅរកបែបផែនរបៀបច្បាប់ទំនើបថ្មីអំពីទីដទៃវិញ ។

១០ — ច្បាប់ហិណ្ឌូ  ច្បាប់ហិណ្ឌូប្លែកផ្សេងពីច្បាប់ចិនច្រើន គួរសិក្សាដោយឡែកក្នុងប្រវត្តិសាស្ត្រច្បាប់ ដោយហេតុច្បាប់ហិណ្ឌូនេះ មានដំឡៃក្នុងតួច្បាប់ ទាំងមានឥទ្ធិពលផ្សាយចេញទៅក្នុងច្បាប់របស់ជំនុំជនឯទៀតៗ ច្បាប់ហិណ្ឌូសម្រាប់ប្រើក្នុងប្រទេសឥណ្ឌា រហូតមកដល់សព្វថ្ងៃនេះ ទាំងបានផ្សាយចេញទៅតាំងអំពីបុរាណកាល ទាំងក្នុងឥណ្ឌា ទាំងឥណ្ឌូនេស៊ី (Indonésia) សិលាចារិកក្នុងប្រទេសចម្ប៉ា កាលសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ ក៏មានសេចក្ដីពាំងថា គម្ពីរមនុធម្មសាស្ត្រដែលបានប្រើនៅក្នុងប្រទេសចម្ប៉ាសម័យនោះ ។ បណ្ដាប្រជុំច្បាប់ផ្សា ដែលចាស់បំផុតដែលយើងបានឃើញនោះ សឹងបញ្ញត្តឡើងអាស្រ័យបែបផែននៃច្បាប់ហិណ្ឌូមានទំនងដូចជាពួកប្រជុំច្បាប់ចាស់របស់ មន និង កូមា ។ ក្បួនខ្នាតផ្សេងៗ របស់ហិណ្ឌូមានច្រើនហើយ មានអាយុកប់ជយក្រោយឡើងទៅដល់សម័យកាលដ៏យូរអង្វែង ។ តម្រាច្បាប់ដែលចាស់បំផុត ដែលធ្លាក់មកដល់ដៃយើងគឺធម្មសូត្ររបស់គោតមៈ (Gautama) ធម្មសូត្រច្បាប់នេះ ពោលតាមហេតុផលដែលគេបានរកឃើញក្នុងគ្រាក្រោយបំផុត គេស្មានថា ប្រហែលជាបានតែងឡើងក្នុងរវាងមួយសតវត្សរ៍មុនពុទ្ធសករាជទឹងសតវត្សរ៍ដំបូងនៃពុទ្ធសករាជ ។ ធម្មសូត្ររបស់អាបស្តម្ពៈ (Apastamba) និងរបស់បោធាយនៈ (Baudhâyana) សឹងជា

ក្នុងប្រទេសបារាំងសែស ក្នុងវេលាឥឡូវៗនេះឯង ថាមានបុរសម្នាក់កំបុតជើងយកឈើមកធ្វើបួមជំនួសជើងកំណើត បុរសជើងឈើនេះកើតសតិវិបល្លាសឡើងយ៉ាងណា មិនប្រាកដច្បាស់ ស្រាប់តែស្ទុះក្រទឹក្រទាឡើងសម្លាប់មនុស្សទាំងឡាយមិនថាអ្នកណាទេ ទម្រាំចាប់ខ្លួនបុរសជើងឈើនោះបាន អ្នកបានសម្លាប់មនុស្សអស់ ៤៥ នាក់ ។

លុះប៉ូលិសចាប់ខ្លួនបុរសនោះបាន ក៏មានសេចក្ដីសង្ស័យពល់គ្នាថា ធ្វើដូចម្ដេចទើបវាសម្លាប់គេបានដល់ទៅ ៤៥ នាក់? ក្នុងទីបំផុត ចាប់បានកាំភ្លើងដៃតូចលាក់ទុកក្នុងជើងឈើ ពោះជាប្រហោងមានខ្សែល្លួសចងយោងពីកៃកាំភ្លើង ហើយដៃកាន់ចុងខ្សែ (សម្រាប់បាញ់) ។

## ថ្នាំដែលធ្វើឲ្យសក់ស្កូវ ក្លាយទៅជាសក់ខ្មៅ ហើយអាចធ្វើសក់ខ្មៅ ឲ្យប្រែជាស្កូវវិញក៏បាន

សកាវិទ្យាសាស្ត្រផ្នែកស្រាវជ្រាវរកអាហារបំពួកផ្សេងៗ របស់ប្រទេសអាមេរិក បានធ្វើសេចក្ដីរាយការមួយអំពីហេតុដែលគេឃើញរបស់ថ្មីម្យ៉ាង ក្នុងកាលឥឡូវៗនេះឯង គឺចៅនាទីបានចាប់កណ្ដុរមួយមកចិញ្ចឹមដោយចំណីអាហារដែលបណ្ដេញធាតុវីតាមីន B. ចេញអស់ឥតសល់ កណ្ដុរដែលឲ្យស៊ីចំណីបែបនេះ មិនយូរប៉ុន្មានក៏មានសម្បុររោមពណ៌ប្រផេះ ៗ លុះគ្រាក្រោយមក ត្រឡប់ផ្សំចំណីឲ្យមានធាតុវីតាមីន B. ឲ្យស៊ីវិញ កណ្ដុរនោះក៏ប្រែត្រឡប់ជាមានរោមសម្បុរខ្មៅឡើងវិញ ។

បទបញ្ញត្តិជាក់ត ៗ មកដល់យើងមានគ្រប់បរិបូណ៌ដូចដើម មានអាយុកន្
រវាងពុទ្ធសករាជ១៥០ ។ ប្រជុំច្បាប់ហិណ្ឌូដែលល្បីឈ្មោះស៊ុះសាយបំផុត នោះហៅថា មានូធម្មសាស្ត្រ គឺគម្ពីរមនូធម្មសាស្ត្រដែលមានអាយុមិនមុនពុទ្ធសករាជ ៣៥០ តែជាច្បាប់ដែលជាប់តៗមកអំពីធម្មសាស្ត្រដែលមានអាយុចាស់ជាងគេ ។ ក្រៅអំពីនេះនៅមានគម្ពីររបស់វិស្ណុ ( Visnusmrti) ដែលកើតមុនគម្ពីរមនូធម្មសាស្ត្រ និងគម្ពីររបស់យាជ្ញវល្ក្យ:(Yâjyavalkya) ដែលបានតែងជាខាងក្រោយមនូធម្មសាស្ត្រ មិនជាឆ្ងាយគ្នាប៉ុន្មានទេ និងគម្ពីររបស់នារទ: (Nârada) និងព្រហស្បតិ (Brhaspati) ជុំង ។ សៀវភៅទ្បាក់ហានតាំងនេះនឹងពាក្យអធិប្បាយដែលមានអ្នកតែងឡើងជាប់តាក់ទងតមកពីបុរាណរហូតមកដល់សព្វថ្ងៃនេះ ជាហេតុឲ្យច្បាប់ចាស់របស់ហិណ្ឌូជាច្បាប់សម័យបុរាណមួយរហូតតមក ។ ច្បាប់ហិណ្ឌូក្នុងសម័យដើមៗ ជាបញ្ញត្តិដែលមានលក្ខណៈជំសំខាន់ធ្ងន់ទៅខាងសាសនា ដូចជា ខប្រតិបត្តិសម្រាប់គហបតី ខប្រតិបត្តិសម្រាប់ព្រាហ្មណ៍ និងពិធីផ្សេងៗ ជាច្រើនយ៉ាងទៀត ហេតុនេះ ការសិក្សាច្បាប់ហិណ្ឌូទុកដូចជាបានរៀនសខាមួយក្នុងគម្ពីរព្រះវេទ ក្នុងគម្ពីរមនូធម្មសាស្ត្រជាដើម សឹងផ្ដើម ដោយរឿងរ៉ាវកំណើតលោក ហើយក្នុងបណ្ដាបទបញ្ញត្តិដែលមាននៅក្នុងគម្ពីរធម្មសាស្ត្រនេះមានច្រើនជាងពាក់កណ្ដាលដែលមានសេចក្ដីបញ្ញត្តិ

តាមផ្លូវសាសនា ។ គម្ពីរបែងចែកចេញជា ១២ បព្វៈហើយក្នុង ១២ បព្វៈ នោះមានច្បាប់ដ៏ពិតប្រាកដ គឺច្បាប់ក្រមព្រហ្មទណ្ឌនឹងច្បាប់រដ្ឋប្បវេណីសុទ្ធ ៗ ត្រឹម ២ បព្វៈគឺ បព្វៈ ៨ នឹងបព្វៈ ៩ ប៉ុណ្ណោះ ។ នៅប្រទេសឥណ្ឌៀមានអ្នកប្រាជ្ញនីតិសាស្ត្រ ដែលពិតប្រាកដបានខំខ្នះខ្នែង ដើម្បីសិក្សាចំពោះវិជ្ជាច្បាប់ហើយបានរៀបចំនឹងធ្វើឲ្យវិជ្ជាផ្នែកនេះចំរើនឡើង ។

## គុណដ៏ថ្លៃនៃច្បាប់រោម

១១ — បណ្ដាច្បាប់បុរាណទាំងឡាយ ច្បាប់រោមមានគុណដ៏ថ្លៃជាប់ទាក់ទងមកពីហេតុក្នុងផ្លូវផ្សេងៗ ។

ក — ក្នុងប្រវត្តិសាស្ត្រច្បាប់, ច្បាប់រោមមានអាយុស្ថិតស្ថេរមកជាវេលាយូរ ដល់ទៅ ១៣ សតវត្សរ៍ ចាប់ផ្ដើមតាំងអំពីកសាងក្រុងរោម (ប្រមាណ ២១១ ឆ្នាំមុនពុទ្ធកាលហួតដល់ឆ្នាំដែលព្រះចៅចក្រពត្តិយុស្ទីនិយ៉ានុស (Justinianus) លុះស្ដេចនេះទិវង្គតទៅ (ព. ស. ១១០៨) នៅយុគដំបូងៗ ច្បាប់រោមមិនមានលក្ខណៈប្លែកផ្សេងនឹងបណ្ដាច្បាប់របស់ជំនុំជនដទៃក្នុងសម័យបុរាណដូចគ្នា ប៉ុន្តែបានថែមថយកែខៃឲ្យមានបរិបូណ៌គ្រប់គ្រាន់ឡើងជានិច្ច កាលដំបូងពួករោមមានអំណាចតែក្នុងនគរតូចៗនគរមួយប៉ុណ្ណោះ លុះកាលតមកក៏កាន់តែរីកធំឡើងបន្តិចម្ដងៗ គ្របដណ្ដប់ជិតអស់ទ្វីបអឺរ៉ុបទាំងមូល នឹងចំណែកមួយខាងត្បូងប្រទេសផង ។

អាស្រ័យហេតុក្រុងរោមមានឡាក់ថានទាក់ទងនឹងវិជ្ជាច្បាប់ជាច្រើនយ៉ាង ទើបយើងអាចការកឃើញរឿងរ៉ាវដែលថ្លែងអំពីសេចក្ដីចំរើននានារបស់ដំនុំជនជាតិរោមបានច្រើនជាងជនជាតិឯទៀតៗ ក្នុងសម័យបុរាណដូចគ្នា ។

១ – បើនិយាយពីដំឡៃ ច្បាប់រោមមានគុណដំឡៃថ្លៃថ្នូរជាងច្បាប់របស់ដំនុំជនឯទៀតៗក្នុងសម័យបុរាណដូចគ្នា ដោយមិនបាច់ជជែកឡើយ ។ ជនជាតិរោមមាននិស្ស័យសន្ដានជាអ្នកប្រាជ្ញនីតិសាស្ដ្រដោយពិត ជាជនជាតិដែលអាចរៀបចំច្បាប់ជាវិជ្ជាមួយដោយឡែក បំបែកចេញពីសាសនានឹងធម្មចរិយា មិនមានដំនុំជនដទៃធ្វើបានដូច្នេះទេក្នុងសម័យនោះ ជនជាតិរោមជាជាតិដំបូងដែលបានរៀបចំចាត់ការស្រុកទេសរបស់ជាតិផ្សេងៗ ដែលខ្លួនច្បាំងឈ្នះឲ្យរាបសាល្អ ហេតុនេះបានជាច្បាប់របស់រោមក៏ផ្សាយគ្របទៅលើផែនដីនៃជនជាតិផ្សេងៗជាច្រើនដោយមិនមានកំណត់ ហេតុនេះបានជាប្រកាន់ថា ច្បាប់រោមជាបែបច្បាប់ឬជានីតិសាស្ដ្រ គុណដំឡៃនេះធ្វើឲ្យច្បាប់រោមបានទទួលនាមថា “ព្រះគម្ពីរនៃសតិបញ្ញា” ។

គ — មហាអាណាចក្ររោមបានរលត់សាបសូន្យទៅក៏ពិតមែន តែច្បាប់បែបផែនជាច្បាប់សម្រាប់ប្រើបង្គាប់ដល់ជនជាតិផ្សេងៗ ដែលធ្លាក់ទៅនៅក្រោមអំណាចរបស់ក្រុងរោម ។ មួយវិញទៀត ព្រោះច្បាប់រោមជាឫសគល់នៃច្បាប់របស់ប្រទេសផ្សេងៗ ក្នុងទ្វីបឥរុប ច្បាប់របស់ជនជាតិ

ទាំងពួងសឹងនៅក្រោមអំណាច គឺមានច្បាប់ខេមរជ្រៀតជ្រែកចូលទៅគ្រប់ផ្នែក ហេតុនេះកាលបើយើងពិចារណារើសរកយកគោលច្បាប់ឧរុបមកធ្វើជាគ្រោងក្នុងការព្រាងច្បាប់សៀម យើងអាចពោលបានថា ច្បាប់ខេមរជាឫសគល់យ៉ាងឆ្ងាយ ៗ ពីច្បាប់សៀមសម័យនេះ មានទំនងដូចជាច្បាប់ជប៉ុន-ចិនដែលទទួលយកមកពីទ្វីបឧរុបជាគោលដូចជាច្បាប់សៀមនេះដែរ ។

## ប្រវត្តិសាស្ត្រច្បាប់សៀម

១២– មុននឹងសិក្សាប្រវត្តិសាស្ត្រ ច្បាប់របស់ប្រទេសណាមួយ យើងតោងរួបរួមប្រមូលឡាក់ហាន ដែលអាចជួយឲ្យយើងបានដឹងអំពីរបៀបនឹងខបន្ទាប់ផ្សេង ៗ របស់ជំនុំជនក្នុងប្រទេសនោះ ៗ ។ តាមធម្មតា យើងតែងបានទទួលមកពីបទបញ្ញត្តិនានា ដែលសេសសល់មកពីបុរាណ នឹងពាក្យជំនុំជំរះរបស់សាលាវិនិច្ឆ័យ នឹងគម្រានីតិសាស្ត្រដែលគេបានចងក្រងទុកមក ក្រៅពីនេះ យើងតោងរើសប្រមូលយកពីទំនៀមទម្លាប់ប្រ-វេណី, ពង្សាវតារឬសេចក្តីកត់ហេតុ រឿងរ៉ាវផ្សេង ៗ ដែលពួកអ្នកនៅតាមប្រទេសបានរៀបរៀងទុកមក ។ បើពោលចំពោះប្រវត្តិសាស្ត្រច្បាប់សៀម យើងអាចបែងចេញដោយឡាក់ហានផ្សេង ៗ ដែលរកបានក្នុងពេលនេះមាន ៥ ចំពូក គឺ ១. សិលាចារឹក ២ ឯកសារផ្សេងៗ កប់ថយ

ក្រោយឡើងទៅដល់សម័យក្រុងស្រីអយុធ្យា, ៣ ប្រជុំច្បាប់ដែលបានតាក់ធ្វើឡើងកាលពី ព. ស. ២៣៤៧–២៣៤៨ ។ ៤ – ក្បួនបញ្ញត្តិ ដែលបានតាក់រៀបចំធ្វើក្រោយប្រជុំច្បាប់ ព.ស. ២៣៤៧-២៣៤៨ ។ ៥ – សៀវភៅឬក្រាំងដែលរួបរួមពាក្យដំនុំជម្រះនេះ ។

ប្រវត្តិសាស្ត្រច្បាប់របស់លោកលង្កាត់នេះ មានសេចក្តីពិស្តារវែងឆ្ងាយតទៅទៀត តែបានដកស្រង់យកមកតែដោយសង្ខេប ដើម្បីឲ្យស្គាល់ដំណើរច្បាប់របស់នានាជាតិសម័យបុរាណចំពូកខ្លះប៉ុណ្ណោះ ។

អ្នកប្រែ ខេមរង្សី



១៧ — អំពីទ្រង់កាត់ព្រះកេសា

## ១៥— អំពីការទ្រង់ជួបប្រទះនឹងលោកសង្ឃ

លុះតមកក្នុងសម័យមួយទៀត ព្រះអង្គស្ដេចយាងចេញទៅតាមទ្វារទិសខាងជើង ទ្រង់បានប្រទះនឹងភិក្ខុមួយរូប ទ្រង់បាត្រ សង្រួមឥន្ទ្រីយ គួរជាទីជ្រះថ្លា ។

## ១៦— អំពីមហាភិនេស្ក្រមណ៍

ព្រះបរមពោធិសត្វស្ដេចចេញទៅតាមផ្លូវអាកាស មានពួកនាងទេពអប្សរនាំគ្នាច្រៀងថ្វាយលាន់ឮកងរំពង ។

## ១៧— អំពីទ្រង់កាត់ព្រះកេសា

ខណៈនោះ ព្រះពោធិសត្វទ្រង់កាត់ព្រះកេសាដោយព្រះខ័នហើយ ទ្រង់បោះសំណុំព្រះកេសាទៅតាមអាកាសទៅ ។

## ១៨— ព្រះពោធិសត្វទ្រង់គង់នៅក្នុងព្រៃ

ឥសីកគវ័ន្តបានសំដែងសេចក្ដីគប់អានព្រះពោធិសត្វ ទុកដូចជាទេវតាជាទីគោរពមួយទាំងខ្លួនទាំងគណៈសិស្សានុសិស្ស បានអារាធនាសុំឲ្យទ្រង់គង់នៅក្នុងសំណាក់ខ្លួន ។

## ១៩— អំពីទ្រង់បំពេញទុក្ករកិរិយា

ជាវេលា ៦ ឆ្នាំ ដែលព្រះបរមពោធិសត្វទ្រង់ពិចារណារកផ្លូវត្រាស់ដឹង ដោយវិធីបង្អាប់កាយឲ្យលុះនៅក្នុងអំណាចនៃចិត្ត ។ (មាន៩)



១៨ — ព្រះពោធិសត្វទ្រង់គង់នៅក្នុងព្រៃ

# ប្រវត្តិមីលរេប៉ះ

(តពីលេខ ៩ មក)

ឯពួកកូនប្រុស កូនប្រុសស្រីនិងមនុស្សដទៃនៅក្នុងគ្រួសារនោះក៏ត្រូវផ្ទះដែលបាក់រលំធ្លាក់មកសង្កត់ស្លាប់អស់ទៅ ។ ឯម្តាយរបស់មីលរេប៉ះមានចិត្តត្រេកអរណាស់ដែលបានឃើញមន្តអាគមរបស់កូនខ្លាំងពូកែល្មមតទល់ជល់នឹងពួកចាស់ៗនៅក្នុងស្រុកនោះបាន ។ ចំណែកឪពុកធំចង់សម្លាប់ប្អូនស្រីរបស់ខ្លួន (ម្តាយមីលរេប៉ះ) ប៉ុន្តែអ្នកស្រុកបានឃាត់ហាមឪពុកធំនោះហើយប្រាប់ថា "ពីព្រោះកាលពីដើមមិនស្មោះត្រង់នឹងសំដីរបស់ខ្លួន ទើបអ្នកត្រូវទទួលគ្រោះថ្នាក់នេះជាមុន" ។

ខណៈនោះ ម្តាយមីលរេប៉ះបានដឹងរឿងនោះហើយ ទើបបញ្ជាក់ឲ្យកូនបានដឹងផង ហើយសុំឲ្យកូនកំទេចស្រុកនោះចោលទៅ ដោយវិធីបង្អុរគ្រាប់ព្រឹលធំៗឲ្យធ្លាក់ចុះមក ។ លុះកន្លងកាលតមក មីលរេប៉ះដឹងខ្លួនហើយផ្លាស់ចិត្តគំនិតនឹកស្តាយក្រោយ ដែលខ្លួនបានធ្វើអំពើអាក្រក់មកជាច្រើន ហើយប្រាថ្នាចង់ប្រតិបត្តិខាងផ្លូវធម៌ដែលល្អបរិសុទ្ធវិញ ។ តអំពីនោះ មីលរេប៉ះ ធ្វើដំណើរចេញទៅរកលោកអ្នកប្រាជ្ញធំឈ្មោះម៉ារប៉ះ ដើម្បីផ្ញើខ្លួនជាសិស្សរបស់លោក បានទៅជួបនឹងអ្នកប្រាជ្ញនោះនៅទីវាលមួយ ( មើលរូបនៅទំព័រ ៤៧ )

( នៅមានតទៅទៀត )



១៩ — អំពីទ្រង់បំពេញទុក្ករកិរិយា

ធាតុវីតាមីន B. នេះនៅក្នុងគ្រាប់ស្រូវផ្សេងៗ ក្នុងស៊ុតក្រហម, ក្នុងផ្លែឈើសំបករឹង, ក្នុងថ្លើមសត្វ, បេះដូង ពោះវៀន អស់នេះសឹងឃើញបានថា បណ្ដាអាហារផ្សេងៗរបស់មនុស្សយើងនេះសឹងមានធាតុវីតាមីន B. បរិបូណ៌ហើយ ។

កាលបើនិយាយពីសក់របស់យើងដែលក្លាយជាពណ៌សស្កុសទៅបាននោះ ពីដើមមកយើងធ្លាប់ប៉ូលចិត្តថា ដោយព្រោះអ្នកនោះមានសេចក្ដីកង្វល់វិតក្កហួសប្រមាណ បើមិនដូច្នេះទេ ដោយមានកិតភ័យតក្កមាយ៉ាងស្រួកន់ ឬដោយហេតុប្រព្រឹត្តទៅតាមពូជ ដល់មកឥឡូវនេះមានកើតជូវគំនិតឡើងថ្មីថា សក់សស្កុសក់ស្កូវនោះ អាចកើតមកអំពីការខ្វះខាតអាហារដែលប្រកបដោយធាតុវីតាមីន B. នេះមួយដែរ ។

ប៉ុន្តែធាតុវីតាមីន B. នេះ បើមានច្រើនហួសប្រមាណក្នុងអាហារដែលយើងបរិភោគ ក៏បែរជាឲ្យទោសវិញដែរ ។ ឯវិធីល្បងសត្វកណ្ដុរនោះបានចាប់ល្បងតមកទៀត គឺបានយកវីតាមីន B. ផ្សំក្នុងចំណីដែលមានធាតុនេះល្មមគ្រប់គ្រាន់ ហើយបន្ថែមឲ្យកាន់តែមានចំនួនច្រើនឡើងទៀតហើយឲ្យកណ្ដុរនោះស៊ី ទើបពេលកណ្ដុរប្រែត្រឡប់ជាមានសម្បុរខ្មៅឡើងវិញម្ដងនោះក៏ផ្លាស់ប្រែសម្បុរសទៅបានវិញទៀត ។ (សេចក្ដីអស់នេះបានស្រង់យកអំពីកាសែតថៃម៉ៃ) ។

ដំណឹងផ្សេងៗ

ក្នុងនានាប្រទេស

# អំពីវិទ្យាសាស្ត្រនឹងព្រះពុទ្ធសាសនា

លោក W. A. ដែសីល្វ: ជាសេនាបតីក្រសួងសុខាភិបាល (L'Hygiène) នៅសីឡូន៍ ជាពុទ្ធសាសនិកជនដែលមានឈ្មោះល្បីមួយ នៅកោះលង្កា មិនមែនដោយហេតុលោកមានមុខក្រសួងធំដុំទេ តែដោយអំណាចសេចក្តីចេះដឹងជ្រៅជ្រះខាងព្រះពុទ្ធសាសនា ។ សារមន្ទីរ (Musée) នៃស្រុកកូឡុម្បូ ទើបនឹងបានបោះពុម្ពសៀវភៅមួយ និយាយពីលទ្ធិពុទ្ធ-សាសនានឹងសេចក្តីពន្យល់ដោយសង្ខេបផង សៀវភៅនេះមិនមែនជាប្រ-យោជន៍ចំពោះពួកពុទ្ធសាសនិកជន នឹងអស់លោកអ្នកដែលចេះដឹងបាលីប៉ុណ្ណោះទេ ជាប្រយោជន៍ដល់អ្នកដទៃក្រៅដែលចង់ចេះដឹងរបៀបអក្សរ-សាស្ត្រខាងពុទ្ធសាសនាផង ។

យើងបានដកស្រង់យកសេចក្តីសង្ខេបនៃសុន្ទរកថារបស់លោក ដែលលោកបានសំដែងកាលពីដំណាច់ឆ្នាំ ១៩៣៨ ។

« បណ្តាចំណេះវិទ្យាសាស្ត្រនឹងលទ្ធិពុទ្ធសាសនា ត្រូវតែនាំមកពន្យល់នៅទីចំពោះមុខនៃទីប្រជុំទំនើបថ្មីស្តាប់ ទើបយល់សេចក្តីនៃវិជ្ជាទាំងពីរច្បាស់លាស់ ប៉ុន្តែបើនិយាយតាមយោបល់របស់អ្នកប្រាជ្ញវិទ្យា-

សាស្ត្រនិងអ្នកដែលមិនមានចំណេះខាងវិទ្យាសាស្ត្រ ទៅជាមិនមានប្រ-
យោជន៍ដល់ពួកអ្នកបួសក្នុងសាសនាដោយការពន្យល់ទៅតាមគំនិតយោ-
បល់ដែលមិនមានជំនឿអ្វី ៗ អ្នកប្រាជ្ញអង់គ្លេសម្នាក់បានតែងសៀវភៅមួយ
និយាយពីប្រវត្តិរបស់ព្រះពុទ្ធជាម្ចាស់ ហៅថា ប្រទីបនៃទ្វីបអាស៊ី(La lumi-
ére de l'Asie) និយាយពីគោលសំខាន់ៗ នៃព្រះពុទ្ធសាសនា ទាំង
យោបល់នឹងគំនិតគិតឃើញជារបស់ពួកអ្នកនៅទិសខាងលិច កាលបើបាន
ជ្រួតជ្រាបលទ្ធិពុទ្ធសាសនា ក៏អាចរលាយចូលគ្នាបាននឹងលទ្ធិយោបល់
របស់អ្នកនៅទិសខាងកើតបាន ហើយក្លាយទៅជាវិជ្ជាចំណេះរបស់អ្នក
នៅទិសខាងលិចទៅវិញ សេចក្តីពិតមិនមែនសោះឡើយ ៗ លោកអ្នកសំ-
ដែងបាឋកថាថ្លែងថា ប្រសិនបើគណសង្ឃអាចពន្យល់លទ្ធិពុទ្ធសាសនា
តាមផ្លូវវិទ្យាសាស្ត្រទំនើបថ្មី ជាការមានប្រយោជន៍ច្រើនណាស់ ៗ អ្នក
ដែលចេះអក្សរសាស្ត្រជាន់ចាស់នឹងចេះគម្ពីរបាលី ក៏នៅតែមិនអាចចេះ
ដឹងតាមចំណេះវិជ្ជាទំនើបថ្មីដោយសព្វគ្រប់ទេ ៗ ព្រោះសាសនាមិនមែន
ជាវិទ្យាសាស្ត្រទេ គ្រាន់តែជាគោលនៃសិក្សា ព្រមទាំងការប្រតិបត្តិ
ដោយម៉ឺងម៉ាត់ដើម្បីធ្វើជីវិតរបស់មនុស្សឲ្យប្រព្រឹត្តទៅបានស្រួល ហើយ
កាលណានាំគ្នាគោរពប្រតិបត្តិតាមគោលធម៌វិន័យដូចគ្នានេះ ទុកជាការ
សិក្សាជាន់ខ្ពស់ តាមពាក្យប្រៀនប្រដៅនៃព្រះពុទ្ធជាម្ចាស់ ៗ ហើយនៅ

កាលតមកគង់មិនមានអ្នកក្រៀចសេចក្ដីប្រតិបត្តិនេះក្នុងលទ្ធិដ៏ប្រកបដោយសេចក្ដីក្សេមក្សាន្តក្នុងសាសនាព្រះស្រីអារិយមេត្រៃយនោះឡើយ ។

*　　*
✿

អធិបតីស្រីនៃពុទ្ធិកសមាគមក្រុងប៉ារីសបានធ្វើដំណើរមកសំចតនៅស្រុកសីឡូន កាលពីខែដេសម្ប៊រ ឆ្នាំ ១៩៣៨ លោកស្រីមានបំណងចង់ប្រែព្រះត្រៃបិដកជាភាសាបារាំងសែស ក្រោមសេចក្ដីជួយទំនុកបំរុងនៃពួកភិក្ខុអ្នកប្រាជ្ញក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

ឯការប្រែព្រះពុទ្ធដីកាមកជាភាសាបារាំងសែសនេះ ពុទ្ធិកសមាគមបារាំងសែសល្មមជួយថែមថយបំពេញសេចក្ដីឲ្យបាន ប៉ុន្តែមានឧបសគ្គធំបំផុតត្រង់រឿងប្រាក់កាសក្នុងខណៈនេះ ប៉ុន្តែអ្នកស្រីជាអធិបតីពុទ្ធិកសមាគមយល់ថា មានចំនួនជនជាតិបារាំងសែសជាច្រើនដែលបានធ្វើដំណើរមកកាន់ចុងបូព៌ាប្រទេស សឹងមានសេចក្ដីជាប់ចិត្តនឹងពុទ្ធសាសនារាល់គ្នា តាំងពីក្រោយមហាសង្គ្រាមឆ្នាំ ១៩១៤ មក គេបាននាំគ្នាស្រាវជ្រាវរកវិជ្ជាជាគ្រឿងប្រដៅចិត្ត ក៏បានមកជួបប្រទះនឹងព្រះពុទ្ធសាសនា ហើយមានចំនួនបារាំងសែសជាច្រើនដែលងាកមុខបែរទៅរកព្រះពុទ្ធសាសនា ។

## ការចេះប្រើពេលទំនេរឲ្យមានប្រយោជន៍

ពេលវេលាជារបស់មានតំលៃ ដែលយើងដឹងស្រាប់ហើយ តែយើងមិន

សូវគិតធ្វើការ ដែលមានប្រយោជន៍សមនឹងដំឡៃរបស់ពេលវេលាឡើយ ។

ការប្រើពេលទំនេរជាផ្លូវនាំខ្លួនឲ្យវិនាសក៏មាន នាំខ្លួនឲ្យចំរើនកើនទៅមុខក៏មាន ការប្រើពេលទំនេរដែលជាផ្លូវនាំខ្លួនឲ្យវិនាសខូចប្រយោជន៍នោះដូចជាលេងល្បែងបៀរប៉ោធួរ ផឹកស្រាមេរ៉ៃ និន្ទាអ្នកដទៃ ល្មោភកាមគុណជាដើម ។ ឯការប្រើពេលឲ្យមានប្រយោជន៍នោះ ដូចជាការហាត់ប្រាណ ដើរស្វែងរកវិជ្ជា មើលសៀវភៅមានប្រយោជន៍ជាដើម ។

ក្មេងកំឡោះដែលគិតតែប្រើពេលទំនេរក្នុងផ្លូវសប្បាយក្អឹកក្អេងដែលឥតមានប្រយោជន៍ មិនព្យាយាមសិក្សាហ្វឹកហ្វឺនខ្លួនឲ្យមានសេចក្ដីចំរើន ទាល់តែចាស់ជ្រេលដល់ទៅអាយុ៣០ឡើងទៅ ទើបដឹងខ្លួន ហើយតាំងកើតទុក្ខទោមនស្សដោយបានឃើញមនុស្សស្រករខ្លួន គេមានសេចក្ដីចំរើនជាងខ្លួន ក៏ទឹកក្នាញ់ក្នុងចិត្តតែម្នាក់ឯង ។ ចំណែកឯក្មេងកំឡោះដែលចេះរំពឹងទឹកដល់អនាគតរបស់ខ្លួន ក៏ខំប្រឹងសិក្សារៀនសូត្រស្វែងរកចំណេះដាក់ខ្លួន មិនបណ្ដោយឲ្យពេលវេលាកន្លងទៅទទេ ៗ ហើយចេះប្រើចំណេះដែលខ្លួនខំសន្សំមកឲ្យមានប្រយោជន៍ដល់ខ្លួន កុមារបែបនេះទើបមានសេចក្ដីចំរើនរុងរឿងហូតទៅ ។

ការចេះប្រើពេលទំនេរឲ្យមានផលប្រយោជន៍ ដោយការហ្វឹកហ្វឺនខ្លួនឯង សូម្បីតែ១ថ្ងៃបន្តិចៗ ក៏អាចញ៉ាំងមនុស្សល្ងង់ខ្លៅឲ្យទៅជាឆ្លាតឡើងបាន ធ្វើដួងចិត្តដែលជារបស់មិនទៀងទាត់ឲ្យជាដួងចិត្តទៀងទាត់

ឡើងបាន ធ្វើមនុស្សដែលអស់សង្ឃឹមក្នុងការរស់នៃជីវិតឲ្យមានឡើងវិញ ធ្វើមនុស្សសាមញ្ញធម្មតាឲ្យទៅជាមនុស្សវិសាមញ្ញ ធ្វើមនុស្សខ្លាចឲ្យក្លា-ហានវិញបាន សរុបសេចក្ដីថា អាចផ្លាស់លក្ខណៈអាក្រក់ៗរបស់មនុស្សឲ្យមានលក្ខណៈល្អឡើងវិញបានគ្រប់បំណែក ។

មនុស្សដែលច្រើនតែនិយាយថា ខ្ញុំមានពេលតិចពេកមិនអាចរៀនអ្វីៗបានទេ រវល់តែធ្វើការរកចិញ្ចឹមជីវិត គិតដូច្នេះមិនត្រូវទំនងសោះ ព្រោះមនុស្សកើតមកក្នុងលោកនេះ គ្មានទរណាធ្វើការតាំងពីពេលក្រោកពីដេករហូតដល់ពេលដេកវិញទេ ។ មនុស្សគ្រប់រូបតែងមានពេលដេក ដើរ ឈរ អង្គុយ ធ្វើការ សម្រាក បរិភោគ ពេលកំសាន្តចិត្ត ។ ទុកជាអ្នកដែលមានពេលឱកាសតិចតែចេះលៃពេលឲ្យមានប្រយោជន៍ រមែងមានផលចំណូលចំរើនឡើង ចំណេះក៏ចំរើនឡើងដែរ ឯអ្នកដែលមានពេលទំ-នេរច្រើន តែមិនចេះតែរិះគិតឲ្យមានប្រយោជន៍ ពេលវេលាដែលមានដំឡៃក៏មិនថ្លៃជាងដុំក្រួសដុំថ្មប៉ុន្មានឡើយ ។

ក្រៅអំពីការប្រើពេលទំនេរសម្រាប់សិក្សារៀនសូត្រ នៅមានវិធីប្រើពេលទំនេរសម្រាប់ត្រួតត្រាការងារដែលបានធ្វើរួច ហើយឲ្យរៀបរយឡើងទៀត ឬប្រើពេលទំនេរនេះ កំណត់កាលខាងមុខ ឬដើម្បីកែខកិច្ចការដែលចាស់ខុសឆ្គងមកហើយឲ្យរៀបរយល្អឡើង ។

ហេតុនេះវេលាទំនេរជាពេលសំខាន់បំផុត អំពីសេចក្ដីចំរើនរបស់ជីវិត មានអ្នកធ្លាប់គិតលេខមើលថា ការមើលសៀវភៅល្អៗត្រឹម១ថ្ងៃ ១៥ មីនុត ខាងក្នុងវេលា ៤ ឆ្នាំកន្លងទៅ នឹងទៅជាអ្នកមានការសិក្សាល្អមួយបាន គំនិតគិតគូរក៏ដុះអណ្ដែតខ្ពស់ឡើងច្រើន ៗ

សូមប្រជាជនខ្មែរជាតិភ្ញាក់កំណើតកើតគំនិតគិតតែលៃលកពេលវេលាឲ្យមានប្រយោជន៍ឡើង ដើម្បីស្ទុះរត់ឲ្យទាន់កាលសម័យនឹងគេ ដោយការបណ្ដុះវិជ្ជាផ្សេងៗដែលខ្លួនស្ម័គ្រចិត្តចង់រៀនសូត្រ ឲ្យបានលូតលាស់ចំរើនពេញលេញល្អ មិនមែនប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាងទេ គឺជាបច្ច័យឲ្យប្រទេសជាតិចំរើនឡើងទៀតផង នាំឲ្យនានាជាតិមិនហ៊ានមើលងាយប្រមាថជាតិយើងបាន ។

ទេមរង្ស៊ី



នេះកាលមិលរេប៉ៈ បានជួបនឹងអ្នកប្រាជ្ញធំម្នាក់ឈ្មោះម៉ារប៉ៈនៅទីបំការមួយ

# វេយ្យាករណសំស្ក្រឹត

## ភាគទី ៦

(តនឹងចប់)

## (៩០) វិធីបំបែកប្រក្ឫតិសំខ្យា តាំងពី ១១ ដល់ ៩៩

សំខ្យាសព្ទ តាំងពី ឯកាទឝ "១១" ដល់ នវទឝ "១៩[1]" ជាត្រៃលិង្គទាំងអស់ ត្រូវបំបែកដូច បញ្ច (ម.ល.៨៧) ។

តាំងពី វឹំឝតិ "២០" ដល់ នវនវតិ "៩៩"[2] សុទ្ធតែជាស្ត្រីលិង្គ ត្រូវបំបែកតាមសមគួរដល់ការន្តរបស់ខ្លួន សព្ទដែលជាឥការន្ត មានវឹំឝតិ ជាដើម ត្រូវបំបែកដូច មតិ ចំពោះតែត្រង់ឯកវចន (ម.ល.៦២); សព្ទដែលជា ត-ការន្ត មាន ត្រឹំឝត៑ ជាដើម ត្រូវបំបែកដូច ទ្វិបទ៑ ចំពោះតែត្រង់ឯកវចន (ម.ល.៦៤) ទើបបំបែកឲ្យឃើញជាបែបយ៉ាងខ្លះ ដូចតទៅនេះ :

### វឹំឝតិ "២០"

ប្ર. វឹំឝតិស៑, ទ្វិ. វឹំឝតិម៑, ត្ឫ. វឹំឝត្យា, ច. វឹំឝតយេ ឬ វឹំឝត្យៃ, ប.ប. វឹំឝតេស៑ ឬ វឹំឝត្យាស៑, ស. វឹំឝតៅ ឬ វឹំឝត្យាម៑ ។

### ត្រឹំឝត៑ "៣០"

ប្រ. ត្រឹំឝត៑, ទ្វិ. ត្រឹំឝតម៑, ត្ឫ. ត្រឹំឝតា, ច. ត្រឹំឝតេ, ប.ប. ត្រឹំឝតស៑, ស. ត្រឹំឝតិ.

---

១ ឯកោនវឹំឝតិ "១៩" ដូចគ្នា តែត្រូវបំបែកដូច វឹំឝតិ;- ២ ឯកោនឝត ក៏ប្រែថា ៩៩ ដូចគ្នា តែត្រូវបំបែកដូច ឝត "រយ" (ម.ល.៩៣) ។

# សេចក្ដីពន្យល់ដោយសង្ខេប

(៩១) សំខ្យាសព្ទតាំងពី ២០ ដល់ ៩៩ នេះជាស្ត្រីលិង្គតាំងអស់ បំបែកផ្សំនឹងវិភត្តិបានតែខាងឯកវចនៈ ដោយពិត តែអាចប្រើជាបទវិសេស-ណៈនឹងនាមសព្ទបានទាំង ៣ លិង្គ ពោះបើនាមសព្ទនោះជាឯកវចនក្ដី ជាពហុវចនក្ដី តែត្រូវឲ្យមានវិភត្តិស្មើគ្នានឹងវិភត្តិរបស់នាមសព្ទដែលខ្លួនប្រាប់ចំនួន ។ . វីសតិ: ស្ត្រិយោ, "ស្ត្រីទាំងឡាយ ២០ នាក់"; វីសតិ: បុរិសា: "ប្រុសទាំងឡាយ ២០ នាក់"; អស្សេ វីសត្យា "ដោយសេះទាំងឡាយ ២០"; គជេហិ តឹសតា "ដោយដំរីទាំងឡាយ ៣០"; ចត្តាលីសាយ ភិក្ខូនំ ភត្តំ ទេតិ "គេប្រគេននូវភត្តដល់ភិក្ខុទាំងឡាយ ៤០ រូប" ។ល។

ម្យ៉ាងទៀត, បើសំខ្យាសព្ទទាំងនេះ ប្រកបផ្សំនឹងបឋមាវិភត្តិ ប្រើជាបទប្រធានក្ដី ប្រកបផ្សំនឹងវិភត្តិឯទៀត; ប្រាប់ចំនួននាមសព្ទផ្ទាល់លើខ្លួនតែម្ដង មិនមែនជាបទវិសេសនៈរបស់នាមសព្ទទេ នោះនាមសព្ទត្រូវប្រកបផ្សំនឹងឆដ្ឋី ពហុវចនៈ ។. វីសតិ: ព្រាហ្មណានំ ឬ បុរិសានំ វីសតិ: "ចំនួន ២០ នៃប្រុសទាំងឡាយ គឺ ប្រុស ២០ នាក់"; អស្សានំ បញ្ចវីសត្យា "ដោយចំនួន ២៥ នៃសេះទាំងឡាយ គឺ សេះ ២៥"; ហត្ថីនំ បញ្ញាសតា "ដោយចំនួន ៥០ នៃដំរីទាំងឡាយ គឺ ដំរីចំនួន ៥០"; ឯកស្មិំ អារាមេ ភិក្ខូនំ បញ្ចនវុតិ ស្តិ "ចំនួន ៩៥ នៃភិក្ខុទាំងឡាយ មាន ក្នុងវត្ត ១ គឺ ក្នុងវត្ត ១ មានភិក្ខុចំនួន ៩៥ រូប ។ល។

# ប្រជុំពាក្យកាព្យភាគទី ៣

# កាព្យសង្វាស

# ជារបស់ផ្សេងអោហារគ្នា

## (៩២) វិធីរាប់ប្រក្ឫតិសំខ្យា តាំងពី រយ ដល់ កោដិ[1]

| | | | |
|---|---|---|---|
| शत | សត | រយ | ១០០ |
| सहस्र | សហស្រ | ពាន់ | ១.០០០ |
| अयुत | អយុត | ម៉ឺន | ១០.០០០ |
| लक्ष | លក្ស | សែន | ១០០.០០០ |
| प्रयुत | ប្រយុត | លាន | ១.០០០.០០០ |
| कोटि | កោដិ | កោដិ | ១០.០០០.០០០ |

## (៩៣) សេចក្ដីពន្យល់ដោយសង្ខេប អំពីការបំបែក និង វិធីផ្សំសំខ្យាសព្ទ ឲ្យកើនច្រើនឡើងដោយលំដាប់ គឺតាំងពីចំនួន ១០០ ដល់ ១.០០០ ជាដើម ។

១. តាំងពី សត ដល់ ប្រយុត ជា ន.បុំ. ត្រូវបំបែកដូច ចិត្ត (ម. ល. ៥៩) ឯ កោដិ ជា ស្ត្រី. ត្រូវបំបែកដូចមតិ (ម. ល. ៦២) ។

២. សំខ្យាដែលជាចំនួនក្រាយ ផ្សំនឹងចំនួន រយ ទៅជា ១០១, ១០២ ជាដើម រហូតដល់ ២០០, ៣០០ ទៅទល់នឹង ១.០០០ តាំងពី ១.០០០

---

[1] វិធីរាប់ប្រក្ឫតិសំខ្យា មិនមែនមានត្រឹមតែកោដិប៉ុណ្ណោះទេ នៅមានច្រើនតទៅទៀត តែមិនបាច់នាំយកមកពោលដោយសព្វគ្រប់ឡើយ ក្នុងទីនេះ ពោលត្រឹមតែកោដិ ព្រោះជាសំខ្យាមានត្រូវការប្រើញឹកញាប់ ។

ទៅដល់ ១០.០០០ នោះ មានចំនួនច្រើនពេកណាស់ ទាំងរបៀបផ្សំ ក៏ផ្សេងពីគ្នាច្រើនយ៉ាងណាស់ ក្នុងទីនេះ នឹងពោលចំពោះតែសំខ្យាសព្ទ ដែលត្រូវការប្រើញឹកញាប់ ទុកជាគ្រឿងជៀបល្មមនឹងឲ្យយល់ក្នុងវិធីផ្សំ សំខ្យាចំនួនរាយ នឹងចំនួនរយជាដើមគ្រប់អន្លើទៅបាន ដូចតទៅនេះ:

១០១ = ឯកសត[១] (< ឯក:សតំ ប), ឯកោត្តរសត (< ឯកន + ឧត្តរ[២] + សតំ), ឬ ឯកាធិកសត (< ឯកន + អធិក[២] + សតំ)

| | |
|---|---|
| ១០២ = ទ្វាធិកសត, ទ្វុត្តរសត | ១០៦ = ឆធិកសត, ឆុត្តរសត |
| ១០៣ = តេយោធិកសត, តេ្យុត្តរសត | ១០៧ = សត្តាធិកសត, |
| | ១០៨ = អដ្ឋាធិកសត |
| ១០៤ = ចតុរាធិកសត, ចតុរុត្តរសត | ១០៩ = ឩនទសោត្តរសត |
| ១០៥ = បញ្ចាធិកសត, បញ្ចុត្តរសត | ១១៩ = ឯកោនវីសតុត្តរសត |

១ ឯកសត ដែលប្រែថា ១០១ នេះ មានប្រើម្ដងកាល ព្រោះគេអែងក្រែងច្រឡំនឹង ១០០ តែដែលអាចប្រើទៅបានខ្លះនោះ ដោយគតនេះ បើមិនបាច់មាន ឯក ផ្សំជាមួយ ក៏គង់នៅអានដឹងថា ១០០; បើតាំងពី២០០ឡើងទៅ ទើបត្រូវឲ្យមានសំខ្យារាយផ្សំជាមួយជាដរាប ។

២ សត្ត ឧត្តរ នឹង អធិក ទាំងពីរនេះ ត្រូវដាក់ក្នុងចន្លោះនៃសំខ្យាចំនួនរាយ នឹងចំនួនរយ គ្រប់កន្លែងបាន តែគួរពិនិត្យមើលកន្លែងណាគួរផ្សំដោយ ឧត្តរ កន្លែងណាគួរផ្សំដោយ អធិក ដើម្បីឲ្យស្រួលក្នុងការសរសេរ នឹងការអាន ។ ដល់ចំនួន ពាន់ ក៏មានទំនងផ្សំដូចគ្នា ។

១២០ = វីសត្យុត្តរសត

១៣០ = ត្រឹង្សុត្តរសត

១៣៩ = ឯកោនចត្តាឡីសាធិកសត

១៤០ = ចត្តាឡីសាធិកសត

១៥០ = បញ្ញាសាធិកសត

១៦០ = សដ្ឋ្យធិកសត

១៧០ = សត្តត្យធិកសត

១៨០ = អសីត្យធិកសត

១៩០ = នវុត្យុត្តរសត

២០០ = ទ្វិសត

២០១ = ឯកាធិកទ្វិសត

២០៩ = នវោត្តរទ្វិសត

២៨៨ = អដ្ឋាសីត្យុត្តរទ្វិសត

៣០០ = ត្រិសត

៣៧២ = ទ្វិសត្តត្យុត្តរទ្វិសត

៤០០ = ចតុះសត

៤៨០ = អសីត្យុត្តរចតុះសត

៥០០ = បញ្ចសត

៦០០ = ឆសត

៦៦១ = ឯកសដ្ឋ្យុត្តរឆសត

៧០០ = សត្តសត

៧៧៧ = សត្តាធិកសត្តត្យុត្តរសត្តសត ឬ សត្តសត្តត្យុត្តរសត្តសត

៨០០ = អដ្ឋសត

៩០០ = នវសត

៩០៥ = បញ្ចុត្តរនវសត

១០០០ = សហស្រ

១០០១ = ឯកោត្តរសហស្រ

១០១៧ = សត្តទសោត្តរសហស្រ

១០៥១ = ឯកបញ្ញាសាធិកសហស្រ

១២០០ = ទ្វិសតោត្តរសហស្រ

១២៥៤ = ចតុះបញ្ញាសុត្តរទ្វិសតាធិកសហស្រ

១៩៣៦ = ឆត្តឹសុត្តរនវសតា- ធិកសហស្ស

២០០០ = ទ្វិសហស្ស

២៤០០ = ចតុ:សតោត្តរទ្វិសហស្ស

២៤៧៩ = ឯកោនាសីត្យុត្តរចតុ: សតាធិកទ្វិសហស្ស

៩០០០ = នវសហស្ស

៩៩៩៩ = ឯកោនសតុត្តរនវសតា- ធិកនវសហស្ស ឬ នវនវុត្យុត្តរនវសតាធិ- កនវសហស្ស

១០.០០០= អយុត

៣. តាំងពីចំនួន ១០,០០០ ដល់ ១០០,០០០ នោះ គេយក ទសសហស្ស "១ ពាន់ដប់ដង" ទុកជាបទដើម ហើយយកសំខ្យាចំនួនតិច ទៅផ្សំនឹង ទសសហស្ស មិនមែនផ្សំនឹង អយុត ឡើយ ដរាបដល់ចំនួន សែន ដែលហៅថា លក្ស ដូចមានតទៅដោយសង្ខេបនេះ:

១០.០០០ = ទសសហស្ស

១២.០០០ = ទ្វាទសសហស្ស

១៧.២០០ = ទ្វិ សតោត្តរសត្តទស- សហស្ស

២០.០០០ = វីសតិសហស្ស

២០.២០០ = ទ្វិសតោត្តរវីសតិ- សហស្ស

២៤.០០០ = ចតុវីសតិសហស្ស

៣០,៥០០ = បញ្ចសតោត្តរត្រឹំ- សតិសហស្ស

៤០.០០០ = ចត្តាឡីសតិសហស្ស

៥០.០៧០ = សត្តត្យុត្តរបញ្ញា- សតិសហស្ស

៦០.០០០ = សដ្ឋិសហស្ស

៧០.០០០ = សប្តតិសហស្រ ៩០.០០០ = នវតិសហស្រ

៨០.០០០ = អសីតិសហស្រ ១០០.០០០ = លក្ស

៤. វិធីផ្សំ ឬ គុណ សំខ្យាសព្ទឲ្យមានចំនួនច្រើនឡើងនោះមាន ២ យ៉ាង គឺ:

ក) ធ្វើឲ្យរួមគ្នាជាបទសមាសដូចខាងលើនេះ:

១) ឲ្យនៅជាបទពាយដោយខ្លួនពីគ្នា ដោយប្រកបផ្សំនឹងវិភត្តិពល់បទតាមសមគួរដល់លិង្គនិងវចន ឧ. ទ្វេ ឝតេ, "២០០"; ត្រីណិ ឝតានិ, "៣០០"; ចត្វារិ ឝតានិ, "៤០០"; ទ្វេ សហស្រេ, "២.០០០"; ត្រីណិ សហស្រាណិ, "៣០០០" ។ ល ។ បើសំខ្យាសព្ទនោះ មានចំនួនពយ តាំងពី១ដល់៩ ខ្លះ មានចំនួន ១០, ២០, ៣០, ជាដើមខ្លះ ផ្សំជាមួយគ្នានឹងសំខ្យាសព្ទដែលមានចំនួន ១០០ ខ្លះ ១.០០០ ខ្លះ ដើម្បីឲ្យកើនចំនួនច្រើនឡើងនោះត្រូវឲ្យប្រកបនិបាត-សព្ទ ច ដែលប្រែថា "ផង" ក្នុងប្រយោគនៃសំខ្យាសព្ទទាំងនោះត្រង់កន្លែងដែលគួរប្រកប ដើម្បីកុំឲ្យច្រឡំចំនួន ឧ. នវសត្តតិ ឝតំ ច "៧៩ផង១០០ផង" = ១៧៩; ទ្វេអសីតិ-ត្រីណិ ច ឝតានិ "៨២ ផង៣០០ផង" = ៣៨២; បតាតិកិស តិស្សតិ-គីតិកិត្វាក្យាំ ច "ដោយពលប្រើដើងទាំងឡាយ ៨០ បីដងផង ២ ផង= ២៤២ (៣ × ៨០ + ២ = ២៤២) នវ ឝតំ ច "៩ ផង ១០០

ផង" = ១០៩.; ចតុរាសីតិ នវ ច សតានិ "៨៤ ផង ៩០០ ផង" = ៩៨៤: បញ្ចវីសតិ នវ ច សតានិ ត្រីណិ ច សហស្សាណិ, "២៥ ផង ៩០០ ផង ៣.០០០ផង" = ៣.៩២៥; ទស ច សហស្សាណ្យដ្ឋ ច សតានេ្យកវីសតិ "១០.០០០ផង ៨០០ផង ២១ ផង" = ១០.៨២១ ។ល។

## បូរណសំខ្យា

(៩៤) បូរណសំខ្យានេះ ដែលបានអធិប្បាយខ្លះហើយត្រង់លេខ ៥៥ ជាសំខ្យាក្លាយមកពីប្រកតិសំខ្យាគ្រប់អន្ទើទាំងអស់ វៀរលែងតែត្រង់ទី មួយចេញ ដោយអាស្រ័យនឹងប្រត្យយខ្លះ មិនអាស្រ័យនឹងប្រត្យយខ្លះ ដូចមានសេចក្តីពន្យល់ក្នុងខាងមុខ

### ១ វិធីរាប់បូរណសំខ្យា តាំងពីទី ១ ដល់ទី ១០

| | | | | |
|---|---|---|---|---|
| បឋម | ប្រថម | ទី ១ | ឬ | ជាដំបូង |
| ទុតិយ | ទ្វិទីយ | " | " | គំរប់ ២ |
| តតិយ | ត្រិតីយ | " | " | " ៣ |
| ចតុត្ថ | ចតុថ៌ | " | " | " ៤ |
| បញ្ចម | បញ្ចម | " | " | " ៥ |

| | | | | |
|---|---|---|---|---|
| षष्ठ | ឆដ្ឋ | ទី | ឬ | គំរប់ ៦ |
| सप्तम | សប្តម | " | " | " ៧ |
| अष्टम | អដ្ឋម | " | " | " ៨ |
| नवम | នវម | " | " | " ៩ |
| दशम | ទសម | " | " | " ១០ |

## ២ វិធីរាប់បូរណសំខ្យា តាំងពីទី ១១ ដល់ទី ១៩

| | | | | |
|---|---|---|---|---|
| एकादश | ឯកាទស | ទី | ឬ | គំរប់ ១១ |
| द्वादश | ទ្វាទស | " | " | " ១២ |
| त्रयोदश | ត្រយោទស | " | " | " ១៣ |
| चतुर्दश | ចតុទ្ទស | " | " | " ១៤ |
| पञ्चदश | បញ្ចទស | " | " | " ១៥ |
| षोडश | សោឡស | " | " | " ១៦ |
| सप्तदश | សប្តទស | " | " | " ១៧ |
| अष्टदश | អដ្ឋទស | " | " | " ១៨ |
| नवदश | នវទស | } " | " | " ១៩ |
| ऊनविंशतितम | ឯកូនវីសតិម | | | |

## ៣ វិធីរាប់បូរណសំខ្យា(១) តាំងពីទី២០ ដល់៩៩

| | | |
|---|---|---|
| विंशतितम | វីសតិតម | ទី ឬ គំរប់ ២០ |
| विंश | វីស | |
| एकविंश | ឯកវីស | " " " ២១ |
| द्वाविंश | ទ្វាវីស | " " " ២២ |
| नवविंश | នវវីស | " " " ២៩ |
| ऊनत्रिंशत्तम | ឩនត្រឹសត្តម | |
| त्रिंशत्तम | ត្រឹសត្តម | " " " ៣០ |
| त्रिंश | ត្រឹស | |
| त्रयस्त्रिंश | ត្រយស្ត្រឹស | " " " ៣៣ |
| नवत्रिंश | នវត្រឹស | " " " ៣៩ |
| ऊनचत्वारिंशत्तम | ឩនចត្តាឡីសត្តម | |
| चत्वारिंशत्तम | ចត្តាឡីសត្តម | " " " ៤០ |
| चत्वारिंश | ចត្តាឡីស | |
| एकचत्वारिंश | ឯកចត្តាឡីស | " " " ៤១ |

---

១ វិធីរាប់បូរណសំខ្យានេះ មិនបានរៀបរៀងឲ្យក្បួរហែដោយសព្វគ្រប់ទេ រៀបរៀងក្នុងទីនេះដោយអន្លើៗ, ល្មមតែអ្នកសិក្សាសង្កេតទៅអាចយល់ អាចរាប់ដោយខ្លួនឯងបានដោយសព្វគ្រប់ ។

| | | | | | |
|---|---|---|---|---|---|
| अष्टचत्वारिंश | អដ្ឋចត្វារឹឝ | ទី | ប្ដ | គំរប់ | ៤៨ |
| नवचत्वारिंश | នវចត្វារឹឝ | " | " | " | ៤៩ |
| ऊनपञ्चाशत्तम | ឩនបញ្ចាឝត្តម | | | | |
| पञ्चाशत्तम | បញ្ចាឝត្តម | " | " | " | ៥០ |
| पञ्चाश | បញ្ចាឝ | | | | |
| षष्टितम | ឞដ្ឋិតម | " | " | " | ៦០ |
| एकषष्ट | ឯកឞដ្ឋ | " | " | " | ៦១ |
| चतुःषष्ट | ចតុះឞដ្ឋ | " | " | " | ៦៤ |
| सप्ततितम | សប្តតិតម | " | " | " | ៧០ |
| चतुःसप्तत | ចតុះសប្តត | " | " | " | ៧៤ |
| अशीतितम | អឝិតិតម | " | " | " | ៨០ |
| एकाशीत | ឯកាឝីត | " | " | " | ៨១ |
| नवाशीत | នវាឝីត | " | " | " | ៨៩ |
| नवतितम | នវតិតម | " | " | " | ៩០ |
| चतुर्णवत | ចតុណ៌វត | " | " | " | ៩៤ |
| नवनवत | នវនវត | " | " | " | ៩៩ |

## ៤ វិធីរាប់បូរណសំខ្យា តាំងពីទី ១០០ ឡើងទៅ

| | | | | | |
|---|---|---|---|---|---|
| ឝតតម | សតតម | ទី | ឬ | គំរប់ | ១០០ |
| ឯកឝត | ឯកសត(១) | " | " | " | ១០១ |
| នវឝត | នវសត | " | " | " | ១០៩ |
| ទឝឝត | ទសសត | " | " | " | ១១០ |
| ត្រិំឝឝត | តឹសសត | " | " | " | ១២០ |
| នវសប្តតឝត | នវសត្តតិសត | " | " | " | ១៧៩ |
| ទ្វិឝតតម | ទ្វិសតតម | " | " | " | ២០០ |
| ត្រិឝតតម | តិសតតម | " | " | " | ៣០០ |
| ឞឝីតត្រិឝត | ឆឡសីតិតិសត | " | " | " | ៣៨៦ |
| ចតុះឝតតម | ចតុះសតតម | " | " | " | ៤០០ |
| ឞដ៑ឝតតម | ឆសតតម | " | " | " | ៦០០ |
| អឞ្ឋឝតតម | អដ្ឋសតតម | " | " | " | ៨០០ |
| នវឝតតម | នវសតតម | " | " | " | ៩០០ |
| សហស្រតម | សហស្សតម | " | " | " | ១.០០០ |

១ សំខ្យាសព្ទ ដែលជាចំនួនរាយ ផ្សំនឹងចំនួន រយ, ពាន់ បើយក អធិក ឬ ឧត្តរ មកប្រកប ត្រង់ចន្លោះកណ្តាល ដើម្បីកុំឲ្យច្រឡំចំនួន ជាការប្រពៃ ដូចបានពន្យល់ម្តងហើយខាងប៉ែកប្រកតិសំខ្យា ។

៙ ក្ដីស្នេហ៍នេះនឹងប្រៀបឧបមា បីដូចមច្ឆាពឹងសាគរ

បើទឹកត្រជាក់ស្ត្រីស្មោះសរ នឹងគរទាល់ផុតរលត់ជន្ម ។

បើទឹកនោះក្ដៅពុំត្រជាក់ សត្វដែលសំណាក់កើតទុក្ខធ្ងន់

មិនមានសប្បាយកាយទោរទន់ ស្រពោនស្រពន់គ្រប់វេលា ។

សេចក្ដីសំរើបមិនដែលស្រស់ បេះតែក្រៀមក្រស់ក្រំគ្រប់គ្រា

ជួបក្រហាក់បានក្សាន្តទំយា នេះថែមៈវេទនាជាចិន្ត្រៃយ ។

ប្រះប្រាណដេកទៅតែឯកា ឈោងចាប់ក្រមាយកមកហើយ

លាតលាដណ្ដប់ទុក្ខគ្រាន់ស្បើយ កូនស្រីនៅឡើយបងចាំបាន ។

មិនមានប្រែប្រួលចំឡែកសោះ ចំពោះជាកូនកែវកល្យាណ

ដើបហើយស្បើយទុក្ខពីកូនប្រាណ ចាប់បានថ្ងៃចន្ទកាន់ចើបទៀត ។

ក្បៀងកំងតាំងថែមទុក្ខជាថ្មី ទឹកថ្លៃទ្រូងវែងរឹងបង្អៀត

ទុក្ខមួយដែលបងចំឈ្លប់ទៀត មានទៀតឲ្យថ្ងៃឈឺចិត្តផ្សា ។

កែវអើយខ្លួនបងពេញហៅខុស ដោយសារជាប្រុសលោកតណ្ហា

ត្រង់ណេះនេះតាមតែមេត្តា ទោសានុទោសប្រណីអើយ ។

៙ អក្ខាដោមយង់អង្គអក្ខរេត ប្រែងកាយក្លាយកេទកង់ចិន្តា

កាលដើមថាស្ដួបរដើរ ទឹកថាស្ងួស្ងាប់ដួបអន្ទ្រៃ ។

មិនខ្លាចទៅក្រងចមយកក្សា នេះពេញហៅជាក្លាចិត្តមុត

ខ្លួនយើងៗប្រៀបដូចអនិរុទ្ធ
ខ្លួនប្អូនវិសុទ្ធដូចឧសា ៗ
ស្រឡាញ់ប្រាកដដូចពាក្យស្តី
មិនប្រែចិត្តខ្ចីដូចកល្យាណ៍
នឹងទៀងប្រាកដដូចសញ្ញា
នឹកថាមិនឲ្យកើតអប្រិយ ៗ
ខ្លួនយើងជាប្រុសមែនពិតហើយ
កែវអើយតែចិត្តដូចកង្រី
មិនឲ្យមានពីរៈខប្អូនស្រី
សេចក្តីដូចប្អូនផ្តាំបងថា ៗ
ឲ្យខំរក្សាសីលសត្យញ្ញាណ
កុំមានសេចក្តីនឹកកង្ខា
យើងសោកយើងចាំដូចសញ្ញា
កនិដ្ឋាបែរចិត្តពុំទៀងត្រង់ ៗ

១ នុ ព្រះសុរិយោអស្តង្គត
ទៀបផុតភ្នាំងជ្រុងសុមេរុ
បំព្រាងរស្មីនៅភ្លឺថ្លា
សព្វសត្វសកុណាវិលទ្រនំ ៗ
ត្រឡប់ងងឹតសព្វទិសទី
ទៀបនឹងកើតព្រលប់ធំ
សកុណីចាកព្រៃវិលទ្រនំ
ក៏មកចាកបង់ក្របកេសរ ៗ
ចតុប្បាទទ្វេបាទចាកវាលបឹង
ក៏មកទ្រហឹងសំឡេងខ្ទរ
ដំរេកគ្រែកគ្រះហើយសាទរ
សត្វក៏គ្រែកអគ្រូសប្បាយ ៗ
គាកព្រោងប្រុះផ្ទុះរហោស៍
អស់ទាំងមនុស្សម្នាសុខក្នុងកាយ
ឃ្លាតគូប្តូគូមិនមានឆ្ងាយ
តែប្រាណាឯកាយឯកោនៅ ៗ
កំព្រាវេទនាសែនរំខាន
ហើយថែមទាំងមានសេចក្តីក្តៅ
ម៉ោងមួយរៀមព្រួយនឹកដល់ពៅ
ឱថ្ងារនេះនៅឬទៅណា ៗ

ប្ដមួយប្អូនទៅកង់ដំណោក
ទល់ទុក្ខវិវេកឧបេក្ខា
ទឹករៀមប្ដស្រៀមប្ដបពោ
ប្ដមាននរណានាំនិយាយ ៗ
ប្ដមួយមានមិត្តនិត្យទៅផង
ចំពោសោសង់លេងសប្បាយ
ភ្ញាំងក្មេចក្ដីស្ម័គ្រក់ពយមាយ
ថ្ងៃអើយរៀមអួលអន់ទក ៗ
ប្ដប្អូនគិតដែរតែយ៉ាងស្បើយ
ធើយៗ ពុំផ្ចិតពីចិន្តា +
ថ្ងៃនេះរៀមចង់យល់កក្ដា
ឲ្យធូរទុក្ខាណាប្អូនអើយ ៗ
ទៀបម៉ោងពីរបងតាំងតែក្ក
សៀតចុកចិន្ដាមិនមានស្បើយ
រៀមត្រេកទឹកណាស់ណាទួនអើយ
វិទនត់តស្បើយអំពល់ចិត្ត ៗ
ឈើទៀបលេងកង្ទឧរា
ណែនខ្លោចក្ដៅផ្សាចិន្ដាផ្អិត
សែនរំជួលក្ដួលណាស់អំពល់គិត
រៀមអាណិតទឹកអាណាតក់ទិដ្ឋា ៗ
រង្គួបរឹតផ្គួតសែនអួលអាក់
វែងវេរត្រដាក់តែឯកា
ទោរទន់ស្រពន់អស់កាយា
រៀមកំព្រាសែនវេរសញ្ជប់គិត ៗ
ទឹកណាស់តែខ្វល់គត់ឧបមា
ចុកសៀតខ្ពាដេកមិនលក់
យប់ស្ងាត់សត្វស្រៀមរៀមរែក្ក
គិតគ្រប់ទៅទុក្ខកល់វេលា ៗ
លុះដល់ម៉ោងបីចិត្តបងព្រួច
ទឹងទៅមិនរួបបើទេវតា
ទឹងបានបបមថ្នមស្ងួនភ្ញា
ឲ្យអស់ចិន្ដាណាប្អូនអើយ ៗ
អនិច្ចាវេទនាតែឯកអង្គ
ទៅកង់ដំណោកវិវេកផ្សា

សង្ស័យអាល័យគិតសង្ការ
លុះដល់វេលាទៀបព្រឹកព្រាង ។
ប្រះប្រាណកែះកើយតែខ្វើយខ្វល់
ហាក់ប្រែផល់ផល់ខ្វើយក្វាង
រួបតែបួបផិតស្នានទួនទាន
ភ្ញាភ្ញាន់ដឹងផាក់ភ្ញាក់ចិត្តា ។
ឱអញ្ជូមមើមើអើដល់ម៉្លេះ
ពុំគួរដុះបុះឡើយទេត្តា
ដល់ជាក្រសោបឱបប្រាណ
ឡើយឱបស្នានថាជាថ្លៃបង ។
កម្មអើយកើតទុក្ខកន់គ្រានេះ
ពុំមានរបះសេចក្តីមង
អំពល់ហើយខ្វល់សល់កន្វង
បើម៉្លេះម្រាងបងទឹងសៀយទុក្ខ ។
បើបួនខ្ទីមខ្លួនមានមេត្តា
ស្នេហាស្រឡាញ់តទៅមុខ
ឲ្យបងអ្នកបានសៀយហើយទុក្ខ
ទៅមុខគង់ទឹងសំរេចការ ។
នេះហើយជាការក្តីសុខុម
ចូរមុំនាងគិតកែប្រាជ្ញ
លៃលកមកឲ្យបងស្នេហា
កន្លៃខះណាព្រលឹងអើយ ។
អនិច្ចាចិត្តអើយអើដល់ម៉្លេះ
ដូច្នេះដិតឃើញជាក្ស័យ
ព្រោះដៀតសង្ការសែនសង្ស័យ
តែវថ្លៃចូរស្តាប់បងថ្លែងទុក្ខ ។
ទុក្ខៈហើយថែមទាំងក្រៀមជំ
ឱភាក្រៀមក្រំសមសៀតពុក
ដៀតបានដោយខ្លួនមិនជួនមុខ
កើតទុក្ខៈកន្សីប្រៀបពុំបាន ។
ទេះគឺជាកម្មផងខ្លួនហើយ
តែរអើយដូចក្ខុសង្កត់ប្រាណ
ទឹងគិតដូចម្តេចក៏មិនបាន
រំខានចិត្តណាស់មាសបងអើយ ។

សព្វថ្ងៃកើតទុក្ខមុខក្រៀមក្រស់ គ្មានស្រើបគ្មានស្រស់ស្រួលត្រង់ណា
សើចលេងតែមាត់ចិត្តខ្លោចផ្សា ទុក្ខកង់ឧរាណែនស្មើរថ្លោយ ៗ
រូបនេះដល់នោះមកថ្មី ៗ ជួបជួលតើបើមិនមានស្បើយ
វេហាវេហាលចិត្តណាស់ហើយ កម្មអើយតៀរព្រេងអីដល់ម៉្លេះ ៗ
កាលបានឃើញមុខមួយវេលា ចិត្តអើយខ្លោចផ្សាទ្រូងស្មើរប្រេះ
រន្ធត់សែនខ្វល់ចិត្តអីម៉្លេះ កាន់តែជូរចេះទប់ពុំបាន ៗ
សព្វថ្ងៃខ្វួនបង់ដូចសមុទ្រ មៀងមើលងឹតមិនយល់ត្រើយ
មួយឆ្នាំជួបមួយថ្ងៃឃ្លាតវិញហើយ ម៉្លេះសមកន្ទើយបង់អាសារ ៗ

១ អនិច្ចាទុក្ខព្រួយព្រោះក្ដីអាល័យ
កាត់ប្នូខំតែកែស្នេហ៍ក្នុងហទ័យ
ព្រួយគិតតែពុំស្បើយល្ហើយដល់មួយថ្ងៃ
តែងសង្រែងតែងសង្រែក្ដីអាងខ្នង ៗ
បងព្រួកដល់ប្អូនស្ងួនកល្យាណ៍
លុះវេលាជាទីងហៀបទៀបព្រឹកព្រាង
ស្ដាប់សព្ទសត្វយំទៅដោយយ៉ាង
ទៀបទីងស្វាងហើយទើបសត្វយំឆ្ងាស់ផ្ទើយ ៗ

## (៩៥) សេចក្ដីពន្យល់ក្នុងបូណ៌សំខ្យា

១ អំពីប្រត្យយ បូណ៌សំខ្យាមានប្រត្យយ ៤ គឺ ម, តីយ, ថ និង តម; ត្រង់ទី ១, ទី ៥, ទី ៧, ទី ៨, ទី ៩ និងទី ១០ ប្រកបដោយប្រត្យយ ម; ទី ២ និងទី ៣ ប្រកបដោយប្រត្យយ តីយ។ ទី ៤ និងទី ៦ ប្រកបដោយប្រត្យយ ថ; តាំងពីទី ១១ ដល់ទី ១៩ ឥតមានប្រត្យយឡើយ វៀរលែងតែទី ១៩ នោះ ដែលកើតពីប្រកតិសំខ្យា ឩនវីសតិ នោះត្រូវប្រកបដោយប្រត្យយ តម ជាឩនវីសតិតម ក្រៅពីនោះតាំងពី ២០ ឡើងទៅ រហូតដល់ រយ, ពាន់ មានប្រកបដោយប្រត្យយខ្លះ មិនប្រកបដោយប្រត្យយខ្លះ បើប្រកបដោយប្រត្យយ ចំពោះតែប្រត្យយ តម ១ ប៉ុណ្ណោះ ដូចបានពោលទុកក្នុងខាងលើជាបែបរួចមកហើយ ។

២. អំពីលិង្គ បូណ៌សំខ្យាទាំងអស់ជា គ.ស.ត្រៃលិង្គ ។ របៀបបូណ៌សំខ្យាដែលបានចារិកទុកខាងដើម សុទ្ធតែជា អការន្ត បុំ. និង នបុំ.; ត្រង់ទី ១, ទី ២, ទី ៣ បើជាស្ត្រី. ជាអាការន្ត : ប្រថមា, ទ្វិតីយា, តតី-យា — តាំងពីទី ៤ ឡើងទៅ ជាឦការន្ត : ចតុត្ថី, បញ្ចមី, ។ល។ ឯកាទសី, ទ្វាទសី ។ល។ សហស្រតមី ។

## ៣. អំពីសព្ទប្លែកដែលមានសេចក្ដីដូចគ្នានឹងប្រឋម ចតុត្ថ

ត្រង់ប្រឋម ប្រែថា "បឋម, ជាដំបូង" មានសព្ទ ២ ដោយឡែក គឺ បូវ៌ "ជាខាងដើម, ជាមុន" អាទ្យ "ជាខាងដើម" ដែលអាចប្រើផ្លាស់ប្ដូរគ្នានឹងប្រឋម បានសេចក្ដីដូចគ្នា បើជាស្ត្រី. ជាអាការន្តៈ បូវ៌ា, អាទ្យា; ត្រង់ចតុត្ថ "ទី ៤" គេអាចធ្វើជា តុរីយ ឬ តុយ៌ ប្រែថាទី ៤ ដូចគ្នា តែបើជាស្ត្រី. ទៅជាអាការន្ត : តុរីយា តុយ៌ា ។

៤. **អំពីវិធីបំបែក** បណ្ដាបូណ៌សំខ្យាទាំងអស់, សព្ទណាជាអការន្ត បុំ. នឹង នបុំ. ត្រូវបំបែកដូច ទេវ នឹង ចិត្ត (ម.ល.៥៩) សព្ទណា ជាអាការន្តស្ត្រី. ត្រូវបំបែកដូច កថា (ម.ល. ៦០); សព្ទណា ជាឦការន្តស្ត្រី. ត្រូវបំបែកដូច ទេវី (ម.ល. ៦១)

## សំខ្យាសព្ទក្លាយ

(៩៦) ដែលហៅថា សំខ្យាសព្ទក្លាយ គឺសំខ្យាសព្ទ មានភាពរបស់ខ្លួនមិនតាំងនៅជាប្រក្រតី ឬ មានវិធីប្រើមិនតាំងនៅតាមធម្មតា (៨៥ - ៩៥) អាចក្លាយទៅជាកិរិយាវិសេសណ ឬ ជាបទផ្សេងៗដោយការស្រ័យនឹងប្រត្យយខ្លះ ទេខ្លះ ដូចមានដោយសង្ខេបតទៅនេះ:

១. ជាកិរិយាវិសេសណ (គ្មានប្រត្យយ) សំដែងពី ចំនួន, លើក, ដង, ត្រា: ទ្វិស៑, ករ: ២ ដង ឬ អស់ករ: ២ ដង; ត្រិស៑, ៣ ដង; ចតុរ៑, ៤ ដង (បើតែ ១ ដង ជា សក្ឫត៑, ករៈម្ដង ឬ អស់ករៈម្ដង)

២. ជាកិរិយាវិសេសណ ដោយអាស្រ័យនឹងបច្ច័យ ធា, គសោ សំដែងពីភាគ, បំណែក: ឯកធា, ទ្វិធា, ត្រិធា, ចតុធា, បញ្ចធា(១) ។ល។ ឯកគសោ, ទ្វិគសោ, ត្រិគសោ(១) ។ល។ (ម. ល. ៨៤. ត្រង់ ៥)

៣. មាននាមសព្ទខ្លះ កើតអំពីសំខ្យាសព្ទ ២ – ៣ អន្ទើ (ប្រែថា ប្រជុំ....) ជានាមសព្ទគេត្រូវការប្រើដោយច្រើន: ទ្វយ, នបុំ. "ប្រជុំពីរ, គូ;" ត្រយ. នបុំ. ត្រយី, ស្ត្រី. "ប្រជុំបី"; ចតុក្កយ, នបុំ. "ប្រជុំបួន"; បត្តិ ឬ បង្ក្តិ, ស្ត្រី. "ប្រជុំប្រាំ"; ទសត, ស្ត្រី ឬ ទសតយ(២), នបុំ. "ប្រជុំដប់" ។

៤. សំខ្យាសព្ទខ្លះ ផ្សំរួមជាមួយនឹងនាមសព្ទ កើតទៅបទសមាសដូច្នេះ:

ក) សំខ្យានាមសព្ទជាបទខាងចុង ប្រាប់ចំនួននាមសព្ទជាបទខាងដើម រួមជាបទ ឆដ្ឋី–តប្បុរិសសមាស: វេទ-ត្តយ "ប្រជុំ ៣ នៃវេទ"; រត្ន-ត្តយ, "ប្រជុំ ៣ នៃរតន" ។ល។

ខ) សំខ្យាសព្ទជាបទខាងដើម ប្រាប់ចំនួននាមសព្ទជាបទខាងចុង រួមជាបទ ឆដ្ឋី-ពហុព្វីហិសមាស ជា គ. ស. ប្រែថា "មាន"...: ឯកស្សោ រថ:, "រថ មានសេះ ១"; ទ្វិទន្តោ ហត្ថី, "ដំរី មានភ្លុក ២"; ទ្វិគុណា រជ្ជុ:, "ខ្សែ មាន ២ ជាន់" ។ល។

---

១ ក្នុងកច្ចាយនពោធិ ជាវិភាគតទ្ធិត ។ ២ នាមសព្ទទាំងនេះ ក្នុងកច្ចាយនពោធិ ជាសមូហតទ្ធិត ។

# ប្រជុំពាក្យកាព្យ

# ភាគទី ៤

របស់គ្រូកវីរម្យ អ៊ួង
ហ៊ុមវេច មហាតឡោក
( តមក )

ដោមក៏ក្ត្រទឹករៀមដៃរប្អ៊ូ ។
ឯរៀមរឹងរឹតចិត្តថែមត្រួត
ដំរួតអាល័យដល់តីរបី
សែនគុណលានគុណៈទៀតណាថ្ងៃ
ម្តេចពុំប្រណីទ្រូងរៀមផង ។
បំណាច់កើតក្នុងខត្តិយវង្ស
ម្តេចឡើយមិនទ្រង់ជ្រាបទំនង
ពីទុក្ខពីមានក្តីសៅហ្មង
ពីចិត្តព្រាំរងគម្នាល់ថ្ងៃ ។
ទុកជីវិតមិត្តមួលមួយ
ជាត្រួយបណ្តាច់ដួងហឫទ័យ
ពុំគិតស្តាយផន្លជីវិតក្ស័យ
នៃថ្ងៃថ្មើមរៀមផ្ញើជន្មបាន ។
សព្វថ្ងៃយកព្រះជាទីពឹង
ពំនឹងផ្សងតាមបុណ្យបុពណ
បំណាច់ព្រះទ័យដែលរាប់អាន
ឲ្យបានដូចចិត្តគិតប្រាថ្នា ។

កនិដ្ឋាចិន្តាឈ្វេងដូចម្តេច
ឬភ្លេចបន្ទូលដែលសញ្ញា
ជាមួយនឹងព្រះជាជេដ្ឋា
សច្ចាគ្រប់សព្វឥតចន្លោះ ៗ

ស្ងួនអើយបើកស្នាយើងមាន
គង់តែនឹងបានជាស្មានស្មោះ
មិនមានខ្វែប្រែទៅណាសោះ
ដូចកលរបស់ក្នុងលំនៅ ៗ

ខំរៀបរក្សាគិតថែទាំ
ប្រុងចាំកាលណានឹងបាត់ទៅ
ដូចកលកនិដ្ឋាថ្វាចោមខ្មៅ
ចាំព្រះទ័យនៅមិនភ្លេចឡើយ ៗ

បើបានមកដល់សូមមេត្តា
ឥតបសាក៏កុំកន្តើយ
ឲ្យមានរៀមរក្សអ្នកបានស្បើយ
ថ្ងៃមអើយអាសូរពិត្តរៀមផង ៗ

បំណាច់បានមកប្រសព្វគ្នា
កុំឲ្យកំព្រាពេកឡើយហោង

សូមស៊ូជីវិតជាមួយផង
ថ្ងៃបង់សូមមាសមានមេត្តា ។
ឲ្យបានដំណឹងដល់រៀមរ័ក្ស
ដែលជាប់ជំពាក់ដោយតណ្ហា
ក្តៅក្តួលរំជួលក្នុងខ្ញុំ
នេត្រាហូរល្ហែងស៊ូរទឹងក្ស័យ ។
ក្សត្រីមិនទតមករៀមសោះ
ចរបុះអស្សប្រុទ្ធ៍បើកឃ្លាឃ្លៃ
នេត្រារៀមរ័ក្សរែងរំពៃ
ក្សត្រីលុះផុតវេលានោះ ។
វិលឡើងមកឯលំនៅវិញ
ទ្រង់ម្នេញតែម្នាក់ឯងម៉ងម៉ោះ
មិនគួរទឹងកាត់ព្រះទ័យសោះ
គេបដោះបោលរៀមគ្មានសង្ស័យ ។
មាំនបំរើពីលោកធរមា
ហៅរៀមនេះណាវេលាថ្ងៃ
ពុធពីរដណ្ដប់ខែជេស្ឋនៃ
ហើយលោកប្រាស្រ័យប្រើពជការ ។

ថ្ងៃមុនមានចុតហ្មាយ ១ ច្បាប់
ថ្ងៃឥ ប្រាប់ទៅថាវរក្សត្រី
ខានពុំបានទៅហែឡើយនៃ
សេចក្តីបានសួរទៅរៀមថា ។
ទៅហែឬពុំបានទៅឡើយ
ចុតហ្មាយរៀមឆ្លើយតបសព្វសា
បើទ្រង់ខានទៅដូច្នោះណា
ជេដ្ឋាក៏ពុំបានទៅដែរ ។
លុះដល់ស្តេចយាងដំណើរទៅ
ក្សត្រីឆោមឆ្ងៅហែទៅហើយ
ខុសទឹងសញ្ញាដែលឆ្លះឆ្លើយ
ថ្លើមអើយរៀមថប់ត្រប់ប្រការ ។
រៀមឃើញកនិដ្ឋាយាត្រាត្ពោះ
ចរចុះអស្សបុទ្ធវេលាណា
. . . . . . . . . .
. . . . . . . . . . ។
ថាឲ្យទៅចំរើនពន្ធស្រូវ
ឲ្យទៅក្នុងថ្ងៃនោះឯងណា

ឯរៀមពុំហ៊ានប្រកែកថា
ដោយសារខ្លួនតូចទាបយសស័ក្តិ ។
ចេញដើរទៅចំរើនពន្ធស្រូវ
តាមផ្លូវទៅចិត្តគិតអួលអាក់
ទឹកដល់កទិដ្ឋាថ្វាវល័ក្ខណ៍
កើតអាក់តើពីព្រោះរឿងអ្វី ។
ទើបទៅពុំមានបន្ទូលប្រាប់
ឲ្យដឹងសាស័ព្ទសព្វសេចក្តី
ស្រាប់តែស្តេចយាងចុះអស្សរី
សំឡឹងព្រះទ័យហាក់ដូចស្សើយ ។
ឬមួយមានមនុស្សទូលញុះញង់
ឲ្យទ្រង់អន់អាក់ខេដឹងអើយ
ទើបទៅពុំមានបន្ទូលឆ្លើយ
ព្រងើយពុំឲ្យដឹងស័ព្ទសា ។
ខំធ្វើកជការតែទាំងទុក្ខ
ក្តីសុខពុំមានសោះឡើយណា
ចំរើនបានពីរបីទិវា
ឮថាស្តេចយាងមកវាំងវិញ ។

បញ្ឈប់ពន្លកផ្ការនោះទុកស្នេះ
គេបេះមកពីគិតអម្ចេញ
ឲ្យប្អូនទឹងក្រើសំឡាញ់
ទឹងកាញ់ទូលសួរឲ្យដឹងការ ។
ឥឡូវថា មានគេទូលថ្លែង
ថារៀមនេះឯងចរយាត្រា
សំដៅទៅនៅទឹងកិរិយា
នរណា តើគេទូលក្រើ ។
រៀមចង់ឲ្យជាក់ដំណើរនោះ
ឲ្យដឹងចំពោះសព្វសេចក្តី
ឬមួយកនិដ្ឋាក្មេងបំភ័យ
ឲ្យរៀមនេះនៃព្រួយរិះគិត ។
សព្វថ្ងៃស្តាប់រស់ពុំគិតខ្លួន
លែងតែបានជួនជួបឆោមស្និទ្ធ
ឥឡូវប្រែថារៀមទ្រុស្តមិត្ត
កែគិតក្បត់ថ្លៃកនិដ្ឋា ។
រៀមនេះត្រង់ណា សុំកុំសង្ស័យ
ទ្រង់ថ្លៃនោះខុសទឹងទេវតា

ដោយគួរនៅជាសុខសព្វព្រឹក្សា
ភ្ញាក់កាលណា ឃើញនៅមុខទុក្ខបានស្បើយ
តែខ្លួនបងកំព្រាគេឲបតែល្ហើយ
ឱកម្មអើយធ្វើកម្មអ្វីក៏វល់ម្ល៉េះ ។
សារមេត្រីតែងដោយក្តីគិសរង់
ធ្វើមកត្រង់បងឲ្យរងឹតពីចិន្តា
ពីចិត្តបងគិតមួយត្រួយដ៏ពី"
ពុំបង់ឃ្លាឲ្យជាឃ្លាតមួយរាត្រី ។
តែរៀមកាត់ដោយជាតិសត្វកើតក្នុងកម្ម
វេងតែចាំទ្រាំតែទុក្ខជាប្រក្រតី
ទឹងបៀសចាកពីសង្សារទោះលោកិយ
ទោះប្រុសស្រីវេងជួបគ្នាកល់រូបា ។
ម៉្លោះប្រាំបួនប្អូនគេខ្លួនយាមវែបប្រាណ
ចិត្តគិតស្មានជួបបានថ្ងើមថ្ងៃ
ដោយជាសុខលក់ស៊ិនហួសដល់ថ្ងៃ
ចិត្តគិតថ្លៃដោយខ្វល់ដល់ក្តីវេទនា ។

បើជឿជាក់ហើយពុំសង្កា
សូមមានអក្សរតបទៅវិញ ៗ
នៅណាកែវណា រៀមលាទៅ
ធីតាគង់នៅរក្សាអង្គ
ខំប្រឹងព្រះទ័យថ្លៃផ្ចិតផ្ចង់
ដំរង់ទំរាំរៀមមកវិញ ៗ
រៀមទៅតែប្រាំពីរខែ
មិនហានយូរយារទេកុំម្ញេញ
អផ្សុកព្រះទ័យដូចម្ដេចមិញ
កុំចេញក្រសាលដោយបឹងបួរ ៗ
ផ្សិតមនុស្សឥឡូវច្រើនអាក្រក់
ភរភូតកុហកចិត្តជងជួរ
ពនាំបំបែកមិនគិតគួរ
ដោយសារចិត្តជួរពោរសោម៉ាន្យ ៗ
រាគិតនាំយកឈ្មោះទៅលក់
សព្វក្ដីសព្វស្រុកឲ្យតែបាន
កាសប្រាក់តាយលេងជាកំសាន្ត

៦ អនិច្ចា ព្រះសុរិយា ជិតព្រលប់ ទៀបយប់ភ្លៀងធ្ងរដោកពសុធា
ហ៊ឹងក្អាត់យំឆ្ងងឆ្ងើយគ្នាក់ ជួបគូជិតគូស្រស់ស្រើបចិត្ត ៗ
តែបងរងកម្មទ្រាំតែទុក្ខ គ្មានសុខមុខគួរឲ្យអាណិត
បងស្នេហ៍ប្រែខានពុំបានជិត រងគិតរឹងកើតតែទុក្ខា ៗ
រំពឹងរកកល់ខ្វល់ក្នុងចិត្ត ទឹកបង់ឲ្យជិតរួមក៏ស្នា
គិតណាស់អំពល់ខ្វល់ប្រាជ្ញា សែនមហាវិតក្កទុក្ខមិនស្បើយ ៗ

ឃុខស៊ីមនោម័យ

# រឿងបុរសកំសត់ចេញទៅជួញ

មាននិទានមួយថា មានបុរសកំសត់ម្នាក់ចេញទៅជួញបានមាសប្រាំផែន នាំមកដល់ស្ថានអាត្មាហើយ យកមាសនោះទៅកប់ក្រោមជើងជណ្តើរហើយយកថ្មទីងកាំបិតដាក់លើ ។ ឯប្រពន្ធបុរសនោះមានអន្ទករ ឯចៅអន្ទករនោះមកនៅក្រោមផ្ទះ កាលបើប្តីឡើងទៅលើផ្ទះហើយ ប្រពន្ធដណ្តឹងថា ឯងមកពីជួញតើបានអ្វីខ្លះ ។ ឯប្តីនោះសោតប្រាប់ប្រពន្ធថា អញបានមាសប្រាំផែន ។ ប្រពន្ធដណ្តឹងថា មាសនោះទុកឯណា ។ ប្តីប្រាប់ថា អញកប់នៅជើងជណ្តើរហើយយកថ្មទឹងកាំបិតសង្កត់លើ ។ ឯអាអន្ទករមេនោះមិញឮហើយ ក៏ទៅកាយយកមាសនៅក្រោមជើងជណ្តើរបាត់ទៅ ។ លុះព្រឹកឡើងបុរសនោះទៅមើលកំណប់មាសនោះបាត់ហើយ បុរសនោះថា ឯងអើយអញកប់មាសនេះយប់ពន់វេលាការ ឥតអ្នកឯណាមួយទឹងដឹងផងឡើយ មានតែកាំបិតទឹងថ្មនេះឯង ឥឡូវនេះមាសអញបាត់ អញមិនថានរណាឡើយ អញថាថ្មទឹងកាំបិតនេះឯងលួចមាសអញ ម៉្លេះហើយពុំអត់ឡើយ ។ ទើបបុរសនាំទៅប្តឹងដល់ចៅក្រម ។ កាត់សេចក្តីនុ៎ះពុំបានឡើយ ទើបបុរសនាំសេចក្តីនុ៎ះទៅដល់សម្តេចព្រះមហាក្សត្រាធិរាជហើយក្រាបទូលដោយនូវដំណើរថា ទូលព្រះបង្គំកប់មាសប្រាំផែននៅក្រោមជើងជណ្តើរ ឥតនរណាដឹងឡើយ មានតែថ្មទឹងកាំបិតនេះឯងនៅនោះ ក៏ឥឡូវនេះមាសបាត់ ទូលព្រះបង្គំ

មិនថានរណាឡើយ ថាថ្នឹងកាំបិតនេះឯងល្អមាស ទើបទូលព្រះបង្គំ
នាំថ្នឹងកាំបិតនេះមកក្រាបទូលទ្រង់ព្រះករុណាពិសេស ពុំបានទឹងព្រះ
ប្រាជ្ញាពិសេសពិចារណាសេចក្ដីនេះហោង ៗ ទើបព្រះមហាក្សត្រាធិរាជ
ទ្រង់ព្រះចិន្ដាពិចារណាថា សមជាប្រពន្ធបុរសនេះពុំស្លូតឡើយ ហើយ
ព្រះអង្គថា បើដូច្នោះទៅរកខួបបានមួយមកឲ្យអញ ទើបបុរសនោះរកខួប
មួយមកថ្វាយ ព្រះអង្គឲ្យកាប្រេងអប់ត្រឡប់សឹងគន្ធពិដោរប្រោកក្នុងខួប
នោះពេញហើយឲ្យបុរសយកទៅកប់ទុកនោះក្បាលដំណេកឲ្យស្រួលបួល
ទ្រង់ផ្ដាំថាបើប្រេងនេះនោះពេញខួបដូចដែលនោះ ទៅកុំមកកាន់សំណាក់
អញឡើយ ថាបើប្រេងនេះបាត់សឹមទៅមកប្រាប់អញហោង ៗ ម៉្លោះ
ហើយបុរសនោះយកប្រេងទៅទុកនៅក្បាលដេកយូរបន្តិចក្ដី អាអន្ធករ
នោះមិញវាមករកមេនោះ ៗ ឯមេនោះយល់ប្រេងនោះហើយក៏លាបឲ្យអា
អន្ធករនោះស្រកចុះកន្លះខួបក្ដី បុរសនោះដណ្ដឹងទៅប្រពន្ធថា នាងអើយ
ប្រេងអញទុកនៅនេះតើទៅឯណាបាត់ក៏កន្លះខួប ៗ ឯមេប្រពន្ធថា អញ
ពុំដឹងឯណា បើអញលាបតើមិនលើចុងក្បាលអញឬអី ៗ ទើបបុរស
នោះទៅក្រាបទូលព្រះមហាក្សត្រាធិរាជ ៗ ឲ្យយកអ្នកចាំទ្វារគ្រឿងឲ្យ
កាំលេងមហោស្រពហើយឲ្យយកគងទៅវ៉ាយប្រាប់អស់មហាជនជនទាំង
ឡាយឲ្យទៅមើលរបាំកុំខានឡើយ ៗ អ្នកឆងទាំងឡាយទៅមើលរបាំនោះ
ច្រើនសឹងពុំមានប្រេងពិដោរលាបឡើយ មានតែអាអន្ធករមេនោះលាប

ប្រេងគន្ធពិដោរធុំហួងឡប់ហើយដើរចូលទៅមើលប្រាំកូរ ៗ អាមាត្យធុំក្លិនពិដោរអំពីអានោះហើយ ក៏ចាប់នាំមកថ្វាយព្រះមហាក្សត្រាធិរាជ ទើបព្រះអង្គមានបន្ទូលដណ្ដឹងថា ប្រេងដែលចៅលាបនេះតើជារបស់ចៅឯងឬចៅបានពីណា ៗ រីឯចៅនោះសោតឥតចម្លើយអ្វីនឹងក្រាបទូលព្រះមហាក្សត្រាធិរាជឡើយ ស្ងៀមនៅហោង ៗ ទើបព្រះអង្គមានព្រះបន្ទូលថា ចៅអើយម្ដេចចៅមិនឆ្លើយមក បើចៅនឹងឆ្លើយថាម៉េច ៗ ចូរចៅឆ្លើយមក ៗ រីចៅនោះសារភាពថាទោសមិញទឹងហោកពុំបានឆ្លើយក្ដីក៏ឆ្លើយដោយពិតហោងថា ទូលព្រះបង្គំបានប្រេងអំពីផ្ទះចៅនេះឯង ៗ មហាក្សត្រាធិរាជដណ្ដឹងថាបើចៅបានអំពីផ្ទះចៅនេះតើនរណាឲ្យចៅ ឬចៅយកឯង អានោះថា ប្រពន្ធចៅនេះឲ្យ ទើបព្រះអង្គឲ្យទៅហៅប្រ-ពន្ធចៅនោះមកដណ្ដឹងសួរ ៗ ឯប្រពន្ធឆ្លើយថា ប្រេងនេះខ្ញុំម្ចាស់ពុំបានឲ្យឡើយ ចៅនេះយកលាបឯង ព្រះអង្គមានព្រះបន្ទូលថា ចៅនេះឯងលួចមាសហើយលួចទាំងប្រពន្ធចៅផង ដ្បិតកាលចៅមកពីលួញនោះកប់មាសនៅក្រោមជើងជណ្ដើរហើយចៅស្រដីប្រាប់ប្រពន្ធ អានេះពុំពាក្យចៅស្រដីហើយក៏ទៅកាយយកមាសចៅ ទើបព្រះអង្គបង្គាប់គាអន្ទកថា ចៅឯងទៅយកមាសមកឲ្យគេ ទើបអានោះទៅយកមាសមកឲ្យម្ចាស់ហើយ ព្រះអង្គកាត់ឲ្យម្ចាស់នោះឈ្នះ ទើបសម្ដេចព្រះមហាក្សត្រាធិរាជព្រះអង្គបង្គាប់ឲ្យលក់អាចោរប្រុសនឹងមេស្រីនោះដាច់សុរិលបង់ហោង ៗ

NATIONALE
DU CAMBODGE

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ២

កុងស៊ីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព ស ២៤៨២

គ. ស. ១៩៤០

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


១ — អំពីគំនូរថ្មីពីរបែប របស់ព្រះរាជបណ្ណាល័យ និងសេចក្ដីអធិប្បាយរបស់ ទេមររង្សី . . . . . . . . . . . . . . . . . . . . . . ៣

២ — អំពីសេចក្ដីអធិប្បាយរបស់ជាតិហុល្លង់ដេស៍ម្នាក់ អំពីការពឹងពាក់ប្រាស្រ័យ ទៅស្រុកខ្មែរ ចិតិម-ហាក់ លេខានុការក្រសួងប្រៃសនីយ៍ប្រែ . . . . ១០

៣ — អំពីអាយុសម័យនៃពុទ្ធរូបមន-ខ្មែរ-ថៃ . . . . . . . . . . . . . . . ១៩

៤ — ពង្សាវតារប្រទេសអេស៊ីប្ដ៍ ស្រង់យកអំពីពង្សាវតារសាកលលោករបស់ហ្លួង វិចិត្រវាទការ អ្នកមហាថែម ប្រែនិងរៀបរៀង (មានត) . . . . . . . ២៥

៥ — វេយ្យាករណ៍សំស្ក្រឹត ភាគទី ៤ ព្រះវិសុទ្ធិវង្ស (ហ. តាត) រៀបរៀង (មានត) . . . . . . . . . . . . . . . . . . . . . . . . . ៣៧

៦ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . ៦១


## រូបក្រៅរឿង


រូបនេះ ជាជំនាន់កាលព្រះពុទ្ធជាម្ចាស់ ស្ដេចយាងទៅរក្សាជម្ងឺព្រះថេរៈ មួយអង្គមានជម្ងឺជាទម្ងន់ . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages.

1° Commentaire sur deux dessins de l'artiste TUK par KHEMARARANSI ........ 3

2° Extraits d'une relation sur le CAMBODGE, parue dans le B. E. F. E. O, par un Hollandais et traduit en cambodgien par Mr. KÈM-HAK ........ 10

3° Au sujet de statues du Bouddha (art Mon-Khmer-Thai)... 19

4° Histoire de l'ÉGYPTE, extraits de l'histoire générale thailandaise, de LUONG VICHITRA-VADAKAR, traduit en cambodgien par MAHA THÈM ........ 25

5° GRAMMAIRE SANSCRITE, 4e partie, par le Vénérable Préas VISUDDHIVONG (suite) ........ 37

6° INFORMATIONS DIVERSES ........ 61

HORS TEXTE :

Le Bouddha soignant le bhikkhu TISSA gravement malade ........ 1



៥ នេះកាលព្រះសម្មាសម្ពុទ្ធស្តេចទៅមើលភិក្ខុឈឺ ព្រះថេរឈ្មោះ បូតិគត្តតិស្ស
កើតរោគ កមបើប្លោកពងពាសពេញទាំងខ្លួន មានទឹកខ្ទុះហៀរស្រស្រាក់ មាន
ក្លិនស្អុយស្អោច ភិក្ខុឯទៀតគ្នាបោះបង់លោកចោល ទើបព្រះអង្គទ្រង់ដាំទឹកក្តៅ
ទ្រង់ស្ងួតផ្ចិតសំអាតរាងកាយ ភិក្ខុទាំងឡាយក៏នាំគ្នាមកជួយទូលរ៉ាយរ៉ៃ
ជម្ងឺ លោកអ្នកឈឺក៏បានសះស្បើយ ទើបព្រះអង្គសំដែងគាថា១ថា អចិរំវតយំ
កាយោ ។ល។ ចប់លោកក៏បានសម្រេចព្រះអរហត្ត (ធម្មបទដ្ឋកថា ភាគ២ ទំ៩—

គំនូរថ្មីពីរបែប

# របស់ព្រះរាជបណ្ណាល័យ

# សេចក្ដីអធិប្បាយ

របស់

## ខេមររង្សី

(មាឧត)

# អំពីគំនូរប្ញឹរបស់ព្រះរាជបណ្ណាល័យ

គំនូរមួយនេះគូរជារូបដំណាងកាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានព្រះទ័យប្រកបដោយមេត្តាករុណាទ្រង់ប្រោសព្រះថេរៈមួយរូបឈ្មោះថា បូតិគត្តតិស្សៈ លោកមានជម្ងឺជាទម្ងន់ ភិក្ខុឯទៀតៗបោះបង់លោកចោលលែងថែរក្សា ព្រះបរមគ្រូទ្រង់ឈ្វេងយល់ឧបនិស្ស័យធម៌របស់លោក ទើបស្តេចទៅថែរក្សាជម្ងឺទ្រង់ដាំទឹកក្តៅ ងូតជម្រះពងកាយជាដើម ភិក្ខុទាំងឡាយក៏នាំគ្នាមកជួយខ្វល់ខ្វាយជាច្រើន ដូចមានសំដែងទុកនៅរូបគំនូរនោះស្រាប់ ។

ឯលោកបូតិគត្តតិស្សត្ថេរនេះ កាលជាន់ដើមលោកជាកុលបុត្រមួយនៅក្រុងសាវត្ថី បានស្តាប់ធម៌ទេសនាមានចិត្តជ្រះថ្លា ទើបប្រគល់កាយថ្វាយខ្លួនដល់ព្រះពុទ្ធសាសនា ហើយសូមបួស ។ លុះបួសរួចហើយក្នុងកាលតមកលោកមានរោគកើតឡើងក្នុងពងកាយ ដំបូងកើតដួតតូចៗល្អិតៗប៉ុនគ្រាប់ស្ពៃ តមកកាន់តែធំឡើងប៉ុនគ្រាប់សណ្តែកបាយ,សណ្តែកខៀវ, គ្រាប់ក្របៅ, ផ្លែកន្ធូតព្រៃ, រហូតឡើងធំប៉ុនផ្លែព្នៅ ហើយក៏បែកធ្លាយពងកាយទាំងមូល មានរន្ធតូចរន្ធធំទៅជាដំបៅរលាយរលួយស្អុចមើលមិនជា តាំងអំពីនោះមកទើបគេហៅថា បូតិគត្តតិស្សត្ថេរ ។ តមកឆ្អឹងក៏ពុកផុយ ភិក្ខុទាំងឡាយក៏លែងថែជម្ងឺលោក ស្បង់ចីពរក៏ប្រឡាក់

ដោយឈាមទឹកខ្ទុះប្រឡេកប្រឡាកអស់ ៗ ទាំងសិស្សគណរបស់លោក ក៏លែងទៅទ្រាំផ្សើនាំគ្នារត់ចោលអស់ លោកជាអ្នកអនាថានៅតែម្នាក់ឯង ឥតគ្នីគ្នា ៗ ឯធម្មតាព្រះពុទ្ធទាំងឡាយ តែងទ្រង់ក្រាលសំណាញ់ញាណ ពីរដងក្នុងមួយថ្ងៃ គឺវេលាព្រឹកម្តង វេលាល្ងាចម្តង ៗ ក្នុងសម័យនោះ ព្រះបូតិគត្តតិស្សត្ថេរប្រាកដក្នុងសំណាញ់ញាណរបស់ព្រះអង្គ ៗ ទ្រង់ទត ឃើញឧបនិស្ស័យនៃអរហត្តផល ហើយទ្រង់ជ្រាបថាលោកនោះមានជម្ងឺ ជាទម្ងន់ សិស្សគណរត់ចោលអស់ វៀរលែងតែតថាគតចេញគតនរណា ជាទីពឹងបានឡើយ ហើយស្តេចយាងទៅកាន់រោងភ្លើង ទ្រង់លាងឆ្នាំង (ឬកមៀវ) ចាក់ទឹកដាក់ដាំលើចង្ក្រាន លុះទឹកក្តៅហើយទើបស្តេច យាងទៅកាន់គ្រែសំណឹងរបស់ព្រះបូតិគត្តតិស្សត្ថេរនោះ ៗ ឯភិក្ខុទាំង ឡាយបានឃើញក៏នាំគ្នាឈូឆរមកក្រាបទូលថា សូមព្រះអង្គកុំព្រួយព្រះ ទ័យទុកធុរៈឲ្យយើងខ្ញុំព្រះអង្គ ហើយនាំគ្នាសែងគ្រែសំណឹងទៅឯរោង ភ្លើង ៗ សម្តេចព្រះបរមសាស្តាទ្រង់ឲ្យលើកស្បកមកហើយ ទ្រង់ឲ្យ ចាក់ទឹកក្តៅ ហើយឲ្យយកចីវរដាក់ត្រាំក្នុងស្បកទឹកក្តៅហើយឲ្យគក់បោក លាងឲ្យស្អាតយកទៅហាលថ្ងៃ ទើបទ្រង់ស្ថិតក្បែរអ្នកជម្ងឺ ទ្រង់ជូតសំអាត ខ្លួនអ្នកជម្ងឺដោយទឹកក្តៅហើយទ្រង់ផ្ងូតឲ្យផង លុះហើយកិច្ចដុសខាត់សំ- អាតរាងកាយនិងងូតទឹក ចីវរសំពត់ដណ្តប់ក៏ស្ងួត ទើបទ្រង់ឲ្យយកចីវរ

នោះមកស្លៀកផ្លាស់យកស្បង់ទៅគក់ហាលថ្ងៃវិញ ។ លុះស្បង់នោះស្ងួតហើយ ទើបព្រះអង្គឲ្យស្លៀកស្បង់គ្រងចីវរស្រួលបួល ។ លោកអ្នកផងក៏មានចិត្តសប្បាយរីករាយស្រាលខ្លួនប្រាណមានចិត្តមូលល្អ ស៊ប់លើគ្រែសំណឹងរបស់ខ្លួន ។ ព្រះបរមសាស្តាយាងស្តេចទ្រង់ស្ថិតពីខាងក្បាលសំណឹង ហើយទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុ រាងកាយរបស់អ្នកឯងនេះជាសភាវៈប្រាសចាកវិញ្ញាណ គ្មានឧបការគុណអ្វីឡើយ នឹងដេកនៅលើផែនដីដូចជាអង្កត់ឧសមិនខាន ហើយត្រាស់សំដែងព្រះគាថាមួយថា :

អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ
ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ប្រែសេចក្តីថា រាងកាយនេះជារបស់មិនស្ថិតស្ថេរទៀងទាត់ឡើយ តែងដេកសង្កត់ផែនដី ជារបស់ប្រាសចាកវិញ្ញាណ គ្មានប្រយោជន៍ គេតែងបោះបង់ចោល (គ្មានអាល័យ) ដូចជាកំណាត់អង្កត់ឧស ។

វេលាចប់ធម្មទេសនា ព្រះបូតិគត្តតិស្សត្ថេរ ក៏បានសម្រេចអរហត្តព្រមដោយបដិសម្ភិទាញាណ ។ ជនឯទៀតជាច្រើនក៏បានសម្រេចមគ្គផលមានសោតាបត្តិផលជាដើម ។ ឯព្រះថេរៈលុះបានសម្រេចព្រះអរហត្តហើយ ក៏ចូលបរិនិព្វាន (ក្នុងថ្ងៃនោះឯង) សម្តេចព្រះបរមសាស្តាទ្រង់ឲ្យរៀបចំបូជាសពលោករើសធាតុបញ្ចុះក្នុងចេតិយ ។

ឯភិក្ខុទាំងឡាយនាំគ្នាទូលសួរព្រះអង្គថា ព្រះបូតិគត្តតិស្សត្ថេរ លោកបានទៅកើតក្នុងទីណា ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តិស្សភិក្ខុនោះនិព្វានហើយ ។ ពួកភិក្ខុមានសេចក្ដីសង្ស័យនាំគ្នាក្រាបទូលសួរទៀតថា ព្រះអង្គ បើមានឧបនិស្ស័យធម៌ដល់អរហត្តដូច្នោះ ចុះហេតុអ្វី ក៏ខ្លួនលោកកើតដំបៅស្អុយធុយដល់ឆ្អឹងឆ្អែង លោកកសាងដូចម្ដេចទើបបានសម្រេចដល់អរហត្ត ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផលល្អអាក្រក់អស់នេះកើតឡើងដោយអំពើកម្មដែលខ្លួនបានកសាងមក អ្នកទាំងឡាយបូរប្រុងចាំស្ដាប់ចុះ តថាគតនឹងសំដែង ទ្រង់ថ្លែងអតីតនិទានថា ៖

ក្នុងសម័យពុទ្ធកាល ព្រះពុទ្ធព្រះនាមកស្សបនោះ តិស្សភិក្ខុនេះបានកើតជានាយព្រានសត្វស្លាប តែងទៅនេសាទសត្វស្លាបទាំងឡាយយកទៅជូនឥស្សរជនម្នាក់ ក្រៅពីនេះយកទៅលក់ ដែលសល់ពីលក់គាត់កាច់បំបាក់ឆ្អឹងជើងនិងឆ្អឹងស្លាប មិនឲ្យសត្វអស់នោះហើរឡើងរួច ហើយគរទុកទៅ ដល់ព្រឹកឡើងទើបគាត់យកទៅលក់ កាលបើបានច្រើនសល់ពីលក់ទើបឲ្យគេយកទៅឆ្អើរអាំងសម្រាប់ខ្លួន ។ មានថ្ងៃមួយ គេបានចំអិនភោជនាហារឆ្អិនស្រេចហើយ ស្រាប់តែមានព្រះខីណាស្រពមួយអង្គនិមន្តបិណ្ឌបាតឈរនៅមុខទ្វារផ្ទះរបស់គាត់ ។ បានឃើញព្រះថេរៈនិមន្ត

មក ក៏មានចិត្តជ្រះថ្លាដោយគិតឃើញថា ខ្លួនអាត្មាអញបានសម្លាប់សត្វអស់ជាចំនួនច្រើនហើយ ឯព្រះថេរក៏និមន្តមកដល់មាត់ទ្វារផ្ទះហើយ ទាំងអាហារដ៏មានឱជារសក៏មាននៅក្នុងផ្ទះអញ គួរអាត្មាអញប្រគេនបង្ហាន់បិណ្ឌបាតដល់លោក ហើយចុះទៅទទួលយកបាត្រមកដាក់បង្ហាន់បិណ្ឌ-បាតដ៏មានឱជារស ហើយយកទៅប្រគេន ថ្វាយបង្គំប្រកបដោយអង្គ ៥ តាំងប្រាថ្នាថា សូមឲ្យខ្ញុំព្រះករុណាបានសម្រេចធម៌ដែលលោកម្ចាស់បានឃើញបានយល់នោះក្នុងអនាគត ។ ឯព្រះថេរក៏ទទួលធ្វើអនុមោទនាថា សូមឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា ។

ម្នាលភិក្ខុទាំងឡាយ ដោយអំណាចកម្មដែលតិស្សភិក្ខុបានកសាងមកក្នុងគ្រានោះ ទើបសម្រេចផលដល់តិស្សភិក្ខុដូច្នេះ ដោយហេតុកាច់បំបាក់ឆ្អឹងសត្វទាំងឡាយ ទើបតិស្សភិក្ខុមានខ្លួនស្អុយរលួយពុកឆ្អឹង ដោយអំណាចផលទានដែលបានប្រគេនដល់ព្រះខីណាស្រពនោះ ទើបបានសម្រេចអរហត្តក្នុងកាលឥឡូវនេះ ។

ចប់រឿងបូតិគត្តតិស្សត្ថេរតែប៉ុណ្ណោះ ។

(មានត)

# សេចក្ដីអធិប្បាយរបស់ជាតិហុល្លង់ដេស៍មួយនាក់

## អំពីការប្រាស្រ័យពឹងពាក់របស់ស្រុកខ្មែរ ក្នុងរវាង ព. ស. ២១៨៤

ក្នុងសៀវភៅលេខ ៣៧ ផ្នែកទី ១ ដែលសាលាបារាំងសែសនៅចុងបូព៌ាប្រទេស (អេចស្ត្រែមអូរីយ៉ង់) នៅទីក្រុងហាណូយ បានបោះពុម្ពផ្សាយអំពីការរាវរកបុរាណស្ថានចាស់ៗ នៅប្រទេសឥណ្ឌូចិន មានទីអង្គរជាដើម នោះមានសេចក្ដីអធិប្បាយមួយ អំពីក្រុមសមាគមជាតិហុល្លង់ដេស៍ដែលនៅស្រុកជ្វា សេចក្ដីអធិប្បាយនេះប្រែចេញពីភាសាហុល្លង់ដេស៍មកជាភាសាបារាំង មានរឿងរ៉ាវស្រុកខ្មែរ ដែលយើងសូមពណ៌នាដោយសង្ខេប យើងមានសេចក្ដីជឿជាក់ថា លោកអ្នកដែលមើលសៀវភៅកម្ពុជសុរិយាទាំងប៉ុន្មាន នឹងមានសោមនស្សត្រេកអរ ដោយបានដឹងពង្សាវតារនគររបស់ខ្លួន ចំនួន ៤០០ ឆ្នាំមុននេះ ។

កាល ព. ស. ២.១៩៥ មានពួកឈ្មួញជាតិហុល្លង់ដេស៍នាំគ្នាមកនៅស្រុកខ្មែរ ប៉ុន្តែមិនបានយូរប៉ុន្មានទេ កាលមុនដម្បូងបង្អស់គេបានចាប់ពួកហុល្លង់ដេស៍នេះ នៅក្នុងទន្លេមេគុងមកដាក់គុកធ្វើទោស គេមានសេចក្ដីសង្ស័យថា ការចាប់ចងពួកហុល្លង់ដេស៍នេះ គឺជាស្នាដៃនៃពួកពរទុយកែស ការជំនួញក្រុមសមាគមហុល្លង់ដេស៍នឹងជំនួញរបស់ខ្មែរអាស្រ័យគ្នាទៅវិញទៅមកមុនដម្បូងបង្អស់ ក្នុងរជ្ជកាលព្រះជ័យចេស្ដា

(ព.ស. ២១៦១–២១៧១) មាននាក់ហូឡង់ដេស៍ជាច្រើនចូលមកស្រុកខ្មែរ ទិញស្រូវ-កញ្ជាន មានពួកហូឡង់ដេស៍ខ្លះ មកតាំងគេហស្ថាននៅក្នុងស្រុកខ្មែរនេះ ។ តាំងពីមាត់សមុទ្រមកដល់ទីក្រុងស្រុកខ្មែរបើកកប៉ាល់ចំនួន ៤ ខែទើបបានដល់ ។

កប៉ាល់ហូឡង់ដេស៍ចេញចូលពីក្រុងបាតាវីយ៉ា (ទីក្រុងស្រុកជ្វា ចំណុះស្រុកហូឡង់ដេស៍) មកស្រុកខ្មែរមានជានិច្ចទៀងទាត់ ក្រុមសមាគមហូឡង់ដេស៍នេះ គ្មានប្រាថ្នាមកលាយឡំនឹងកិច្ចការស្រុកខ្មែរនឹងស្រុកសៀមដែលកំពុងតែកើតចម្បាំងនឹងគ្នានោះទេ កាល ព.ស. ២១៧៤ ស្តេចអង្គតុនរាមាធិបតីបានផ្ញើសារមួយទៅឲ្យពួកសមាគមហូឡង់ដេស៍នេះ មកជួយច្បាំងនឹងសៀម ។

កាល ព.ស. ២១៧៩ ពួកហូឡង់ដេស៍បានមកដល់បន្ទាយលង្វែក ដែលក្នុងសម័យនោះមានភូមិជប៉ុនមួយ ភូមិពារទុយកែសមួយ ភូមិចិនមួយ ហើយនឹងភូមិចាមមួយផង ។

ពួកហូឡង់ដេស៍ប្រព្រឹត្តធ្វើតាមច្បាប់ខ្មែរ នាំគ្នាដើរតារហូតដល់កន្ទួលសម្រាប់អង្គុយ ចូលមកគាល់ស្តេចខ្មែរៗដ៏មានកិត្តិសព្ទល្បីថាប្រកបដោយមហាករុណា ហើយជាទីគាប់ចិត្តស្រឡាញ់នៃបណ្តារាស្ត្រទាំងអស់ ទ្រង់មានព្រះរាជឧក្ការសាកសួរច្រើនកន្លែង ទ្រង់បានអនុញ្ញាតឲ្យពួកនេះ

មកធ្វើជំនួញរកស៊ីក្នុងស្រុកខ្មែរតាមចិត្ត ហើយឲ្យមកនៅក្នុងភូមិដប៉ុនតែទ្រង់ហាមឲ្យពួកហុល្លង់ដេស៍នេះរក្សាសេចក្ដីសុខនឹងសត្រូវរបស់ខ្លួនខាងផ្លូវជំនួញគឺជាតិពារទុយកែស ។

ព្រះអគ្គមហេសីស្ដេចខ្មែរដែលសុគតទៅ ហើយដែលត្រូវជាព្រះរៀមនៃស្ដេចគ្រប់គ្រងរាជ្យក្នុងពេលនោះ បានរៀបទទួលពួកហុល្លង់ដេស៍នេះដោយរាក់ទាក់ ហើយទុកពួកនេះដូចជាកូនបុត្រធម៌ ។

ព្រះអង្គម្ចាស់ឧបរាជ ដែលព្រះពុំសូវចូលចិត្តដូចជាមហាក្សត្រដែលគ្រប់គ្រងរាជ្យ មិនសូវស្រួលយករាក់ទាក់នឹងពួកហុល្លង់ដេស៍នេះទេ តែបើកឲ្យពួកនេះរកស៊ីបានក្នុងស្រុកខ្មែរ ប៉ុន្តែការរាប់អាននេះ មានហេតុកើតវិបត្តិវែងឆ្ងាយទៅទៀត ស្ដេចខ្មែរដកសេចក្ដីអនុញ្ញាតពីពួកហុល្លង់ដេស៍មិនឲ្យនាំស្រូវចេញពីស្រុកខ្មែរទៀតឡើយ ដោយទាស់ហេតុនឹងហុល្លង់ដេស៍ម្នាក់មានចិត្តក្លៀវក្លាហានហួស ទៅនិយាយការសុំរបស់អ្វីមួយមិនគប្បក្រុមសមាគមហុល្លង់ដេស៍នោះ ក៏នាំសួយសាអាករមកថ្វាយស្ដេចខ្មែរ នឹងព្រះរាជវង្សានុវង្សព្រមទាំងមន្ត្រីដែលគាប់ព្រះរាជហឫទ័យ ដើម្បីកុំឲ្យមហាក្សត្រនេះខ្ញាល់នឹងពួកខ្លួនតទៅទៀតឡើយ ក្នុងឱកាសដែលពួកហុល្លង់ដេស៍មកនៅស្រុកខ្មែរ ជាតិនេះប្រឹងឈ្លៀតចងសម្ពន្ធមិត្តនឹងជាតិលាវដែលចុះមកស្រុកខ្មែរតាមទន្លេក្នុងរវាង ព. ស. ២១៨៥ សេចក្ដីរាប់អានស្រុកលាវ ហើយនឹងស្រុកខ្មែរនេះបានវែងឆ្ងាយណាស់ ។

ដល់ក្រោយកើតបះបោចលាចលមួយលើកក្នុងស្រុកខ្មែរ រួចទៅព្រះបទុមរាជាទី ២ បានទទួលរាជសម្បត្តិ ព្រះអង្គពុំសព្វព្រះរាជហឫទ័យនឹងជំនួញហុល្លង់ដេស់ទេ ស្តេចនេះមានព្រះទ័យឃោរឃៅកាចណាស់ ទ្រង់បានរាយធ្វើបាបព្រះរាជនុរសេតីព្រះអង្គ ដែលជារាជបុត្រស្តេចដែលសោយរាជ្យមុន អ្នកស្រុកទាំងអស់គ្នាមានសេចក្តីស្ញបកោតខ្លាចពេកណាស់ដល់ព្រះទ័យព្រះរាជនុរសទាំងពីរអង្គនេះដែលគ្មានកោតញញើតព្រះចេស្តាស្តេចបទុមរាជាទី ២ សោះ ។

ព្រះបទុមរាជាទី ២ ចូលសាសនមហាម៉ាត់ ហើយទ្រង់បានព្រះនាមថា អ៊ីប្រាហ៊ីម ដោយហេតុនេះបានជាព្រះបទុមរាជាទី ២ មានមិត្តភក្តិនឹងចាមជ្វា ដែលកាន់សាសនាមហាម៉ាត់ដូចព្រះអង្គ ពួកហុល្លង់ដេស់នឹងពួកពរទុយកែសនៅតែទាស់វែងខ្វែងគំនិតយ៉ាងធំនឹងគ្នាជានិច្ច ។

ស្តេចអ៊ីប្រាហ៊ីម ទ្រង់សព្វព្រះទ័យនឹងគ្រឿងស្រវឹងមេរ៉ាយល្បែងពាណាទាំងពួង មិនទ្រង់ព្រះសណ្តាប់យកពាក្យទុកទល្អ ៗ ទាំងឡាយ ហើយមិនព្រមឲ្យនាក់ហុល្លង់ដេស់មកឈប់ចតនៅក្រុងភ្នំពេញទៀតឡើយ កាលពីដើមស្តេចនេះព្រមឲ្យទំនិញហុល្លង់ដេស់ទាំងប៉ុន្មានរួចពន្ធទាំងអស់ប៉ុន្តែដល់ពីរបីឆ្នាំមកទៀត ទ្រង់បញ្ញត្តិឲ្យបង់ពន្ធថ្ងៃដឹកនាំទំនិញចូលមកស្រុកខ្មែរវិញ ។

ពួកក្រុមសមាគមហុល្លង់ដេស៍ ដែលនៅស្រុកខ្មែរធ្លាក់ក្នុងគ្រោះថ្នាក់មួយយ៉ាងធំ ក្នុងឱកាសដែលពួកហុល្លង់ដេស៍ចូលទៅគាល់ស្តេច គេបានសម្លាប់ពួកនេះអស់ ៣៦ នាក់ ចាប់ ៩០ នាក់ទៅដាក់គុក រឹបជាន់យកទំនិញទាំងអស់មកដាក់ទុកក្នុងរាំង ក្រុមសមាគមហុល្លង់ដេស៍ក៏លើកមនុស្សចំនួន ៤៣២ នាក់ ដែលមានសេនាទាហានចំនួន ១៦០ នាក់ និងកប៉ាល់ជាច្រើន ចេញពីក្រុងបាតាវីយ៉ា មកដើម្បីនឹងសងសឹកពួកខ្មែរវិញ នៅថ្ងៃ ៣ យូកុំង ព.ស. ២១៨៧ ពួកហុល្លង់ដេស៍មក . ប់ក្រុងភ្នំពេញ មានមន្ត្រីខ្មែរម្នាក់ឈ្មោះឧកញ៉ាពមា បានលើកកប៉ាល់ចំនួន ៥ ទៅជួបហើយសួរមេទ័ពជើងទឹកហុល្លង់ដេស៍ អំពីសេចក្តីប្រាថ្នារបស់ជាតិនេះ ហើយក៏លើកស្លួយសាអាករដែលស្តេចខ្មែរជើមកឲ្យ លុះបានបន្តិចទៅមានកប៉ាល់ខ្មែរមួយបាញ់កប៉ាល់ហុល្លង់ដេស៍ៗក៏បាញ់តបតគ្នាទៅវិញទៅមក ដល់តយុទ្ធគ្នារួចពួកទាហានជើងទឹកហុល្លង់ដេស៍កាត់ខ្សែប្រវាក់ដែលខ្មែរចងយាំងកណ្តាលទន្លេបាន ប៉ុន្តែកប៉ាល់របស់ហុល្លង់ដេស៍ខូចខាតអន្តរាយច្រើនណាស់ ក៏បើកត្រឡប់វិលមកស្រុកជ្វាវិញ ពួកហុល្លង់ដេស៍អបរាជ័យចាញ់ខ្មែរ ការសងសឹកព្យាបាទក៏ពុំបានសម្រេចដូចសេចក្តីប្រាថ្នាឡើយ ។

ស្តេចស្រុកខ្មែរទ្រង់គិតធ្វើឲ្យជាតិទាំងពីរនេះ បានស្រុះស្រួលនឹងគ្នាវិញ កាល ព.ស. ២១៨៨ មានសំពៅចិនមួយនាំមនុស្សទោសហុល្លង់-

ដេស៍ពីរនាក់ និងសារមួយពីស្ដេចខ្មែរ ឲ្យយកទៅជូនលោកគូវែរណេរ-ស៊ែណេរ៉ាល់នៅក្រុងបាតាវីយ៉ា ក្នុងសារនោះមានសេចក្ដីថា ស្ដេចខ្មែរដែលបានធ្វើចម្បាំងនេះគ្រាន់តែការពារខ្លួនប៉ុណ្ណោះទេ ដោយហេតុហុល្លង់-ដេស៍នាំបង្កើតហេតុមុន ឲ្យនគរខ្មែរចៀសផុតពីសង្គ្រាមនេះពុំបាន លោកគូវែរណេរស៊ែណេរ៉ាល់ក្រុងបាតាវីយ៉ា បានឆ្លើយតបមកមហាក្សត្រខ្មែរវិញថា បើប្រសិនណាជារាជការខ្មែរបើកលែងអ្នកទោសហុល្លង់ដេស៍ទាំងប៉ុន្មានព្រមទាំងទ្រព្យសម្បត្តិដែលរឹបជាន់យកទៅ ឲ្យមករាជការហុល្លង់ដេស៍វិញ នោះរាជការហុល្លង់ដេស៍នឹងលែងទាក់ទាពីការដែលខ្មែរពិឃាដសម្លាប់ជាតិហុល្លង់ដេស៍ទាំងប៉ុន្មានកាលជាន់មុននោះ ដល់ពេលក្រោយដែលបានធ្វើកិច្ចសញ្ញានឹងគ្នាជាច្រើនលើក នោះរាជការខ្មែរក៏បានបើកលែងអ្នកទោសហុល្លង់ដេស៍២៩នាក់ បញ្ជូនទៅក្រុងបាតាវីយ៉ាឲ្យរាជការហុល្លង់ដេស៍វិញ ក្រុមសមាគមហុល្លង់ដេស៍គិតលើកទ័ពមកកំហែងវាយស្រុកខ្មែរម្ដងទៀត ពីព្រោះរាជការខ្មែរមិនបានប្រគល់របស់ដែលរឹបជាន់ឲ្យវិញ ហើយគិតចង់ឲ្យនគរខ្មែរនិងនគរសៀមកើតទាស់ទែងនឹងគ្នាផង ទើបវាយខ្មែរបានដោយងាយ រាជការហុល្លង់ដេស៍ចង់ចងសម្ពន្ធមិត្តនឹងរាជការសៀមពុំកើតឡើយ ហើយមកគិតថាបើឲ្យមានចម្បាំងទៀត នឹងនាំឲ្យខាតផលប្រយោជន៍ជំនួញខ្លាំងណាស់ ។

ចំណែកខាងពាណិជ្ជករខ្មែរ មានចិត្តប្រាថ្នាចង់ឲ្យតែការជំនួញទំនិញ កណ្ដាប់ចេញចូលរបស់ប្រទេសទាំងពីរនេះបានស្រួលដូចពីដើមវិញ កាល ព.ស. ២១៩៧ នគរទាំងពីរនេះរាប់អានគ្នាមាំមួនជាថ្មីវិញទៀត ហើយបានចុះសញ្ញានឹងគ្នាជាច្រើនប្រការ មានសេចក្ដីសញ្ញាមួយថា តាំងអំពីថ្ងៃនេះតទៅ បើកឲ្យតែស្រុកហុល្លង់ដែសមួយនេះទេមកធ្វើជំនួញនៅស្រុកខ្មែរ មហាក្សត្រខ្មែរទ្រង់គាំពារពាក្យបាលសមាគមហុល្លង់ដែសនេះ មានសេចក្ដីសុំរបស់ហុល្លង់ដែសច្រើនកន្លែង ដែលពាណិជ្ជករខ្មែរទទឹងទាស់ ហើយកែប្រែចោលចេញ កិច្ចសញ្ញាទាំងប៉ុន្មាននេះ បានធ្វើនៅក្នុងដំណាក់ដៃ ដែលស្ដេចខ្មែរគង់នៅទីនោះ ។

ប៉ុន្តែមិនបានជាយូរប៉ុន្មានទេ មានជាតិអង់គ្លេសនឹងដាណូរចូលមករកស៊ីប្រកួតប្រណាំងតតាំងនឹងពួកហុល្លង់ដែសដែលនៅស្រុកខ្មែរ ។

ដល់ ព.ស. ២២០១ មានក្សត្រមួយអង្គព្រះនាមអ្នកព្រះបទុមនាំបណ្ដារាស្ត្របះប្រាំងនឹងស្ដេច អ៊ីព្រាហ៊ីម ដោយស្ដេចនេះមានព្រះទ័យកាចមារយាទអាក្រក់ ព្រះអយ្យកោព្រះអង្គម្ចាស់អ្នកព្រះបទុម បានសោយរាជ្យនៅស្រុកខ្មែរ ហើយគេពិឃាតចោលទៅក្នុង ព.ស. ២១៨៥ ក្នុងវេលាដែលបះបោរបលនោះ ការជំនួញនៅស្រុកខ្មែរក៏សាបសូន្យទៅ អ្នកព្រះបទុមយល់ឃើញថា ខាងស្ដេចអ៊ីព្រាហ៊ីមមានកម្លាំងជាង ក៏ទៅពឹងស្រុកយួនឲ្យមកជួយ ស្រុកយួនទើបនឹងវាយដណ្ដើមបានស្រុក

ចាមមកថ្មី ៗ ស្ដេចអ៊ីព្រាហ៊ីមបរាជ័យជាប់ទោសគេដាក់ក្នុងទ្រុងបញ្ជូនទៅស្រុកយួនហើយសុគតនៅក្នុងស្រុកនោះទៅ ។ នគរយួនហើយនឹងនគរសៀមក៏បានលើកអ្នកព្រះបទុមដែលជាមិត្តរបស់ខ្លួន ឲ្យឡើងសោយរាជសម្បត្តិស្រុកខ្មែរ ថ្វាយព្រះនាមជាព្រះបទុមរាជាទី ៣ ពួកសេនា-ទាហានយួនវាយប្លន់ភូមិហុល្លង់ដេស៍ខ្ទេចខ្ទីអស់ មេកងទ័ពយួនបានផ្ញើលិ-ខិតមួយទៅឲ្យរាជការស្រុកបាតាវីយ៉ា ថ្លែងអំពីសេចក្ដីស្ដាយដោយសេនា-ទាហានបានធ្វើអំពើទុច្ចរិតនេះ ។

ដល់ ព. ស. ២២០៧ មានកប៉ាល់ហុល្លង់ដេស៍មួយចូលមកដល់ក្រុងភ្នំពេញ ស្ដេចខ្មែរបានអនុញ្ញាតឲ្យពួកហុល្លង់ដេស៍តាំងភូមិមួយថ្មីទៀត ហើយបានធ្វើសេចក្ដីសញ្ញាថ្មីមួយវិញទៀតផង ស្ដេចខ្មែរបានសូមឲ្យរាជការហុល្លង់ដេស៍នៅក្រុងបាតាវីយ៉ាផ្ញើកាំភ្លើងធំ នឹងមួកមួយរាងតាមបែបសម័យថ្មី មានស្លាបសត្វជាគ្រឿងលំអមកថ្វាយ ហើយទ្រង់បានផ្ញើកំញានទឹងឈើមួយមុខយ៉ាងល្អ ទៅជូនលោកគូវែរណឺរសេណេរ៉ាល់ក្រុងបាតាវីយ៉ា ប៉ុន្ដែការជំនួញហុល្លង់ដេស៍នៅស្រុកខ្មែរនៅក្នុងសេចក្ដីលំបាកវេទនា ដោយមានពួកអេស្ប៉ាញ៉ុលមកដណ្ដើមរកស៊ីដែរផង មួយវិញទៀត ពួកហុល្លង់ដេស៍បែកសមគ្គីសមគ្គា ទាស់ទែងខ្វែងគំនិតគ្នាឯង ក៏បំបាត់មន្ទីរជំនួញរបស់ខ្លួនដែលនៅស្រុកខ្មែរចោលចេញទៅ ។

តាំងពី ព. ស. ២២១១ គ្មានកប៉ាល់ហុល្លង់ដេស៍មួយសោះចូលមក កាន់នគរកម្ពុជា ដោយសារនគរនេះ មានកើតចលាចល មានព្រះអង្គម្ចាស់មួយអង្គត្រូវជាព្រះសុណិសានៃព្រះបទុមរាជាទី ៣ បានសម្លាប់ស្ដេចនេះចោលចេញ ឡើងសោយរាជសម្បត្តិទ្រង់ព្រះនាមជាព្រះជ័យ-ជេស្ឋាទីបី ។ បានកំហែងបង្ខំព្រះអគ្គមហេសីរបស់ព្រះបទុមរាជាទី ៣ យកមកធ្វើជាព្រះអគ្គៈទេវី ។ នេះ បានប្រើពួកចាមឲ្យពិឃាដសម្លាប់ព្រះជ័យ-ជេស្ឋាទី ៣ ចោលទៅ ព្រះជ័យជេស្ឋាទី ៣ បានសោយរាជសម្បត្តិចំនួន ៥ ខែប៉ុណ្ណោះទេ តាំងអំពីនោះមកការប្រាស្រ័យពឹងពាក់ស្រុកខ្មែរនឹងស្រុកផ្សេងគ្រាន់តែជាគំរប់ការ មិនបានស្និទ្ធស្នាលដូចជាន់មុនឡើយ ពួកយួនលើកគ្នាវាយស្រុកខ្មែរ ៗ ចាញ់យួន ក៏លើកស្រុកកូសាំងស៊ីនឲ្យទៅយួនទៅ តាំងអំពីនោះមក ជំនួញខ្មែរហើយនឹងហុល្លង់ដេស៍ក៏ខានចេញចូលកាន់គ្នាទៅវិញទៅមករហូតដល់សព្វថ្ងៃនេះ ។

# ព្រះពុទ្ធរូបសម័យផ្សេងៗ

កាលពីខែសេបតមប្រ៍ ឆ្នាំ ១៩៣៨ នៅស្រុកប្រ៊ុកសែល ជាទីក្រុងនៃប្រទេសបេលស៊ិក ស្រុកនេះជាស្រុកតូចតាំងនៅខាងជើងស្រុកបារាំង ។ ស្រុកនេះហើយជាទីប្រជុំដ៏សំខាន់មួយ ដែលមានការមករួបរួមប្រជុំគ្នានៃបណ្ដាបុគ្គលគ្រប់ៗប្រទេសក្នុងលោក ដើម្បីពិគ្រោះការងារជាមួយគ្នាអំពីប្រស្នាផ្សេងៗ ដែលទាក់ទងនឹងចំណែកទិសខាងកើត ។

មានអ្នកប្រាជ្ញបារាំងសែសម្នាក់ឈ្មោះលោក ហ្វីយេរ្យូសាត៍ បានពោលថ្លែងអំពីកិច្ចការរបស់អ្នកប្រាជ្ញ ១ រូបប៉ែកខាងព្រះពុទ្ធសាសនាលទ្ធិមហាយានឈ្មោះលោក នាគាជុន៌ ជាអ្នកប្រាជ្ញល្បីល្បាញ លោកអ្នកប្រាជ្ញនេះបានតែងគម្ពីរពេទ្យសាស្ត្រនិងគម្ពីរញែកធាតុ ផ្សំធាតុ ជាភាសាសំស្ក្រឹតដែលគេអាចនាំទៅប្រៀបផ្ទឹមនឹងអ្នកប្រាជ្ញ ១ រូបនៅខាងទក្សិណទិសនៃស្រុកឥណ្ឌា "អយស្ព្យៈ" ជាអ្នករៀបចំតែងគម្ពីរពេទ្យសាស្ត្រ និងគម្ពីរញែកធាតុផ្សំធាតុដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកសៀមនិងស្រុកខ្មែរកាលពីជាន់ដើម ។

លោកអ្នកប្រាជ្ញទាំងពីររូបនេះបានតែងគម្ពីរ មានសេចក្ដីជាគោលសំខាន់ៗដូចគ្នាអំពីវេជ្ជបិត្តសាស្ត្រនិងវិទ្យាសាស្ត្រ នៃប្រទេសឥណ្ឌា ហើយគម្ពីរទាំងពីរនេះមិនមានរឿងរ៉ាវខាងសាសនាលាយសោះឡើយ ។

មានជនជាតិអង់គ្លេសម្នាក់ឈ្មោះឡឺម៉ៃដែលធ្លាប់នៅស្រុកសៀមជាវេលាយូរ បាននិយាយអំពីពង្សាវតារនៅសម័យផ្សេងៗនៃស្រុកសៀមនេះ ដែលលោកឡឺម៉ៃបានឃើញគ្រឿងចម្លាក់ចេនាផ្សេងៗ ដែលមាននៅក្នុងស្រុក ហើយមានប្រយោជន៍ដល់អ្នកមើលរឿងនេះឲ្យទៅក្នុងស្រុកខ្មែរ ។ ឯសេចក្ដីតទៅនេះជាសេចក្ដីសង្ខេបខ្លីៗទេ ។

១ សម័យមុនពុទ្ធសករាជ ៩៤៣-១៥៤៣ — បែបចំឡាក់ចេនាជាន់បុរាណច្រើនជាងគេដែលមាននៅស្រុកសៀមនោះជាចំឡាក់បែបមន ។ ពួកមននេះមកអំពីប្រទេសភូមាក្រោម (Basse Birmanie) កំណើតដើមនៅមាត់សមុទ្រ (ស្រុកតណ្ហោ) ខាងកើត ។ ក្បាច់ចេនារបស់មននេះសុទ្ធតែមានកិនភាគបែបឥណ្ឌូ តាំងអំពីសម័យនៃពុទ្ធសករាជ ៨៤៣ ដល់ ៩៤៣ ក្រោយមកទើបគេស្គាល់ព្រះនាមនៃវង្សស្ដេចមននេះ តាំងអំពីកាលនៅ (ស្រុកតណ្ហោ) គឺក្នុងសម័យ "ក្សេត្រគុប្ត:" នៅប្រទេសប៉ែកខាងជើង ។

២ សម័យខ្មែរ ពុទ្ធសករាជ ១៥៤៣ ដល់ពុទ្ធសករាជ ១៧៩៣ — តាំងអំពីពុទ្ធសករាជ ១៥៤៣ មក ពួកខ្មែរបានរាតត្បាតអំណាចឲ្យរីកចេញទៅ ក្រោយដែលបានតាំងក្រុងនៅទីក្រុងអង្គរ ប្រទេសកម្ពុជា ។ កាលក្នុងពុទ្ធសករាជ ១៧៤៣ ស្រុកសៀមកណ្ដាលនៅក្នុងអំណាចមហាអាណាចក្រខ្មែរនៅឡើយ ។ មានឧបរាជមួយអង្គគង់នៅក្រុងលពបុរីជាទីប្រជុំជាន់បុរាណ

ប្រកាន់តាមអារ្យធម៌របស់មន ក្រុងលពបុរីនេះនៅជាខាងជើងក្រុងបាងកក ចម្ងាយ ៨០ ម៉ាយល៍ (80 miles ខ្នាតរបស់អង់គ្លេសមួយយ៉ាង គានថាម៉ៃ ក្នុង ១ ម៉ៃប្រហែល ១.៥០០ ម៉ែត្រ) ។ នៅទីនោះមានសាលាបង្រៀនចម្លាក់បែបខ្មែរ ១ យ៉ាង ប៉ុន្តែមានបែបភាពប្លែកផ្សេងពីក្បាច់ចម្លាក់ដែលមាននៅក្នុងស្រុកខ្មែរ ។

បែបភាពព្រះពុទ្ធរូបខ្មែរមានទ្រង់ទ្រាយជាភេទបុរស ឃើញស្តែងជាងព្រះពុទ្ធរូបដែលធ្វើដោយស្នាដៃមន ។ ពួកខ្មែរច្រើនប្រើដីពេជ្រទឹងសំរិទ្ធសាងព្រះ ប៉ុន្តែរូបធ្វើពីសំរិទ្ធធ្លាប់មានតែព្រះអង្គតូចៗ ហើយដំកល់ទុកបូជានៅផ្ទះ ។

៣ — សម័យធៀងសែន ព. ស. ១.៦៤៧ ដល់ ១.៧៤៧ — តាំងអំពីពុទ្ធសករាជ ១៣៩៣ នោះពួកថៃ (សៀម) មានលំនៅដើម (ស្រុកកំណើត) នៅស្រុកចិនខាងត្បូង ហើយមកតាំងស្រុកទេសថ្មីនៅស្រុកលាវ-សៀមខាងជើង កាលពី ព. ស. ១.៦០០ នោះមហាក្សត្រជាតិភូមា ព្រះនាមអនុរុទ្ធមហារាជទី ១ ទ្រង់មានស្ពានមេត្រីនឹងស្តេចព្រះនាមបលៈ ស្រុកកណ្ដៀនៅខេត្តពិហារ ក្សត្រភូមាអង្គនេះទ្រង់បានព្រះពុទ្ធរូបបែបថ្មី ១ អង្គ នាំមកដំកល់ទុកនៅប្រទេសភូមា ហើយវេលានោះនៅខាងជើងស្រុកសៀម ក្នុងតំបន់ដែនធៀងសែននោះ មានរូបសំរិទ្ធជាចំនួនច្រើនដែលគេបានកសាងឡើងក្នុងសម័យនោះ ។

**៤ — សម័យសុខោទ័យប្រហែលពី ព. ស. ១.៧៤៣ ដល់ ព. ស. ១.៨៤៣—** គឺកាលពី ព. ស. ១.៧៩៣ ដែលពួកថៃ (សៀម) តាំងប្រទេសអាណាចក្រនៅស្រុកហៅថា សុខោទ័យ ទីងស្ងួតលោក (សៀមអានថា ស៊ុនខុះលោក) មួយទៀត ទុកដូចជាទីក្រុងដែរ ។ ឯបែបសិល្បកម្មក្នុងសម័យនោះ បានទទួលបែបភាពច្នៃដែលបានមកពីកោះលង្កា ហើយបែបផែនព្រះពុទ្ធរូបថ្មីនេះក្លាយទៅជាបែបសិល្បកម្មយ៉ាងវិចិត្រជារបស់សៀម ដែលប្លែកយ៉ាងស្រឡះពីបែបខ្មែរដោយមានរង្វង់ព្រះភក្ត្រទម្រង់ពងក្រពើ មានព្រះកូមា (បំពេញ) កោងដូចជារង្គ្វ ហើយមានព្រះអាការជាគ្រឿងសំដែងភាពបែបផែនព្រះពុទ្ធរូប ។

អស់ពួកលោកដែលដើរប្រកាសសាសនា បានដើរផ្សាយបែបសិល្បកម្មពុទ្ធសាសនាថ្មីនេះចូលទៅស្រុកសៀម តាំងអំពីខាងជើងទៅខាងត្បូង ។

**៥ — សម័យអ៊ូថង អំណាចខ្មែរនឹងសៀម ប្រហែលជាក្នុង ព. ស. ១.៧៤៣ ដល់** ១.៨៤៣ — ក្នុងចំណែកដែនលពបុរី មានពេលខ្លះគង់ទ្រង់នៅមិនធ្លាក់នៅក្នុងអំណាចស្រុកសុខោទ័យ ហើយក្នុងសម័យនោះ ទុកដូចជាឈ្មោះក្រុង ១ ដែលនៅខាងលិចស្រុកអយុធ្យា ។ បណ្ដារូបដែលធ្វើពីសំរិទ្ធក៏ផ្ដើមកើតមានឡើងតាមបែបផែនខ្មែរ ច្រើនជាងបែបជារបស់សៀម ប៉ុន្តែតបន្តិច ៗ មក គេក៏កែប្រែទៅតាមគំនិតយោបល់ជាបែបសៀមវិញ ។

**៦ — សម័យសៀមអយុធ្យាពី ព. ស. ១.៦៩៣ ប្រហែលដល់ទៅ ព ស. ២.១៤៣-**

ក្នុង ព.ស.១.៨៩៣ ក្សត្រនៃស្រុកអ៊ូថងបានកតាំងទីក្រុងថ្មីនៅស្រុកអយុធ្យា ហើយភ្ជាប់ទាំងស្រុកសុខោទ័យ (មកជាចំណុះផង) ។ ការចំឡាក់លើផ្ទាំងថ្មនៅស្រុកលុពបុរីក៏នៅមាននៅឡើយ ប៉ុន្តែបែបរចនាយ៉ាងល្អៗជាច្រើនអំពីដើមរលត់រលាយទៅក៏ពិតមែន តែបានឲ្យកំណើតដល់បែបសិល្បកម្មទំនើបថ្មីជារបស់សម្រាប់ជាតិ ដោយបង្កើតសាលាបង្រៀនដែលឈ្មោះថាសាលាអយុធ្យាឡើង ។

អំណាចបែបផែនខ្មែរនៅមានជាប់ដិតៈនៅទឹងគ្រឿងលំអរនៃគ្រឿងកសាងទឹងរូបផ្សេងៗខ្លះ ហើយមានរូបសំរិទ្ធិជាច្រើនទឹងរូបធ្វើពីឈើក៏មានច្រើនដែរ ។

លោកការិតកាល់ ដែលជាអ្នកគាស់កកាយរុករកក្នុងស្រុកម៉ាឡាយូ បានផ្ញើសេចក្តីរាយការមួយទៅជូនក្រុមជំនុំនានាជាតិបំណែកបូរាណប្រទេសពិនិត្យមើល នោះមានសេចក្តីថា គេបានរកឃើញរឿងរ៉ាវខាងពុទ្ធសាសនាដែលឆ្លាក់ទុកនៅទឹងសិលាចារឹកជាន់ចាស់ ទឹងបណ្តុំព្រះដែលគេទំពិនិត្យមើលនៅវេលានេះ នៅត្រង់កន្លែងនេះដើម្បីឲ្យបានដឹងថាបណ្តាបោរាណវត្ថុផ្សេងៗ (ដែលជាសម្បត្តិពុទ្ធសាសនា) ដែលគេបានរកឃើញតើនៅក្នុងសម័យណា ។

ពង្សាវតារ ប្រទេសអេស៊ីថ្មី

មហាញ៉ុក-ថៃម

# ប្រែចេញពីប្រវត្តិសាស្ត្រសាកល
# របស់ហ្លួងវិចិត្រវាទការរដ្ឋមន្ត្រីនៃប្រទេសថៃ

(នៅមានត)

ពង្សាវតារសង្ខេប

## ប្រទេសអេស៊ីប្ដ៍ (L'Egypte)

ប្រទេសអេស៊ីប្ដ៍ ជាប្រទេសមានសេចក្ដីចំរើនរុងរឿងប្រមាណជាងប្រាំពីរពាន់ឆ្នាំមកហើយ ដរាបមកដល់សម័យបច្ចុប្បន្ននេះក៏នៅមានថាវរវត្ថុជាគ្រឿងសំដែងឲ្យយើងមើលឃើញសេចក្ដីព្យាយាមប៉ុនប៉ៅ នឹងចំណេះយ៉ាងខ្ពង់ខ្ពស់ របស់ប្រជាជនជាតិនោះយ៉ាងប្រាកដច្បាស់ក្នុងលោក ។ ដោយហេតុប្រទេសអេស៊ីប្ដ៍ មានសេចក្ដីចំរើនរុងរឿងខាងការរចនា ការកសាង ការគ្រប់គ្រង នឹងវិទ្យាសាស្ត្រប្រភេទខ្លះ ជាប្រទេសពេញទៅដោយរឿងស្ងាត់កំបាំង ហើយជីវិតរបស់ប្រជាជនច្រើនប្រកបដោយសេចក្ដីក្សេមក្សាន្ត មានជួនកាលការប្រឌិតតែងរឿងឡើងថ្មីខ្លះនៅតែមិនល្អវិសេសជាងរឿងពិតដែលមានក្នុងពង្សាវតាររបស់អេស៊ីប្ដ៍ ដូចជារឿងព្រះនាងគ្លេអូប៉ាត្រ ជាស្ត្រីមានលំអយ៉ាងឆើតឆោមបំផុត ត្រាតែមេទ័ពសេសារ៍ដែលជាមនុស្សមានចិត្តប៉ឹងរឹងស្មើដែក បែរជាទន់ភ្លន់កាន់តាំងស្មារតី ហើយសូម្បីព្រះនាងមាននោមល្អឯកទិវង្គតទៅជាច្រើនពាន់ឆ្នាំមកហើយក៏ដោយ ក៏នៅតែមានគេយកចិត្តទុកដាក់ចង់ដឹងរឿងរ៉ាវរបស់ព្រះនាង ដូចជាហ្សង់ប៉ូលីយ៉ុង ជាជាតិបារាំងសែសមួយដែលមានកេរ្ដិ៍ឈ្មោះល្បីល្បាញ ដោយហេតុយកចិត្តទុកដាក់មើលអក្សរ

អេស៊ីប្ដ៍បុរាណដាច់ ព្រោះតែមានសេចក្ដីចាប់ចិត្តនឹងលំអរបស់ព្រះនាងនេះឯង ហើយខំព្យាយាមមើលអក្សរអេស៊ីប្ដ៍បុរាណត្រាតែសម្រេច ដើម្បីការរកប្រវត្តិរបស់ព្រះនាងឲ្យបានដឹងសព្វគ្រប់ ។

ប្រទេសអេស៊ីប្ដ៍និងទន្លេនិល. — ប្រទេសនេះ តាំងនៅក្នុងទ្វីបអាហ្វ្រិកខាងទិសឦសានជាប់នឹងទ្វីបអាស៊ីតាមព្រែកជីកស៊ុយអេស (Suez) អា-ណាខេត្តទិសខាងជើងទល់នឹងសមុទ្រម៉េឌីតែរ៉ាណេ (la Méditerranée) ទិសខាងកើតទល់នឹងសមុទ្រក្រហម (la mer Rouge) ចំណែកខាងលិចនឹងទិសខាងត្បូងទល់នឹងសមុទ្រខ្សាច់តាំង ២ ទិស ។ ប្រទេសអេស៊ីប្ដ៍នេះបែងចែកចេញជា ២ ចំណែក ៗ ដែលនៅលើមាត់ទន្លេនិល (le Nil) ខាងលើហៅថា អេស៊ីប្ដ៍ខ្ពស់ ព្រោះផែនដីចំណែកនេះនៅលើទីខ្ពស់ ។ ឯចំ-ណែកខាងមាត់ទន្លេនិលជិតផ្លូវចេញទៅសមុទ្រម៉េឌីតែរ៉ាណេ ហៅថាអេស៊ីប្ដ៍ក្រោម ជាទីដែលទន្លេនិលបង្ហូរទឹកចាក់ល្បាប់មកចោលទុកជាយូរអង្វែងជាវេលាច្រើនពាន់ឆ្នាំ ហើយកន្លែងនេះក៏កាន់តែរីកធំឡើង ៗ ជាលំ-ដាប់ ទៅជាដីពកធំបម្រើម ។ នៅចំណែកខាងលើជាទីទួលខ្ពស់មានសណ្ឋានជាជ្រុងដូចតួ V ចំណែកខាងក្រោមមានសណ្ឋានរីងលយទៅទល់នឹងសមុទ្រ មានសណ្ឋានជា ៣ ជ្រុង ទើបគេហៅថា ដែលតា (Delta) ដែលតា គឺតួ D របស់ក្រិកគេសរសេរជារូប ៣ ជ្រុង ។

ទន្លេនីលជាសរសៃជីវិតរបស់អេស៊ីប្ត. — ប្រទេសអេស៊ីប្តនេះ ជាប្រទេសមានទឹកភ្លៀងតិចណាស់ លោកអ័ល្បែរមាលេត៍ជាអ្នកប្រាជ្ញពង្សាវតារបារាំងសែសពោលទុកថា ភ្លៀងធ្លាក់នៅប្រទេសអេស៊ីប្ត១០០ឆ្នាំ មិនប្រហែលទឹកភ្លៀងដែលធ្លាក់នៅក្រុងប៉ារីស ១ ឆ្នាំទេ ។ ទុកជាប្រទេសអេស៊ីប្តមានចំនួនទឹកភ្លៀងតិចដល់ម្ល៉េះក៏ដោយ ក៏នៅតែគេអាចធ្វើស្រែចំការច្បារដំណាំល្មមចិញ្ចឹមជីវិតប្រជាជនបាន ដោយអាស្រ័យទន្លេនីលមួយដែលហូរកាត់ប្រទេសអេស៊ីប្ត បើទឹកទន្លេនេះជោរជន់ឡើងហៀរហូរទៅលិចដល់តំបន់ណា ផ្ទៃផែនដីដែលក្រៀមក្រស់ក្នុងតំបន់នោះ ក៏ប្រែត្រឡប់ជាស្រស់បស់មានជីជាតិល្អឡើង ហើយគេអាចដាំដំណាំនានាបានទាំងអស់ ប្រសិនបើប្រទេសនេះមិនបានអាស្រ័យទឹកទន្លេនីលនេះហើយ ប្រទេសអេស៊ីប្តទាំងមូលនឹងក្លាយទៅជាសមុទ្រខ្សាច់ ដែលមនុស្សនឹងសត្វនានាមិនអាចអាស្រ័យនៅទីនោះបានឡើយ ។ វេលាដែលទឹកលិចផែនដីប្រទេសអេស៊ីប្តនោះចំនួន ៤ ខែគឺតាំងពីខែអ៊ូតដល់ខែសេបតមប្រ៍ ។

តាមធម្មតា ប្រទេសអេស៊ីប្តនេះ មានអាកាសហែងស្ងួតក្រៀមផែនដី តាំងពីខែម៉ារ្សដល់ខែយូកាំង ក្នុងរវាងនេះ ទឹកទន្លេនីលស្រកចុះទៅនៅត្រឹមពាក់កណ្តាលមាត់ច្រាំង ហើយទឹកថ្លាស្អាតទើបក្លាយទៅជាមានពណ៌ខៀវ ក្នុងខណៈដែលទឹកកាន់តែរីងស្ងួតទៅនោះ ក៏មានខ្យល់

បក់យកកំដៅពីសមុទ្រខ្សាច់មកធ្វើឲ្យព្រឹក្សជាតិផ្សេងៗ ស្ងួតក្រៀមទៅអស់ ទន្លេនីលកាន់តែហែងហួតទៅ ទឹកក៏កាន់តែមានសម្បុរខៀវខ្លាំងឡើងរហូតដល់ពាក់កណ្ដាលខែស៊ីយេត សម្បុរទឹកទន្លេនីលទើបប្រែផ្លាស់ពណ៌ខៀវក្លាយជាសម្បុរក្រហមបន្តិចៗ ឡើងវិញ ជាសញ្ញាឲ្យដឹងថា ទឹករៀបឡើងហើយ ដោយមានជំនន់ហូរធ្លាក់ចុះមកពីទីដទៃ ទាំងបក់ជញ្ជូនយកល្បាប់លាយនឹងដីខ្សាច់មកដាក់ក្នុងទន្លេនីល ទើបធ្វើឲ្យទឹកទន្លេផ្លាស់ពណ៌ៗ ក្នុងវេលានេះប្រជាជនអេស៊ីប្ដបានបើកទំនប់បង្ហូរទឹកឲ្យលិចទៅលើទីតម្បន់ផ្សេងៗ ដើម្បីធ្វើឲ្យដីមានជីជាតិល្អឡើង លុះដល់ខែអុំតូទឹកក៏ដោរជន់ឡើងពេញជំនន់ លិចទីតម្បន់នានាទាំងសងខាងមាត់ទន្លេ លុះដល់ខែដេសម្ប៊ែទឹកក៏តាំងស្រកទៅវិញ ៈទុកសល់តែល្បាប់ដីដែលមានជីជាតិៗ ខណៈនេះហាក់ដូចជាធម្មជាតិនឹងមនុស្ស, សត្វទាំងឡាយ ទើបក្រោកឡើងពីដេកលក់ ប្រជាជនក៏នាំគ្នាព្រោះសាបនឹងដាំដំណាំនានាជួនកាលគេលែងសត្វឲ្យដើរជាន់ពន្លិចគ្រាប់ដំណាំដោយមិនបាច់ភ្ជួរៗ ស្រែនឹងសណ្ដែកទាំងឡាយ ក៏ដុះលូតលាស់ឡើងដោយរួសរាន់ បណ្ដាមនុស្សទាំងឡាយក៏មានចិត្តសប្បាយរីករាយគ្រប់គ្នា ភូមិប្រទេសក៏មានពណ៌ខៀវស្រស់ ហើយត្រឡប់ប្រែប្រួលទៅវិញជាដាប់ ការប្រែប្រួលដូច្នេះ រមែងមានរហូតរៀងកាល មានមេទ័ពជាតិអារ៉ុបម្នាក់ឈ្មោះអមរុ

ពោលទុកថា "ប្រទេសអេស៊ីប្ដនោះ ក្នុងវេលាដំបូងជាទីវាលមានតែអាចម៍ដីហុយដេរដាស តមកជាទន្លេសាប ហើយក្លាយទៅជាសួនច្បារ" ៗ

ដែល.ពាលមកនេះ ប្រទេសអេស៊ីប្ដចិញ្ចឹមជីវិតដោយទឹកទន្លេនីលតែមួយនេះឯង ៗ មួយវិញទៀត ទន្លេនីលនេះជាទីអាស្រ័យរបស់សត្វតូចធំដូចជាត្រី, ក្រពើ និងរមាសទឹក (hippopotames) ហើយតាមមាត់ទន្លេមានដើមឈើមួយយ៉ាងគឺដើមប៉ាពីរុសដែលគេធ្លាប់ប្រើសម្បកវាធ្វើជាក្រដាសបណ្ដោះអាសន្នក្នុងគ្រានោះ ដល់មកក្នុងសម័យនេះ គេប្រើធ្វើជាក្រដាសបានតែម្ដង ក្រៅពីនេះ នៅមានឈូកដែលគេយកគ្រាប់វាធ្វើជាអាហារយ៉ាងសំខាន់ម្យ៉ាងទៀតផង ៗ

ហេតុដែលមានទឹកជោរនាចមិនបាច់មានទឹកភ្លៀងនេះ ជនជាតិអេ-ស៊ីប្ដក៏មានសេចក្ដីជឿងឆ្ងល់អស្ចារ្យណាស់ កាលបើរកពាក្យអធិប្បាយមិនឃើញ ទើបគេសន្មតជានិទានរឿងព្រេង ដែលគេតែងបង្រៀនគ្នាតមកថា ទន្លេនីលនេះជាទឹកភ្នែករបស់ព្រះ អ៊ិស៊ិស ដែលទ្រង់ព្រះកន្សែងសោកស្ដាយអាល័យព្រះស្វាមី ជាព្រះប្រចាំទន្លេនេះប៉ុណ្ណោះ ប្រជាជនតែងបន់ស្រន់បួងសួងជានិច្ច មានបទភ្លេងឬមន្ដសម្រាប់សូត្រសរសើរដែលគេចេះចាំតគ្នាមកដល់ឥឡូវនេះថា :

ឱ ! ខ្ញុំសូមនមស្ការ ព្រះនីលជាម្ចាស់ ដែលទ្រង់ឧបត្តិឡើងទ្រង់ជួយស្រោចស្រង់ជីវិតប្រទេសអេស៊ីប្ដយ៉ាងស្ងាត់ៗ ទ្រង់ប្រទានទឹកឲ្យហូរ

លិចទៅគ្រប់អន្លើ ព្រះអង្គជាព្រះនៃដំណាំនានា, ជាព្រះនៃសត្វទឹក, ជាព្រះនៃធញ្ញាហារគ្រប់យ៉ាង, ទ្រង់ធ្វើឲ្យពិភពពេញទៅដោយសេចក្ដីសុខសំកន្ត, ធ្វើឲ្យផ្លែពស្ដុជាផ្អែតផ្អូន, អវយវៈគ្រប់យ៉ាងបានទទួលអាហារ, ធ្វើឲ្យធ្មេញគ្រប់ៗ ចំរើកមានរបស់ទំពារ, ធ្វើឲ្យស្មៅមានពណ៌ខៀវស្រស់ជាអាហាររបស់សត្វ, ចាត់វករបស់របរជាគ្រឿងសែនបួងព្រះអង្គឯទៀតៗ ជាជង្រុកបំពេញសេចក្ដីសុខក្សេមក្សាន្តនៃអ្នកទីទ័លក្រ ។

ជាវេលាជាង ៣.០០០ ឆ្នាំ ដែលជនជាតិអេស៊ីប្ដ៍ទៅជឿប្រកាន់ថា ហេតុដែលទឹកទន្លេនីលឡើងចុះជន់លៀងប្រទេសអេស៊ីប្ដ៍រហូតមកនេះ ដោយអំណាចព្រះជាម្ចាស់ គេទើបតែនឹងដឹងច្បាស់កាលពីពុទ្ធសករាជប្រហែល ៥០០ ឆ្នាំ (រវាង ២.០០០ ឆ្នាំមកហើយ) គឺគេយល់ថា សេចក្ដីពិត ហេតុដែលធ្វើឲ្យទន្លេនីលមានទឹកជោរជន់ឡើងនេះព្រោះនៅខាងលើទន្លេនេះមានទន្លេសាបធំមហិមាដល់ទៅពីរអន្លើទាំងពីរតំបន់នេះមានភ្លៀងធ្លាក់ច្រើនផង មានទឹកហូរច្រោះដីជាប្រឡាយតូចធំគ្គុំគ្នាជាដងទន្លេធំឡើង ។

កាលបើយើងពិនិត្យមើលតទៅទៀតនឹងឃើញថា ទន្លេនីលនេះមិនមែនត្រឹមតែជន់លៀងប្រជាជនឲ្យមានជីវិតរស់នៅប៉ុណ្ណោះទេ ទន្លេនីលជាទីកើតនៃសាសនា, ធម្មក្រិត្យា ជាគ្រឿងអប់រំចិត្តគំនិតរបស់ជនជាតិ

អេស៊ីប្ដទៀតផង កាលបើយើងសិក្សាឲ្យស្គាល់លក្ខណៈរបស់ទន្លេនីល ដែលមានបណ្ដោយដល់ទៅ ៦.៤០០គីឡូម៉ែត្រនេះហើយ ទើបធ្វើឲ្យយើងស្គាល់ពង្សាវតាររបស់អេស៊ីប្ដទាំងមូលបាន ។

ផែនដីប្រទេសអេស៊ីប្ដ ដែលប្រជាជនល្មមធ្វើការដប់លៀងអាត្មាបាននោះ មានត្រឹម ៣ ម៉ឺនក្រឡាគីឡូម៉ែត្រ ក្នុងវេលានេះមានប្រជាជនចំនួន ១៤ លាននាក់ប៉ុណ្ណោះ ។

ប្រជាជនជាតិអេស៊ីប្ដ — ពួកអេស៊ីប្ដនេះមានខ្សែស្រឡាយចេញមកពីពួកសេមីទិក (Sémitique)[១] តែមកតាមផ្លូវណា អ្នកប្រាជ្ញពង្សាវតារមិនទាន់មានមតិមូលគ្នានៅឡើយ ។ ឯពួកក្រិកក្នុងគ្រានោះគេយល់ថា ពួកអេស៊ីប្ដ កើតក្នុងអាហ្វ្រិក ចេញមកពីអាហ្វ្រិកជ្រៅទៅខាងក្នុង តែពួកអ្នកប្រាជ្ញប្រវត្តិសាស្ត្រក្នុងសម័យនេះយល់ថា ពួកអេស៊ីប្ដ ចេញទៅពីទ្វីបអាស៊ី ជនជាតិអេស៊ីប្ដ ដែលមានឈាមជ័រអេស៊ីប្ដសុទ្ធនោះ សំគាល់មើលបានដោយងាយ ព្រោះមានស្មាទូលាយ មានដងខ្លួនរៀវតូចចុះទៅក្រោម ដល់ទៅជើងកាន់តែតូចទៅទៀត, មានដៃវែង, ម្រាមដៃជើងក៏វែង, ថ្ពាសតូច, ច្រមុះខ្លី, ភ្នែកធំ, បបូរមាត់ក្រាស់; មានសម្បុរ

---

១ ពួកនេះមានខ្សែស្រឡាយជាដំណតមកពីបុព្វបុរសឈ្មោះសេម (Sem) ដែលជាកូនរបស់ណូអេ (Noé) ។

សក៏មាន សម្បុរខ្មៅក៏មាន តាមទំនង់នេះ ទើបសន្និដ្ឋានថា ជនអេស៊ីប្ដ៍នេះជាជាតិមានឈាមអាស៊ីនឹងអាហ្វ្រិកផ្សំលាយគ្នា ពោលតាមទំនង់នេះដូចជាត្រូវដែរ ។

ជនជាតិអេស៊ីប្ដ៍ មានមុខមាត់នឹងនិស្ស័យសន្តានជាមនុស្សសុភាព អត់ធ្មត់នឹងការងារ ឱនលំទោនដល់អ្នកមានអំណាចលើខ្លួន មានអាការជាអ្នកសប្បាយចិត្តជានិច្ច ប្រកាន់ជាតគតា ចេះស្រឡាញ់វង្សត្រកូល មិនសូវចេះនៅបែកចេញពីពួកញាតិ ។ ពួកស្ត្រីជាតិអេស៊ីប្ដ៍ ខុសពីស្ត្រីជាតិក្ដិឯទៀត ។ ទៅណាមកណាមិនបាច់មានសំពត់រុំមុខ មាននាទីជាមេផ្ទះ ហើយមានអំណាចដាច់ស្រេចក្នុងផ្ទះរបស់ខ្លួន ។ ការគោរពកប់អានមាតាបិតានោះ ជនជាតិអេស៊ីប្ដ៍ ប្រកាន់ថាជាកិច្ចខាងដើមរបស់មនុស្សជាតិ ។

ការចិញ្ចឹមជីវិត, លំនៅ និងគ្រឿងសំលៀកបំពាក់ — ជនជាតិអេស៊ីប្ដ៍ មានការបរិភោគអាហារងាយ ៗ ស្រួល ៗ មិនបាច់មានម្ហូបច្រើនមុខ ឯផ្ទះនោះ មានសណ្ឋាន ៤ ជ្រុង ហើយកសាងដោយឥដ្ឋដែលធ្វើដោយដីកក់ច្របល់នឹងចំបើង សណ្ឋានផ្ទះរាបដំបូលសំប៉ែត ឯសន្លឹកបង្អួចទ្វារកម្រមានណាស់ ។

រូបគំនូរនឹងរូបចម្លាក់ដែលជាប់នៅតាមកំផែងនោះ ធ្វើឲ្យយើងដឹងរបៀបសំលៀកបំពាក់របស់អេស៊ីប្ដ៍ក្នុងសម័យនោះយ៉ាងច្បាស់លាស់ គឺ

ពួកប្រុសៗ មានស័ក្តិយសស្លៀកសំលុយអង្កាញ់ខ្នត់ អាវមានដៃ អ្នកស្រុកស្លៀកសំពត់បែបក្រមា គឺទំនងស្លៀកក្រមាចងក្បិនស្រង់ចុះក្រោមត្រឹមពាក់កណ្ដាលភ្លៅ ពួកស្រីៗ ស្លៀកសំលុយវែងតូចហើយមានខ្សែចងៈយោងបំពាក់លើស្មា ស្បែកជើងច្រើនធ្វើដោយស្បែក ១ បន្ទះ ប្រើខ្សែស្បែកពីរសរសៃ គឺ ១ សរសៃសម្រាប់ចងកជើង ១ សរសៃទៀតចងស៊កម្រាមជើង ។ មនុស្សជាតិអេស៊ីប្ដិ៍គ្រប់ៗ រូបនិយមលាបផ្ទន់ត្របកភ្នែកដោយវត្ថុព័ណ៌ខ្មៅ សម្រាប់បង្ការពន្លឺថ្ងៃចូលភ្នែកខ្លាំង និងបង្ការពេគភ្នែកក្រហម បើជាអ្នកមានទ្រព្យធនគ្រាន់បើ គេទិញសក់មកធ្វើបង្ការពន្លឺថ្ងៃ ។

បឋមក្សត្ររបស់អេស៊ីប្ដិ៍ — ប្រទេសអេស៊ីប្ដិ៍នេះ មានស្រុកធំៗ បែកចេញជាពីរចំណែក ដែលហៅថា អេស៊ីប្ដិ៍ខាងក្រោម ឬស្រុកខាងជើងនៅជិតសមុទ្រ មានស្រុកម៉ំមហ្វិស (Memphis) ជាទីក្រុងធំ ប្រទេសអេស៊ីប្ដិ៍ខាងលើ នៅទិសខាងត្បូងឆ្ងាយពីសមុទ្រ មានស្រុកថែប (Thébes) ជាទីក្រុងធំ តមកស្រុកទាំងពីរក៏រួបរួមគ្នាជាស្រុកមួយ មន្ត្រីគ្រប់គ្រងស្រុកតូចៗ ត្រូវជាចំណុះស្រុកធំៗ ព្រះចៅផែនដីប្រទេសអេស៊ីប្ដិ៍ខណៈនោះគឺហ្វារ៉ុង (Pharaon) ។ បឋមក្សត្រដែលទ្រង់រួបរួមប្រទេសអេស៊ីប្ដិ៍នោះគឺព្រះបាទមេណែស (Ménèse) ដែលទ្រង់មានព្រះជន្មនៅក្នុងលោកមុនព្រះពុទ្ធសករាជ ៤.៥០០ ឆ្នាំ ។

(មានតទៅទៀត)

## ភាគទី ៤

# សព៌នាម[១] (បា. សព្វនាម)

(៧៤) សព៌នាមនេះ ចែកជាពីរយ៉ាង គឺ:

១ បុរុស-សព៌នាម (បា. បុរិសសព្វនាម) ជាសព៌នាម មិនប្រែប្រួលទៅតាមលិង្គទាំងបី

២ វិសេសន-សព៌នាម (បា. វិសេសនសព្វនាម) ជាសព៌នាម ប្រែប្រួលទៅតាមលិង្គទាំងបី

## បុរុស-សព៌នាម

(៧៥) បុរុស-សព៌នាមនេះ ចែកតាមទំនងនៃបុរុស ក្នុងកិរិយាសព្ទ ដែលមានសំដែងក្នុងខាងមុខ មាន ៣ យ៉ាង គឺ ប្រថមបុរុស "បុរសទីមួយ" ១ មជ្ឈិមបុរុស "បុរសកណ្ដាល" ១ ឧត្ដមបុរុស "បុរសឧត្ដម" ១ ។ ក្នុងទីនេះ នឹងបំបែកនូវបុរុស-សព៌នាម ចំពោះតែ មជ្ឈិមបុរុស គឺ យុស្មត៑ និងឧត្ដមបុរុស គឺ អស្មត៑ ព្រោះចំណែកប្រថមបុរុសនោះ ឥតមានសព្ទចំពោះខ្លួនដោយឡែកឡើយ គឺ ត្រូវយកវិសេសនសព៌នាមៈ តទ៑, ឯតទ៑, ឥទម៑,

---

១ សព៌នាម ដែលពោលក្នុងទីនេះដោយសង្ខេប បើត្រូវការចង់ដឹងដោយពិស្ដារ, ចូរមើលក្នុងកច្ចាយនូបត្ថម្ភកភាគទី ១ តាំងពីលេខ ១១១ រហូតដល់លេខ ១២១ ព្រោះសព៌នាមនេះ មិនខុសគ្នានឹងរបៀបសព្វនាមក្នុងបាលីដោយច្រើនឡើយ ។

អខតិ ៗ ល ៗ ដែលបានពោលខាងមុខ ត្រង់លេខ ៨២ មកជា ជំនួសនៃនាមសព្ទណាមួយ ដែលមានស្ថានជាប្រថមបុរុសឬយកនាមសព្ទណាមួយ ដែលបំបែកត្រង់ប្រថមាឯកវចនៈនោះ មកជាប្រថមបុរុស ៗ

(៧៧) វិធីបំបែកបុរុសសព្វនាមនោះ ដូចមានតទៅនេះ:

## មធ្យមបុរុស युष्मत् យុស្មត (បា. តុម្ហ), "ឯង, អ្នក..."

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | त्वम् ត្វម៑ | युवाम् យុវាម៑ | यूयम् យូយម៑ |
| ទុ. | त्वाम्, त्वा<br>ត្វាម៑, ត្វា | युवाम्, वाम्<br>យុវាម៑, វាម៑ | युष्मान्, वः<br>យុស្មាន៑, វស៑ |
| ត. | त्वया ត្វយា | युवाभ्याम् យុវាភ្យាម៑ | युष्माभिः យុស្មាភិស៑ |
| ច. | तुभ्यम्, ते<br>តុភ្យម៑, តេ | युवाभ्याम्, वाम्<br>យុវាភ្យាម៑, វាម៑ | युष्मभ्यम्, वः<br>យុស្មភ្យម៑, វស៑ |
| បំ. | त्वत् ត្វត៑ | युवाभ्याम् យុវាភ្យាម៑ | युष्मत् យុស្មត៑ |
| ឆ. | तव, ते<br>តវ, តេ | युवयोः, वाम्<br>យុវយោស៑ វាម៑ | युष्माकम्, वः<br>យុស្មាកម៑, វស៑ |
| ស. | त्वयि ត្វយិ | युवयोः យុវយោស៑ | युष्मासु យុស្មាសុ |

ឧត្តមបុរស अस्मद् អស្មទ៑ (បា. អម្ហ "អញ, យើង..")

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | अहम् *អហម៑* | आवाम् *អាវាម៑* | वयम् *វយម៑* |
| ទុ. | माम्, मा<br>*មាម៑, មា* | आवाम्, नौ<br>*អាវាម៑, នៅ* | अस्मान्, नस्<br>*អស្មាន៑ នស៑* |
| តប្រ. | मया *មយា* | आवाभ्याम् *អាវាភ្យាម៑* | अस्माभिस् *អស្មាភិស៑* |
| ច. | मह्यम्, मे<br>*មហ្យម៑, មេ* | आवाभ्याम्, नौ<br>*អាវាភ្យាម៑, នៅ* | अस्मभ्यम्, नस्<br>*អស្មភ្យម៑, នស៑* |
| ប. | मत् *មត៑* | आवाभ्याम् *អាវាភ្យាម៑* | अस्मत् *អស្មត៑* |
| ឆ. | मम, मे<br>*មម, មេ* | आवयोस् नौ<br>*អាវយោស៑, នៅ* | अस्माकम्, नस्<br>*អស្មាកម៑, នស៑* |
| ស. | मयि *មយិ* | आवयोस् *អាវយោស៑* | अस्मासु *អស្មាសុ* |

## (២៨) សេចក្ដីពន្យល់ក្នុងបុរសនាម

១ ត្រង់ ទុតិយា, ចតុត្ថី, ឆដ្ឋី, ត្រូវថែមទាំង៣ ខាងមជ្ឈិមបុរស គឺ ត្វា, តេ, វាម៑, វស៑ ទាំងខាងឧត្តមបុរស គឺ មា, មេ, នៅ, នស៑ ទាំងអស់នេះ លុះតែមានបទឯទៀតនៅខាងដើម ហើយត្រូវឲ្យនៅអំពីខាងមុខបទនោះ ទើបប្រើបាន ទ. स त्वा पश्यति *ស ត្វាបឝ្យតិ*, "គេ

បានឃើញហើយ នូវឯង"; स ग्रामपश्यत् ស គ្រាមបឝ្យតិ " គេ បានឃើញហើយ នូវឯងទាំង ២ នាក់"; स त्वां पश्यत् ស ត្វាំ បឝ្យតិ, " គេ បានឃើញហើយ នូវអ្នកទាំងឡាយ" មិនមែនជា ត្វា បឝ្យតិ, គ្រាមបឝ្យតិ, ត្វាំបឝ្យតិ ដូច្នេះទេ; दानं ते मया दत्तम् ទានំ តេ មយា ទត្តម៑, " ទាន អញ ឲ្យហើយ ដល់ឯង" មិនមែនជា តេ មយា ទត្តំ ទានម៑ ដូច្នេះទេ; पिता न पिता मे "បិតា របស់ ខ្ញុំ" មិនមែនជា មេ បិតា ដូច្នេះទេ ។ល។

សព្ទឯទៀតក្រៅពីនោះ ទោះបីរៀងទុកខាងដើមបទក្តី ខាងចុងបទក្តី ត្រូវធ្វើបានសមគួរដល់កិរិយាប្រកប ។

២ បុរុសសព្វនាម ដែលមានសេចក្តីចំពោះខ្លួន គេប្រើសព្ទពីរយ៉ាង:

ក) स्वयम् ស្វយម៑, " ខ្លួនឯង, ដោយខ្លួនឯង, ចំពោះខ្លួនឯង..." ជាអវ្យយសព្ទ គឺសព្ទមានរូបមិនប្រែប្រួលឡើយ ហើយប្រើបានសាធារណ៍គ្រប់លិង្គ, គ្រប់វចន, គ្រប់បុរស, គ្រប់វិភត្តិទាំង ៧. ឧ. स्वय-मुत्पन्न ស្វយមុត្បន្ន, " កើតឡើងដោយខ្លួនឯង"; स्वयम्भू ស្វយម្ភូ, "កើត ឬ មាន ខ្លួនឯង" ។ល។

ខ) आत्मन् អាត្មន៑, ន. ស. "ខ្លួន" (ប្រ. ឯក អាត្មា ។ល។ ម. ល. ៦៦ គន់សេចក្តីចំណាំលេខ ១) ជាសព្ទថ្លែងនូវសេចក្តីចំពោះខ្លួន តាមទំនងដែលបំបែកតាមវិភត្តិគ្រប់អន្លើ តែប្រើជា

ឯករាជទាំងអស់. ឧ. **आत्मानमात्मना यास्तु रक्षेयुस्ताः सुरक्षिताः** អាត្មានមាត្មនា យាស្តុ រក្សេយុស្តាះ សុរក្សិតាះ, "ស្រីទាំងឡាយឯណា រក្សា ខ្លួនខ្លួន ដោយខ្លួនឯង ស្រីទាំងឡាយនោះ ឈ្មោះថា គឺខ្លួនឯង រក្សាហើយដោយល្អ"; ជួនកាលបន្ថែមសព្ទដូចគ្នា ២សព្ទឲ្យជាប់ចូលគ្នា ជាសព្ទមួយ ក៏មាន ឧ. **आत्मात्मानं द्वेष्टि** អាត្មាត្មានំ ទ្វេស្តិ "ឯង ស្អប់ ខ្លួនឯង ដោយខ្លួនឯង ។ល។

៣ បុរុសវិនាម ត្រង់មធ្យមបុរុស ដែលសំដែងសេចក្តីគោរព សេចក្តីគួរសម និងសេចក្តីសុភាព គេតែងយកសព្ទ **भवत्** ភវន្ត ជាប្រថមបុរុសដែលប្រែថា លោក ឬ អ្នក មកប្រើជួសមធ្យមបុរុស ។ ភវន្ត នេះ ត្រូវបំបែកដូច ភគវន្ត; (ប.ឯក.: ភវាន ។ល។ មើល ស្រីលិង្គ: ភវតី ម.ល. ៦៨ ខាងដើម ។ ភវន្ត សព្ទនេះអាចប្រើបាន គ្រប់វចនទាំងបី, កាលដែលប្រកបជាមួយនឹងកិរិយាសព្ទ ក៏ចំពោះត្រង់ កិរិយាសព្ទជាប្រថមបុរុស គ្រប់វចនទាំងបីដូចគ្នា ។

ឧ.- **भवन्तं नमामि** ភវន្តំ នមាមិ[១] ខ្ញុំសូមក្រាបប្រតិបត្តិ លោក

---

១. សព្ទភវន្តនេះ បើប្រែតាមភាសាខ្មែរ ត្រូវប្រែឲ្យសមតាមថ្នាក់របស់មនុស្ស បើជាលោក សង្ឃត្រូវប្រែឲ្យសមតាមពាក្យដែលសម្រាប់និយាយចំពោះនឹងព្រះសង្ឃ; បើជាឃរាវាសត្រូវប្រែ ឲ្យសមតាមពាក្យដែលសម្រាប់និយាយនឹងឃរាវាស តាមថ្នាក់ខ្ពស់ទាប នមាមិ ក៏ត្រូវប្រែតាម ទំនងពាក្យដែលសម្រាប់និយាយនឹងព្រះសង្ឃ ឬឃរាវាស ជា "ថ្វាយបង្គំ, ក្រាបប្រតិបត្តិ, គំនាប់, ជំរាបសួរ" តាមថ្នាក់ខ្ពស់ទាប ។

**ភវន្តំ នមាមិ** ភវន្តំ នមាមិ ខ្ញុំសូមក្រាបប្រតិបត្តិ លោកស្រី

**ភវន្តៅ កុត្រ គច្ឆតះ** ភវន្តៅ កុត្រ គច្ឆតះ { លោកទាំង ២ អង្គនិមន្តទៅណា / អ្នកទាំងពីរនាក់អញ្ជើញទៅណា

**ភវន្តស្តត្រ តិឞ្ឋន្តិ** ភវន្តស្តត្រ តិឞ្ឋន្តិ លោកទាំងឡាយ ស្ថិត នៅ ក្នុងទីនោះ

៤. បុរុសវិនាមដែលបំបែកត្រង់ ឞ្ឋីវិភក្តិទាំង៣វចន ដែល ប្រែថា "របស់..." មានសេចក្តីប្រហែលគ្នានឹងគុណសព្ទ ឧ. **មម បុត្រះ** មម បុត្រះ ឬ **បុត្រោ មេ** បុត្រោ មេ, "កូន របស់ ខ្ញុំ"; **អស្មាកំ គ្ឫហម្** អស្មាកំ គ្ឫហម៑ ឬ **គ្ឫហំ នះ** គ្ឫហំ នះ, "ផ្ទះ របស់យើង" ។ សព្ទ ឯទៀត ដែលមានទំនងសេចក្តីដូចគ្នា អាចយកមកប្រើបាន ដូចជា បុរុសវិនាមដែលបំបែកត្រង់ឞ្ឋីវិភក្តិទាំង៣វចនដែរ ដូចតទៅនេះ

ក) គុណសព្ទ កើតពីបុរុសវិនាមទាំង៣បុរុស ដោយប្រកបផ្សំ នឹងប្រត្យយ ឦយះ: មទីយ-, "របស់ខ្ញុំ, របស់អញ" ឧ. **មទីយះ បុត្រះ** មទីយះ បុត្រះ, "បុត្រ របស់អញ"; **មទីយំ គ្ឫហម្** មទីយំ គ្ឫហម៑, "ផ្ទះ របស់អញ"; ត្វទីយ-, "របស់ឯង"; ភវទីយ-, "របស់អ្នក"; តទីយ-, ឯតទីយ-, "របស់វា, របស់គេ"; អស្មទីយ-, "របស់យើង", យុឞ្មទីយ-, "របស់អ្នក" ។

២) គុណនាមសព្វ ដែលមានសេចក្តីចំពោះខ្លួន ស្វ-, "របស់ខ្លួន" ជាសព្វនាមប្រកបប្រើបានគ្រប់បុរស គ្រប់វចន ។. **स्वं देहं त्यक्ष्यामि** ស្វំ ទេហំ ត្យក្ស្យាមិ, "ខ្ញុំ នឹងលះបង់ នូវរាងកាយ របស់ខ្លួនខ្ញុំ", **स्वं देहं त्यक्ष्यसि** ស្វំ ទេហំ ត្យក្ស្យសិ, "ឯង នឹងលះបង់ នូវរាងកាយ របស់ខ្លួនឯង" **स्वं देहं त्यक्ष्यति** ស្វំ ទេហំ ត្យក្ស្យតិ, "គេ នឹងលះបង់ នូវរាងកាយ របស់ខ្លួនគេ" ។

## វិសេសណសព៌នាម

(៧៩) វិសេសណសព៌នាម មានចំនួនច្រើនពេកណាស់ ក្នុងទីនេះ នឹងបំបែកចំពោះតែវិសេសណសព៌នាម ដែលត្រូវការប្រើញឹកញាប់ជាងគេ សព៌នាមនោះ គឺ

អនិយម-សព៌នាម : យត៑

បុច្ឆា-សព៌នាម : កិម៑

និយម-សព៌នាម : តទ៑, ឯតទ៑, ឥទម៑, អទស៑

សព៌នាមទាំងនេះ បើតាមច្បាប់ ត្រូវបំបែកដូចគ្នានឹងនាមសព្ទជាអការន្តដែរ ប៉ុន្តែត្រង់កន្លែងនៃវចនខ្លះ មានទ្រង់ផ្សេងដោយឡែកពីគ្នាក៏មាន ដូចតទៅនេះ

## [៨០] អនិយម-សព្វនាមៈ यत् យត៑, បុំ. “ណា, ឯណា”

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្ឋ. | यत् | យស៑ | यौ | យៅ | ये | យេ |
| ទុ. | यत् | យម៑ | " | " | यान् | យានិ |
| ត.ប. | येन | យេន | याभ्याम् | យាភ្យាម៑ | यैन् | យៃស៑ |
| ច. | यस्मै | យស្មៃ | " | " | येभ्यन् | យេភ្យស៑ |
| ប. | यस्मात् | យស្មាត៑ | " | " | " | " |
| ឆ. | यस्य | យស្យ | ययोस् | យយោស៑ | येषान् | យេឞាម៑ |
| ស. | यस्मिन् | យស្មិន៑ | " | " | येषु | យេឞុ |

បើជា នបុំ. ត្រង់ប្ឋ. ទុ. ឯក. ជា យត៑;- ទ្វិ. ជា យេ;- ពហុ. ជា យានិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គទាំងអស់ ។

### यत् យត៑, ស្ត្រី.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្ឋ. | या | យា | ये | យេ | यास् | យាស៑ |
| ទុ. | यान् | យាម៑ | " | " | " | " |

| | | ឯក. | | ទ្វិ. | | ពហុ. |
|---|---|---|---|---|---|---|
| ត. | यया | យយា | याभ्याम् | យាភ្យាម៑ | याभिस् | យាភិស៑ |
| ច. | यस्यै | យស្យៃ | " | " | याभ्यस् | យាភ្យស៑ |
| ប. | यस्यास् | យស្យាស៑ | " | " | " | " |
| ឆ. | " | " | ययोस् | យយោស៑ | यासाम् | យាសាម៑ |
| ស. | यस्याम् | យស្យាម៑ | " | " | यासु | យាសុ |

(៥៩) បញ្ហា-សព៌្វនាម: किम् កិម៑ បុំ. "ដូចម្ដេច"

| | | ឯក. | | ទ្វិ. | | ពហុ. |
|---|---|---|---|---|---|---|
| ប. | कस् | កស៑ | कौ | កៅ | के | កេ |
| ទុ. | कम् | កម៑ | " | " | कान् | កាន៑ |
| ត. | केन | កេន | काभ्याम् | កាភ្យាម៑ | कैस् | កៃស៑ |
| ច. | कस्मै | កស្មៃ | " | " | केभ्यस् | កេភ្យស៑ |
| ប. | कस्मात् | កស្មាត៑ | " | " | " | " |
| ឆ. | कस्य | កស្យ | कयोस् | កយោស៑ | केषाम् | កេឞាម៑ |
| ស. | कस्मिन् | កស្មិន៑ | " | " | केषु | កេឞុ |

បើតាមនបុំ. ត្រង់ប. ទុ. ឯក. ជា កិម៑;– ទ្វិ. ជា កេ;– ពហុ. ជា កានិ ក្រៅពីនោះ ដូចគ្នានឹងបុំលិង្គទាំងអស់ ។

## किम् កិម៑, ស្ត្រី.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | का | កា | के | កេ | कास् | កាស៑ |
| ទុ. | काम् | កាម៑ | " | " | " | " |
| ត. ប្ញ | कया | កយា | काभ्याम् | កាភ្យាម៑ | काभिस् | កាភិស៑ |
| ច. | कस्यै | កស្យៃ | " | " | काभ्यस् | កាភ្យស៑ |
| ប. | कस्यास् | កស្យាស៑ | " | " | " | " |
| ឆ. | " | " | कयोस् | កយោស៑ | कासाम् | កាសាម៑ |
| ស. | कस्याम् | កស្យាម៑ | " | " | कासु | កាសុ |

## (៨២) និយម-សវ៌នាម: तद् តទ៑ បុំ "នោះ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | सस् | សស៑ | तौ | តៅ | ते | តេ |
| ទុ. | तम् | តម៑ | " | " | तान् | តាន៑ |
| ត. ប្ញ | तेन | តេន | ताभ्याम् | តាភ្យាម៑ | तैस् | តៃស៑ |
| ច. | तस्मै | តស្មៃ | " | " | तेभ्यस् | តេភ្យស៑ |
| ប. | तस्मात् | តស្មាត៑ | " | " | " | " |
| ឆ. | तस्य | តស្យ | तयोस् | តយោស៑ | तेषाम् | តេឞាម៑ |
| ស. | तस्मिन् | តស្មិន៑ | " | " | तेषु | តេឞុ |

មើល នបុំ. ត្រង់ ប្រ. ទុ. ឯក. ជា តទ៑:–ទ្វិ. ជា តេ;–ពហុ.
ជា តានិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គទាំងអស់ ។

## तद् តទ៑, ស្ត្រី.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | सा | សា | ते | តេ | तास् | តាស៑ |
| ទុ. | ताम् | តាម៑ | " | " | " | " |
| ត្ឫ. | तया | តយា | ताभ्याम् | តាភ្យាម៑ | ताभिस् | តាភិស៑ |
| ច. | तस्यै | តស្យៃ | " | " | ताभ्यस् | តាភ្យស៑ |
| ប. | तस्यास् | តស្យាស៑ | " | " | " | " |
| ឆ. | " | " | तयोस् | តយោស៑ | तासाम् | តាសាម៑ |
| ស. | तस्याम् | តស្យាម៑ | " | " | तासु | តាសុ |

## एतद् ឯតទ៑, បុំ. “ក្លុះ”

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | एषस् | ឯឞស៑ | एतौ | ឯតៅ | एते | ឯតេ |
| ទុ. | एतम्, एनम् | ឯតម៑, ឯនម៑ | एतौ, एनौ | ឯតៅ, ឯនៅ | एतान्, एतान् | ឯតាន៑, ឯនាន៑ |

| | | | |
|---|---|---|---|
| ត. ប. | एतेन, एनेन | एताभ्याम् | एतैस् |
| | ឯតេន, ឯនេន | ឯតាភ្យាម៑ | ឯតៃស៑ |
| ច. | एतस्मै ឯតស្មៃ | " | एतेभ्यस् ឯតេភ្យស៑ |
| ប. | एतस्मात् ឯតស្មាត៑ | " | " " |
| ឆ. | एतस्य | एतयोस्, एनयोस् | एतेषाम् |
| | ឯតស្យ | ឯតយោស៑, ឯនយោស៑ | ឯតេឞាម៑ |
| ស. | एतस्मिन् ឯតស្មិន៑ | ", " | एतेषु ឯតេឞុ |

បើជា នបុំ. ត្រង់ ប. ឯក. ជា ឯតទ៑, ទុ. ឯក. ជា ឯតទ៑, ឯនត៑, ត្រង់ ប. ទ្វិវ. ជា ឯតេ. ទុ. ទ្វិវ. ជា ឯតេ, ឯនេ; ត្រង់ ប. ពហុ. ជា ឯតានិ, ទុ. ពហុ. ជា ឯតានិ, ឯនានិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គទាំងអស់ៗ

## एतद् ឯតទ៑, ស្ត្រី.

| | ឯក. | ទ្វិវ. | ពហុ. |
|---|---|---|---|
| ប្រ. | एषा ឯឞា | एते ឯតេ | एतास् ឯតាស៑ |
| ទុ. | एताम्, एनाम् | एते, एने | एतास्, एनास् |
| | ឯតាម៑, ឯនាម៑ | ឯតេ, ឯនេ | ឯតាស៑, ឯនាស៑ |
| ត. ប. | एतया, एनया | एताभ्याम् | एताभिस् |
| | ឯតយា, ឯនយា | ឯតាភ្យាម៑ | ឯតាភិស៑ |

| | | | | |
|---|---|---|---|---|
| ច. | एतस्यै ឯតស្យៃ, | एताभ्याम् ឯតាភ្យាម៑ | एताभ्यस् ឯតាភ្យស៑ | |
| ប. | एतस्यास् ឯតស្យាស៑ | " " | " " | |
| ឆ. | " " | एतयोस्, एनयोस्<br>ឯតយោស៑, ឯនយោស៑ | एतासाम्<br>ឯតាសាម៑ | |
| ស. | एतस्याम् ឯតស្យាម៑ | " " | एतासु ឯតាសុ | |

## इदम् ឥទម៑, បុំ. "នេះ"

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប. | अयम् អយម៑ | इमौ ឥមៅ, | इमे ឥមេ |
| ទុ. | इमम्, एनम्<br>ឥមម៑, ឯនម៑ | इमौ, एनौ<br>ឥមៅ, ឯនៅ | इमान् एनान्<br>ឥមាន៑, ឯនាន៑ |
| ត. | अनेन, एनेन<br>អនេន, ឯនេន | आभ्याम्<br>អាភ្យាម៑ | एभिस्<br>ឯភិស៑ |
| ច. | अस्मै អស្មៃ | " | एभ्यस् ឯភ្យស៑ |
| ប. | अस्मात् អស្មាត៑ | " | " " |
| ឆ. | अस्य<br>អស្យ | अनयोस्, एनयोस्<br>អនយោស៑, ឯនយោស៑ | एषाम्<br>ឯសាម៑ |
| ស. | अस्मिन् អស្មិន៑ | " " | एषु ឯឞុ |

បើជានបុំ. ត្រង់ប្រ. ឯក. ជា ឥទម៑, ទុ. ឯក. ជា ឥទម៑. ឯនម៑; ត្រង់ប្រ. ទ្វិ. ជា ឥមេ, ឯនេ; ត្រង់ប្រ. ពហុ. ជា ឥមានិ. ទុ. ពហុ. ជា ឥមានិ, ឯនានិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គទាំងអស់ ។

## इदम् ឥទម៑, ស្ត្រី.

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | इयम् ឥយម៑ | इमे ឥមេ | इमाः ឥមាស៑ |
| ទុ. | इमाम्, एनाम् ឥមាម៑, ឯនាម៑ | इमे, एने ឥមេ, ឯនេ | इमाः, एनाः ឥមាស៑, ឯនាស៑ |
| ត. | अनया, एनया អនយា, ឯនយា | आभ्याम् អាភ្យាម៑ | आभिः អាភិស៑ |
| ច. | अस्यै អស្យៃ | " | आभ्यः អាភ្យស៑ |
| ប. | अस्याः អស្យាស៑ | " | " " |
| ឆ. | " " | अनयोः, एनयोः អនយោស៑, ឯនយោស៑ | आसाम् អាសាម៑ |
| ស. | अस्याम् អស្យាម៑ | " , " | आसु អាសុ |

## អទស៑ អទស៍, បុំ. "នោះ ឯនោះ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| បឋ. | អសៅ | អសៅ | អមូ | អមូ | អមី | អមី |
| ទុ. | អមុម៑ | អមុម៍ | " | " | អមូន៑ | អមូន៍ |
| ត. | អមុនា | អមុនា | អមូភ្យាម៑ | អមូភ្យាម៍ | អមីភិស៑ | អមីភិស៍ |
| ច. | អមុឞ្មៃ | អមុឞ្មៃ | " | " | អមីភ្យស៑ | អមីភ្យស៍ |
| ប. | អមុឞ្មាត៑ | អមុឞ្មាត៍ | " | " | " | " |
| ឆ. | អមុឞ្យ | អមុឞ្យ | អមុយោស៑ | អមុះយោស៍ | អមីឞាម៑ | អមីឞាម៍ |
| ស. | អមុឞ្មិន៑ | អមុឞ្មិន៍ | " | " | អមីឞុ | អមីឞុ |

បើជាទបុំ. ត្រង់ បឋ. ទុ. ឯក. ជា អទស៍:- ទ្វិ. ជា អមូ:- ពហុ. ជា អមូនិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គទាំងអស់ ។

## អទស៑ អទស៍ ស្ត្រី.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| បឋ. | អសៅ | អសៅ | អមូ | អមូ | អមូស៑ | អមូស៍ |
| ទុ. | អមូម៑ | អមូម៍ | " | " | " | " |
| ត. | អមុយា | អមុយា | អមូភ្យាម៑ | អមូភ្យាម៍ | អមូភិស៑ | អមូភិស៍ |

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ច. | अमुष्यै | អមុឞ្យៃ | अमूभ्याम् | អមូភ្យាម៑ | अमूभ्यस् | អមូភ្យស៑ |
| ប. | अमुष्यास् | អមុឞ្យាស៑ | " | " | " | " |
| ឆ. | " | " | अमुयोस् | អមុយោស៑ | अमूषाम् | អមូឞាម៑ |
| ស. | अमुष्याम् | អមុឞ្យាម៑ | " | " | अमूषु | អមូឞុ |

(៨៣) សេចក្ដីពន្យល់អំពីសព្វនាម ដែលបំបែកខាងលើនេះ

១ ត្រង់បួនសព្វនាម *កិម៑* កាលបើភ្ជាប់ទៅនឹងនិបាតសព្ទ *ចិទ៑*, *ចន*, *អបិ* ទៅជា *កិំចិទ៑* ឬ *កិញ្ចិទ៑*, *កិំចន* ឬ *កិញ្ចន*. *កិមបិ*, "នីមួយ, ណាមួយ, ឯណាមួយ, តិចតួច, អ្នីមួយ, អ្នកណាមួយ (១)..." សព្ទទាំងអស់នេះ ជាសព្ទដើម, កាលដែលបំបែកតាមវិភត្តិទាំង៧, ក៏ត្រូវប្រែប្រួលផ្សេងពីគ្នា ដោយអំណាចនៃលិង្គ; រីឯនិងវិភត្តិ តែដែលប្រែប្រួលនោះចំពោះតែ *កិំ* សព្ទទេ ឯនិបាតសព្ទមាន *ចិត៑* ជាដើម ដែលភ្ជាប់មកនឹង *កិំ* សព្ទនោះ ឥតមានប្រែប្រួលឡើយ (បើមានផ្លាស់ប្ដូរប្រែប្រួលខ្លះ តែដោយអំណាចសន្ធិ គឺជ៍

១ ពាក្យប្រែទាំងអស់នេះ មិនទៀងទាត់តែម្យ៉ាងឡើយ អាចប្រែបានតាមទំនងសេចក្ដី ។

វេលាដែលមានសព្ទឯទៀតនៅខាងមុខ ដោយឡែកទៅវិញ) ដូចបែប
បំបែកតទៅនេះ

## ក្រិឃ្ឍ កិញ្ចិទ៑ បុំ

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | កឝ្ចិត៑ | កៅ ចិត៑ | កេ ចិត៑ |
| ទ្វិ. | កញ្ចិត៑ (< កម៑ + ចិត៑) | " | កាញ្ចិត៑ (< កាន៑ + ចិត៑) |
| តឫ. | កេន ចិត៑ | កាភ្យាញ្ចិត៑ | កៃឝ្ចិត៑ |
| ច. | កស្មៃ ចិត៑ | " | កេភ្យឝ្ចិត៑ |
| ប. | កស្មាច្ចិត៑ (< កស្មាត៑ + ចិត៑) | " | " |
| ឞ. | កស្យ ចិត៑ | កយោឝ្ចិត៑ | កេឞាញ្ចិត៑ (< កេឞាម៑ + ចិត៑) |
| ស. | កស្មិញ្ចិទ៑ (< កស្មិន៑ + ចិត៑) | " | កេឞុ ចិត៑ |

បើជានបុំ. ត្រង់ ប្រ. ទ្វិ. ឯក. ជា កិញ្ចិត៑;– ទ្វិ. ជា កេ ចិត៑;–
ពហុ. ជា កានិ ចិត៑ ក្រៅពីនោះ ដូចគ្នានឹងបុំលិង្គ ។

## ក្រិឃ្ឍ កិញ្ចិទ៑, ស្ត្រី.

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | កា ចិត៑ | កេ ចិត៑ | កាឝ្ចិត៑ |
| ទ្វិ. | កាញ្ចិត៑ (< កាម៑ + ចិត៑) | " | " |

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ត. ឬ | កយា ចិត៍ | កាក្យាញ្ចិត៍ | កាកិញ្ចិត៍ |
| ច. | កស្យៃ ចិត៍ | " | កាក្យញ្ចិត៍ |
| ប. | កស្យាទ្ចិត៍ | " | " |
| ឆ. | " | កយោញ្ចិត៍ | កាសាញ្ចិត៍ |
| ស. | កស្យាញ្ចិត៍ | " | កាសុ ចិត៍ |

ឯ កិញ្ចន និង កិមបិ មានវិធីបំបែកដូចគ្នានឹង កិញ្ចិទ ខាងលើនេះដែរ គឺត្រូវប្រែប្រួលផ្លាស់ប្ដូរតែត្រង់ កិម ឯ បិន និង អបិ មិនត្រូវផ្លាស់ប្ដូរឡើយ ទឹងបំបែកឲ្យឃើញតែរូបទ្រង់ត្រង់ប្រថមាឯកវចន ទាំង ៣ លិង្គ:

កិញ្ចន, បុំ. កញ្ចន; ស្រី. កាចន; នបុំ. កិញ្ចន.
កិមបិ, បុំ. កោបិ; ស្រី. កាបិ; នបុំ. កិមបិ.

សព្វទាំងនេះ, កាលបើបែកបង្វែរដោយអនិយមសព្វនាម យទ៍ ពីខាងដើមមកទៀត ទៅជា យត្កិញ្ចិទ (ឧ. យំកិញ្ចិ) " ណាមួយ, អ្វីមួយ, ណាមួយក៏ដោយ, អ្វីក៏ដោយ" សព្វនេះ មានវិធីបំបែកដូចគ្នា គឺត្រូវបំបែកតែត្រង់ យត៍ និង កិម ឯ ចិទ មិនត្រូវបំបែកឡើយ ៗ ទឹងបំបែកឲ្យឃើញតែត្រង់ ឯកវចនទាំង ៣ លិង្គដូចមានខាងក្រោមនេះ

បុំ. ឯក.: យ: កឝ្ចិត៑. យំ កញ្ចិត៑, យេន កេនចិត៑, យស្មៃ កស្មៃចិត៑, យស្មាត៑ កស្មាច្ចិត៑, យស្យ កស្យចិត៑, យស្មិន៑ កស្មិំឝ្ចិត៑.

ស្ត្រី. ឯក.: យា កាចិត៑. យាំ កាញ្ចិត៑, យយា កយាចិត៑, យស្យៃ កស្យៃចិត៑, យស្យា: កស្យាឝ្ចិត៑, យស្យា: កស្យាឝ្ចិត៑, យស្យាំ កស្យាញ្ចិត៑.

នបុំ. ឯក.: យត្កិញ្ចិត៑, យត្កិញ្ចិត៑, (ក្រៅពីនេះ ដូចគ្នានឹងបុំលិង្គ)

៦. ត្រង់នីយមសព្វនាម តទ៑. ត្រង់ប្រ. ឯក. សស៑. សស៑ នេះ បើនៅទីបំផុតបណ្តាច់នៃប្រយោគ ត្រូវយកតួ ស៑ ខាងចុងធ្វើជា វិសគ៌ ទៅជា ស: (ម. ល. ១៣ នឹង ៦០) ឧ. មាំ បច្ឆតិ ស: "គេ សួរ នូវខ្ញុំ";— បើមានស្រះ អ នៅខាងមុខ ត្រូវធ្វើជា ឱ ទៅជា សោ តែត្រូវលុបស្រះ អ ខាងមុខចេញហើយ ដាក់អវគ្រហត្រង់ កន្លែងស្រះ អ នោះ (ម. ល. ២៤ ខាងដើម) ឧ. សស៑ អបិ > សោ'បិ; សស៑ + អហម៑ > សោ'ហម ;— ក្រៅពីនោះ ទោះបីមានឃោសក្តី អឃោសក្តី នៅខាងមុខ ក៏ត្រូវតែលុបតួ ស៑ នេះចេញឲ្យនៅតែ ស ១ តួប៉ុណ្ណោះ ឧ. ស អាគច្ឆតិ "គេ មក"; ស ករោតិ, "គេ ធ្វើ"; ស បច្ឆតិ, "គេ សួរ"; ស គច្ឆតិ, "គេ ទៅ" ។ល។

៣. និយមសព្វនាម តទ៑ ប្រែថា "នោះ..." ចំពោះអ្វីមួយដែលនៅឆ្ងាយ មើលមិនឃើញ;- ឯតទ៑ ប្រែថា "នុ៎ះ..." ចំពោះអ្វីមួយដែលនៅឆ្ងាយអំពីហត្ថបាស គឺនៅឆ្ងាយជាង ២ ហត្ថ ១ ចំអាមអំពីខ្លួនអ្នកនិយាយ ល្មមមើលឃើញច្បាស់;- ឥទម៑ ប្រែថា "នេះ..." ចំពោះអ្វីមួយដែលនៅជិតខ្លួនអ្នកនិយាយ គឺជិតក្នុងរវាង ២ ហត្ថ ១ ចំអាម ៗ ចំណែក ឯន ប្រែថា "នុ៎ះ..." ក៏បាន "នេះ..." ក៏បាន (តាមទំនងសេចក្តី) ព្រោះ ឯន នេះ កើតអំពី ឯតទ៑ នឹង ឥទម៑ ហើយ ឯន នោះមានត្រូវការប្រើតែត្រង់ ទុ. តួ. ប. ស. គ្រប់លិង្គទាំង ៣ គ្រប់វចនទាំង ៣ (ម. ល. ៨២ ត្រង់ ឯតទ៑ នឹង ឥទម៑) ។

៤. សព្វដែលមានវិធីបំបែកត្រូវគ្នាគ្រប់អន្លើនឹងវិធីបំបែកនៃសព្វនាមខាងដើមនោះគឺ វិសេស-គុណសព្វខ្លះ អតិរេកគុណសព្វខ្លះ ដូចតទៅនេះ:

ក) កតរ[១], "ណា, ណាមួយ"; កតម[២] "ដូចម្តេចខ្លះ, អ្វីខ្លះ, ណាខ្លះ"; យតរ[១], "ណា, ណាមួយ"; យតម,[២] "ណាខ្លះ"; ឥតរ

---

១ សព្វដែលមានប្រត្យយ តរ ជាពាក្យសួររកក្នុងចំនួនតិចត្រឹមតែពីរ ។ ២ សព្វដែលមានប្រត្យយ តម ជាពាក្យសួររកក្នុងចំនួនច្រើន ។